# ប្រជុំរឿងប្រេត-នរក
# និង
# ផលានិសង្សបុណ្យ


រៀបរៀងដោយ

**ភិក្ខុធម្មជោតោ ខែម វិបុល**

វត្តឥន្ទនិមិត្ត ហៅវត្តព្រែកតូច
ឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្ដាល

ទទួលបានពីលោក ចៅ ឃុនសំរ៉េង ដល់ក្រុមការងារ
ដើម្បីដាក់បញ្ចូលក្នុង elibrary of Cambodia.

កញ្ញា 2015.

# ប្រជុំរឿងព្រេត ~ នរក

# និង

# ផលានិសង្សបុណ្យ

រៀបរៀងដោយ

## ភិក្ខុធម្មជោតោ ខែម វិបុល

វត្តឥន្ទនិម្មិត្ត ហៅវត្តព្រែកតូច

ឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្ដាល

សម្រាប់ជាធម្មទាន



ភិក្ខុធម្មជោតោ ខែម វិបុល

# ចែកធម្មទានដោយ

**លោក កែវ រស្មី អ្នកស្រី ត្រា មុជនារីរ័ត្ន**

*ព្រមទាំងកូនចៅ ( ប្រទេសអូស្ត្រាលី )*

ដោយអំណាចផលានិសង្សនៃធម្មទាននេះ សូមឧទ្ទិសមហាកុសលជូនចំពោះបុព្វការីជនមាន មាតាបិតា ជីដូនជីតា និងគ្រូឧបជ្ឈាយាចារ្យ មួយអន្លើដោយពពួកញាតិក្នុងសង្សារវដ្ត និងសព្វសត្វទាំងអស់ដែលជាញាតិក្តី និងមិនមែនជាញាតិក្តីគ្រប់ៗគ្នា ។

សូមអស់លោកអ្នកដ៏មានគុណទាំងអស់នោះ អញ្ជើញទទួលអនុមោទនាត្រេកអរ ហើយសូមឱ្យបានសម្រេចនូវឧត្តមប្រយោជន៍ ព្រមទាំងបានសោយសុខក្នុងសុគតិភពមានព្រះនិព្វានជាអវសានកុំបីឃ្លៀងឃ្លាតឡើយ។

**សព្វទានំ ធម្មទានំ ជិនាតិ**

**ធម្មទានរមែងឈ្នះអស់ទានទាំងពួង ។**

**ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦**

# គណៈកម្មការត្រួតពិនិត្យ

ពុទ្ធិកបណ្ឌិតសភា

## រៀបរៀងដោយ


ភិក្ខុធម្មជោតោ **ខែម វិបុល**

គង់នៅវត្តឥន្ទនិម្មិត្ត ហៅវត្តព្រៃកគួច

ឃុំព្រៃកដាច់ ស្រុកលើកដែក ខេត្តកណ្ដាល


## បច្ចេកទេសកុំព្យូទ័រដោយ


សាស្ត្រាចារ្យ **ស៊ុម សំអឿន**

អនុវិទ្យាល័យ ព្រៃកគួច

ឃុំព្រៃកដាច់ ស្រុកលើកដែក ខេត្តកណ្ដាល



បោះពុម្ពលើកទី១

២០១១



រក្សាសិទ្ធិគ្រប់យ៉ាង

# មាតិកា

ខ្លឹមសារ ទំព័រ

អារម្ភកថា ........ ឃ
១. រឿងសង្ឃីកូដប្រេត ........ ១
២. រឿងអជគរប្រេត ........ ៣
៣. រឿងព្រះមហាមោគ្គល្លានត្ថេរ ........ ៣
៤. រឿងសូករប្រេត ........ ៥
៥. រឿងប្រេតក្លាយជាទេវតា ........ ៦
៦. រឿងយមលោក និងទេវលោក ........ ៧
៧. រឿងគហបតីប្រេត ........ ១០
៨. រឿងនាងវិមានប្រេត ........ ១១
៩. រឿងស្រីពេស្យាកើតជាប្រេត ........ ១៤
១០. រឿងប្រេតប្ដីប្រពន្ធ ........ ១៦
១១. រឿងមិគលុទ្ទកប្រេត ........ ១៨
១២. រឿងប្រេតស៊ីសាច់ឯង ........ ១៩
១៣. រឿងឆ្កែខាំប្រេត ........ ២០
១៤. រឿងភិក្ខុជាញាតិ និងប្រេត ........ ២៣
១៥. រឿងប្រេតញីស៊ីខ្ទុះឈាម ........ ២៦
១៦. រឿងប្រេត៤នាក់ ........ ២៨
១៧. រឿងប្រេតមាត់ស្អុយ ........ ២៩
១៨. រឿងព្រានប្រេត ........ ៣២
១៩. រឿងប្រេតស៊ីកូនម្ដង៧ ........ ៣៦
២០. រឿងប្រេតញីស៊ីកូនម្ដង៥ ........ ៣៨
២១. រឿងរថកាប្រេត ........ ៤១

២២. រឿងអហិប្រេត ........................................ ៤៣
២៣. រឿងប្រេតញីឈ្មោះឧត្តរមាតា ........................................ ៤៥
២៤. រឿងស្តេចលិច្ឆវី និងប្រេត ........................................ ៤៦
២៥. រឿងសានុវាសីប្រេត ........................................ ៥១
២៦. រឿងព្រះបាទបិង្គលកៈ និងប្រេត ........................................ ៥៣
២៧. រឿងមាតាព្រះសារីបុត្តកើតជាប្រេត ........................................ ៥៦
២៨. រឿងនាងមត្តាប្រេត ........................................ ៥៨
២៩. រឿងនាងនន្ទាប្រេត ........................................ ៦១
៣០. រឿងប្រេតជាញាតិព្រះបាទពិម្ពិសារ ........................................ ៦៣
៣១. រឿងកូនធ្វើបុណ្យជូនមាតាបិតាស្លាប់ ........................................ ៦៨
៣២. រឿងបុរសស្លាប់ធ្លាក់នរក ........................................ ៧១
៣៣. រឿងនន្ទយក្សធ្លាក់មហានរក ........................................ ៧៤
៣៤. រឿងនាងចិញ្ចាមាណវិកា ........................................ ៧៧
៣៥. រឿងនាយចុន្ទសូករិក ........................................ ៨១
៣៦. រឿងឧប្បលវណ្ណាថេរី ........................................ ៨២
៣៧. រឿងជម្ពុកាជីវក ........................................ ៨៣
៣៨. រឿងគោឃាតកបុត្រ ........................................ ៨៥
៣៩. រឿងឧត្តរសាមណេរ ........................................ ៨៩
៤០. រឿងនាងបដិបូជិកា ........................................ ៩២
៤១. រឿងព្រះបាទមន្ទាតុ ........................................ ៩៤
៤២. រឿងនាងជូនទាសី ........................................ ៩៧
៤៣. រឿងនាងទុគ្គតធីតា ........................................ ១០១
៤៤. រឿងនាងពុទ្ធេណី ........................................ ១០២
៤៥. រឿងមាតុឃាតក ........................................ ១០៤

៤៦. រឿងមហល្លកចណ្ឌាល ............................................ ១០៧
៤៧. រឿងនាងកេសការី ............................................ ១០៨
៤៨. រឿងបល្ល័ង្កអណ្តែត ............................................ ១១០
៤៩. រឿងសត្វមៀម ............................................ ១១២
៥០. រឿងភ័យរបស់សុបតិដ្ឋិតាទេវបុត្ត ............................................ ១១៤
៥១. រឿងនាងគព្ភិនី ............................................ ១១៩
៥២. រឿងនាងសេសវតី ............................................ ១២០
៥៣. រឿងឥល្លិសសេដ្ឋី ............................................ ១២៣
៥៤. រឿងនាងវិសាខា ............................................ ១២៦

**អារម្ភកថា**

ដោយយល់ឃើញថា ព្រះករុណាម្ចាស់ទាំងឡាយ និងពុទ្ធបរិស័ទទាំងឡាយ មិនធុញទ្រាន់ក្នុងការប្រតិបត្តិធម៌វិន័យ ស្អប់ខ្ពើមនូវអបាយភូមិ៤គឺ នរក ប្រេត អសុរកាយ តិរច្ឆាន ហើយមានបំណងចង់ជៀសឲ្យរួច គេចឲ្យផុតពីកំណើតទាំងអស់នេះ ឃើញភ័យក្នុងអបាយភូមិ បានចូលមកបួសទ្រទ្រង់នូវព្រះវិន័យ និងគោរពស្តាប់ឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ។ ដើម្បីងាយស្រួលក្នុងការសិក្សាដល់ធម្មកថិក យកទៅសម្តែងបំភ្លឺដល់ពុទ្ធបរិស័ទដែលជ្រះថ្លា ហើយឲ្យរិតតែជ្រះថ្លាថែមទៀត និងជនមិនទាន់ជ្រះថ្លាឲ្យបានយល់ដឹងបុណ្យ បាប ជ្រះថ្លាផង គ្រាន់និងបានជាទីពឹងសម្រាប់ខ្លួន ។

សៀវភៅ **ប្រជុំរឿងប្រេត-នរក** និងផលានិសង្សបុណ្យនេះ កើតឡើងដោយសទ្ធាជ្រះថ្លារបស់ខ្ញុំព្រះករុណា និងលោកគ្រូ ស៊ុម សំអឿន ដែលជាអ្នកផ្តួចផ្តើមឡើង ។ ដោយយល់ឃើញថា មានគម្ពីរខ្លះចាស់ទ្រុឌទ្រោម និងមានរឿងបុណ្យបាប នរក ប្រេត នៅផ្សេងពីគ្នា ជាហេតុនាំឲ្យពិបាកសិក្សាស្រាវជ្រាវ និងមានប្រយោជន៍ដល់ពុទ្ធសាសនិកជនទូទៅផងនោះ ។

អាស្រ័យហេតុនេះ បានជាខ្ញុំព្រះករុណាប្រមូលសៀវភៅនានាមករៀបរៀងសៀវភៅនេះឡើង ។ ដូចជាដកស្រង់ចេញពីសៀវភៅ "គាថាធម្មបទប្រែ" របស់លោកគ្រូមហា យិន នឿន សៀវភៅ "ប្រជុំនិទានជាតក" ភាគ១ដល់ភាគ៧ របស់សិទ្ធត្ថបណ្ឌិត សុង ស៊ីវ និងព្រះមហា សំ សុខ សាស្ត្រាចារ្យបាលីវត្តលង្កា សៀវភៅ "នានាធម្មសមុហោ" របស់ព្រះតេជគុណ ម៉ី ស៊ាន សៀវភៅ "ទក្ខិណា-នុប្បទានអធិប្បាយ" របស់ព្រះតេជគុណ ឡេង លេខ សៀវភៅ "ការបម្រើភ្លើង" របស់ព្រះតេជគុណ ទ្រី ប៉ោណៃ និងពីបិដក សៀវភៅ "វិធីបង្រៀនធម្មកថិកថ្មីឲ្យចេះទេសនា" របស់លោកគ្រូ យិន វន់ ដែលមានប្រាប់ឈ្មោះ និងលេខទំព័រសៀវភៅខាងក្រោមផ្ទៃរឿងនោះស្រាប់ ។

ខ្ញុំព្រះករុណា សូមអភ័យទោសចំពោះអ្នកអានទាំងឡាយ ដោយសាររឿង

ខ្លះវែងពេក មិនបានសរសេរឲ្យពិស្តារ សូមសង្ខេបខ្លះៗ ប៉ុន្តែមិនបានបំបាត់អត្ថន័យខ្លឹមសារដើមនោះទេ ក្រៅពីនេះរឿងខ្លះខ្លីល្មមយល់ចូលចិត្តបាន ក៏ទុកតាមលំនាំដើមទាំងអស់ ។ សូមនិមន្តព្រះតេជគុណ អស់លោកទាំងឡាយជាពហុស្សូត កវីរាជបណ្ឌិត ពេញទៅដោយបច្ចេកទេសខាង " អត្ថគម្ពីភាព" មេត្តាចារបំពេញនូវបន្ទាត់ណាដែលឃ្លាតចាក សំយោគព្យញ្ជនៈ អក្ខរាវិរុទ្ធ វោហារវត្តល្បះ ឃ្លា ភាសាបាលីសេចក្តីសម្រាយនោះឲ្យទាន ដើម្បីបានជាច្បាប់គម្រាមួយដ៏ល្អប្រសើរ សម្រាប់សិក្ខាកាម បុត្រទាំងឡាយសិក្សាបណ្តុះនិស្ស័យ សតិបញ្ញា ស្មារតីទៅ ។

សូមប្រមូលមហាកុសលដែលកើត អំពីការខិតខំប្រឹងប្រែងរៀបរៀងទាំងថ្ងៃទាំងយប់នេះ សូមជូនបុណ្យដល់ ញោមប្រុស ដេក ខៃ ញោមស្រី សឹង បន សូមឧទ្ទិសបុណ្យប្រគេនជូនចំពោះព្រះគ្រូឧបជ្ឈាយ៍ ព្រំ មាឃ ព្រមទាំងញាតិការទាំង៧សន្តាន និងញាតិក្នុងសង្សារវដ្តទាំងអស់ ទោះបីធ្លាក់ទៅទីដ៏ ថោកទាបយ៉ាងណា សូមបុណ្យកុសលនេះជួយយឹតយោងឲ្យបានទៅកើតសុគតិភពកុំបីអាក់ខាងឡើយ មានព្រះនិព្វានជាអវសាន ។

សូមឲ្យសប្បុរសទាំងអស់ ទទួលនូវចំណែកបុណ្យស្មើៗគ្នា បាននូវសទ្ធានិងបញ្ញាជាគូនឹងគ្នា ជាសម្មាទិដ្ឋិស្មើៗគ្នា និងរួចចាកទុក្ខតាមឧបនិស្ស័យសន្សំមករៀងៗខ្លួន ។

សូមឲ្យព្រះពុទ្ធសាសនារុងរឿងអស់កាលជាយូរអង្វែង និងផ្សាយទៅពេញសាកលលោក សូមឲ្យសាកលលោកទាំងមូលបានតែសេចក្តីសន្តិភាពតទៅ ។

សូមអនុមោទនា ! សូមអនុមោទនា ! សូមអនុមោទនា !

រៀបរៀងដោយ និក្ខុធម្មជោតោ **ខែម ទិបុល**

ពុទ្ធសករាជ ២៥៥៥

គ្រិះសករាជ ២០១១

## បទនមស្សការ

*នមោ តស្សារហន្តស្ស　　ភគវន្តស្ស តាទិនោ*
*សម្មា សាមំ វ ពុទ្ធស្ស　　ធម្មេ វិភជ្ជវាទិនោ*
*សូមថ្វាយបង្គំព្រោះព្រះអរហន្ត　　ទ្រង់នាមភគវន្តប្រសើរបវរ*
*ព្រះអង្គមិនមានព្រះទ័យញាប់ញ័រ　　ដោយលោកធម៌ទាំង ៨ឡើយ*
*ទ្រង់ត្រាស់ដឹងធម៌ដោយប្រពៃហើយ ចែកធម៌នោះដល់សត្វទាំងពួង ។*

*នមោ តស្សេវ ធម្មស្ស　　និយ្យានិកស្ស វដ្តតោ*
*បតេទា នវវិធស្ស　　ស្វាក្ខាតស្សេវ សច្ចតោ*
*សូមថ្វាយបង្គំព្រោះគុណព្រះធម៌　　ស្រង់សត្វនិករចេញចាកសង្សារ*
*ជាសង្ឃប្រតិបត្តិលះកាត់តណ្ហា　　ព្រះទ័យជ្រះថ្លា គ្មានសៅហ្មងឡើយ*
*អនុស័យកិលេស លោកលះអស់ហើយ និងឆ្លងដល់ត្រើយគឺព្រះនិព្វាន ។*

## ចិត្តជាប្រធាន

លោកធម៌ទាំងឡាយចិត្តជាប្រធាន　ប្រសើរពុំមានអ្វីធំលើសចិត្ត
ដឹងសុខដឹងទុក្ខមុខគួរអាណិត　សម្រេចដោយចិត្តជាអ្នកចាត់ចែង ។
បុគ្គលមានចិត្តជ្រះថ្លាល្អហើយ　ពុំប្រព្រឹត្តឡើយការនាំចំបែង
ទោះនិយាយស្តីប្រពៃក្រៃលែង　គោរពកោតក្រែងធ្វើតែកុសល ។
ព្រោះជ្រះថ្លាបរិសុទ្ធនោះឯង　ក្តីសុខរមែងតាមជាប់បុគ្គល
ដូចជាស្រមោលអន្ទោលវិលវល់　តាមប្រាណបុគ្គលយ៉ាងដូច្នោះឯង ។
យោ ន រោ វីនរៈជនឯណា　មានចិត្តល្អថ្លាប្រាថ្នាចាត់ចែង
ធ្វើបុណ្យឲ្យទានឥតមានចំបែង　ក្តីសុខរមែងតាក់តែងជននោះ ។[1]

---

[1] ជំនួយសតិភាគទី៥ ទំព័រ ២៣០ របស់លោកគ្រូ ប៊ុត សាវង្ស

# ១.រឿងសង្ខីកូដប្រេត[1]

ព្រះបរមសាស្តា ទ្រង់ប្រារព្ធសង្ខីកូដប្រេតមួយដែលរស់នៅលើកំពូលភ្នំគិជ្ឈកូដ មានអត្តភាពប្រមាណជាបីគាវុត មានដែកក្រហមឆ្អិនឆ្អៅ៦ហ្មឺនដុំធ្លាក់ចុះមកសំពងក្បាលម្តងហើយម្តងទៀតឥតមានឈប់ឈរឡើយ ។

ព្រះមហាមោគ្គល្លានត្ថេរ បានឃើញប្រេតនោះហើយសន្ទនាគ្នា ជាមួយព្រះលក្ខណត្ថេរ នៅទីចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បានជួយធ្វើជាសាក្សីរបស់ព្រះមហាមោគ្គល្លានត្ថេរដែរ ។ ភិក្ខុទាំងឡាយបានក្រាបទូលសួរបុព្វកម្មរបស់ប្រេតនោះនឹងព្រះបរមសាស្តា ។

គ្រានោះ ព្រះសាស្តាទ្រង់សម្តែងនូវអតីតនិទាននេះថា សម័យថ្ងៃមួយមានបុរសគឿម្នាក់ ជាអ្នកពូកែណាស់ក្នុងការផ្ទាត់គ្រាប់គ្រួស ។ ថ្ងៃមួយព្រះរាជាទ្រង់បានត្រាស់បញ្ជាឲ្យពួកអាមាត្យ ទៅតាមនូវបុរសនោះមកគាល់ ហើយទ្រង់ត្រាស់ទៅកាន់បុរសគឿនោះថា យើងមានបុរោហិត ម្នាក់ចូលចិត្តនិយាយច្រើនណាស់ បើបុរោហិតនោះចូលគាល់ហើយហាមាត់និយាយពេលណាអ្នកចូរផ្ទាត់អាចម៍ពពែទាំងអស់នេះ តម្រង់ចូលទៅក្នុងមាត់របស់គេនៅពេលនោះភ្លាម តើអ្នកអាចធ្វើតាមនេះបានឬទេ? ។ បុរសគឿនោះបានក្រាបទូលថា ទូលព្រះបង្គំអាចធ្វើបាន ហើយបានធ្វើតាមព្រះរាជបញ្ជារបស់ព្រះរាជាគ្រប់បែបយ៉ាង ។

ចាប់តាំងពីពេលនោះមក បុរោហិតបានស្ងប់ស្ងាត់ សួរស័ព្ទសម្តីលែងនិយាយច្រើន ដូចពេលមុនទៀត ។ ព្រះរាជាទ្រង់បានព្រះរាជទានរង្វាន់ជាច្រើនដល់បុរសគឿនោះ ។ ក្រោយមកមានបុរសម្នាក់ចង់រៀននូវចំណេះវិជ្ជាផ្ទាត់ដុំគ្រួសអំពីបុរសគឿនោះ ហើយបានចូលទៅផ្ញើខ្លួនប្រាណធ្វើជាកូនសិស្សសុំរៀនវិជ្ជានោះ ។ ទោះជាបុរសនោះមិនព្រមទទួល ក៏បុរសម្នាក់នោះចេះតែតាមបម្រើយកចិត្តថ្លើម បុរសគឿលុះត្រាតែព្រមឲ្យខានមិនបាន លុះរៀនចប់សព្វ

[1] គាថាធម្មបទទំព័រ ១១៣

គ្រប់អស់ហើយ បុរសតឿបានហាមថាអ្នកឯងកុំសម្លាប់អ្នកណាដែលមានសាច់ញាតិ ។

ថ្ងៃមួយ បុរសនោះបានមកជួបប្រទះជាមួយនឹងព្រះបច្ចេកពុទ្ធមួយព្រះអង្គ ក៏គិតថា បុគ្គលម្នាក់នេះប្រាកដជាគ្មានឪពុកម្តាយ ហើយបានផ្ទាត់ដុំគ្រួសសំដៅត្រង់រន្ធត្រចៀកខាងស្តាំរបស់ព្រះបច្ចេកពុទ្ធ ធ្លុះចេញទៅរន្ធត្រចៀកខាងឆ្វេង ធ្វើឲ្យព្រះបច្ចេកពុទ្ធអង្គនោះបរិនិព្វាន ក្នុងមួយរំពេចនោះឯង ។ ដោយបាបកម្មនេះឯងពួកមហាជនដែលតែងតែគោរពបូជា ព្រះបច្ចេកពុទ្ធពេលឃើញទ្រង់បរិនិព្វានលើសាលាឆទានក៏យំសោកស្តាយ ពេលក្រោយមកបុរសសម្លាប់ព្រះបច្ចេកពុទ្ធ បានប្រាប់ថាខ្ញុំផ្ទាត់គ្រាប់គ្រួសសម្លាប់ចង់ឲ្យមហាជនសរសើរថាខ្លួនផ្ទាត់ត្រង់ តែបែរជាធ្វើឲ្យមហាជនខឹងយ៉ាងខ្លាំង ហើយប្រួតចាប់បានសម្លាប់ចោលទៅ ។ លុះស្លាប់ក៏បានទៅកើតសោយទុក្ខវេទនានៅក្នុងមហាអវិចីនរករហូតដល់ផែនដីដុះបានមួយយោជន៍ ទើបបានមកកើតជាសង្ហិកូដប្រេតនៅលើកំពូលភ្នំគិជ្ឈកូដនេះនៅទីបញ្ចប់នៃអតីតនិទាន ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះថា៖

**យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ**
**ហន្តិ ពាលស្ស សុក្កំសំ មុទ្ធមស្ស វិបាតយំ ។**

ចំណេះវិជ្ជាកើតឡើងដល់បុគ្គលពាល ដើម្បីសេចក្តីវិនាសឥតប្រយោជន៍ តែម្យ៉ាងប៉ុណ្ណោះ ចំណេះវិជ្ជានោះ ញ៉ាំងបញ្ញារបស់គេឲ្យធ្លាក់ចុះ រមែងកម្ចាត់បង់នូវចំណែកនៃធម៌ល្អរបស់បុគ្គលពាលនោះចោល ។

---

[2] គាថាធម្មបទប្រែទំព័រ២១៥

## ២. រឿងអជគរប្រេត[2]

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវអជគរប្រេតដែលមានអត្តភាពបីដូចជាពស់ថ្លាន់វែងប្រមាណ២៥យោជន៍ ពេលដែលព្រះមហាមោគ្គល្លានត្ថេរចុះពីកំពូលភ្នំគិជ្ឈកូដបានឃើញប្រេតនោះដោយទិព្វចក្ខុ ហើយនិយាយជាមួយព្រះលក្ខណត្ថេរនៅទីចំពោះព្រះភក្ត្រព្រះសាស្តាៗ ទ្រង់សម្តែងនូវធម្មិកថា ថាតថាគត ក៏បានឃើញដូចគ្នាដែរ ។ ពួកភិក្ខុទាំងអស់ បានក្រាបទូលសួរនូវបុព្វកម្មរបស់ប្រេតនោះនឹងព្រះសាស្តាៗទ្រង់ត្រាស់នូវ អតីតនិទានថានៅក្នុងសាសនានៃព្រះពុទ្ធ ទ្រង់ព្រះនាមកស្សបទសពល ប្រេតនេះជាចោរបានប្រទូសរ៉ាយដល់សុមង្គលសេដ្ឋី គឺបានដុតស្រែ កាប់ជើងគោ ដុតផ្ទះរបស់លោកសេដ្ឋី ដល់ទៅ ៧លើក ប៉ុណ្ណេះហើយនៅតែមិនអស់ចិត្តទៀត បានទាំងទៅដុតព្រះគន្ធកុដិដែលលោកសេដ្ឋី សាងថ្វាយដល់ព្រះពុទ្ធកស្សបទសពលទៀត ។

លុះស្លាប់ទៅ បានកើតក្នុងអវិចីនរក អស់កម្មពីនោះមកបានមកកើតក្នុងពុទ្ធកាលនេះ កើតជាអជគរប្រេតមានភ្លើងឆេះនៅលើភ្នំគិជ្ឈកូដនេះ ក្នុងទីបំផុតនៃអតីតនិទានព្រះអង្គត្រាស់នូវព្រះគាថានេះថា៖

**អថ បាបានិ កម្មានិ ករំ ពាលោ ន ពុជ្ឈតិ**
**សេហិ កម្មេហិ ទុម្មេធោ អគ្គិទឌ្ឍោវ តប្បតិ ។**

ក៏បុគ្គលពាល គ្មានបញ្ញា កំពុងធ្វើនូវបាបកម្មទាំងឡាយ ក៏នៅតែមិនដឹងខ្លួន, តែនឹងក្តៅក្រហាយ ដូចជាភ្លើងឆេះអាលរាល ព្រោះកម្មទាំងឡាយរបស់ខ្លួន ។

## ៣. រឿងព្រះមហាមោគ្គល្លានត្ថេរ[3]

(ប្រទូសរ៉ាយអ្នកឥតគប ស្លាប់ទៅរមែងធ្លាក់នរក)

ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះមហាមោគ្គល្លានត្ថេរ ដែលត្រូវពួកតិរ្ថិយជួលពួកចោរឲ្យទៅសម្លាប់ ។ ព្រះបាទអជាតសត្រូវ ទ្រង់ស៊ើបសួររករឿងពិត

[3] គាថាធម្មបទប្រែ ទំព័រ២១៦

លុះទ្រង់ជ្រាបច្បាស់ហើយ ទ្រង់ព្រះរាជបញ្ជាឲ្យចាប់ពួកតិរ្ថិយដែលជាដើមហេតុ ព្រមទាំងពួកចោរ ដែលជាអ្នកសម្លាប់ព្រះថេរផង ហើយទ្រង់បញ្ជាឲ្យជីកអន្លង់កប់ត្រឹមផ្ចិត ឲ្យយកចំបើងដាក់ពីលើ ហើយឲ្យយកភ្លើងទៅដុតទាំងរស់ឲ្យស្លាប់ទាំងអស់គ្មានសេសសល់ម្នាក់ឡើយ ។

ពួកភិក្ខុទាំងឡាយ បានសន្ទនាគ្នាពីរឿងព្រះមហាមោគ្គល្លានត្ថេរ ។ ព្រះសាស្តាទ្រង់សម្តែងនូវអតីតនិទានរបស់ព្រះមហាមោគ្គល្លានត្ថេរថា គ្រាដែលព្រះមហាមោគ្គល្លានត្ថេរ កើតជាកុសលបុត្រមានភរិយាមួយត្រូវភរិយានោះនិយាយចាក់ដោត ញុះញង់ឲ្យយកមាតាបិតារបស់ខ្លួនទៅសម្លាប់ចោល លុះកុសលបុត្រនោះស្លាប់ពីលោកនេះទៅ បានទៅកើតក្នុងនរករាប់សែនឆ្នាំ ដោយផលវិបាកនៃកម្មនោះ ព្រះមហាមោគ្គល្លានត្ថេរត្រូវគេវាយដំខ្ទេចឆ្អឹងយ៉ាង នេះ រហូត១រយអត្តភាព គឺ១រយជាតិ ព្រះមហាមោគ្គល្លានត្ថេរបរិនិព្វានយ៉ាងនេះសមគួរនឹងកម្មរបស់ខ្លួនហើយ ។

ចំណែកពួកតិរ្ថិយ និងពួកចោរ ដែលបានប្រទូសរ៉ាយដល់ព្រះមហាមោគ្គល្លានត្ថេរ ជាអ្នកមិនប្រទូសរ៉ាយតបនោះ បានទទួលនូវសេចក្តីស្លាប់សមគួរដូចគ្នាដែរ នៅទីបំផុតនៃអតីតនិទាន ព្រះអង្គត្រាស់ព្រះគាថានេះថា៖

**យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ**
**ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ**
**វេទនំ ផរុសំ ជានឹ សរីរស្ស ច ភេទនំ**
**គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ បាបុណេ**
**រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ**
**បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ**
**អថវាស្ស អគារានិ អគ្គិ ឌហតិ បាវកោ**
**កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ។**

អ្នកណាប្រទូសរ៉ាយ ក្នុងជនទាំងឡាយ ដែលមិនប្រទូសរ៉ាយ ជាអ្នកមិនមានអាជ្ញា ដោយអាជ្ញារមែងដល់នូវឋានៈ១០ យ៉ាងណាមួយយ៉ាងឆាប់រហ័សគឺ គប្បីដល់នូវវេទនាយ៉ាងធ្ងន់១ សេចក្ដីវិនាសទ្រព្យ១ ការបែកធ្លាយនៃរាងកាយ១ អាពាធជាទម្ងន់១ សេចក្ដីរាយមាយនៃចិត្ត១ ឧបសគ្គពីព្រះរាជា១ ការនិយាយមួលបង្កាច់យ៉ាងធ្ងន់១ ការអស់ទៅនៃពួកញាតិ១ ការវិនាសបាត់បង់នូវភោគៈទាំងឡាយ១ ម្យ៉ាងទៀតភ្លើងព្រៃនឹងឆេះផ្ទះរបស់គេ ដោយខ្លួនឯង១ ។ អ្នកនោះជាអ្នកមានបញ្ញាអន់ថយ ព្រោះទម្លាយរាងកាយគឺស្លាប់ រមែងចូលទៅកាន់ឋាននរក ។

## ៤. រឿងសូករប្រេត[4]

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធសូករប្រេត ។ ប្រេតនេះកាលអតីតជាតិបានបួសជាភិក្ខុក្នុងសាសនានៃព្រះពុទ្ធកស្សប បានពោលពាក្យចាក់ដោតញុះញង់ឲ្យព្រះថេរៈពីអង្គដែលមានសីលបរិសុទ្ធ ឈ្លោះប្រកែកបែកបាក់សាមគ្គីគ្នា ព្រោះកម្មដែលបានពោលពាក្យ ញុះញង់ចាក់ដោតនោះ លុះស្លាប់ទៅកើតនៅក្នុងនរកអវិចី អស់កាលមួយពុទ្ធន្តរ ក្នុងចន្លោះព្រះពុទ្ធមួយអង្គ មកដល់សាសនានេះ ក៏បានមកកើតជាប្រេត មានដងខ្លួនដូចជាមនុស្សតែមានក្បាលដូចជាសត្វជ្រូក អាស្រ័យនៅលើភ្នំគិជ្ឈកូដ ។

ព្រះមហាមោគ្គល្លានត្ថេរ បានឃើញប្រេតនេះហើយ ក៏និយាយប្រាស្រ័យជាមួយព្រះលក្ខណត្ថេរ នៅក្នុងទីចំពោះព្រះភក្ត្រនៃព្រះសាស្ដា ។ ព្រះអង្គត្រាស់ព្រះគាថានេះថា៖

**វាចានុរក្ខី មនសា សុសំវុតោ**
**កាយេន ច អកុសលំ ន កយិរា**
**ឯតេ តយោ កម្មបថេ វិសោធយេ**
**អារាធយេ មគ្គមិសិប្បវេទិតំ ។**

---

[4] គាថាធម្មបទប្រែទំព័រ ៣៨១

បុគ្គលមានប្រក្រតីរក្សាវាចា សង្រួមហើយដោយចិត្ត និងមិនគួរធ្វើអកុសលដោយកាយ, គប្បីញ៉ាំងកម្មបថទាំង៣ ប្រការនេះឲ្យបានបរិសុទ្ធល្អ, គប្បីត្រេកអរ និងផ្លូវដែលអ្នកស្វែងរកគុណាបានប្រកាសហើយ ។

## ៥. រឿងប្រេតក្លាយជាទេវតា[5]

(គុណនៃការផ្សាយកុសលដល់ប្រេត)

ក្នុងកាលកន្លងទៅហើយមានប្រេតមួយរូប អត់ឃ្លានអាហារច្រើនលានឆ្នាំ តែងនឹករឭករកញាតិមិត្តបងប្អូនជានិច្ច ប៉ុន្តែពុំដែលបងប្អូនញាតិមិត្តណាឧទ្ទិសកុសលផ្សាយឲ្យម្ដងសោះ ។ ថ្ងៃមួយមានឧបាសកម្នាក់ឈ្មោះ វិទេហៈ ដេកនៅក្នុងខ្ទមស្រែ ចាំស្រូវក្នុងលង្កាទ្វីប ស្រាប់តែប្រេតនោះទៅសុំអាហារបរិភោគ ដោយនឹករឭកឃើញថា វិទេហឧបាសកនេះ ត្រូវជាសម្លាញ់របស់អញក្នុងជាតិមុនយូរអង្វែងណាស់ហើយ ។ វិទេហឧបាសកឮសំឡេងប្រេតស្រែកសុំអាហារបរិភោគដូច្នោះ ក៏សួរថាអ្នកជាអ្វី? មកពីណា? ។

ប្រេតប្រាប់ថា ខ្ញុំត្រូវជាសម្លាញ់របស់អ្នកក្នុងជាតិដែលកន្លងទៅយូរអង្វែងណាស់ហើយ ខ្ញុំស្លាប់ពីជាតិនោះបានមកកើតជាប្រេតនៅក្នុងលង្កាទ្វីបនេះ ពុំដែលបានអាហារបរិភោគឡើយ ញាតិមិត្តបងប្អូនទាំងឡាយ គេមិនដែលឧទ្ទិសផលដល់ខ្ញុំម្ដងសោះបានជាខ្ញុំមកសុំអាហាររបស់សម្លាញ់បរិភោគ ។ វិទេហឧបាសកឮដូច្នោះ មានចិត្តអាណិតពន់ពេក ទើបហៅប្រេតឲ្យឡើងលើខ្ទមយកបាយមកឲ្យប្រេតស៊ី ។ ប្រេតឃើញឧបាសកឲ្យបាយដូច្នេះហើយ ក៏ប្រាប់ថា ម្នាលសម្លាញ់បើអាណិតខ្ញុំ អ្នកចូរយកភត្តទៅថ្វាយដល់ព្រះសង្ឃ ហើយឧទ្ទិសផលឲ្យដល់ខ្ញុំ ទើបខ្ញុំទទួលបរិភោគបាន ។

លុះព្រឹកឡើងវិទេហឧបាសក បានចាត់ចែងថ្វាយភត្តដល់ព្រះសង្ឃ ឧទ្ទិសបញ្ជូនផលទៅប្រេតនោះៗ កាលបើបានទទួលផលហើយ ក៏មានរូបកាយស្អាត

[5] ប្រជុំនិទានជាតក ភាគ១ទំព័រ ១២៦

បាតបរិភោគអាហារទិព្វឆ្អែតស្កប់ស្កល់ ប៉ុន្តែនៅខ្វះសំពត់ស្លៀកទៀតក៏ដើរទៅបង្ហាញខ្លួនដល់វិទេហឧបាសកសុំសំពត់អាវស្លៀកពាក់ ។ វិទេហឧបាសកប្រាប់ថា បើអ្នកខ្វះសំពត់ខ្ញុំមានសំពត់កម្ពលពា អ្នកយកទៅស្លៀកចុះ ។ ប្រេតនិយាយថា ឲ្យខ្ញុំយ៉ាងហ្នឹងមិនបានទេ ចូរសម្លាញ់យកទៅប្រគេនព្រះសង្ឃដូចមុន ទើបខ្ញុំទទួលបាន ។ វិទេហឧបាសក ក៏ចាត់ចែងសំពត់ប្រគេនដល់ព្រះសង្ឃ សំពត់នោះក៏ក្លាយជាសំពត់ទិព្វ កើតដល់ប្រេត ។ វេលានោះប្រេតក៏ក្លាយខ្លួនទៅជាទេវបុត្រ ដោយអំណាចកុសលដែលវិទេហឧបាសកឧទ្ទិសផ្សាយឲ្យ ។ កាលបើបានរួចពីកំណើតប្រេតហើយ ក៏រឭកដល់គុណរបស់វិទេហឧបាសក ទើបបង្ហាញខ្លួននិយាយថា សម្លាញ់អ្នកមានគុណច្រើនណាស់លើរូបខ្ញុំ ខ្ញុំគ្មានអ្វីតបគុណសម្លាញ់ទេ ចូរសម្លាញ់ទៅគាស់យកកំណប់ទ្រព្យពាក្អមនៅក្រោមដើមជ្រៃក្បែរភ្លឺស្រែអ្នកចុះ ព្រោះកំណប់នោះខ្ញុំឃើញយូរហើយគ្មានម្ចាស់ថែរក្សាទេ ។ ឧបាសកយកចបទៅកាប់មើល ឃើញជាកំណប់ទ្រព្យពិតមែន ក៏ទៅក្រាបទូលដល់ព្រះរាជារបស់ខ្លួន ។ ព្រះរាជាបានចាត់ចែងឲ្យយករទេះទៅដឹកមកចាក់គរនៅមុខព្រះបរមរាជវាំង ហើយទ្រង់តាំងឧបាសកនោះធ្វើមហាសេដ្ឋីគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនទៅ ។ ឯទេវបុត្រនោះមានប្រាសាទមាសផុសនៅស្ថានត្រៃត្រឹង ក៏ឡើងទៅនៅក្នុងស្ថានទេវលោកបរិបូណ៌ដោយទិព្វសិរីខ្ពាត់ផុតពីសេចក្តីទាល់ក្រគ្រប់យ៉ាង ។

## ៦. រឿងយមលោក និងទេវតាលោក[6]

(អានិសង្ស និងទោសរបស់អកុសលកម្ម)

កាលព្រះបរមគ្រូសម្ពុទ្ធ ទ្រង់គង់នៅក្នុងវត្តជេតពននាក្រុងសាវត្ថី ។ កាលនោះព្រះមហាមោគ្គល្លានត្ថេរ ជាអ្នកមានឫទ្ធិច្រើនមានបំណងចង់ទៅមើលស្ថាននរក បានចូលទៅថ្វាយបង្គំលាព្រះពុទ្ធជាបរមគ្រូហើយ ក៏និមន្តទៅយមលោក

[6] ប្រជុំនិទានជាតក ភាគ១ទំព័រ ៨១

ពិនិត្យមើលស្ថានភាពទីកន្លែងនរក តាំងពីនរកតូចៗ រហូតដល់នរកធំឈ្មោះ អវិចីលោកនិមន្តទៅដល់ទីណា សត្វនរកក៏បានស្បើយទុក្ខក្នុងទីនោះ ដោយអំណាចឫទ្ធិរបស់លោក ។ មហានរកឈ្មោះអវិចីកាលបើព្រះមហាមោគ្គល្លាននិមន្តទៅដល់ហើយ គំនរភ្លើងក៏វិនាសបាត់ទៅមានផ្កាឈូកប៉ុនកង់រទេះផុសឡើង លោកក៏ឡើងគង់លើផ្កាឈូកនោះ ។ ពួកនរកទាំងឡាយ បានចូលទៅចោមរោមថ្វាយបង្គំសួរថា លោកម្ចាស់និមន្តមកអំពីទីណា? ព្រះមោគ្គល្លានប្រាប់ថា អាត្មាមកពីមនុស្សលោក ។ សត្វនរកទាំងឡាយ បានឮដូច្នោះហើយក៏ផ្តាំទៅញាតិមិត្តរបស់ខ្លួនថា សូមលោកម្ចាស់ប្រាប់ដល់មាតាបិតា បុត្រភរិយាញាតិមិត្របស់ខ្ញុំព្រះករុណាផង ថាខ្ញុំព្រះករុណាជាកូន ជាឪពុកម្តាយ ជាមីងមា ធ្លាប់ទៅកើតក្នុងនរក សោយទុក្ខ វេទនាជាយូរយារណាស់ហើយមានសេចក្តីនឹករលឹកមកជាខ្លាំងណាស់ អាណិតធ្វើ បុណ្យទានឧទ្ទិសផលបញ្ជូនឲ្យផង ។ ព្រះមហាមោគ្គល្លានទទួលដំណឹងនោះហើយ ក៏ត្រឡប់មកមនុស្សលោកវិញ មុននឹងត្រឡប់មក លោកបានយកភ្លើងអវិចីប៉ុនគ្រាប់ ស្ពៃ ខ្ចប់នឹងជាយចីវររបស់លោកដោយឫទ្ធិ មកដល់មនុស្សលោកបានប្រកាសប្រាប់ញាតិមិត្រ មាតាបិតារបស់សត្វនរកទាំងនោះតាមបណ្តាំ ។ ពួកមហាជនទាំងឡាយដែលត្រូវជាញាតិមិត្ររបស់សត្វនរក បានដឹងដូច្នោះហើយ ក៏យំសោកបោកខ្លួនប្រាណ តែលំពួខ្លួនលុះ បន្ទាបង់នូវសេចក្តីសោកនោះហើយ បាននិមន្តព្រះសង្ឃមានព្រះពុទ្ធ ជាប្រធានមកថ្វាយទក្ខិណាទាន ឧទ្ទិសបញ្ជូនផលទៅសត្វនរកទាំងនោះដោយអំណោយរបស់ព្រះមោគ្គល្លាន និងដោយសត្វនរកទាំងនោះមានចិត្តទន្ទឹងចាំតែទទួលផលផងក៏បានទទួលដូចបំណង ។ ពេលនោះសត្វនរកទាំងឡាយ បានរួចចាកទុក្ខទៅ កើតក្នុងស្ថានសួគ៌ជាច្រើនដូចមានបាលីក្នុងគម្ពីរនោះថា៖

**តេនិរយកសត្តា ទុក្ខតោ មុញ្ចន្តិ តតោ ចវិត្វា សគ្គបទំ បូរយឹសុ ។**

សត្វនរកទាំងនោះបានរួចចាកទុក្ខ ទៅកើតក្នុងស្ថានសួគ៌មីរដេរដាសត្រៀបត្រា ។

ក្នុងពេលនោះព្រះមោគ្គល្លានបាននិមន្តទៅស្ថានសួគ៌ទាំង៦ជាន់ បាននិមន្តទៅឈររេរានៅស្ថានត្រៃត្រិង ពេលនោះពួកទេវតាក្នុងសួគ៌ទាំង៦ជាន់ក្តៅក្រហល់ក្រហាយនឹងចំហាយភ្លើងអវិចីដែលខ្ទប់នឹងជាយចីវរនោះគ្រប់ៗគ្នា ។ សក្កទេវរាជ បានជ្រាបហេតុហើយ ទៅប្រគេនសញ្ញាដល់ព្រះមោគ្គល្លានៗយល់ថាទេវតាទាំង អស់ក្តៅក្រហាយដោយកម្តៅភ្លើងដែលជាប់នឹងជាយចីវររបស់អញទេតើ! បាន ជាឆ្លេឆ្លាយ៉ាងនេះ លោកគិតថាភ្លើងប៉ុនគ្រាប់ស្ពៃនេះមានកម្លាំងក្តៅខ្លាំងណាស់ បើអាត្មាអញចោលលើផែនដីនឹងឆេះខ្ទេចខ្ទីអស់ ចោលទៅក្នុងសមុទ្រនឹងរីងខះទឹក អស់ឥតសល់ ចោលទៅឰដ៏អាកាសនឹងរាំងភ្លៀងអស់១២ឆ្នាំ បើដូច្នោះ មានតែអាត្មាអញយកទៅចោលនៅកន្លែងអវិចីវិញ ក៏យកទៅចោលក្នុងអវិចីនោះទៅ ហើយនិមន្តទៅថ្វាយបង្គំព្រះពុទ្ធ ក្រាបទូលដំណឹងអំពីយមលោក និងទេវលោកដោយសព្វគ្រប់ ។ ព្រះសម្ពុទ្ធទ្រង់ប្រារព្ធនូវហេតុនោះហើយ ក៏ប្រទាននូវធម្មទេសនាដល់ពុទ្ធបរិស័ទទាំងឡាយថា៖

**នហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ ។**

សភាវៈពីរប្រការគឺៈ កុសលធម៌១ អកុសលធម៌១ឲ្យផលមិនស្មើគ្នា អកុសលធម៌តែងនាំសត្វទៅនរក កុសលធម៌តែងនាំសត្វទៅស្ថានសួគ៌ ។ លុះចប់នូវធម្មទេសនានេះហើយពួកពុទ្ធបរិស័ទទាំងឡាយ បានលុះនូវមគ្គានិសម័យចំនួន៣ ម៉ឺន៤ពាន់នាក់ក្នុងវេលានោះឯង ។

[7] ប្រជុំនិទានជាតក ភាគ៣ទំព័រ ៣១៣

## ៧. រឿងគហបតីប្រេត[7]

(ទោសនៃការមើលងាយព្រះសារីរិកធាតុ)

កាលព្រះសម្ពុទ្ធបរមគ្រូបរិនិព្វានហើយ ពួកពុទ្ធបរិស័ទទាំងឡាយមានព្រះបាទមល្លរាជជាប្រធានបានរៀបបូជាព្រះបរមសពព្រះសម្ពុទ្ធ លុះបូជាហើយព្រះមហាក្សត្រទាំងឡាយក្នុងជម្ពូទ្វីប លើកទ័ពមកច្បាំងដណ្តើមព្រះបរមធាតុ កាលនោះ ទោណអាចារ្យបានសម្រុះសម្រួលចែកព្រះបរមធាតុដល់ព្រះរាជាទាំងឡាយនោះដោយសន្តិវិធី ។ ព្រះរាជាទាំងឡាយនោះក៏នាំយកព្រះបរមធាតុ ទៅនគររៀងរាល់ព្រះអង្គ ។ ឯព្រះបាទអជាតសត្រូវព្រះអង្គមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង បានរៀបចាត់ចែងធ្វើពិធីដង្ហែយ៉ាងឱឡារិកសន្និកមហិមា ចាប់តាំងតែពីចេញដំណើរពីក្រុងកុសិនារា ទៅដរាបដល់ក្រុងរាជគ្រឹះ គឺតម្កល់ព្រះបរមធាតុលើព្រះរាជរថជ័យ ដែលវិចិត្រដោយរតនៈ៧ប្រការ .កាលបើចេញហែបានចម្ងាយប្រវែង១រាជរថហើយ ឈប់ធ្វើបុណ្យម្តងចំនួន៧យប់៧ថ្ងៃ ។ ចេះតែធ្វើតាមលំដាប់ដូច្នេះដរាបដល់ក្រុងរាជគ្រឹះ ។ រួបរួមរយៈវេលាដែលហែចេញពីក្រុងកុសិនារាទៅដល់ក្រុងរាជគ្រឹះអស់៧ឆ្នាំ៧ខែ ៧ថ្ងៃទើបដល់ ។ ពួកពុទ្ធបរិស័ទទាំងអស់ក្នុងក្រុងរាជគ្រឹះ មានសេចក្តីជ្រះថ្លា សប្បាយរីករាយយ៉ាងក្រៃលែង ។ ឯពួកជនមិច្ឆាទិដ្ឋិជាង៨ម៉ឺននាក់ មិនជ្រះថ្លាបែរជានិយាយត្អូញត្អែរថា ធ្វើបុណ្យយូរយ៉ាងនេះ គ្មានអ្នកណារកស៊ីធ្វើការអ្វីកើតទេ ម្យ៉ាងទៀតគ្មានប្រយោជន៍អ្វីអំពីឆ្អឹងដែលគេដុតជាធ្យូងនោះទេ ។ ពួកជនទាំងនោះ ចងសេចក្តីក្រោធចំពោះព្រះធាតុ និងព្រះមហាក្សត្រជាដើមរាល់ពេលវេលា ។ បណ្តាមនុស្សមិច្ឆាទិដ្ឋិជាង៨ម៉ឺននោះ មានគហបតីម្នាក់មានទ្រព្យច្រើន ជាអ្នកមិច្ឆាទិដ្ឋិចំណាប់មួយដែរ ឯភរិយា បុត្រី កូនប្រសាគាត់ ជាសម្មាទិដ្ឋិ មានចិត្តជ្រះថ្លា ទៅហែព្រះសារីរិកធាតុ ធ្វើបុណ្យជាមួយគេឯងរាលពេលវេលា ទោះបីគហបតីស្តីបន្ទោសយ៉ាងណាក៏មិនធ្វើជាដឹងឮ ។ លុះធ្វើមរណកាលតាមលំដាប់សង្ខារ របស់ខ្លួន

ទៅគហបតីកើតជាប្រេតជាមួយពួកជនមិច្ឆាទិដ្ឋិជាង៨ម៉ឺននាក់នោះ នៅចន្លោះភ្នំគិជ្ឈកូដ ។ ឯភរិយា បុត្រី បុត្រប្រសាទៅកើតជាទេវតានៅស្ថានសួគ៌ ។

ថ្ងៃមួយព្រះមហាកស្សបត្ថេរ ចេញពីសមាបត្តិ ហើយពិចារណាឃើញមនុស្សស្លាប់ទៅកើតជាប្រេត នរកច្រើនទើបលោកនិមន្តទៅឈរត្រង់ទីលានមុខព្រះចេតិយដែលបញ្ចុះព្រះបរមធាតុ ហើយថ្លែងឫទ្ធិធ្វើឲ្យនរក ប្រេត មនុស្សទេវតាមើលឃើញគ្នាទៅវិញទៅមក ។

ឯគហបតីប្រេតនោះ ក្រឡេកមើលទៅឰដ៏អាកាសឃើញភរិយា បុត្រី បុត្រប្រសាខ្លួនកើតជាទេវតាសោយទិព្វសម្បត្តិដូច្នោះ នឹកក្តៅក្រហាយនឹងវាសនារបស់ខ្លួន ក៏ចូលទៅជិតព្រះមហាកស្សបហើយប្រកាសថា ឲ្យតែបានរួចពីប្រេតវិស័យទៅកើតជាមនុស្សវិញនឹងខំគោរព បូជាព្រះសារីរិកធាតុគ្រប់ពេលវេលា ។ មួយស្របក់ក្រោយមក ព្រះមហាកស្សបរំសាយឫទ្ធិ លែងឲ្យឃើញ នៅដូចធម្មតាវិញ ។ ពួកពុទ្ធបរិស័ទទាំងឡាយ ឃើញហេតុអស្ចារ្យដូច្នោះ ក៏ចូលទៅថ្វាយបង្គំសួរបុព្វកម្មរបស់នរកប្រេតដែលខ្លួនបានឃើញផ្សេងៗគ្នា ។ ព្រះមហាថេរ ក៏ប្រារព្ធយករឿងប្រេតជាង៨ម៉ឺននាក់មានគហបតីប្រេតមកសម្តែង តាមដំណើរបុព្វកម្មរបស់ប្រេតទាំងនោះក្នុងកាលនោះឯង ។ ឯពួកប្រេតជាង៨ម៉ឺននាក់មានគហបតីប្រេតជាប្រធាន នៅរងទុក្ខវេទនាដរាបដល់សព្វថ្ងៃព្រោះតែការមើលងាយព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះឯង។

## ៨.រឿងនាងវិមានប្រេត[8]

(ទោសលួចទ្រព្យគេ និងទោសបិតសុរាលក់)

ក្នុងកាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានស្ត្រីក្រមុំម្នាក់ឈ្មោះកល្យាណី មានរូបល្អជាទីស្រលាញ់ពេញចិត្តចំពោះមហាជន ដែលបានឃើញរូបនាង ។ ថ្ងៃមួយមានបុរសម្នាក់ចាប់ចិត្តស្រលាញ់ បានចូលទៅនិយាយ

[8] ប្រជុំនិទានជាតក ភាគ៣ទំព័រ ៣២៤

ជាច្រើនដង នាងមិនព្រមយកក៏កើតទោសៈ ព្យាបាទនាងយកថ្នាំជម្រុះសក់ទៅជួលនាងទាសីឲ្យដាក់ក្នុងប្រអប់រមៀត ដល់នាងទៅមុជទឹកនាកំពង់ក្បែរផ្ទះ យករមៀតនោះកក់ក្បាលសក់ក៏ជ្រុះអស់គ្មានសល់មួយសរសៃ នៅតែលលាដ៍ក្បាលទទេ នាងកើតសេចក្ដីអៀនខ្មាស ក៏យកក្រមាទទូរក្បាលរត់គៀសខ្លួនទៅនៅស្រុកចុងកាត់មាត់ញក ឆ្ងាយពីស្រុកកំណើត ។ ក្រោយមកនាងកល្យាណីដល់នាងនៅស្រុកចុងកាត់មាត់ញក យូរទៅសក់ក៏ឥតមានដុះឡើងវិញ ប្ដីក៏នាងមិនយក ទៅជាអ្នកទ័លក្រ ទើបប្រកបរបរបិតស្រាលក់ ពួកប្រមឹកទាំងឡាយតែងចោមរោមរកនាងជានិច្ចរាល់ថ្ងៃ ។ កាលនោះមានអ្នកប្រមឹក ពីរនាក់ដេកលក់ នាងលួចសម្រាតយកសំពត់អាវអស់ នៅអាក្រាតកាយទទេ ពួកប្រមឹកដឹងខ្លួនឡើង មានសេចក្ដីអៀនខ្មាស ក៏នាំគ្នារត់ទៅផ្ទះអស់ទៅ ។ ថ្ងៃក្រោយមកនាងកល្យាណី បានឃើញព្រះខីណាស្រព១អង្គនិមន្តទៅបិណ្ឌបាត មានសេចក្ដីជ្រះថ្លា ក៏និមន្តចូលគង់លើអាសនៈក្នុងផ្ទះរបស់ខ្លួន ហើយចាត់ចែងប្រគេនប្រអូលលាយដោយប្រេងល្ង កាលបើព្រះខីណាស្រពឆាន់ហើយ នាងតាំងសេចក្ដីប្រាថ្នាថា សូមឲ្យមានរូបល្អ មានសក់ល្អសរសៃល្អិតដូចរោមទ្រាយព្រះខីណាស្រព ធ្វើអនុមោទនាហើយនិមន្តទៅទីដទៃទៀត ។ ដល់នាងអស់អាយុបានកើតជាប្រេតញី មានរូបល្អ សក់ដុះល្អដូចប្រាថ្នា ស្ថិតនៅក្នុងវិមានមាសតែម្នាក់ឯងកណ្ដាលមហាសមុទ្រ ប៉ុន្តែគ្មានសំពត់អាវស្លៀកពាក់ អាក្រាតកាយទទេយកសក់ក្បាលគ្របខ្លួន មានសេចក្ដីអៀនខ្មាសយ៉ាងខ្លាំងតែម្នាក់ឯងមិនដែលចេញទៅណា នៅតែក្នុងវិមានស្ងាត់ជ្រងំកណ្ដាលមហាសមុទ្រនោះឯង ។

សម័យនោះ មានឈ្មួញសំពៅ៧រយនាក់ឆ្លងកាត់មហាសមុទ្រទៅប្រកបការងារត្រើយម្ខាង ត្រូវខ្យល់ព្យុះបក់បោករសាត់ចុះឡើងនៅកណ្ដាលមហាសមុទ្រនោះក៏ទៅជួបនឹងវិមានរបស់នាងប្រេតនោះ ។ អ្នកសំពៅទាំងឡាយឃើញរូបនាងស្អាតល្អស្រស់ នៅតែម្នាក់ឯង ក៏សំគាល់ថាទេពធីតាបានអញ្ជើញ

នាងឲ្យចេញមកក្រៅ ដើម្បីចរចាគ្នាឲ្យដឹងដំណើររឿង នាងមិនព្រមចេញមកសោះ ដោយសេចក្តីអៀនខ្មាសគ្របសង្កត់ខ្លាំងពួកអ្នកសំពៅចេះតែទទូចសួរថា នាងមានរូបល្អយ៉ាងនេះពួកយើងមិនដែលឃើញសោះ តើនាងជាទេពធីតាឬ? សួរញយៗពេក នាងក៏ប្រាប់ថាខ្ញុំនេះជាប្រេតទេ ឈ្មោះវិមានប្រេតតាំងពីកើតមកខ្ញុំមិនដែលបានសំពត់ស្លៀកសោះ ព្រោះផលអាក្រក់ដែលខ្ញុំលួចសំពត់ អ្នកប្រមឹកពីជាតិមុន ដែលខ្ញុំមានរូបល្អ មានចំណីអាហារទិព្វ វិមានមាសប្រតិស្ឋាននៅកណ្តាលមហាសមុទ្រនេះ កើតឡើងដោយផលបុណ្យ ដែលខ្ញុំបានប្រគេនប្រអូលដល់ព្រះខីណាស្រព។ ពួកអ្នកសំពៅសួរទៀតថា នាងមកកើតនៅទីនេះប៉ុន្មានឆ្នាំហើយ ? នាងប្រាប់ថារាប់ឆ្នាំមិនបានទេចំនួនមួយកប្បមកហើយ ។

នាយសំពៅអាណិតដល់នាងប្រេតនោះពេក បានយកសំពត់១គូហុចឲ្យទៅស្លៀក នាងលើកដៃសំពះអង្វរថា ខ្ញុំទទួលយកមកស្លៀកពុំបានទេ ព្រោះខ្ញុំជាប្រេត បើលោកមេត្តាឲ្យទានខ្ញុំ សូមឲ្យទៅព្រះសង្ឃ ឬអ្នកមានសីលបរិសុទ្ធហើយឧទ្ទិសផលឲ្យខ្ញុំ ទើបខ្ញុំទទួលបាន ។ គួរអស្ចារ្យណាស់ក្នុងសំពៅនោះគ្មានព្រះសង្ឃមួយអង្គសោះ មានតែឧបាសកម្នាក់មានសីលបរិសុទ្ធ នាយសំពៅក៏ជូនសំពត់ទៅឧបាសកនោះ ហើយឧទ្ទិសផលចំពោះដល់ប្រេតនោះស្រាប់តែប្រេតបានសំពត់ទិព្វស្លៀកដណ្តប់ភ្លាម (រឿងនេះតាមដឹងរៀងមកថាទាល់តែឲ្យដល់សង្ឃ ទើបឧទ្ទិសផលដល់ប្រេតបាន សូមបញ្ជាក់ប្រាប់ថាឲ្យតែធ្វើជាមួយអ្នកមានសីលបានផលខ្លះដែរ ប៉ុន្តែឲ្យដល់ឧបាសកមានផលពុំស្មើព្រះសង្ឃទេ ពីព្រោះព្រះសង្ឃមានសីលខ្ពស់ជាង និងជាស្រែបុណ្យក្នុងលោក) ។ នាងវិមានប្រេត កាលបើបានសំពត់ស្លៀកពាក់ហើយ ក៏និម្មិតយកអាហារទិព្វជប់លៀងអ្នកសំពៅនោះ ឲ្យឆ្អែតស្កប់ស្កល់គ្រប់គ្នា ទើបយំសោកប្រាប់ដល់អ្នកសំពៅថា អស់លោកអើយ! ខ្ញុំជាស្ត្រីកម្មក្រាស់ណាស់នៅតែ៤ ខែទៀតទេខ្ញុំត្រូវអស់អាយុធ្លាក់ទៅកើតក្នុងនរកហើយព្រោះទោសដែលខ្ញុំបិតស្រាលក់ពីជាតិមុន។ នាយសំពៅ និងឧបាសកមានសេចក្តីមេត្តា ករុណាប្រាប់ថា បើនាងចង់បាន។

នាយសំពៅ និងឧបាសកមានសេចក្ដីមេត្តា ករុណាប្រាប់ថា បើនាងចង់បាន សុខ នាងត្រូវយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭកស្មើដោយជីវិត នាងលើកដៃសំពះទទួលថាសាធុៗ ក៏នឹកភាវនាគុណព្រះរតនត្រ័យ ក្នុងចិត្តជាប់ជានិច្ច ។ ដល់ពេលស្ងប់ខ្យល់ នាយសំពៅលានាងប្រេតត្រឡប់មកនគរវិញ នាងបានផ្ញើសម្បត្តិទិព្វ មានមាសប្រាក់ជាដើម មកបូជាព្រះសម្មទ្ធបរមគ្រូ កាលនោះព្រះអង្គគង់នៅវត្តជេតពន ។ នាយសំពៅ និងឧបាសកទទួលបញ្ញើ ក៏ចេញសំពៅមក លុះសំពៅមកដល់នគរហើយ ក៏យកគ្រឿងសក្ការៈដែលនាងប្រេតផ្ញើទៅបូជាព្រះមានព្រះភាគៗ ទ្រង់ទទួលហើយ ប្រជុំពុទ្ធបរិស័ទសំដែងធម្មទេសនាប្រារព្ធ រឿងប្រេតនោះជាហេតុ ទីបំផុតព្រះអង្គទ្រង់ត្រាស់ថា នាងវិមានប្រេតនោះនៅ៤ ខែទៀតអស់អាយុហើយ ត្រូវទៅកើតក្នុងនរក ដោយអំណាចបិតស្រាលក់ ប៉ុន្តែដោយអំណាចសទ្ធាដែលនាងជឿចំពោះគុណព្រះរតនត្រ័យ ហើយបានបូជាចំពោះតថាគត ដល់គម្រប់៤ខែនាងអស់អាយុទៅ បានទៅកើតជាទេពធីតា នៅស្ថានត្រៃត្រឹងសួគ៌ សោយសម្បត្តិទិព្វយ៉ាងធំ ។

## ៩. រឿងស្រីពេស្យាកើតជាប្រេត[9]

(ការមើលងាយអ្នកដទៃជាពូជនៃពៀរវេរាក្នុងលោក)

ក្នុងកាលកន្លងទៅហើយ មានស្ត្រីពេស្យាផ្កាមាសម្នាក់ ឈ្មោះសិរិនី នៅក្នុងហត្ថិនីជនបទនាដែនកុរុ ជាស្ត្រីគ្មានសីលធម៌ប្រចាំខ្លួន ។

ថ្ងៃមួយជាថ្ងៃឧបោសថ ពួកភិក្ខុសង្ឃប្រជុំគ្នាធ្វើ ឧបោសថកម្ម ឧបាសក ឧបាសិកាទាំងឡាយមានសេចក្ដីជ្រះថ្លា ក៏នាំគ្នាយកភេសជ្ជៈផ្សេងៗ មានស្ករ ទឹកឃ្មុំ ទឹកអំពៅជាដើម រៀបចាត់ចែកក្នុងសាលាភត្ត បម្រុងចាំប្រគេនព្រះសង្ឃដែលចេញពីរោងឧបោសថមក ។ ពេលនោះពួកឧបាសក ឧបាសិកាទាំងឡាយជូនជាឃើញនាងសិរិនីស្រីផ្កាមាស ដើរទៅក្បែរទីនោះ ក៏ហៅឲ្យចូលទៅ

[9] ប្រជុំនិទានជាតក ភាគ៣ទំព័រ ៣៤៧

មាតាក៏ធ្វើទានរក្សាសីល ៥រាបដល់អស់អាយុ បានទៅកើតក្នុងសុគតិភព សួគ៌ហោង ។

អនុមោទនា យកចំណែកបុណ្យ ស្រីផ្កាមាសនោះ មានចិត្តក្រោធខឹង ឆ្លើយតបទៅវិញថា យើងមិនចង់បានទេ ឡានបុណ្យអ្វីកើតអំពីពួកសមណ៍ត្រងោលអ្នកតិះដៀលមាតុគ្រាមនេះទេ ពួកអ្នករាល់គ្នាសុទ្ធតែចាញ់បោកសមណ៍ត្រងោលទាំងនេះនិយាយហើយ ក៏ដើរហួសទៅ ។ សម័យខាងក្រោយមកនាងធ្វើមរណកាល ទៅកើតជាប្រេតញីនៅលើកំពែង ដែលគេជីកគូព័ទ្ធជុំវិញនគរមានរូបកាយអាក្រក់ ជុំក្លិនស្អុយចេញពីមាត់ ដូចសពស្អុយរលួយ មិនដែលបានបាយទឹក បរិភោគឡើយ ។ ថ្ងៃមួយមានឈ្មួញម្នាក់បររទេះទៅលក់ដូរវេវ៉ាន់ដល់ពេលយប់ ក៏ដាក់រទេះដេកក្បែរកំពែងនគរនោះ ។ ប្រេតញីឃើញបុរសនោះស្គាល់ជាអ្នកមកពីស្រុកកំណើតខ្លួន ក៏ទៅបង្ហាញខ្លួនឲ្យឃើញ ។

ឈ្មួញបានឃើញហើយក៏កិតភ័យ ព្រោះរូបនោះអាក្រក់គួរឲ្យខ្លាច ទើបសួរប្រញាប់ប្រញាល់ថានាងជាអ្វី ? យើងមិនដែលឃើញមនុស្សបែបនេះសោះ នាងប្រេតប្រាប់តាមដំណើរបុព្វកម្មរបស់នាង ហើយផ្តាំនឹងបុរសឈ្មួញនោះទៅមាតារបស់នាងថានាងសិរិនីជាកូនដែលស្លាប់នោះ មកកើតជាប្រេតនៅកំពែងនគរ មានសេចក្តីលំបាកស្រេកឃ្លានណាស់ សុំឲ្យមាតាយកប្រាក់៤សែននៅកប់ក្រោមគ្រែដែលនាងដេក ហើយបែងចែកប្រាក់នោះជាពីរចំណែក មួយចំណែកឲ្យមាតាទុកចិញ្ចឹមជីវិត មួយចំណែកទៀតយកទៅធ្វើបុណ្យទានឧទ្ទិសផលឲ្យខ្ញុំ ត្បិតប្រាក់នោះខ្ញុំសន្សំទុកមកយូរហើយ ។

ឈ្មួញត្រឡប់ទៅស្រុកវិញ ប្រាប់ដល់មាតារបស់ប្រេតនោះតាមបណ្តាំ មាតាក៏ចាត់ចែងគាស់យកប្រាក់ ធ្វើបុណ្យឧទ្ទិសផលឲ្យប្រេតនោះៗ ក៏បានរួចកម្មពៀរ ក្លាយខ្លួនជារុក្ខទេវធីតា សោយសម្បត្តិទិព្វ មានរូបកាយល្អប្រិមប្រិយ ។ យប់មួយទៅបង្ហាញខ្លួនឲ្យមាតាឃើញ ហើយរៀបរាប់សេចក្តីទុក្ខរបស់ខ្លួនកាលកើតជាប្រេតជម្រាបមាតា ទើបរំលឹកអង្វរមាតាឲ្យធ្វើទានរក្សាសីល កុំឲ្យធ្វេសប្រហែស ហើយលាមាតាទៅលំនៅខ្លួនវិញទៅ ។

## ១០. រឿងប្រេតប្ដីប្រពន្ធ[10]

(ទោសនៃសេចក្ដីកំណាញ់មិនមានសទ្ធា)

ក្នុងសម័យពុទ្ធកាល មានត្រកូលព្រាហ្មណ៍មួយ ក្នុងក្រុងពារាណសី ។ ត្រកូលនោះមានកូនបីនាក់ ប្រុស២ ស្រី១ ពៅបង្អស់ កូនទាំងបីនេះជាពួកម៉ាកមិត្រភ័ក្ដរាប់អានគ្នា ជាមួយឧបាសកម្នាក់ ជាឧបដ្ឋាកព្រះសង្ឃ៍ចភិក្ខុបានថ្វាយខ្លួនជាឧបាសក ឧបាសិកា ចំណាយទ្រព្យធ្វើបុណ្យទាន ក្នុងព្រះពុទ្ធសាសនា ។ ចំណែកខាងព្រាហ្មណ៍ប្ដីប្រពន្ធ ដែលជាមាតាបិតាកូនទាំងបីនោះជាបុគ្គលកំណាញ់គ្មាន សទ្ធាមិច្ឆាទិដ្ឋិ មិនជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ថ្ងៃមួយមានខ្យល់ព្យុះធំ បក់បោករលំផ្ទះព្រាហ្មណ៍ស្លាប់អស់មនុស្សក្នុងផ្ទះគឺព្រាហ្មណ៍ប្ដីប្រពន្ធក៏ស្លាប់ កូនបីនាក់ក៏ស្លាប់ ។ ព្រាហ្មណ៍ប្ដីប្រពន្ធស្លាប់ទៅកើតជាប្រេតទាំងពីរនាក់ ឯកូនប្រុសពីរនាក់ស្លាប់ទៅកើតជាភូមទេវតា កូនស្រីកើតជាភូមទេវធីតា បរិបូណ៌ដោយទិព្វសម្បត្តិនៅអាស្រ័យក្នុងព្រៃធំក្បែរក្រុងរាជគ្រឹះ ។

ប្រេតប្ដីប្រពន្ធ មានរូបកាយអាក្រក់គួរឲ្យខ្លាច កម្ពស់ប៉ុន្នោតលៃ ខ្លួនប្រឡាក់សុទ្ធតែឈាម និងខ្ទុះ ដៃកាន់ដំបងដែកប៉ុនដើមត្នោត សំពងក្បាលគ្នាទៅវិញទៅមក បែកជាំដំពេញខ្លួន ហើយខាំហែកសាច់គ្នាស៊ីរាល់ពេលវេលា ព្រោះស្រេកឃ្លានខ្លាំងណាស់ ។ ប្រេតទាំងពីរនេះចេះតែដើរតាមភូមទេវតាជាកូនទាំងបី ប៉ុន្តែមិនអាចទទួលយកអំណោយពីកូនបានឡើយ ព្រោះកាលជាតិមុនកូនបបួលដឹកនាំឲ្យធ្វើទានសីលមិនព្រមស្ដាប់តាមសោះ ។

ចំណែកប្រេតប្ដីប្រពន្ធមានក្មួយបួសជាសាមណេរ ក្នុងសំណាក់សង្ឃ៍ច

[10] ប្រជុំនិទានជាតក ភាគ៣ទំព័រ ៣៦២

ភិក្ខុជាឧបជ្ឈាយ៍ បានដឹងថាព្រាហ្មណ៍ជាឪពុកមា ម្ដាយមីងព្រមទាំងបងប្អូន បីនាក់រលំផ្ទះស្លាប់អស់ ហើយក៏ចូលទៅសុំលាឧបជ្ឈាយ៍សឹកទៅផ្ទះវិញ ។ ឧបជ្ឈាយ៍ឃាត់ឲ្យបង្អង់សិន ទើបលោកនាំសាមណេរនោះទៅគង់ក្នុងព្រៃធំ ស្រាប់តែសាមណេរនោះបានឃើញ ទេវតាបីរូបហោះចុះឡើងសប្បាយរីករាយ ក្នុងដងព្រៃ ក៏សួរឧបជ្ឈាយ៍ៗ ឲ្យសួរចំពោះទេវតាខ្លួនឯង ។ សាមណេរក៏សួរទេវតាដែលហោះមុនគេថា អ្នកជាអ្វីបានធ្វើកម្មអ្វីខ្លះពីជាតិមុន? សួរដូច្នេះគ្រប់ទេវតាទាំងបីនោះៗគ្រាន់តែប្រាប់ថាចាំសួរ ប្រេតពីរនាក់នៅខាងក្រោយ ។ មួយស្របក់ស្រាប់តែប្រេតមកដល់សាមណេរឃើញនឹកអស្ចារ្យក្នុងចិត្តពន់ពេក ទើបសួរប្រេតថា អ្នកបានធ្វើកម្មដូចម្ដេចខ្លះ កាលពីជាតិមុន? អ្នកស្គាល់ទេវតាបីរូបដែលហោះមុនអ្នកឬទេ? កាលពីដើមទេវតានោះ ធ្វើកម្មអ្វីខ្លះ? អាត្មាចង់ដឹងណាស់ ព្រោះមិនដែលឃើញ ។ ប្រេតនិយាយប្រាប់សាមណេរនោះថា ខ្ញុំព្រះករុណាកាលពីជាតិមុននៅក្រុងពារាណសី ជាមនុស្សកំណាញ់គ្មានសទ្ធាជឿក្នុងព្រះពុទ្ធសាសនា ឯទេវតាបីរូបនោះជាកូនបង្កើតរបស់ខ្ញុំព្រះករុណា កាលពីជាតិមុនបានធ្វើបុណ្យទានក្នុងសំណាក់ព្រះសង្ឃិចភិក្ខុ ដល់ពេលមានខ្យល់ព្យុះធំរលំផ្ទះស្លាប់ បានមកកើតជាទេវតានេះឯង ឯខ្ញុំព្រះករុណាជាមាតាបិតាស្លាប់ក្នុងពេលរលំផ្ទះនោះដែរ បានមកកើតជាប្រេតនេះ ។ ចំណែកលោកម្ចាស់ក៏មិនមែនអ្នកដទៃ គឺជាក្មួយបង្កើតរបស់ខ្ញុំព្រះករុណា ។

គ្រាន់តែថាដូច្នេះហើយ ប្រេត និងទេវតាក៏បាត់រូបលែងឃើញតាំងពីពេលនោះមក ។ សង្ខេបប៉ុណ្ណោះ ឯសាមណេរក៏និមន្តទៅវត្តជាមួយឧបជ្ឈាយ៍នាំរឿងប្រេតទៅក្រាបទូលដល់ ព្រះសម្ពុទ្ធទ្រង់ប្រារព្ធយករឿងប្រេតជាហេតុ ហើយសម្ដែងធម្មទេសនាប្រកាសអរិយសច្ច៤ប្រការ មហាជនបានសម្រេចមគ្គផលតាមនិស្ស័យរៀងៗខ្លួន ឯសាមណេរដែលទើបបានឧបសម្បទាថ្មីនោះក៏ខំចម្រើនសមណធម៌ មិនយូរប៉ុន្មានបានសម្រេចមគ្គផលជាព្រះអរហន្តមួយអង្គក្នុងលោក ។

## ១១. រឿងមិគលុទ្ទកប្រេត[11]

(ទោសសម្លាប់សត្វ និងគុណរបស់មិត្ត)

ក្នុងកាលកន្លងទៅហើយ ក្នុងក្រុងរាជគ្រឹះ មានព្រានម្រឹគម្នាក់ជាមិត្រនឹងធម្មឧបាសក ។ ព្រាននោះសម្លាប់ម្រឹគ ទាំងយប់ទាំងថ្ងៃឥតមានបង្អង់ពេលវេលាណាមួយឡើយ ។ ឧបាសកជាមិត្រ ចេះតែនិយាយលួងលោមអង្វរឲ្យឈប់សម្លាប់ ព្រានមិនព្រមតាម ។ ឧបាសកចេះតែឧស្សាហ៍និយាយមិនឈប់មិនធុញទ្រាន់ដល់យូរៗ ទៅព្រាននោះក៏និយាយប្រាប់ឧបាសកថា ម្នាលសម្លាញ់ខ្ញុំមានសេចក្តីរាប់អាន សម្លាញ់ក្រៃពេក ខ្ញុំឈប់សម្លាប់សត្វក្នុងវេលាយប់ជូនអ្នកចុះ ឧបាសកឮហើយ ទទួលថាសាធុ!ៗ ខ្ញុំត្រេកអរណាស់ ក្នុងវេលាយប់ដែលអ្នកឈប់នោះ អ្នកត្រូវតាំងចិត្តរឭកចំពោះគុណព្រះរតនត្រ័យ កុំរឭកដល់ការនេសាទរបស់អ្នក ។ ព្រានធ្វើតាមទាំងអស់តែដល់ពេលយប់ទៅដកអន្ទាក់ដកលប់ជាដើមទុកក្នុងទីមួយហើយ តម្កល់ចិត្តក្នុងគុណព្រះរតនត្រ័យ ដល់វេលាថ្ងៃទើបទៅនេសាទតាមធម្មតា ។

សម័យក្រោយមក ព្រាននោះស្លាប់ទៅ កើតជាវេមានិកប្រេត នៅក្បែរភ្នំគិជ្ឈកូដ ពេលថ្ងៃរងទុក្ខវេទនា មានឆ្កែទាំងហ្វូងដេញខាំ ស៊ីអស់សាច់ នៅសល់តែឆ្អឹងដល់វេលាយប់ក្លាយខ្លួនជាទេវបុត្រ សោយសម្បត្តិទិព្វនៅក្នុងវិមានមាសមានអ្នកបម្រើរាប់រយនាក់ ។ ផ្លាស់ប្តូរសោយផលសុខទុក្ខៗ តែយ៉ាងនេះជាដរាបរាល់ពេលវេលា ។ ជួនជាថ្ងៃមួយនោះ ព្រះនារទត្ថេរ លោកនិមន្តទៅក្បែរភ្នំនោះ បានឃើញហើយសួរដំណឹងសព្វគ្រប់ ទើបនាំដំណឹងនោះទៅកាន់សំណាក់ព្រះសម្ពុទ្ធ ក្រាបទូលតាមដំណើរ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ ប្រារព្ធរឿងប្រេតនោះជាហេតុ ហើយសម្តែងធម៌ទេសនា ដើម្បីជាប្រយោជន៍មគ្គផលសុខចម្រើនដល់ពុទ្ធបរិស័ទទាំងឡាយ ។

---

[11] ប្រជុំនិទានជាតក ភាគ៣ទំព័រ ៣៧៩

## ១២. រឿងប្រេតស៊ីសាច់ឯង[12]

(ទោសទុច្ចរិតផ្សេងៗ មានស៊ីសំណូកជាដើម)

កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅវត្តវេឡុវ័ន នាក្រុងរាជគ្រឹះ ។ កាលនោះ ព្រះបាទពិម្ពិសារ ទ្រង់ជាធម្មិកមហារាជ បាននាំអ្នករាជការ និងបណ្តារាស្ត្រ សមាទានរក្សាឧបោសថសីល ១ខែ ៦ដងជានិច្ចរាល់ឆ្នាំ ពួកអ្នករាជការទាំងអស់ គ្រប់ក្រសួងរាប់តាំងពីសេនាបតី រហូតដល់បុគ្គលិកតូចតាច សុទ្ធតែរក្សាសីលទាំងអស់ ឯបណ្តារាស្ត្រក៏នាំគ្នារក្សាសីលស្ទើរតែអស់ប្រទេស ។ ចំឡែកស្នាក្តីម្នាក់(អាវុកា) ជាមនុស្សអន្ធពាលប្រព្រឹត្តទុច្ចរិត និយាយកុហកបំភាន់ត្រូវជាខុសៗជាត្រូវ គិតតែប្រយោជន៍ផ្ទាល់ខ្លួនស៊ីសំណូកសព្វយ៉ាង រាល់វេលាថ្ងៃសីល គាត់ទៅអង្គុយសុំសីលជាមួយគេ ដើម្បីឲ្យព្រះរាជាទតឃើញថាគាត់ជាឧបាសកចំណាប់មួយដែរ ។

ថ្ងៃមួយ គាត់និយាយប្រាប់ឧបាសកម្នាក់ ដែលស្និទ្ធស្នាលនឹងគាត់ថា ខ្ញុំគ្រាន់តែទៅសុំសីលកុំឲ្យតែព្រះរាជាទ្រង់សំគាល់ថា ជាមនុស្សគ្មានសីលប៉ុណ្ណោះ ខ្ញុំមិនកាន់សិក្ខាបទអ្វីទេ ។ ឧបាសកនិយាយរំលឹកថា កុំធ្វើដូច្នោះ បើអ្នកមិនរក្សាអស់១យប់ ១ថ្ងៃដូចគេឯង ក៏រក្សាតែមួយកំណាត់ថ្ងៃពាក់កណ្តាលឧបោសថ ក៏បានបុណ្យដែរ ។ បុរសស្នាក្តីនោះ ក៏បានរក្សា១យប់ពាក់កណ្តាលឧបោសថ ជួនជាខ្យល់ចាប់ស្លាប់យប់នោះទៅ បានទៅកើតជាវិមានប្រេតនៅក្បែរភ្នំគិជ្ឈ-កូដ ពេលថ្ងៃសោយទិព្វសម្បត្តិ វេលាយប់កើតជាប្រេត មានក្រចកវែងៗធំៗដូចកាំបិតចាប់ហែកសាច់ខ្លួនឯងស៊ីវាអស់នៅសល់តែឆ្អឹង ពេលថ្ងៃសោយទិព្វសម្បត្តិវិញផ្លាស់ប្តូរយ៉ាងនេះរាល់ថ្ងៃ ។

សម័យមួយព្រះនារទត្ថេរ និមន្តទៅភ្នំគិជ្ឈកូដបានឃើញប្រេតនោះ ក៏សួរបុព្វកម្មសព្វគ្រប់បានដឹងហើយ និមន្តនាំដំណឹងនោះទៅក្រាបទូលព្រះសម្ពុទ្ធបរមគ្រូ

---

[12] ប្រជុំនិទានជាតក ភាគ៣ទំព័រ ៣៨៧

ព្រះអង្គទ្រង់ប្រារព្ធរឿងនោះជាហេតុ ហើយសម្តែងព្រះធម៌ទេសនាទូន្មានពុទ្ធបរិស័ទឲ្យលះទុច្ចរិត ប្រព្រឹត្តសុចរិត ។ ទីបំផុតនៃធម្មទេសនា ព្រះអង្គទ្រង់ប្រទានអរិយសច្ច៤ប្រការ ពុទ្ធបរិស័ទទាំងឡាយ ក៏បានសម្រេចមគ្គផលតាមនិស្ស័យរៀងៗខ្លួន ។

## ១៣. រឿងឆ្កែខាំប្រេត[13]

(ទោសក្បត់ស្វាមី និងមុសាវាទស្បថបំពាន)

រឿងនេះក្នុងប្រជុំនិទានជាតក ភាគបីទំព័រ៤៩៨មានសម្តែងពិស្តារ តែក្នុងទីនេះសូមសង្ខេបយកតែខ្លឹមសារគោលៗមកសម្តែងតែប៉ុណ្ណោះ ។

កាលក្នុងសាសនាព្រះពុទ្ធកស្សប មានគហបតីម្នាក់ជាឧបាសកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានបបួលឧបាសក៥០០នាក់ សុទ្ធតែបានសម្រេច សោតាបត្តិផល នាំគ្នាធ្វើទានផ្សេងៗ ធ្វើវត្តធ្វើស្ពាន ផ្លូវថ្នល់ ធ្វើទីចង្រ្កម ធ្វើព្រះវិហារថ្វាយព្រះសង្ឃមានព្រះពុទ្ធជាប្រធាន បាននាំភរិយារបស់ខ្លួនគ្រប់គ្នា ដើរធ្វើបុណ្យទាន ពីវត្តមួយទៅវត្តមួយ មានបីតិរីករាយសើចសប្បាយរាល់ថ្ងៃ ។ មានថ្ងៃមួយនោះ ភរិយាគហបតីឧបាសក នាំបរិវារ៥០០ទៅវត្ត ទៅដល់សាលាសំណាក់មួយ នាំគ្នាឈប់សម្រាក ជួនជាមានអ្នកលេងរបាំកំលោះពីរនាក់ នៅលើសាលានោះបានឃើញពួកស្ត្រីមានរូបល្អឆើតឆាយក៏និយាយ គៀរគនាយអាយ ឯពួកស្ត្រីទាំងនោះមិនស្តីរកមួយមាត់សោះ ។ អ្នកលេងរបាំ បានទៅនិយាយនឹងបុរសម្នាក់ឲ្យជួយនិយាយ បើបានឲ្យរង្វាន់១ពាន់កហាបណៈ បុរសនោះទៅនិយាយបានលើភរិយា គហបតីឧបាសក ។ ថ្ងៃក្រោយមកភរិយានោះ បានប្រព្រឹត្តអសទ្ធម្មក្បត់ស្វាមីខ្លួន ហើយហាមស្ត្រីបរិវារ៥០០នោះមិនឲ្យនិយាយឲ្យស្វាមីដឹង ។ អំពើអាក្រក់លាក់មិនកំបាំងដូចស្លោកបូរាណថា ផោមក្នុងទឹកគង់ធុំស្អុយ ថ្ងៃមួយគហបតីឧបាសកបាន

[13] ប្រជុំនិទានជាតក ភាគ៣ទំព័រ ៤៩៨

ដឹងថា ភរិយាក្បត់ចិត្តខ្លួន និងអ្នករបាំក៏ហៅសួរស្ងាត់កំបាំង នាងកុហកថាមិនបានក្បត់ដូច្នោះទេ កំពុងតែនិយាយជួនជាមានផ្លែខ្មៅកំបុតត្រចៀកមួយរត់កាត់មុខ នាងក៏ស្បថថាបើខ្ញុំក្បត់មែន សូមឲ្យផ្លែខ្មៅកំបុតត្រចៀកនេះខាំស៊ីសាច់ឈាមខ្ញុំរាល់ៗថ្ងៃ ។ គហបតីឧបាសក ក៏មិនទាន់ជឿស៊ប់ទើបហៅស្ត្រីបរិវារទាំង៥០០ មកសួរម្នាក់ម្តងៗស្ត្រីទាំងនោះឆ្លើយតែពាក្យមួយដូចគ្នា ថាខ្ញុំមិនដឹង មិនដែលឃើញបុរសណាទៅជិត ឬនិយាយអ្វីជាមួយម្ចាស់ស្ត្រីឡើយ បើបែរជាឃើញហើយថាមិនដឹង ខ្ញុំស្បថជូនកើតជាតិណាៗ ឲ្យកើតជាបរិវារម្ចាស់ស្ត្រីរាល់ៗជាតិ ។ គហបតីឧបាសក ក៏ជឿស៊ប់ថា ភរិយាខ្លួនបរិសុទ្ធមែន ។

នាងភរិយានោះ ត្រូវទោសក្បត់ឲ្យផលក៏ចេះតែក្តៅញ័រក្នុងខ្លួនស្គមរីងយូរៗទៅ ក៏ស្លាប់ទៅកើតជាប្រេតញីនៅក្នុងចន្លោះភ្នំនាព្រៃហិមពាន្ត មានវិមានប្រាសាទសួនច្បារ និងស្រះធំមួយឈ្មោះ កណ្ណមុណ្ឌៈ ជាទីមនោរម្យក្រៃលែង ដោយផលបុណ្យដែលបានធ្វើពីជាតិមុន ។ ចំណែកស្ត្រីជាបរិវារទាំង៥រយដល់ស្លាប់ក៏កើតជាបរិវារនាងទាំងអស់ព្រោះត្រូវសម្បថ ។ ឯនាងប្រេតនោះវេលាយប់ទទួលទោសដែលស្បថ បណ្តាលឲ្យចុះពីប្រាសាទទៅក្នុងស្រះកណ្ណមុណ្ឌៈបាបកម្ម បណ្តាលឲ្យផ្លែខ្មៅកំបុតត្រចៀកមួយ ធំប៉ុនដំរីកើតឡើងស្ទុះទៅខាំស៊ីនាងជាកំណាត់តូចធំ ហើយកើតឡើងវិញភ្លាមខាំស៊ីទៀតដរាបដល់ភ្លឺទើបផ្លែទៅវិញ ពេលថ្ងៃសោយសម្បត្តិទិព្វ ផ្លាស់ប្តូរតែយ៉ាងនេះរាល់ពេលវេលា ។

ថ្ងៃមួយនាងនាំពួកស្ត្រី៥០០ទៅលេងសួនច្បារ បេះផ្លែស្វាយទិព្វបរិភោគ ហើយបណ្តែតលេងតាមស្ទឹងដែលហូរទៅជាប់សំណាក់ មុខព្រះរាជវាំងព្រះបាទព្រហ្មទត្តពួករាជសេវកាមាត្យរើសស្វាយនោះមកថ្វាយស្តេចសោយ ក៏មានព្រះកាយពលល្អស្រស់ដូចព្រះជន្ម១៦ឆ្នាំ ដល់អស់បានចាត់ព្រានម្រឹគម្នាក់ឲ្យស្វែងរកមកថ្វាយ បានដឹងថានៅឯព្រៃហិមពាន្តមាន ក៏ឲ្យព្រានម្រឹគជូន

ដំណើរព្រះរាជាទៅដល់ ហើយក៏ឲ្យបុរសនោះមកវិញ ។ ព្រះរាជាបានយាងទៅក្នុងសួនច្បារ ពួកស្រ្តីបរិវារ៥០០ ឃើញហើយរត់មកថ្វាយបង្គំនាំទៅប្រាសាទ នាងប្រេតសួរដឹងថាជាព្រះចៅក្រុងពារាណសី ក៏ថ្វាយខ្លួនជាបាទបរិចារិកានាំព្រះអង្គទៅស្រង់ទឹកស្រះ ហើយថ្វាយសំពត់ទិព្វ ព្រះស្ងោយទិព្វ នាំស្រ្តី៥០០ ច្រៀងរាំថ្វាយ នាំក្រសាលក្នុងសួនច្បារ សោយផ្លែស្វាយហើយស្រេច មានព្រះកាយពលស្រស់ដូចទេវបុត្រសុទ្ធវិស័យ នៅជាមួយនាងប្រេតអស់៤០ឆ្នាំ គិតត្រឹមព្រះរាជា យាងទៅឥតដឹងសោះ ព្រោះកម្មបិទបាំង ។ យប់មួយនាងសោយកម្មចុងក្រោយបង្អស់ ព្រះរាជាតើនមិនឃើញ តាមរកឃើញផ្លែខាំជាកំណាត់ៗ ក៏យកព្រះខ័នកាប់ផ្លែ ដាច់ជាពីរកំណាត់កើត ផ្លែពីរឡើងខាំទៀត កាប់ពីរកើតឡើង៤ កាប់៤កើតឡើង៨កាប់៨កើតឡើងផ្លែ១៦ ទើបនាងប្រេតស្រែកថាកុំធ្វើដូច្នេះ បើព្រះអង្គសង្គ្រោះខ្ញុំសូមខាកស្តោះទៅផែនដីយកព្រះបាទ-ឈ្លី ទើបផលកម្មខ្ញុំអស់ផ្លែលែងកើតទៀត ទ្រង់ធ្វើតាមក៏វិនាសកម្មពៀរក្នុងពេលនោះឯង[14] ។

ប្រេតទូលថាកម្មខ្ញុំព្រះអង្គអស់ត្រឹមនេះហើយ លែងសោយផលដូច្នេះទៀតហើយ ។ ព្រះរាជាសួរថាផលកម្មដូចម្តេចពីជាតិមុនបានជាដូច្នេះ នាងទូលតាមដំណើរជ្រាបសព្វគ្រប់ថាជាប្រេត ក៏មានព្រះទ័យអផ្សុកលានាងត្រឡប់ទៅនគរវិញ ទោះដឹងច្បាស់ថា ទ្រង់មិននៅជាមួយ ក៏យកសម្បត្តិទិព្វជាច្រើនបូជាព្រះរាជា ហើយហោះបីពរព្រះអង្គ ទៅដាក់ប្រាសាទ នាក្រុងពារាណសី ហើយថ្វាយបង្គំឱបព្រះបាទាយំសោកលាត្រឡប់ មកលំនៅខ្លួនវិញហោង ។

---

[14] នាងប្រេតនោះ ដល់ពេលអាធ្រាត្រ ចុះទៅឈរក្បែរឆ្នេរស្រះកណ្ណមុណ្ឌៈ ផ្លែខ្មៅកំបុតត្រចៀកកើតឡើងភ្លាម ខាំស៊ីដាច់ជាកំណាត់តូចធំ ស្លាប់កើតៗ ដរាបដល់ជិតភ្លឺផុតអំណាចកម្មនាងឡើងមុលទៅផ្ទុំក្បែរព្រះរាជាវិញ តែយ៉ាងនេះរាល់ថ្ងៃ ចំនួន៤០ឆ្នាំគត់គិតត្រឹមព្រះរាជា នៅជាមួយ ។

ចំណែកព្រះរាជា មានព្រះទ័យអាណិតក្រៃពេកទ្រង់ហូរទឹកនេត្រាខ្សឹបខ្សួលក្នុងព្រះរាជហឫទ័យ រួចហើយកើតធម្មសង្វេគយល់ច្បាស់នូវកម្មផលឲ្យទានរក្សាសីលដរាបទិវង្គតទៅកើតស្ថានសួគ៌ ទេវលោកទៅហោង ។

លុះមកដល់ក្នុងពុទ្ធកាល យើងនេះកាលព្រះអង្គសម្តែងធម្មចក្រហើយគង់នៅក្បែរក្រុងសាវត្ថី កាលនោះព្រះមហាមោគ្គល្លាន និមន្តទៅព្រៃហិមពាន្តឃើញប្រេតនោះ ព្រមទាំងបរិវារទាំង៥០០ដើរលេងត្រៀបត្រាក្បែរស្រះកុណ្ឌមុណ្ឌៈក៏ត្រាស់សួរប្រវត្តិបុព្វកម្មដឹងសព្វគ្រប់ហើយ និមន្តវិលត្រឡប់ទៅក្រាបទូលព្រះពុទ្ធតាមដំណើររឿង ។ ព្រះសាស្តាទ្រង់ប្រជុំពុទ្ធបរិស័ទទាំងគ្រហស្ថបព្វជិត ហើយត្រាស់ថានាងប្រេតនោះ តថាគតបានឃើញបានដឹងបុព្វកម្មសព្វគ្រប់តាំងពីត្រាស់ដឹងអនុត្តរធម៌ នៅលើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សម្ល៉េះ តែគ្មានអ្នកដទៃជាសាក្សីទើបតថាគតស្ងៀម ។

ហើយព្រះអង្គទ្រង់ប្រារព្ធយករឿងប្រេតនោះជាហេតុ ទីបំផុតប្រកាសអរិយសច្ចធម៌៤ប្រការ ពុទ្ធបរិស័ទទាំងឡាយស្តាប់ហើយមានសទ្ធាជ្រះថ្លាបានសម្រេចមគ្គផល តាមនិស្ស័យរៀងៗខ្លួន ។

## ១៤. រឿងតិក្ខជាញាតិ និងប្រេត[15]

(ទោសបាណាតិបាត និងទោសនៃសេចក្តីកំណាញ់)

កាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានព្រះរាជាមួយអង្គព្រះនាមកិត្តិវាសសោយរាជ្យក្នុងនគរនោះ មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមទុដ្ឋកុមារ ។ ព្រះរាជបុត្រអង្គនេះបានមើលងាយព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដោយប្រកាន់មានះឲ្យព្រះបច្ចេកពុទ្ធថ្វាយបង្គំខ្លួន ក៏លោតចុះពីខ្នងដំរីទៅកញ្ឆក់យកបាត្រពីព្រះបច្ចេកពុទ្ធ ដែលកំពុងនិមន្តបិណ្ឌបាត បោកបំបែកជាន់កម្ទេចចោល ធ្វើឲ្យលោកអត់ចង្ហាន់ ។ ព្រះបច្ចេកពុទ្ធ ក៏និមន្តទៅកាន់ញកភ្នំនន្ទមូលវិញ ។ រឿង

[15] ប្រជុំនិទានជាតក ភាគ៣ទំព័រ ៤៣៨ ឬ ទំព័រ១២៦សម្រាប់ភាគ៣ដាច់ពីគ្នា

នេះសង្ខេបតែប៉ណ្ណោះ ដល់ព្រះរាជកុមារនោះទិវង្គតទៅ ទៅកើតក្នុងអវិចីមហានរកអស់ ៨៤០០០ឆ្នាំ ដល់អស់ផលកម្ម មកកើតជាប្រេតអត់ឃ្លាន ។ ដល់ពុទ្ធកាលនេះ បានមកកើតក្នុងត្រកូលនេសាទម្នាក់ នៅក្នុងអាណាខេត្តក្រុងសាវត្ថី ឈ្មោះហិរិកកុមារ ជាបុគ្គលរលឹកជាតិបាន ។ កុមារនេះតាំងពីធំដឹងក្តីឡើងកាលណាឮកឃើញសេចក្តីទុក្ខ ដែលខ្លួនទៅកើតក្នុងនរកប្រេត ក៏កើតសេចក្តីខ្លាចបាបជាទីបំផុត ។ ក្នុងគ្រួសារហិរិកកុមារ មានមុខរបរតែមួយគឺនេសាទត្រី រាល់តែថ្ងៃមាតាបិតា និងបងៗ នាំកុមារទៅដាក់លប ដាក់លាយចងសន្ទូច បង់សំណាញ់ជាដើម ។ កុមារចេះតែហែកលបលាយ ចាប់ត្រីរស់ៗបោះចោលទៅក្នុងទឹក ហើយចេះតែនិយាយថាបាបៗ ទោះបីមាតាបិតាបងៗជេរស្តីវាយដូចម្តេចក៏នៅតែធ្វើដូច្នោះទៀត ។ បើទុកឲ្យនៅផ្ទះ លួចដុតលបលាយចោលអស់ ។ មាតាបិតាខឹងខ្លាំង ក៏បណ្តេញចេញពីផ្ទះឈប់ឲ្យនៅជាមួយ ។ កុមារក៏ចុះពីផ្ទះដើរតាមផ្លូវទៅ បងប្រុសមានសេចក្តីអាណិត យំសោកអង្វរមាតាបិតាឲ្យហៅមកវិញ តែមាតាបិតាមិនព្រម ។ លុះកុមារដើរឆ្ងាយផុតពីភូមិទៅ បានជួបនឹងព្រះអានន្ទ កំពុងនិមន្តបិណ្ឌបាត ក៏ចេះតែដើរតាមដរាបដល់វត្ត ។ លោកសួរដឹងថា មាតាបិតាលះបង់ចោលហើយ ក៏បំបួសជាសាមណេរតាមសេចក្តីសុំរបស់កុមារនោះ ។ ដល់បួសហើយទៅបិណ្ឌបាតមិនបានសោះដោយផលបាបកាលកើតជាទុដ្ឋកុមារ វាយបំបែកបាត្រព្រះបច្ចេកពុទ្ធនោះឯង ។ ថ្ងៃមួយព្រះអានន្ទនាំទៅថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបកម្មពៀរមួយឲ្យដោយប្រាប់ឲ្យដងទឹកប្រគេនភិក្ខុសង្ឃឆាន់ស្រង់រាល់ៗថ្ងៃ ពួកភិក្ខុមានសេចក្តីអាណិត ក៏ឲ្យបាយចំណីតាំងពីពេលនោះមក ដល់អាយុបាន២០ឆ្នាំ ព្រះអានន្ទឲ្យឧបសម្បទាជាភិក្ខុមិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ជាព្រះអរហន្តមួយអង្គក្នុងលោក ។

កាលជាខាងក្រោយមក លោកបាននាំភិក្ខុ១២រូបទៅធ្វើសមណធម៌លើកំពូលភ្នំសានុវាសី ។ ឯមាតាបិតា បងប្អូន គ្រួសារលោកដល់ស្លាប់ទៅកើតជា

ប្រេតអត់ឃ្លាននៅចន្លោះភ្នំនោះមានមាត់តូចប៉ុនក្តិតម្ជុល កើតដំបៅស្អុយរលួយពេញខ្លួន មានសេចក្តីស្រេកឃ្លានខ្លាំង ផឹកទឹកស៊ីបាយមិនកើត ដោយអំណាចទោសបាណាតិបាត និងសេចក្តីកំណាញ់មិនដែលធ្វើបុណ្យទាន ។ ពួកប្រេតទាំងនោះដឹងថា ហិរិកភិក្ខុនៅលើកំពូលភ្នំសានុវាសីនោះត្រូវជាកូន ជាប្អូន ជាបងរបស់ខ្លួនពីជាតិមុន ដល់វេលាលោកនិមន្តចុះទៅបិណ្ឌបាតក៏ទៅឈរបង្ហាញខ្លួនដល់លោក ប៉ុន្តែផលកម្មដែលបណ្តេញលោកមិនឲ្យនៅជាមួយ កាលលោកនៅជាកុមារនោះ បណ្តាលបិទបាំងលោកមិនឲ្យឃើញ ឬគិតនឹកដល់ឡើយ ។

ថ្ងៃមួយ ប្រេតជាបងប្រុស ដែលយំសោកសុំអង្វរមាតាបិតាកាលដែលបណ្តេញលោកត្រូវបានជួបនឹងលោក ហើយយំសោករៀបរាប់ប្រាប់ថា មាតាបិតាគ្រួសារទាំងអស់ស្លាប់ទៅកើតជាប្រេតអត់ឃ្លានវេទនាណាស់ មានមាត់តូចប៉ុនក្តិតម្ជុល ។ លោកឮដូចនោះហើយមានសេចក្តីសង្វេគ អាណិតអាសូរពន់ពេកទើបលោកធ្វើទានចំពោះសង្ឃ ឧទ្ទិសផលឲ្យដល់ប្រេតទាំងនោះ ផលនោះក៏បានតែប្រេតជាបងប្រុសមួយប៉ុណ្ណោះ ដល់ពេលខាងក្រោយមក ទើបបានដល់ប្រេតជាមាតាបិតា និងប្រេតជាញាតិដទៃទៀត ។ ប្រេតទាំងនោះក៏បានក្លាយខ្លួនជារុក្ខទេវតា ក្នុងពេលនោះហោង ដោយអំណាចទានដែលហិរិកភិក្ខុជាព្រះអរហន្តលោកឧទ្ទិសឲ្យ ។

ហិរិកភិក្ខុ និងភិក្ខុទាំង១២អង្គ នាំគ្នាទៅក្រាបទូលព្រះមានព្រះភាគអំពីរឿងប្រេតនោះ ព្រះអង្គទ្រង់ប្រជុំបរិស័ទ ហើយសំដែងធម៌ទេសនា ប្រារព្ធរឿងប្រេតនោះ ដល់ទីបំផុតទ្រង់ប្រកាសអរិយសច្ចធម៌ ៤ប្រការ មនុស្ស និងទេវតាទាំងឡាយដែលបានស្តាប់ ក៏បានសម្រេចមគ្គផលតាមនិស្ស័យរៀងខ្លួន ។

---

[16] *ប្រជុំនិទានជាតក ភាគ៣ទំព័រ ៥០៩*

## ១៥. រឿងប្រេតញីស៊ីខ្ទុះឈាម[16]

(ទោសប្រមាថមើលងាយ ទានរបស់អ្នកដទៃ)

សម័យពុទ្ធកាល មានភិក្ខុ១២អង្គ រៀនយកព្រះកម្មដ្ឋានអំពីសំណាក់ព្រះសាស្ដាហើយ នាំគ្នាចូលទៅក្នុងព្រៃរកទីស្ងាត់ ក៏បានទៅដល់ព្រៃរបោះមួយក្បែរក្រុងសាវត្ថី ។ កាលនោះមានជាងតម្បាញ១៨នាក់នៅក្នុងក្រុងសាវត្ថីនោះ បានដឹងថាមានភិក្ខុ១២អង្គទៅគង់នៅក្នុងព្រៃរបោះជិតលំនៅខ្លួន ក៏ចូលទៅថ្វាយបង្គំបវារណាបច្ច័យ៤ និមន្តមកទទួលភត្តឯគេហដ្ឋានរបស់ខ្លួន ។ ជាងតម្បាញជាធំទទួលយកភិក្ខុពីរអង្គ ក្រៅពីនោះជាងតម្បាញម្នាក់យកភិក្ខុ១អង្គទៅប្រគេនចង្ហាន់ឯផ្ទះរៀងៗខ្លួន ហើយនិមន្តឲ្យចាំវស្សានៅព្រៃនោះ ។

ចំណែកភរិយាជាងតម្បាញជាធំនោះ ជាស្ត្រីមិច្ឆាទិដ្ឋិមិនជ្រះថ្លានឹងភិក្ខុសង្ឃសោះ ជាងតម្បាញខឹង ក៏យកប្អូនស្រីនៃភរិយានោះ មកធ្វើជាភរិយា ប្រគល់ទ្រព្យសម្បត្តិឲ្យជាធំក្នុងផ្ទះ នាំគ្នាធ្វើទានមានប្រគេនចីវរ ជាដើមដល់ភិក្ខុសង្ឃ ។ លុះធ្វើទានហើយ ភរិយាមិច្ឆាទិដ្ឋិនោះ និយាយប្រមាថមើលងាយទានដែលស្វាមីបានធ្វើថា បាយទឹកដែលអ្នកឲ្យភិក្ខុសង្ឃឆាន់នឹងឲ្យផលបុណ្យដល់អ្នកជាលាមក ខ្ទុះឈាម ឯចីវរដែលអ្នកប្រគេនលោកនោះ ឲ្យផលជាភ្លើងឆេះស្រោបកាយអ្នកជាប្រាកដ ។

សង្ខេបសេ្លះសេចក្ដីប៉ុណ្ណេះ ដល់ភរិយាមិច្ឆាទិដ្ឋិនោះស្លាប់ទៅកើតជាប្រេតញីនៅក្បែរព្រៃធំមួយ ឯជាងតម្បាញជាប្ដីរបស់នាងមិច្ឆាទិដ្ឋិនោះស្លាប់ទៅកើតជារុក្ខទេវតាមានស័ក្តិធំនៅអាស្រ័យលើដើមឈើក្នុងព្រៃធំនោះឯង ។

គួរអស្ចារ្យណាស់ប្រេតញីនោះ តាំងពីកើតឡើងពុំដែលបាន ចំណីអាហារស៊ីបានផឹកទឹក និងសំពត់ស្លៀកម្ដងសោះ ទទួលទុក្ខវេទនារកប្រៀបគ្មានចេះតែដើររុកព្រៃស្រែកថ្ងូររកចំណីអាហារ ក៏បានទៅជួបនឹងរុក្ខទេវតាជា ស្វាមីពីជាតិមុននោះ ស្រែកសុំបាយទឹកស៊ីផឹក រុក្ខទេវតា ក៏យកចំណីអាហារទិព្វមកឲ្យស៊ីប្រេតញីនោះគ្រាន់តែដាក់ដល់មាត់ក៏ក្លាយទៅជា លាមកខ្ទុះឈាម មើលទៅខ្លួនអាក្រាតទទេ មានសេចក្ដីអៀនខ្មាស ស្រែកសុំសំពត់ ទៀតរុក្ខទេវតាយក

សំពត់ទិព្វឲ្យ ប្រេតញីទទួលយកទៅគ្របដណ្ដប់ក៏ក្លាយទៅជាភ្លើង ឆេះសន្ធោសន្ធៅ ប្រកាច់ស្រែកទ្ទួញទាល់តែរលាស់សំពត់នោះចោលចេញ ។ ទទួលតែសេចក្ដីទុក្ខបែបនេះជាយូរខែយូរឆ្នាំ ។

ក្នុងថ្ងៃមួយមានភិក្ខុមួយអង្គ ចេញវស្សាហើយចង់ទៅថ្វាយបង្គំព្រះបរមគ្រូ ក៏សុំដោយសារជាមួយឈ្មួញរទេះទៅក្រុងសាវត្ថី ទៅដល់ក្បែរព្រៃធំនោះ ដាក់រទេះឈប់ សម្រាកភិក្ខុក៏ចូលទៅក្នុងព្រៃក្រាលសង្ឃដី សិងក្រោមម្លប់ឈើមួយ ពួកឈ្មួញរទេះ ដល់ពេលចេញដំណើរទៅទៀតរកភិក្ខុនោះ មិនឃើញក៏បររទេះហួសទៅ ។ ដល់ល្ងាច ភិក្ខុនោះភ្ញាក់ឡើង រកឈ្មួញរទេះមិនឃើញចេះតែដើរតាមគន្លងរទេះ ដល់យប់ងងឹត មើលគន្លងរទេះមិនឃើញក៏វង្វេងចូលទៅក្នុងព្រៃជ្រៅ ។ រុក្ខទេវតាឃើញភិក្ខុនោះក៏ចុះពីចុងឈើ បង្ហាញខ្លួនឲ្យភិក្ខុឃើញ នាំលោកទៅក្បែរគល់ឈើនិម្មិតជាប្រាសាទ និមន្តឲ្យស្រង់ទឹករៀបកន្លែងប្រគេន សិងដល់ព្រឹកប្រគេនចង្ហាន់ឆាន់ទៀត ។ លុះឆាន់ហើយស្រាប់តែប្រេតញីនោះទៅសុំអាហារចំណីទេវតានោះទៀត ។ ទេវតាឲ្យស៊ីដូចមុន ចំណីអាហារក៏ក្លាយទៅជាលាមកខ្ទុះឈាម ឲ្យសំពត់ស្លៀកក្លាយទៅជាភ្លើងភិក្ខុឃើញហើយ កើតសង្វេគអស្ចារ្យទើបសួរទេវតាៗប្រាប់បុព្វកម្មសព្វគ្រប់ ហើយសួរទៅភិក្ខុនោះវិញថាធ្វើដូចម្ដេចទើប ឲ្យប្រេតនេះបានស៊ីចំណីបានស្លៀកសំពត់កើត? ភិក្ខុនោះប្រាប់ថាឲ្យយកចំណីអាហារសំពត់ទៅប្រគេនដល់សង្ឃ ហើយឧទ្ទិសផលឲ្យទើបបាន ។

រុក្ខទេវតាក៏យកសំពត់ ចំណីអាហារនាំបង្ហាញផ្លូវ ភិក្ខុនោះទៅវត្តជេតពនទៅ ប្រគេនព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយឧទ្ទិសផលឲ្យប្រេតញីនោះៗ ក៏បានចំណី អាហារស៊ី ស្លៀកពាក់ រួចកម្មពៀរក្លាយខ្លួនទៅជារុក្ខទេវធីតាក្នុងវេលានោះហោង ។

---

[17] ប្រជុំនិទានជាតក ភាគ៤ទំព័រ ៥១៣ ហើយមាននៅភាគ១ដល់ភាគ៧ភ្ជាប់គ្នាក៏មាន ភាគ១ដល់ភាគ៧ដាច់ពីគ្នាក៏មានដែរ ។

## ១៦. រឿងប្រេត៤នាក់[17]

(អំពើទុច្ចរិតជាពូជនៃពៀរទាំងឡាយ)

កាលព្រះសម្ពុទ្ធគង់នៅវត្តជេតពននាក្រុងសាវត្ថី មានឈ្មួញម្នាក់ជួញស្រូវ បានយកសំដីស្រូវ (សង្កៀបស្រូវ) លាយនឹងស្រូវវាល់លក់ឲ្យអ្នកដទៃ ។ ឯកូនប្រុសរបស់គាត់មើលងាយមាតារបស់ខ្លួនយកខ្សែព្រ័ត្រដាក់លើក្បាលមាតា ឯកូនប្រសាស្រីលួចលាក់សាច់ងៀតស៊ីតែម្នាក់ឯងមិនឲ្យស្វាមី មាតាបិតាបរិភោគផង ។ ចំណែកភរិយារបស់ឈ្មួញនោះ ជាមនុស្សកំណាញ់ សំដីអាក្រក់ ឃើញពួកស្មូមទៅសុំអ្វីៗ ស្តីជេរលត្មះថាឲ្យស្មូមនោះទៅស៊ីមូត្រលាមក ។

ក្នុងពេលក្រោយមក ជនទាំង៤នាក់នោះស្លាប់បន្ទាប់ៗគ្នា តាមវ័យរបស់ខ្លួនទៅកើតជាប្រេត នៅចន្លោះភ្នំគិជ្ឈកូដ ប្រេតទាំង៤នេះរងទុក្ខវេទនាផ្សេងៗគ្នា គឺប្រេតឈ្មួញ កម្មបណ្តាលឲ្យមានសំដីស្រូវដែកឆេះក្រហមគរជាគំនរប្រេតនោះចេះតែកើបដាក់លើ ក្បាល ឆេះក្តៅស្រែកទ្រហោយំជានិច្ចឥតស្រាកស្រាន្ត ។ ប្រេតកូនប្រុសរបស់គាត់ ផលកម្មបណ្តាលឲ្យមាន ញញួរដែកឆេះក្រហមកាន់នៅដៃវាយសំពងក្បាលខ្លួនឯង បែកឈាមហូរ ស្រោចពេញខ្លួន ស្រែកថ្ងូរឥតស្រាកស្រាន្ត ។ ប្រេតកូនប្រសាស្រីរបស់គាត់មានក្រចកវែងៗខ្វាហែកសាច់ចំឡករបស់ខ្លួនមកស៊ី ស្រែកយំទូញឥតស្រាកស្រាន្ត ។ ឯប្រេតភរិយារបស់ ឈ្មួញនោះ ផលកម្មបណ្តាលឲ្យកើតរណ្តៅមូត្រ លាមក ស្អុយរលួយ ចុះទៅកើបស៊ីមួយថ្ងៃៗដរាបដល់យប់ៗ ដល់ថ្ងៃវិញមិនចេះឆ្អែត ចេះតែឃ្លានយ៉ាងខ្លាំងក្រៃលែងឥតឧបមា ។

ថ្ងៃមួយព្រះមហាមោគ្គល្លាន និមន្តទៅភ្នំគិជ្ឈកូដបានឃើញប្រេតទាំង៤កំពុងរងទុក្ខវេទនាដូច្នោះ ក៏សួរបុព្វកម្មរបស់ប្រេតនោះបានជ្រាបសព្វគ្រប់ ហើយនិមន្តមក កាន់វត្តជេតពន ក្រាបទូលរឿងប្រេតនោះចំពោះព្រះពុទ្ធៗទ្រង់ប្រជុំបរិស័ទ ហើយសំដែងធម៌ទេសនាប្រារព្ធយករឿងប្រេតនោះជាហេតុដល់ទីបំផុត

នៃព្រះធម៌ទេសនា ទ្រង់ប្រកាសអរិយសច្ច៤ប្រការ ពុទ្ធបរិស័ទទាំងមនុស្សនិងទេវតាបានសម្រេចមគ្គផលតាមនិស្ស័យរៀងៗខ្លួន ។

## ១៧. រឿងប្រេតមាត់ស្អុយ[18]

(មាត់ធុំក្លិនស្អុយ ព្រោះនិយាយញុះញង់)

ក្នុងសាសនានៃព្រះពុទ្ធកស្សប មានភិក្ខុ២អង្គនៅជាមួយគ្នាក្នុងអាវាសមួយមានសេចក្ដីរាប់អានស្រលាញ់គ្នាដូចបងប្អូន ចេញពីឧទរមាតាតែមួយលោកគង់នៅក្នុង អាវាសនោះជាសុខសប្បាយពុំដែលមានមោះមៃ និងគ្នាឡើយ ។ សម័យថ្ងៃមួយមាន ភិក្ខុអាគន្តុកៈមួយអង្គនិមន្តមកពីទីឆ្ងាយជាច់ស្រយាលបានមកដល់អារាមនោះចូលទៅ សុំពឹងពាក់សំណាក់នៅ ព្រោះយល់ថាទីស្រណុកសុខសប្បាយដោយអាហារបិណ្ឌបាតជាដើម ។

ព្រឹកព្រាងស្វាងអរុណោទ័យ ទើបព្រះថេរៈទាំងពីរនាំអាគន្តុកៈភិក្ខុទៅបិណ្ឌបាតក្នុងស្រុកនោះ មនុស្សទាំងឡាយឃើញព្រះថេរៈទាំងពីរអង្គមានចិត្តជ្រះថ្លាធ្វើការបូជាដោយទេយ្យវត្ថុមានបបរអាហារភោជនដ៏ត្រកាល ។ ឯភិក្ខុអាគន្តុកនោះគិត ពិចារណាថាស្រុកនេះជាទី សប្បាយងាយស្រួលបិណ្ឌបាតហើយមនុស្សទាំងឡាយ ក៏មានសទ្ធាជ្រះថ្លា ផ្ចិតផ្ចង់ភោជនាហារប្រគេនហើយអាវាសថែមទៀតក៏ស្រណុក សុខសប្បាយដោយទីកនោះថ្លាបើអាត្មាអញបាននៅទីនេះនឹងបានសេចក្ដីសុខសព្វកាល តែបើព្រះថេរៈទាំងពីរអង្គនេះនៅជាមួយអាត្មាអញពុំមានសេចក្ដីសុខសប្បាយសោះឡើយ បើដូច្នោះ អាត្មាអញគិតធ្វើឲ្យព្រះថេរៈនេះឈ្លោះវិវាទទាស់ទែងគ្នាព្រាត់ប្រាសចាកចេញពីទីនេះ ។

មានថ្ងៃមួយនោះ ព្រះថេរៈទាំងពីរអង្គសន្ទនាឲ្យឱវាទគ្នាទៅវិញទៅមក រួចហើយក៏ទៅកាន់លំនៅរៀងៗខ្លួន ឯភិក្ខុចៃចូវអង្គុយនៅបន្តិចក៏ទៅកាន់សំណាក់ព្រះមហាថេរៈ ថ្វាយបង្គំនមស្ការព្រះមហាថេរដណ្ដឹងសួរថា អាវុសោមកធ្វើអ្វីក្នុង

---

[18] ប្រជុំនិទានជាតក ភាគ៥ទំព័រ ៧០១

វេលានេះ? ភិក្ខុនោះទូលព្រះថេរដីកាថា មានការនិយាយបន្តិចទើប ព្រះមហាថេរ អនុញ្ញាតថា ចូរស្រដីមកចុះ បពិតព្រះមហាថេរដ៏ជាទីស្រឡាញ់ពេញចិត្តនៅចំពោះមុខដូចមិត្តសម្លាញ់កំបាំងវិញដូចជាសត្រូវ ។ ទើបមហាថេរលោកស្រដីដូចម្ដេចអ្នកប្រាប់ឲ្យដឹងផងអនុត្ថេរប្រាប់ខ្ញុំម្ចាស់ថា លោកម្ចាស់ឡេះឡោះកុហកចិញ្ចឹមជីវិតប្រព្រឹត្តខុសវិន័យធម៌ ។ ព្រះមហាថេរថា អាវុសោកុំស្រដីដូច្នោះអនុត្ថេរនេះមិនមែនស្គាល់តែក្នុងកាលឥឡូវនេះទេគឺ ចាប់ស្គាល់ស្រឡាញ់រាប់អានគ្នាតាំងអំពីយរាវាសម្ល៉េះ មួយទៀតលោកពុំជាអ្នកស្រដីដូច្នោះដែរ ។ ភិក្ខុពាលនោះទូលថា បពិត្រមហាថេរកុំស្មានថាអនុត្ថេរនោះជា មនុស្សល្អកេមន្ទិលគ្មាន ខ្ញុំព្រះករុណាថានេះនឹងប៉ុនប៉ងចងពៀរនឹងអនុត្ថេរក៏គ្មាន លោកម្ចាស់ចាំមើលបន្តិចទៅគង់នឹងជ្រាបឯង ។

ដោយព្រះទ័យដ៏ទោរទន់ស្រលាញ់រាប់អាន របស់ព្រះមហាថេរពុំអាចនឹងព្រាត់គ្នាបានឡើយ ទើបភិក្ខុពាលនោះទៅកាន់សំណាក់អនុត្ថេរញុះញង់ដូច្នោះទៀតព្រះថេរៈ ទាំងពីរអង្គធន់ទ្រាំពុំបានលុះព្រឹកឡើងពុំមានស្រដីនឹងគ្នាស្ងៀមដោយរៀងខ្លួនបាន បាត្រចីវរត្រាច់ចរបិណ្ឌបាតក្នុងស្រុកនោះ ហើយត្រឡប់មកអាវាសវិញចូលបន្ទប់បិទ ទ្វារឆាន់តែរៀងៗខ្លួន ពុំបានធ្វើសាមីចិកម្មនឹងគ្នាឡើយ ។ លុះព្រឹកព្រាងស្វាងព្រះសុរិយា ព្រះថេរៈទាំងពីរចេញទៅទីទៃពីគ្នា ភិក្ខុនោះញុះញង់បំបែកបំបាក់បានដូចប្រាថ្នាហើយ ក៏ចូលទៅបិណ្ឌបាតក្នុងស្រុកនោះ ។ អ្នកស្រុកឃើញភិក្ខុនោះ ក៏សួរថា ព្រះថេរៈទាំងពីរអង្គក៏ពុំឃើញមក? ភិក្ខុពាលនោះប្រាប់ថា លោកវិវាទទាស់ទែងគ្នាទាំងយប់អាធ្រាត អាត្មាបានឃាត់កុំឲ្យទាស់ទែងគ្នា ព្រោះការទាស់ទែងនេះរកប្រយោជន៍គ្មាន លោកពុំអាចស្ដាប់ពាក្យអាត្មាឃាត់នោះឡើយ ហើយរៀបខ្លួនដើរចេញទៅតែរៀងខ្លួន ។ ពួកមហាជនថា បើព្រះថេរៈនិមន្តទៅហើយ សូមលោកម្ចាស់អនុគ្រោះនិមន្តគង់ឲ្យសុខសប្បាយនៅទីនេះចុះ ។ ភិក្ខុនោះទទួលចង្ហាន់បិណ្ឌបាតស្រេចហើយ ក៏ត្រឡប់ទៅអាវាសវិញ បានពីរបីថ្ងៃទើបគិតថា ព្រះមហាថេរទាំងពីរព្រះអង្គជា

ចៅអាវាស មានសីល បរិបូណ៌ អាត្មាអញស្រដីកម្ចាយម្លោយឲ្យព្រាត់ប្រាស ចេញពីគ្នា អាត្មាអញធ្វើកម្មនេះ ជាទម្ងន់ពន់ប្រមាណ ព្រោះលោភចង់បាន អាវាសនេះ ។ ដោយផលកម្មអាក្រក់នោះ ក៏បណ្តាលចិត្តឲ្យក្តៅក្រហាយឆាន់អាហារពុំបាន កើតរោគក្តៅក្រហាយអន្ទះអន្ទែងធ្វើ កាលកិរិយាទៅកើតក្នុង អវិចីមហានរក ។

ចំណែកព្រះថេរៈទាំងពីរត្រាច់ទៅតាមលំដាប់ជនបទ បានមកជួបជុំគ្នា នៅក្នុងអាវាស មួយត្រេកអរសោទរជាសុខសប្បាយរាក់ទាក់រកគ្នា និយាយប្រាប់ តាមសេចក្តីពិតដែល ភិក្ខុញុះញង់នោះដល់គ្នាទៅវិញទៅមក ដឹងហេតុពុំពិតក៏ បបួលគ្នាទៅនៅអាវាសដើមវិញ ។ ពួកមហាជនបានឃើញព្រះថេរៈនិមន្តមក វិញ មានចិត្តត្រេកអរនមស្ការគោរពបូជា នូវចតុប្បច្ច័យដូចដើម ហើយលោកខំ ចម្រើនវិបស្សនាកម្មដ្ឋាន បានសម្រេចជាព្រះអរហត្តផល រំលត់ទុក្ខគ្រប់យ៉ាង ។ ឯភិក្ខុញុះញង់ នោះកើតក្នុងអវិចីមហានរកអស់១ពុទ្ធន្តរចន្លោះព្រះពុទ្ធមួយអង្គ លុះព្រះសមណគោតមឧប្បត្តិឡើងក្នុងលោកក៏បានមកកើតជាប្រេត នៅក្បែរ ជើងភ្នំគិជ្ឈកូដ មានមាត់ស្អុយ មានខ្លួនដូចមាស មានដង្កូវវារចេញពីមាត់កាត់ រឹមមាត់ជុំក្លិនស្អុយសាយភាយចេញទៅ ។

លំដាប់នោះព្រះអនុរុទ្ធត្ថេរចុះពីភ្នំគិជ្ឈកូដ បានឃើញប្រេតនោះ សួរថា ហៃព្រះ ស្តែងមានសម្បុរល្អ ភ្លឺច្រាលរន្ទាលឆ្អិនឆ្អៅដូចទេវតានៅឰដ៏កណ្តាល អាកាស រឹមាត់ជុំ ក្លិនស្អុយដូចសាកអសុភមានដង្កូវវារចេញចូលឰដ៏មាត់គួរឲ្យ ខ្ពើមរអើម តើព្រះស្តែងបានធ្វើបុព្វកម្មដូចម្តេចពីជាតិមុន? ។ ប្រេតនោះក្រាប ទូលព្រះពុទ្ធដីកាថា ខ្ញុំម្ចាស់ជាមនុស្សចិត្តបាបស្រដី អាក្រក់ញុះញង់គេឲ្យបែក បាក់គ្នាពីជាតិមុន បានមកកើតជាប្រេតមាត់ស្អុយ មានដង្កូវវារចេញពីមាត់

ព្រោះស្រដីចែចូវញុះញង់ព្រះសង្ឃពីអង្គឲ្យបែកបាក់គ្នា ហើយមានរស្មីផ្សាយចេញពីខ្លួនដូចមាស ព្រោះត្បិតខ្ញុំម្ចាស់បានបួសជាភិក្ខុចម្រើនវិបស្សនាកម្មដ្ឋាន លុះប្រេតប្រាប់នូវបុព្វកម្មរបស់ខ្លួនហើយ ទើបនិយាយផ្តាំផ្ញើនឹងព្រះអនុរុទ្ធ ថាបពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអង្គជាអ្នកប្រាជ្ញ សូមមេត្តាអាសូរករុណាសំដែងទូន្មាន ប្រៀនប្រដៅសត្វទាំងឡាយកុំធ្វើអំពើចែចូវញុះញង់មុសាវាទ ជាហេតុបណ្តាលឲ្យរង ទុក្ខវេទនាដូចខ្ញុំម្ចាស់ ជាឧទាហរណ៍ស្រាប់ ។ បើអ្នកឯណាបានបំពេញបុណ្យទាន សីលភាវនាហើយ មុខនិងបានជាទេវតាឯណានីមួយមានព្រះឥន្ទជាដើមបានសោយសុខសម្បត្តិនោះច្រើនមហិមា ។

ព្រះអនុរុទ្ធត្ថេរលុះបានស្តាប់ពាក្យប្រេតនោះហើយ ទើបនិមន្តទៅក្រុងរាជគ្រឹះដើម្បីយករឿងនោះទៅ ក្រាបទូលព្រះបរមសាស្តា ទ្រង់សម្តែងធម៌ទេសនា យករឿងប្រេតនោះទុកជាទិដ្ឋានុគតិដល់សព្វសត្វទាំងឡាយ ។

## ១៨. រឿងព្រានប្រេត[19]

(ស្លាប់ទៅកើតជាប្រេត ព្រោះទោសសម្លាប់សត្វ)

កាលព្រះបរមលោកនាថ ព្រះអង្គគង់នៅវត្តវេឡុវ័នមានព្រានម្នាក់សំណាក់នៅទិសាភាគនៃនគរពារាណសី ។ ព្រាននោះតែងត្រាច់ទៅព្រៃបរបាញ់សត្វម្រឹគបក្សី បានហើយឆ្អើរសាច់បរិភោគឯសាច់ដែលនៅសល់ពីនោះគាត់រែកយកមកលំនៅ ។ ចំណែកពួកក្មេងៗបានឃើញគាត់រែកសាច់មកដល់មាត់ព្រៃដូច្នោះហើយ ម្នីម្នាប្រញាប់រត់ទៅសុំសាច់នៃព្រាននោះ គាត់ក៏ហុចឲ្យ១ដុំៗម្នាក់ ។ មានកាលសម័យថ្ងៃមួយ ព្រានទៅព្រៃបរបាញ់សត្វពុំបានមួយឡើយ ទើបគាត់បេះផ្ការាជពិស ( ផ្កាត្របែកព្រៃ ) យកមកប្រដាប់អាត្មា ហើយបេះដាក់

[19] *ប្រជុំនិទានជាតក ភាគ៥ទំព័រ ៣២៩*

អង្រែករែកវិលមកវិញ អស់ពួកក្មេងៗរត់ប្រញាយទៅសុំសាច់ព្រាននោះគាត់ឲ្យផ្កាភជពិសមួយចង្កោមម្នាក់ៗ ។

លុះយូរបន្តិចព្រាននោះស្លាប់ ទៅកើតជាប្រេតមានរូបអាក្រក់គួរឲ្យខ្លាចពេកក្រៃ ប្រដាប់ដោយផ្កាភជពិសលើក្បាល ហើយចុះក្នុងទឹកស្ទឹងលុយប្រាសទឹកឡើងលើ ដោយគិតថាទៅរកញាតិការក្នុងស្រុកនោះ ។ លំដាប់នោះមានអាមាត្រម្នាក់ឈ្មោះកាឡី ព្រះបាទពិម្ពិសារទ្រង់ត្រាស់បញ្ជាឲ្យទៅបង្ក្រាបសត្រូវនៅឯជនបទ លុះបង្ក្រាបបានរាបទាបស្រេចហើយក៏ឲ្យពលសេះ រទេះថ្មើរជើងវិលត្រឡប់តាមផ្លូវគោកមកវិញ ។ ឯអាមាត្រនោះចុះមកតាមទន្លេ បានប្រទះប្រេតនោះកំពុងលុយទឹកមានរូបអាក្រក់ក្រៃទើបសួរថា នែព្រះស្តែងមានរូបអាក្រក់ប្រដាប់ដោយផ្កាភជពិសលើក្បាលលុយទឹកទៅឯណា? តើទីលំនៅស្ថិតនៅតំបន់ណា? ចូរព្រះស្តែងប្រាប់យើងឲ្យបានដឹង ។ ប្រេតស្តាប់សំនួរមហាមាត្យសួរថាដូច្នោះហើយឆ្លើយប្រាប់ថា ខ្ញុំទៅរកញាតិការនៅក្នុងស្រុកចូលិតគ្រាម នានគរពារាណសី ដើម្បីនឹងរកភោជនាហារ ។ មហាមាត្យស្តាប់ហើយមានចិត្តមេត្តាករុណា ទើបនិយាយថា បាយសត្វខៅតាកយើងមានតើធ្វើដូចម្តេចនឹងបានដល់អ្នក? ទើបប្រេតឆ្លើយថាបើលោកមេត្តាអាសូរខ្ញុំក្រែងមានអ្នកណាជាឧបាសករក្សាគុណព្រះរតនត្រ័យតាំងនៅក្នុង ព្រះត្រៃសរណគមន៍មាននៅក្នុងទូកលោកសូមលោកឲ្យទៅអ្នកនោះ ហើយឧទ្ទិសចំណែកបុណ្យចំពោះមកខ្ញុំៗនឹងបានសេចក្តីសុខ រួចចាកទុក្ខផងទាំងពួង ។

គ្រានោះមានជាងកាត់សក់ម្នាក់នៅក្នុងទូកនោះ ជាឧបាសកត្រេកអរក្នុងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទើបមហាមាត្យឲ្យឧបាសកនោះងូតទឹកស្លៀកដណ្តប់សំពត់លើងដូចសម្បុរមាសស្រេចហើយ ឲ្យបរិភោគអាហារភោជន រួចឧទ្ទិសចំណែកបុណ្យចំពោះទៅប្រេតថា ឥទំ ទានំ រីទាននេះចូរសម្រេចដល់ប្រេតហោង ។ ដោយការឧទ្ទិសកុសលនេះ ក៏បានសម្រេចដល់ប្រេតនោះឲ្យមានសំពត់ស្លៀកដណ្តប់ មានអាហារបរិភោគដ៏ត្រកាលឃើញជាក់ច្បាស់ទាន់

ហាន់ក្នុងពេលនោះ ។ កាលដែលមហាមាត្យឧទ្ទិសកុសលដល់ប្រេតឃើញ ច្បាស់ជាក់នឹងភ្នែកស្រេចហើយ ក៏ចុះទូកអុំទៅទាំងយប់ពុំឈប់និទ្រា លុះព្រឹក ព្រាងស្វាងព្រះសុរិយា ក៏ទៅដល់នគរពារាណសី ។ ព្រះភគវាទ្រង់ព្រះដំណើរ មកតាមអាកាសដើម្បីនឹងអនុគ្រោះដោះទុក្ខមហាជនទាំងឡាយ ទ្រង់ចុះពី អាកាសមកប្រតិស្ឋានទៀបឆ្នេរមហានទី ។ កាលនោះកាឡីអាមាត្យឡើងមក អំពីទូក ក៏ជួបព្រះសាស្ដាក្នុងទីនោះ មានចិត្តត្រេកអរម្នីម្នាចូលទៅក្រាបថ្វាយ បង្គំអារាធនានិមន្តទទួលចង្ហាន់ក្នុងវេលាព្រឹកនោះ ព្រះអង្គទ្រង់ទទួលនិមន្ត ដោយតុណ្ហីភាព តាមប្រវេណីនៃព្រះពុទ្ធពីបុរាណ ។ មហាមាត្យលុះដឹងថា ព្រះអង្គទទួលនិមន្តហើយក៏ប្រញាប់ប្រញាល់ទៅជម្រះទីឲ្យរាបស្មើ ធ្វើមណ្ឌល មុខ៤ ប្រដាប់គ្រឿងសក្ការបូជាមាលាផ្កាកម្រងគ្រឿងក្រអូបផ្សេងៗក្រាលអាសនៈ ថ្វាយព្រះអង្គគង់ ។ ព្រះអង្គទ្រង់គង់លើអាសនៈដ៏សមគួរហើយ ទើបមហាមាត្យ ក្រាបទូលអំពីហេតុដែលបានឃើញប្រេត ព្រមទាំងបានឧទ្ទិសចំណែកបុណ្យ ឲ្យដល់ប្រេតនោះផង ក៏បានរួចចាក់ទុក្ខទាំងពួង ។ ទើបព្រះអង្គទ្រង់មាន ព្រះចិន្តាថាពួកភិក្ខុសង្ឃចូរមកក្នុងទីនេះ ព្រះអង្គទ្រង់ព្រះចិន្តាដូច្នេះហើយពួក ភិក្ខុសង្ឃក៏មកគង់ចោមរោមព្រះអង្គជាបរិវារ ។ ឃើញដូច្នេះហើយមហាមាត្យរឹងរឹត តែមានសេចក្ដីត្រេកអរចូលទៅ អង្គាសភត្តថ្វាយព្រះអង្គ និងភិក្ខុសង្ឃស្រេច ហើយ ទើបព្រះអង្គទ្រង់អធិដ្ឋានថា មនុស្សផងទាំងឡាយដែលនៅទៀបនគរ នេះចូរមកប្រជុំគ្នាក្នុងទីនេះ ។ ពួកមហាជនក៏មកប្រជុំគ្នាស្រេចហើយព្រះអង្គ ទ្រង់សម្ដែងឫទ្ធិឲ្យមើលពួកប្រេតឃើញដោយចក្ខុរបស់ខ្លួន ។ ឯប្រេតខ្លះមាន កំណាត់សំពត់បន្តិចរុំខ្លួន ខ្លះគ្មានសំពត់ស្លៀកដណ្ដប់ រំសាយសក់គ្របខ្លួន ខ្លះអត់បាយ អត់ទឹក ស្គាំងស្គមមានតែស្បែកដណ្ដប់ឆ្អឹងរត់ទៅរត់មក ព្រះអង្គ ទ្រង់សម្ដែងឥទ្ធិឫទ្ធិឲ្យពួកប្រេតនោះ មូលមកប្រជុំគ្នាតែមួយពួក ហើយឲ្យសម្ដែង បុព្វកម្មរៀងៗខ្លួន ប្រេតខ្លះថាយើងជាមាតានៃក្មេងទាំងឡាយនេះ ជាអ្នកមាន ទ្រព្យសម្បត្តិច្រើនពុំបានធ្វើបុណ្យសុន្ទរទានដល់ស្មូមយាចក ពុំបានដាក់បាត្រ

ប្រគេនព្រះសង្ឃ ខ្លះថាយើងជាមនុស្សមច្ឆរិយកំណាញ់ស្វិតស្វាញជួជាតិសាមាន្យ ពុំមានចិត្តត្រេកអរក្នុងការកុសលនានា ។ ដោយហេតុបាបកម្មយ៉ាងនេះឯង ក៏បណ្តាលឲ្យរងទុក្ខវេទនា អត់បាយ អត់ទឹក មានខ្លួនអាក្រាតរកសំពត់ស្លៀកដណ្តប់ពុំបាន ។ ខ្លះថាយើងរវល់តែស្តាយ អាឡោះអាល័យទ្រព្យសម្បត្តិស្រែចម្ការច្បារដំណាំ ពុំហ៊ានធ្វើបុណ្យទានថែមទាំងខ្លួនក៏ពុំហ៊ានបរិភោគឲ្យបានស្កប់ស្កល់ លុះដល់ស្លាប់ទៅរបស់ទាំងនោះក៏ពុំអាចយកទៅជាមួយបានផងមក តែម្នាក់ឯងកណ្តែងកណ្តោចខ្លោចផ្សាកំព្រារងទុក្ខវេទនាក្រៃពេក លុះលះបង់កំណើតអំពីប្រេតនេះទៅ និងបានទៅកើតក្នុងត្រកូលថោកទាប មានត្រកូលចណ្ឌាលជាដើម ។

កាលដែលព្រះសាស្តាបរមគ្រូទ្រង់សំដែងពីទាន ដែលបុគ្គលបានធ្វើ ដើម្បីកាត់បង់សេចក្តីកំណាញ់ ត្រេកអរនឹងអំពើជាកុសលតម្កល់ទុកក្នុងជាតិនេះ លុះរំលាយខន្ធទៅ រមែងបានទៅកើតស្ថានសួគ៌បរិបូណ៌ ដោយរូបឆោមពណ៌ល្អមានបរិវារចោមរោមថ្កុំថ្កើងរុងរឿង មានរស្មីផ្សាយចេញពីកាយមានស្រះបោក្ខរណីជាទីសប្បាយ មានប្រាសាទមាស ឱកាសដោយរស្មីជាទីស្រណុកសុខសប្បាយឥតអន្តរាយមកបៀតបៀនបានឡើយ លុះច្យុតអំពីស្ថានសួគ៌នោះបានមកកើតក្នុងវង្សត្រកូលថ្កុំថ្កើងរុងរឿង មានត្រកូលក្សត្រជាដើម មានសម្បត្តិនោះច្រើនអនេក មានស្រីស្រិង្គាររោមរោមជាបរិវារ ព្រោះហេតុតែបានធ្វើបុណ្យកុសលតម្កល់ទុកពីជាតិមុន ទើបបានសម្បត្តិក្នុងលោកិយ និងបរលោក ។ ឯសម្បត្តិទាំងពីរនេះបើបុគ្គលពុំបានធ្វើហើយ ក៏ពុំអាចនឹងបានឡើយ ។ ឯពួកមហាជនមានកាឡីអាមាត្យជាប្រធាន បានស្តាប់ហើយមានចិត្តរីករាយត្រេកអរយ៉ាងក្រៃលែង លុះចប់ធម្មវិសេសទេសនា អស់មហាជនក៏បានលុះធម្មាភិសម័យតាមឧបនិស្ស័យវាសនារៀងៗខ្លួន ។

## ១៩. រឿងប្រេតស៊ីកូនម្តង៧[20]

(ទោសទុច្ចរិត និងស្បថបំពានការពិត)

ក្នុងកាលដែលព្រះបរមពុទ្ធង្កុរបណ្ឌូលសារពេជ្ជតាញាណ ទ្រង់គង់សម្រេចសម្រាន្តព្រះឥរិយាបថនាក្រុងស្លាវត្ថី មានឧបាសកម្នាក់មានទីលំនៅៗទៀបទីក្រុងនោះ ។ គាត់មានកូនពីរនាក់ ដែលមានវ័យវឌ្ឍន៍ចម្រើនតាមលំដាប់ ។ ឯភរិយាជាស្ត្រីឆ្នាស់ មានការប្រមាថមើលងាយស្វាមី ទុកស្វាមីដូចជាទាសា ដោយគិតថាស្វាមីនឹងធ្វើអ្វីអញ បើអញមានកូនគ្រាន់ជាទីពឹងហើយ ។ ឯឧបាសកនោះយល់ប្រពន្ធខ្លួនជាស្ត្រីឆ្នាស់ទទឹងរឹងរូស មើលងាយដូច្នោះទៅជានឿយណាយធុញទ្រាន់នឹងអាកប្បកិរិយារបស់ប្រពន្ធ ទើបទៅដណ្តឹងយកនាងកុមារិកាម្នាក់មកធ្វើជាប្រពន្ធចុង ។ នៅរួមរស់មេត្រីដោយក្តីស្នេហាមិនយូរប៉ុន្មាន ប្រពន្ធនោះមានគភ៌ឡើង ឯប្រពន្ធដើមឃើញដូច្នោះ កើតអរិចិត្តច្រណែនឈ្នានិសប្សា ទើបល្បួងលួងលោមប្រពន្ធចុងធ្វើជាមិត្តស្និទ្ធស្នាលដើម្បីបន្លំដាក់ថ្នាំទម្លាក់គភ៌នាង ។ រីឯបងប្អូនញាតិសន្តាន បានដឹងដូច្នោះសួរទៅប្រពន្ធដើមថា នាងខឹងអ្វីបានជាធ្វើថ្នាំដាក់ពន្លូតគភ៌នាងនេះ ។ នាងបដិសេធថាខ្លួនពុំបានធ្វើ អំពើដ៏សាហាវឃោរឃៅដូច្នោះទេ ពួកញាតិទាំងអស់បានឲ្យនាងស្បថ ក៏ស្បថទាំងបំពានថា បើខ្ញុំហើយធ្វើអំពើអាក្រក់លាមកពន្លូតកូននាងកុមារិកានេះមែន សូមឲ្យខ្ញុំកើតជាតិណាៗ ស៊ីតែកូនឯងម្តង៧រាល់ៗថ្ងៃឲ្យខ្លួនខ្ញុំទាំងមូលនេះមានក្លិនស្អុយ អសោចមានរុយរោមពេញទាំងខ្លួន ។

អំណឹះតទៅនាងប្រពន្ធដើមរម្លាយបញ្ចខន្ធទៅកើតជាប្រេតញីមួយ ដោយកម្មដ៏លាមកដែលខ្លួនបានធ្វើ ព្រមទាំងពោលពាក្យស្បថទាំងបំពានដោយមុសាវាទ ។ លំដាប់នោះព្រះថេរៈទាំងឡាយគង់ចាំវស្សាក្នុងជនបទមួយ លុះចេញវស្សាហើយក៏និមន្តទៅក្រុងសាវត្ថីដើម្បីថ្វាយបង្គំព្រះដ៏មានបុណ្យ មកដល់

[20] ប្រជុំនិទានជាតក ភាគ៥ទំព័រ ៧៧៥

ទីទួលមួយមានដីរាបស្មើល្អ ក៏ចូលទៅសម្រាកព្រះកាយ ។ ក្នុងរាត្រីនោះ ប្រេតញីបានសំដែងកាយឲ្យព្រះថេរៈទាំងឡាយឃើញច្បាស់ ។ គ្រានោះ ព្រះសង្ឃត្ថេរ មួយអង្គសួរថា នែនាងប្រេតញី! នាងឯងគ្មានសំពត់បិទបាំង រាងកាយបន្តិចសោះ មានមុខមាត់អាក្រក់ក្រៃ ក្លិនស្អុយអសោច និងរុយរោម ពេញទាំងខ្លួន នាងមកក្នុងទីនេះ តើព្រោះធ្វើកម្មអ្វី? នាងប្រេតទូលថា បពិត្រព្រះករុណាម្ចាស់! ព្រោះខ្ញុំព្រះករុណាធ្វើអំពើដ៏អាក្រក់លាមកណាស់ បានជាត្រូវមកកើតជាប្រេតនៅអាស្រ័យក្នុងទីនេះ វេលាព្រឹកខ្ញុំស៊ីកូនឯងអស់៧ វេលាល្ងាចស៊ីអស់៧ទៀតរាល់ៗថ្ងៃ ។ បើទុកជាដូច្នោះ ក៏ខ្ញុំពុំអាចទប់ទល់នឹង សេចក្ដីស្រេកឃ្លានបានឡើយ ។ ក្នុងកាយរបស់ខ្ញុំម្ចាស់ ក្ដៅក្រហាយជានិច្ច ដូចជាគេឈរនៅកណ្ដាលគំនរភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ ។ ឯបុព្វកម្ម របស់ខ្ញុំម្ចាស់នោះដូច្នោះ កាលពីជាតិមុនខ្ញុំម្ចាស់ជាស្ត្រីរួមរ័ក្ដជាមួយនាងកុមារិកា ម្នាក់ហើយខ្ញុំម្ចាស់មានកូនពីរនាក់ ដែលមានរូបសម្បត្តិដ៏សម្បូរ មានវ័យធំ ល្មមប្រើការបាន តែខ្ញុំម្ចាស់វិញជាស្ត្រីឆ្លាស់ មានការប្រមាទមើលងាយប្ដីជាប្រក្រតី ។ ឯប្ដីខ្ញុំម្ចាស់មិនអាចអត់ទ្រាំនៅជាមួយខ្ញុំម្ចាស់ទៀតបាន ក៏ទៅស្ដីដណ្ដឹងនាង កុមារិកាម្នាក់ទៀតមកជាភរិយាចុង ។ លុះនាងភរិយាចុងមានគភ៌ ខ្ញុំម្ចាស់កើត ចិត្តឫស្យាប្រណែនឈ្នានីសទើបធ្វើឲ្យគភ៌នាងរលូតចេញទៅ ។ ពួកញាតិទាំង ឡាយរបស់នាងកុមារិកានោះបានជេរស្ដីបន្ទោសខ្ញុំម្ចាស់ជាច្រើន តែខ្ញុំម្ចាស់ឆ្លើយ បដិសេធប្រកែកពុំព្រមទទួលកំហុសដោយមុសាវាទ ទានជាខ្ញុំម្ចាស់មកកើតជា ប្រេតញីនៅទីនេះក្នុងជាតិនេះឯង ។

ទូលព្រះថេរៈសព្វគ្រប់ហើយ នាងប្រេតផ្ដែផ្ដាំនឹងព្រះថេរៈសូមឲ្យនិមន្ត ទៅផ្ទះឧបាសកនោះ ហើយសូមប្រាប់ឲ្យឧបាសកនោះធ្វើបុណ្យឧទ្ទិសភាគផល ផ្សាយឲ្យនាងផង ដើម្បីឲ្យឆាប់បានរំដោះជាតិអំពីប្រេតនេះ ។ ព្រះថេរៈទាំង ឡាយ ក៏និមន្តទៅផ្ទះឧបាសកនោះ រៀបរាប់អំពីពាក្យបណ្ដាំរបស់នាងប្រេត សព្វគ្រប់ ឧបាសកនោះក៏ចាត់ចែងរៀបក្រាលអាសនៈ ហើយអង្គាសដោយ

កត្តហារដ៏គួរ រួចឧទ្ទិសផលជូនទៅ ប្រេតញីនោះ តាមចិត្តសទ្ធារបស់ខ្លួន ។ ដោយអំណាចនៃទេយ្យទាន ដែលឧបាសកនោះឧទ្ទិសឲ្យទៅ នាងប្រេតនោះក៏បានរួចចាកទុក្ខសោយសុខដ៏លើសលុប ហើយសម្តែងកាយឲ្យ ឧបាសកនោះឃើញក្នុងរាត្រីនោះ ។

ព្រះថេរៈទាំងឡាយ ក៏យកសេចក្តីនេះទៅក្រាបទូលព្រះដ៏មានជោគ ទ្រង់ក៏សម្តែងបញ្ជាក់រឿងនេះដល់ បរិស័ទទាំង៤ពួក ដោយយកព្រះថេរៈទាំងនេះជាសម្អាង បរិស័ទទាំង៤ក៏កើតសោមនស្សជ្រះថ្លា និងសង្វេគចិត្តគ្រប់ៗគ្នា ចប់ធម្មទេសនា ក៏បានសម្រេចនូវគុណធម៌ដ៏វិសេសគ្រប់ៗគ្នាហោង ។

## ២០. រឿងប្រេតញីស៊ីកូនម្តង៥[21]

កាលព្រះបរមសាស្តា ទ្រង់គង់សម្រាន្តព្រះឥរិយាបថក្នុងក្រុងសាវត្ថីមានប្រេតញីមួយរូបស៊ីកូនឯងម្តង៥ ។ កាលពីអតីតជាតិ ប្រេតញីនោះជាស្ត្រីមួយរូបដែលត្រូវជាភរិយា កុដុម្ពីម្នាក់ ក្នុងក្រុងសាវត្ថីនោះដែរ តែនាងជាស្ត្រីអាឥតកូនម្នាក់សោះ ។ ថ្ងៃមួយពួកញាតិទាំងឡាយនិយាយទៅកាន់កុដុម្ពីនោះថា ភរិយារបស់អ្នកឯងជាស្ត្រីអាឥតកូនមួយសោះ ចូរឯងរកភរិយាដទៃមកក្រែងមានកូននឹងបានតពូជពង្សវង្សត្រកូលទៅទៀត ។ ឯភរិយាក៏និយាយ និងកុដុម្ពីនោះដែរ ថាខ្ញុំជាស្ត្រីអាគ្មានកូនទេ ពូជពង្សវង្សត្រកូល មុខជានឹងត្រូវរលត់ផុតត្រឹមនេះហើយ ដើម្បីបន្តពូជរបស់អ្នកឯងឲ្យបានវែងឆ្ងាយ ចូរអ្នករកភរិយាមួយមកទៀតចុះ ។ កុដុម្ពីដោយឃើញថាភរិយារបស់ខ្លួនយល់ព្រមឲ្យយកប្រពន្ធមួយទៀត ក៏ទៅស្តីដណ្តឹងនាងកុមារិកាម្នាក់មកធ្វើជាភរិយា ។ ភរិយាក្រោយនេះនៅ រួមជាមួយកុដុម្ពីមិនយូរប៉ុន្មាន គភ៌ក៏កើតប្រាកដឡើង ។ ឯស្ត្រីអាបានឃើញនាងកុមារិកានោះមានគភ៌ដូច្នោះ បែរជាគិតថានាងនេះមានកូន អំណឹះទៅនឹងត្រូវបានជាមេផ្ទះធំ ត្រួតលើអញពុំខានធម្មតាមនុស្សដែលនៅក្រោម

[21] ប្រជុំនិទានជាតក ភាគ៥ទំព័រ ៨០១

អំណាចអ្នកដទៃពុំដែល សប្បាយចិត្តក្នុងកាលណាម្តងឡើយ បើដូច្នេះគួរអញធ្វើឧបាយណាមួយ ដើម្បីពន្លូតគភ៌ នាងនេះចេញ ។ គិតហើយនាងក៏បានជួលបរិព្វាជក ម្នាក់ដែលប៉ិនប្រសប់ខាង ផ្សំថ្នាំសម្រាប់ពន្លូតគភ៌ លុះបរិព្វាជកផ្សំថ្នាំរួចយកមកឲ្យនាងបានទាំងផ្តាំថា ចូរនាងយកថ្នាំ នេះដាក់លាយនឹងបាយឲ្យស៊ី គភ៌នឹង. ក់ហើយ ស្ត្រីនោះធ្វើតាមបណ្តាំបរិព្វាជក ក៏បានសម្រេចដូចបំណងមែន ។ កាលដែលគភ៌ធ្លាក់ផុតទៅ នាងកុមារិកានោះ ក៏និយាយរឿងរ៉ាវប្រាប់ដល់ស្វាមី ម្តាយ និងញាតិទាំងអស់របស់ខ្លួន អំពីគំនិតអាឃាតព្យាបាទរបស់ស្ត្រីនោះ ឯពួកញាតិបានស្តីបន្ទោសស្រីអានោះជាច្រើន តែស្រីអានោះជជែកពុំព្រមទទួលសារភាពថា ខ្លួនបានធ្វើអំពើអាក្រក់ដូច្នោះឡើយ ហ៊ានស្បថទាំងបំពានថា បើនាងបានធ្វើអំពើអាក្រក់ដូច្នោះមែន សូមឲ្យធ្លាក់វេទនាក្នុងនរក រួចពីនោះមកកើត ជាប្រេតស៊ីតែកូនឯង សូមឲ្យអត់បាយក្រហាយទឹក ឲ្យមានខ្លួនធុំក្លិនស្អុយរុយរោមជានិច្ច ។ ដោយអំណាចបាបកម្មដ៏គួរឲ្យខ្លើមរអើមនេះ លុះស្លាប់ទៅ ស្ត្រីអានោះក៏ ធ្លាក់ទៅសោយទុក្ខក្នុងនរករួចបានត្រឡប់ពីនរកមកកើតជាប្រេតញីអាស្រ័យនៅក្បែរភូមិនោះ ។

កាលនោះមានព្រះថេរៈ៨អង្គគង់ចាំវស្សា នៅក្នុងជនបទមួយលុះចេញវស្សា ក៏និមន្តចូលទៅក្រុងសាវត្ថី ដើម្បីនមស្ការការព្រះបរមគ្រូ បានចេញពីផ្លូវចូលទៅសម្នាក់អាស្រ័យក្នុង ព្រៃរបោះមួយកន្លែង មានម្លប់ដ៏សែនត្រជាក់ មានទឹកថ្លាឆ្វង់មើលឃើញដី ។ ឯប្រេតញី នោះបានសម្តែងកាយឲ្យព្រះថេរៈទាំងឡាយនោះឃើញ ទើបព្រះសង្ឃត្ថេរ៧អង្គទៀតបាន ឃើញហើយសូត្រជាបទគាថា ថា នាងគ្មានសំពត់ស្លៀក មានខ្លួនអាក្រក់ក្រៃ មានក្លិនស្អុយអសោចមានរុយរោមពេញទាំងខ្លួន មកនៅអាស្រ័យក្នុងព្រៃនេះ ព្រោះធ្វើកម្មដូចម្តេច?

នាងប្រេតនោះតបនឹងថេរដីការបស់ ព្រះសង្ឃត្ថេរអំពីអំពើអាក្រក់លាមកដែលខ្លួនបានធ្វើថា ខ្ញុំធ្លាក់ទៅសោយទុក្ខក្នុងនរក រួចបានមកកើតជាប្រេតក្នុងទីនេះ ក្នុងវេលាព្រឹក ខ្ញុំរលូតកូន៥មកហើយខ្ញុំស៊ីអស់ទៅ វេលារសៀលរលូត៥

ទៀតស៊ីអស់ទៀតទៅ ទុកជាខ្ញុំស៊ីដូច្នេះ ក៏នៅតែពុំអាចចម្អែតផ្ទៃខ្ញុំម្ចាស់បាន ក្នុងចិត្តខ្ញុំម្ចាស់វិញមានសេចក្ដីស្រេកឃ្លានក្ដៅ ក្រហល់ក្រហាយពុំដែលបាន អាហារដ៏មានរសជាតិទទួលទានម្ដងណាឡើយ ដូចព្រះអង្គបានជ្រាបស្រាប់ ហើយខ្លួនខ្ញុំធុំក្លិនអសោច មានរុយរោមពេញទាំងខ្លួន ។ ព្រះថេរៈសួរទៀតថា នាងធ្វើកម្មដូចម្ដេចបានជាត្រូវត្រឡប់ស៊ីកូនឯងវិញ? នាងប្រេតទូលតបថា បពិត្រព្រះករុណាម្ចាស់! កាលពីអតីតជាតិ ខ្ញុំម្ចាស់នេះជាស្ត្រីអារូមស្វាមីជាមួយ នាងកុមារិកា ម្នាក់ជាប្រពន្ធចុង ក្រោយមកនាងកុមារិកាមានគភ៌ ខ្ញុំម្ចាស់មាន ចិត្តឫស្យាច្រណែនឈ្នានីស ព្យាយាមធ្វើឲ្យគភ៌របស់នាងនោះរលូត ត្រាតែ សម្រេចដូចបំណង ។ ឯមាតា ស្វាមីព្រមទាំងញាតិបានស្ដីជេរបន្ទោស ខ្ញុំម្ចាស់ ដោយប្រការផ្សេងៗ ខ្ញុំម្ចាស់ក៏ប្រើមុសា វាទបំពានស្បថថា បើខ្ញុំម្ចាស់បានធ្វើឲ្យ គភ៌នាងរលូតមែន សូមឲ្យខ្ញុំស៊ីតែកូនឯងក្នុង មួយថ្ងៃដប់កុំឲ្យសល់ខានឲ្យ រុយរោមពេញទាំងខ្លួន មានក្លិនស្អុយអសោចអស់កាលជានិច្ច ។ ដោយអំណាច ផលនៃអំពើមុសាវាទ និងសម្បថទាំងបំពាននោះបានធ្វើឲ្យ ខ្ញុំម្ចាស់ទៅសោយ ទុក្ខក្នុងនរក រួចពីនរកមកទើបបានកើតជាប្រេតនេះ ដូចព្រះអង្គបានឃើញ នេះឯង ។ ទូលព្រះសង្ឃគ្គេរួចហើយបានផ្ដាំថាសូមព្រះករុណាមេត្តានិមន្តទៅ ប្រាប់កុដុម្ពីនោះឲ្យថ្វាយទានដល់ព្រះករុណាម្ចាស់ផង ហើយសូមឲ្យឧទ្ទិស ផ្សាយកុសលផលបុណ្យមកចែកខ្ញុំម្ចាស់ទទួលទានផង ដើម្បីឲ្យឆាប់បានរំដោះ អំពីប្រេតវិស័យនេះ ។

ព្រះមហាថេរៈទាំងឡាយ ទ្រង់មានព្រះទ័យដោយមេត្តាក៏បាននិមន្តទៅ ផ្ទះកុដុម្ពីនោះ អធិប្បា យរៀបរាប់អំពីបណ្ដាំរបស់ប្រេតញី កុដុម្ពីក៏បានចាត់ចែង ថ្វាយទាន ឧទ្ទិសផលដល់ប្រេតញីនោះដោយសទ្ធាជ្រះថ្លាដ៏ក្រៃលែង លុះត្រា តែនាងប្រេតនោះ បានរំដោះចាកទុក្ខ បានសោយសុខសម្បត្តិដ៏សែនមនោរម្យ ។ ឯនាងប្រេតនោះក្រោយ ពីរួចចាកទុក្ខហើយ ក៏សំដែងកាយឲ្យកុដុម្ពីនោះឃើញ

ច្បាស់ក្នុងខណៈនោះឯង ។ ព្រះមហាថេរៈទាំងឡាយនាំយករឿងរ៉ាវនេះទៅក្រាបទូលព្រះបរមសាស្តា ព្រះអង្គទ្រង់ សំដែងបញ្ជាក់អំពីកម្មដ៏អកុសលនោះ លុះចប់មហាជនក៏បានសម្រេចនូវអរិយធម៌គ្រប់ៗគ្នា ។

## ២១. រឿងវុត្ថភាប្រេត[22]

(ផលល្អ និងអាក្រក់តែងជ្រៀតជ្រែកឲ្យផលតាមកម្លាំង)

ក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សបៈ មានស្ត្រីម្នាក់មានសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ បានកសាងអារាមមួយ ប្រគេនព្រះភិក្ខុសង្ឃឲ្យគង់នៅជាសប្បាយព្រមទាំង ចង្ហាន់ដ៏ត្រកាលជាប្រក្រតី ។ លុះនាងធ្វើកាលកិរិយាទៅដោយផលកម្មអកុសលដែល នាងបានធ្វើពីជាតិមុនចូលមកជ្រៀតជ្រែក នាំវិញ្ញាណនាងឲ្យទៅកើតជាវិមានប្រេត នៅលើភ្នំហិមពាន្តមានវិមានមាសឱភាសរុងរឿងថ្កើងថ្កាន មានឱទ្យានដូចស្ថានសួគ៌ ប្រកបដោយស្រះបោក្ខរណី៤ជ្រុង ដ៏មានកម្ពស់រាបស្មើសប្បាយពណ្ណរាយ ដោយអានុភាពនៃបុណ្យដែលនាងបានកសាងអារាមមួយប្រគេនដល់ភិក្ខុសង្ឃ ។ ឯរូបនាងសម្បុរល្អដូចមាស ប្រាសចាកមន្ទិលប្រៀបបាននឹងលំអរស្រីទេពអប្សរសោយ សម្បត្តិនៅទីនោះ ព្រោះកុសលតាក់តែងពុំឲ្យមានទុក្ខ ។ ប៉ុន្តែប្រាសចាកកាមសុខត្បិតពុំមានបុរសម្នាក់ក៏បណ្តាលឲ្យក្តៅក្រហាយក្នុងចិត្ត ទើបនាងវិមានប្រេតគិតរកឧបាយ បេះផ្លែស្វាយទិព្វបោះបណ្តែតឲ្យរសាត់តាមទឹកហូរក្នុងស្ទឹងនោះ ។

លំដាប់នោះ មានមាណពម្នាក់នៅក្នុងនគរពារាណសី ចេញពីផ្ទះចុះទៅកំពង់ ទឹកឃើញផ្លែស្វាយទិព្វមួយអណ្តែតទៅដល់ ក៏រើសយកមកពិចារណាដឹងស្គាល់ជាផ្លែ ស្វាយទិព្វ ទើបបុរសនោះបរិភោគ ក៏មានឱជារសឆ្ងាញ់ពិសារប្លែងពីធម្មតា ហើយរៀប ស្បៀងអាហារអម្រស់អម្រដើរ តាមមាគ៌ាឆ្ពោះទៅព្រៃហិមពាន្ត លុះទៅដល់ហើយ នាងវិមានប្រេតចេញមកសួរទទួលនាំទៅវិមាន

[22] ប្រជុំនិទានជាតក ភាគ៥ទំព័រ ៨១៤

ឲ្យអង្គុយលើគ្រែបន្ទំសមរម្យ រួមរក្សស្នេហាតាមប្រពៃណីស្ត្រី និងបុរសក្នុងលោក ។ កាលបុរសនោះឃើញទិព្វសម្បត្តិស្ថាន លំនៅនៃវិមានប្រេតស្រណុកសុខសប្បាយ ទើបសួរថា ម្នាលប្អូនស្រីសម្លាញ់ នាងមាន ឫទ្ធានុភាពដូចស្រីទេពអប្សរ ប្រាង្គប្រាសាទវិមានភ្លឺស្វាងរុងរឿង ដោយកែវពៃទូរ្យសូរ្យកាន្ត ភ្លឺដូចព្រះច័ន្ទពេញបូណ៌មី ហើយនាងស្រីក៏ល្អដូចមាសជម្ពូនុទបរិសុទ្ធផុតចាកមន្ទិលសៅហ្មង តែងនាំចិត្តបុរសឲ្យត្រេកត្រអាលហើយនៅលើប្រាសាទនោះតែម្នាក់ឯងកណ្ដោចកណ្ដែង កំព្រាឥតមានបុរសណាជាស្វាមីមានស្រះបោក្ខរណីប្រកបដោយ ជលជាតដុះពេញត្រៀបត្រាមានហ្វូងបក្សាបក្សី ស្រែកយំទ្រហឹងអឹងកងរំពងព្រៃដូចជាដូរព្រៃ ដូចជាដូរ្យតន្ត្រីទាំងប្អូនស្រីមានមុខញញឹមស្រស់ប្រិមប្រិយសម្ដីនោះពីរោះ យើងបានឃើញហើយតាមចិត្តគិតចង់មកកើតនៅទីនេះ តើធ្វើដូចម្ដេចនឹងបានសម្រេចដូចប្រាថ្នា? ។ នាងវិមានប្រេតស្ដាប់ហើយប្រាប់ថាហែមាណពបើអ្នកចង់មកកើតនៅទីនេះចូរ សង្វាតបំពេញកុសល លុះអស់ជីវិតទៅអ្នកនឹងបានមកកើតនៅទីនេះ បានត្រេកត្រអាល សប្បាយជាមួយនឹងយើងពុំខានឡើយ ។ ឯមាណពបានស្ដាប់ពាក្យនាងប្រេតដូច្នោះ ក៏មានចិត្តត្រេកអរមហិមា លាវិលវិលទៅកាន់ស្ថានលំនៅរបស់ខ្លួនវិញ ហើយធ្វើបុណ្យកុសលតម្កល់ចិត្តគិតចង់បាននាងប្រេតនោះ លុះអស់អាយុសង្ខារពីមនុស្សលោក ក៏បានកើតក្នុងវិមានរួមមគ្គសំវាស ជាមួយនឹងនាងប្រេតនោះដរាបដល់អស់កំណត់កុសលផលបុណ្យដែលខ្លួនបានធ្វើនោះហោង ។ នាងប្រេតបាននៅទីនោះអស់កំឡុងកាលដ៏យូរមួយពុទ្ធន្តរ ដរាបដល់សាសនាព្រះសមណគោតមបរមគ្រូព្រះអង្គបានត្រាស់ប្រាជ្ញាសារពេជ្ញតាញាណក្នុងលោកនេះ ។

សម័យថ្ងៃមួយ ព្រះមហាមោគ្គល្លានដ៏មានអាយុ លោកនិមន្តទៅដល់ភ្នំនោះបានឃើញនាងវិមានប្រេត ស្ថិតនៅលើវិមានឋានទិព្វប្រដាប់សឹងកែវពៃទូរ្យទើបលោកសួរថា វិមានឋាននេះមានរស្មីរុងរឿងថ្កើងថ្កាន តើនាងបានធ្វើកម្មដូចម្ដេចពីជាតិមុន ទើបបានកើតនៅក្នុងវិមាននេះ? នាងប្រេតប្រាប់បុព្វកម្ម

ដែលនាងបានធ្វើពីជាតិមុន ទូលព្រះមហាថេរសព្វគ្រប់ប្រការ ។ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុត្រឡប់នាំយករឿង នោះទៅក្រាបទូលព្រះបរមសាស្តា ទ្រង់ប្រជុំបរិស័ទសម្តែងធម៌ទេសនាប្រារព្ធយករឿង ប្រេតនោះជាហេតុលុះចប់ព្រះធម៌ទេសនា បរិស័ទទាំងឡាយបានសម្រេចមគ្គផល តាមឧបនិស្ស័យវាសនារៀងៗខ្លួន ។

## ២២. រឿងអហិប្រេត[23]

(ទោសនៃការព្យាបាទ ដុតបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ)

សម័យមួយព្រះមហាមោគ្គល្លាន និមន្តទៅភ្នំគិជ្ឈកូដបានឃើញប្រេតមួយឈ្មោះអហិប្រេត មានក្បាលជាមនុស្សខ្លួនជា ពស់មានភ្លើងឆេះសន្ធោសន្ធៅតាំងពីក្បាលដល់ចុងកន្ទុយ ។ លោកបានឃើញប្រេតនេះហើយបានដំណាលប្រាប់ព្រះលក្ខណត្ថេរ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់រឿងប្រេតនេះហើយត្រាស់ថា ម្នាលមោគ្គល្លានតថាគត បានឃើញអហិប្រេតនេះតាំងពីថ្ងៃដែលតថាគតបានត្រាស់ជាព្រះពុទ្ធថ្មីៗម្ល៉េះ ប៉ុន្តែពេលនោះគ្មានសាក្សីបើតថាគតសម្តែងទៅគេមិនជឿនាំឲ្យឥតប្រយោជន៍មានទោស ដល់អ្នកមិនជឿនោះ ឥឡូវបានមោគ្គល្លាន ជាសាក្សីហើយចាំតថាគតសម្តែងអតីតនិទានរបស់ប្រេតនោះឲ្យស្តាប់ ។

ព្រះសម្ពុទ្ធត្រាស់សម្តែងថា កាលកន្លងទៅហើយ ពួកមហាជនបាននាំគ្នាធ្វើបណ្ណសាលា ផ្ទះស្លឹកមួយជិតស្ទឹងក្នុងក្រុងពារាណសីប្រគេនព្រះបច្ចេកពុទ្ធមួយអង្គគង់នៅ ។

អ្នកក្រុងបាននាំគ្នាយកគ្រឿងក្រអូប និងផ្កាកម្រងជាដើមទៅប្រគេនរាល់ថ្ងៃបានដើរជាន់ស្រូវកសិករម្នាក់ ដែលបានភ្ជួរព្រោះកៀកជាប់នឹងផ្លូវបណ្ណសាលានោះ ។ កសិករម្ចាស់ស្រែឃាត់មិនស្តាប់ ក៏មានការអាក់អន់ចិត្តជាខ្លាំង កើតចិត្ត

---

[23] ប្រជុំនិទានជាតក ភាគ៦ទំព័រ ៨៩២

ព្យាបាទថាប្រសិន បើមិនមានបណ្ណសាលា មិនមានព្រះបច្ចេកពុទ្ធមកគង់ក្នុងទីនេះទេ ស្រូវអញក៏មិនវិនាសខ្ទេចខ្ទីដូច្នេះដែរ អញត្រូវដុតបណ្ណសាលានេះចោលទើបបាន ។ ក្នុងពេលដែលព្រះបច្ចេកពុទ្ធនិមន្តទៅបិណ្ឌបាត ក្នុងក្រុងពារាណសី កសិករនោះក៏វាយបំបែកភាជនៈសម្រាប់ប្រើប្រាស់របស់ព្រះបច្ចេកពុទ្ធចោលអស់ ហើយយកភ្លើងដុតបណ្ណសាលាឆេះខ្ទេចខ្ទីអស់ទៅ ។

ព្រះបច្ចេកពុទ្ធកំពុងនិមន្តបិណ្ឌបាត បានឃើញភ្លើងឆេះបណ្ណសាលាអស់ហើយក៏និមន្តតាមអាកាសចាកចេញពីទីនោះបាត់ទៅ ។ ពួកមហាជនដែលបានយកគ្រឿង បូជាទៅប្រគេនព្រះបច្ចេកពុទ្ធនោះ កាលបើឃើញបណ្ណសាលាឆេះអស់ហើយបាត់ព្រះបច្ចេកពុទ្ធដូច្នោះ ក៏សន្និដ្ឋានថា លោកឆេះសុគតក្នុងភ្លើងទៅហើយ ឬក៏មិនទាន់និមន្តមកពីបិណ្ឌបាត ។ កំពុងតែជំនុំគ្នាដូច្នេះស្រាប់តែកសិករដែលនៅក្នុងទីនោះដែរ និយាយថាខ្ញុំជាអ្នកដុតបណ្ណសាលានេះ ព្រោះអ្នករាល់គ្នាបំផ្លាញស្រូវខ្ញុំអស់ ។ ពេលនោះមហាជនស្រែកឆោឡោឡើងថាពួកយើងជួយចាប់ចោរដុតបណ្ណសាលា ពួកយើងខានធ្វើទានចំពោះព្រះបច្ចេកពុទ្ធ ក៏ព្រោះតែវានេះឯងត្រូវចាប់វាឲ្យបាន ។ លុះចាប់កសិករអ្នក ដុតបណ្ណសាលានោះបានហើយ នាំគ្នាវាយតប់យកទៅធ្វើទោសតាមច្បាប់ដរាបដល់ស្លាប់ទៅ ។ កសិករទុច្ចរិតដែលស្លាប់នោះ ធ្លាក់ទៅកើតក្នុងនរកធំ ឈ្មោះអវិចីជាច្រើនសែនឆ្នាំ ដរាបដល់ផែនដីដុះកម្ពស់បានមួយយោជន៍ទើបរួចពីនរកធំនៅសល់ផលកម្មនោះ បានមកកើតជាអហិប្រេតនៅលើកំពូលភ្នំគិជ្ឈកូដនេះឯង ។ នៅក្នុងទីបញ្ចប់នៃអតីតនិទានទ្រង់ត្រាស់នូវព្រះគាថានេះថា៖

**ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ**
**ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ បាវកោ**[24] ។

[24] គាថាធម្មបទប្រែ ទំព័រ ១១២

ក៏បាបកម្មដែលបុគ្គលបានធ្វើហើយ មិនទាន់ហុចផលឲ្យ, ដូចជាទឹកដោះដែលគេរីត ក្នុងខណៈនោះ មិនទាន់ប្រែប្រួលទៅយ៉ាងនោះឯង, បាបកម្មរមែងតាមដុតនូវបុគ្គលពាល ដូចភ្លើងដែលក្តៅងំ, យ៉ាងនោះឯង ។

## ២៣. រឿងប្រេតញីឈ្មោះឧត្តរមាតា[25]

(ទោសនៃការជាក់បណ្តាសា អ្នកធ្វើបុណ្យ)

សម័យមួយ ព្រះកង្ខារេវតត្ថេរ កំពុងសម្រាកក្នុងវេលាថ្ងៃក្បែរឆ្នេរទន្លេគង្គា ពេល នោះមានប្រេតញីមួយសម្បុរអាក្រក់ឃើញគួរឲ្យខ្លាច មានសក់វែងដល់ដី អាក្រាតខ្លួនទទេ បានយកសក់របស់ខ្លួនបិទបាំងកាយ ដើរចូលទៅរកព្រះថេរៈ ហើយនិយាយត្អូញត្អែថា បពិត្រលោកម្ចាស់ ចាប់តាំងពីខ្ញុំធ្វើមរណកាលមក ចំនួន៥៥ឆ្នាំហើយ មិនដែលបានបរិភោគអាហារ ឬផឹកនូវទឹកសោះឡើយ ខ្ញុំស្រេកទឹកណាស់ សូមលោកម្ចាស់ឲ្យទឹកដល់ខ្ញុំ ។

ព្រះកង្ខារេវតត្ថេរតបថា ទន្លេគង្គានេះមានទឹកត្រជាក់ហូរពីភ្នំហិមពាន្ត មកចូរនាងផឹកនូវទឹកទន្លេនេះទៅហេតុអ្វីមកសុំទឹកពីអាត្មាវិញ ។ ប្រេតឆ្លើយតបថា បពិត្រលោកម្ចាស់ ខ្ញុំដងទឹកទន្លេនេះហើយតែផឹកមិនកើត ព្រោះទឹកនេះក្លាយជាឈាម ក្នុងពេលដែលខ្ញុំដងឡើង ។ អាស្រ័យហេតុនេះសូមលោកម្ចាស់ឲ្យទឹកខ្ញុំផឹកផង ។

ព្រះថេរៈសួរថា នាងបានធ្វើកម្មអាក្រក់ដូចម្តេច ដោយកាយវាចាចិត្តពីពេលមុនទើបពេលនេះមានវិបាកដូច្នេះ ?

ប្រេតឆ្លើយថា កាលពីបុព្វជាតិខ្ញុំមានកូនប្រុសម្នាក់ឈ្មោះឧត្តរ ជាឧបាសក អ្នកមានសទ្ធាជ្រះថ្លា ក្នុងពុទ្ធសាសនាខ្ញុំជាមនុស្សកំណាញ់មិនចង់ឲ្យខាតបង់ទ្រព្យ ។ កូនខ្ញុំបានឲ្យចីវរបិណ្ឌបាតសេនាសនៈ និងគិលានភេសជ្ជៈ ចំពោះសាមណៈទាំងឡាយ ។ ពេលនោះ សេចក្តីកំណាញ់របរឹតចិត្តខ្ញុំបណ្តាលឲ្យមាន

---

[25] ប្រជុំនិទានជាតក ភាគ៦ទំព័រ ៩០៤

សេចក្ដីក្រោធញាប់ញ័រជេរប្រទេចដាក់បណ្ដាសាកូនថា ម្នាលឧត្តរៈចីវរប្បច្ច័យជាដើមនោះ ចូរកើតទៅជាឈាមដល់ឯង ក្នុងបរលោកចុះ ព្រោះផលនៃកម្មនេះទើបទឹកទន្លេគង្គានេះក្លាយកើតជាឈាមដល់ខ្ញុំ ។

ព្រះថេរៈមានសេចក្ដីអនុគ្រោះ បានជួយប្រេតនោះឲ្យរួចរំដោះចាកបាបកម្មរបស់ខ្លួនផុតពីសេចក្ដីទុក្ខ ។

## ២៤. រឿងស្ដេចលិច្ឆវី និងប្រេត[26]

(កើតជាប្រេតអាក្រាតកាយ ព្រោះធ្វើឲ្យគេអាក្រាត)

ក្នុងក្រុងសាវត្ថី មានស្ដេចលិច្ឆវីមួយព្រះអង្គព្រះនាមអម្ពសក្ខរៈបានទតឃើញប្រេតមួយ មានរូបធំអាក្រាតកាយទទេ ជិះលើខ្នងសេះសស្អាតមានពន្លឺផ្សាយចេញពីកាយ និងមានក្លិនល្អបក់ផ្សាយចេញពីរូបកាយផង ។ ប្រេតនោះបានជិះសេះទៅឈប់ជិតបុរសអ្នកទោសម្នាក់ ដែលស្ដេចលិច្ឆវីបានដោតឆ្កាងដោយឈើអណ្ដោត នៅក្រៅក្រុង ហើយនិយាយជាមួយអ្នកទោសថា អ្នកចូររស់ចុះព្រោះការរស់នៅរបស់អ្នកប្រសើរជាងស្លាប់ ។

ស្ដេចលិច្ឆវីទតឃើញប្រេតនោះហើយ មានព្រះហឫទ័យចង់ដឹងហេតុទើបយាងទៅជិតសួរប្រេតថា:

-អ្នកទោសនេះត្រូវជាអ្វីនឹងអ្នក ?

បពិត្រព្រះរាជា បុរសនេះកាលពីជាតិមុនជាញាតិរបស់ខ្ញុំ ។

-ចុះហេតុអ្វីអ្នកនិយាយប្រាប់អ្នកទោសថា ចូរអ្នករស់ចុះព្រោះការរស់នៅរបស់អ្នកប្រសើរជាងស្លាប់ ?

បពិត្រព្រះរាជា អ្នកទោសនេះជាអ្នកធ្វើអាក្រក់កាលបើស្លាប់ហើយនឹងកើតក្នុងនរកមិនខាន ព្រោះសេចក្ដីទុក្ខក្នុងនរក ខ្លាំងក្លាជាងការឈឺចាប់ដោយឈើអណ្ដោតនោះឆ្ងាយណាស់ ។ ម្យ៉ាងទៀតបើបានរស់នៅបានរួចទោស ហើយ

[26] ប្រជុំនិទានជាតក ភាគ៦ទំព័រ ៩៤៩

ធ្វើបុណ្យទានតាមខ្ញុំលះបង់អំពើអាក្រក់ចេញ និងមានប្រយោជន៍ច្រើន ។

-យើងយល់ហើយចង់សួររឿងអ្នកទៀត បើអ្នកមិនបើកឱកាសទេយើងក៏មិនហ៊ានសួរដែរ ។

បពិត្រព្រះរាជាខ្ញុំបានប្ដេជ្ញាថា មិនប្រាប់រឿងខ្ញុំដល់អ្នកដែលមិនជ្រះថ្លានឹងគ្នា មិនជឿពាក្យសម្ដីគ្នាឡើយ បើព្រះអង្គមានជំនឿហើយសួរខ្ញុំមកចុះ ។

-យើងចង់សួរអំពីសេះស ជាយានជំនិះល្អអស្ចារ្យគួរឲ្យរមិលមើលរបស់អ្នកនេះ តើអ្នកបានមកដោយផលនៃកម្មអ្វី?

បពិត្រមហារាជ កាលមុនក្នុងក្រុងវេសាលីនេះមានជង្ហុកមួយ ទឹកភក់ដក់នៅរអិលដើរបានដោយលំបាក ថ្ងៃមួយខ្ញុំមានចិត្តជ្រះថ្លា បានយកឆ្អឹងក្បាលគោទៅដាក់ធ្វើជាស្ពានសម្រាប់មហាជនដើរឆ្លងជង្ហុកនោះ ។ ឯសេះសជាយានជំនិះ ល្អអស្ចារ្យរបស់ខ្ញុំនេះ កើតឡើងដោយផលនៃកម្មនេះឯង ។

-អើ! យើងចង់សួរទៀតថា អ្នកមានសម្បុរភ្លឺផ្សាយ ទៅសព្វទិស អ្នកមានក្លិនល្អផ្សាយទៅសព្វទិស អ្នកមានឫទ្ធិ មានអានុភាពច្រើនតែជាអ្នកអាក្រាតកាយទទេ តើការចម្លែកទាំងអស់នេះជាផលនៃកម្មអ្វី?

បពិត្រព្រះរាជា កាលពីមុនខ្ញុំជាមនុស្សមិនក្រោធមានចិត្តជ្រះថ្លាជានិច្ចនិយាយប្រាស្រ័យជាមួយជនដទៃ ដោយពាក្យពីរោះផ្អែមល្ហែមកម្មនេះឯងបញ្ចេញផលឲ្យខ្ញុំមានសម្បុរល្អជានិច្ចដូចសម្បុរទិព្វ ។ មួយទៀតខ្ញុំបានឃើញយសសក្តិនិងកេរ្តិ៍ឈ្មោះរបស់ពួកជន តាំងនៅក្នុងធម៌ ក៏មានចិត្តជ្រះថ្លា ហើយប្រឹក្សាជាមួយកម្មនេះឯងបញ្ចេញផលឲ្យ មានក្លិនល្អដូចជាក្លិនទិព្វ ផ្សព្វផ្សាយទៅជានិច្ចមួយទៀតខ្ញុំ បានយកសំពត់ពួកសម្លាញ់ កំពុងងូតទឹកក្នុងកំពង់លាក់លេងសប្បាយ ធ្វើឲ្យគេអាក្រាតកាយគ្រប់គ្នា ប៉ុន្តែខ្ញុំឥតមានចិត្តប្រទូស្តឡើយ កម្មនេះឯងបញ្ចេញផលឲ្យខ្ញុំអាក្រាតកាយទទេ និងឲ្យមានការបិញ្ជឹមជីវិត យ៉ាងលំបាកពន់ពេក ។

ស្តេចលិច្ឆវីបានទ្រង់ព្រះសណ្តាប់ បុព្វកម្មរបស់ប្រេតដូច្នេះហើយក៏ព្រះអង្គមិនទាន់ជឿបុណ្យបាបច្បាស់លាស់ដែរ ទើបសួរប្រេតទៀតថាៈ

-បើបុគ្គលឈប់ធ្វើបាបហើយ និងបុគ្គលមិនឈប់ធ្វើបាបទេ តើអ្នកប្រាជ្ញាទាំងឡាយបានសំដែងនូវផលនៃកម្មនោះដូចម្តេច?

បពិត្រព្រះរាជា បើពួកមនុស្សណាមានចិត្តប្រទូស្តហើយសៅហ្មងដោយកាយ និងវាចាមនុស្សនោះលុះស្លាប់ទៅពិតជាកើតក្នុងនរក ។ ចំណែកពួកមនុស្សដែលត្រេកអរក្នុងទាន ជាអ្នកសង្គ្រោះគេ លុះស្លាប់ពិតជាទៅកើតក្នុង សុគតិឥតមានឃ្លាតឡើយ ។

-អើ! យើងបានពិចារណាហើយនេះជាផលនៃកល្យាណកម្ម និងបាបកម្មទេតើនរណាអាចធ្វើឲ្យខ្ញុំជឿពាក្យនោះបាន ។

បពិត្រព្រះរាជា ព្រះអង្គទតឃើញហើយសូមជឿចុះ បើគ្មានផលនៃកល្យាណកម្ម និងបាបកម្មនោះទេនរកសួគ៌ក៏គ្មាន ។ អាស្រ័យហេតុនេះឯងទើបមនុស្សសត្វ ដែលបានធ្វើកម្មទាំងពីរនោះ មានសុខមានទុក្ខមានឋានៈខ្ពស់ទាប ល្អអាក្រក់ខុសៗគ្នា ។ ចំពោះរូបខ្ញុំបុញ្ញកម្មដែលធ្វើដោយខ្លួនឯងក៏មិនមាន អ្នកឲ្យគ្រឿងស្លៀកពាក់ទីដេក ទីអង្គុយ បាយ ទឹកហើយ ឧទ្ទិសផលចំពោះខ្ញុំក៏មិនមានដែរ បានជាខ្ញុំមានកាយអាក្រាត មានការចិញ្ចឹម ជីវិតយ៉ាងលំបាកបំផុត ។

-នែប្រេត! យើងចង់ជួយអ្នកឲ្យមានគ្រឿងស្លៀកពាក់ តើឲ្យយើងជួយបែបណាទើបអ្នកទទួលបាន?

បពិត្រព្រះរាជា ក្នុងក្រុងវេសាលីនេះ មានភិក្ខុមួយអង្គឈ្មោះកប្បិតកៈជាអ្នកមានឈាន មានសីលល្អជាព្រះអរហន្តជាបុញ្ញក្ខេត្តជាទក្ខិណេយ្យបុគ្គលរបស់ទេវតា និងមនុស្សទាំងឡាយ លោកជាបុគ្គលគួរបូជា ។ បើព្រះអង្គប្រគេនសំពត់មួយគូក្តី ពីរគូក្តីចំពោះព្រះថេរៈនោះឧទ្ទិសឲ្យខ្ញុំ ខ្ញុំនឹងបានសំពត់ដែលលោកទទួលហើយនោះផងព្រះអង្គនឹងបានទតឃើញខ្ញុំស្លៀកសំពត់នោះផង។

-អើ! ឥឡូវនេះយើងទៅជួបសមណៈនោះ ដើម្បីបន្ទោបង់នូវសេចក្តីសង្ស័យផង នូវការយល់ខុសផង ដែលជាសត្រូវរបស់យើងក្នុងថ្ងៃនេះបានឬទេ?

បពិត្រព្រះរាជា សមណៈនោះគង់នៅឯប្រទេសឈ្មោះគេបិនចូនាមានពួកទេវតាចោមរោមច្រើន លោកមាននាមថាសច្ចៈ ជាអ្នកមិនប្រមាទកំពុងសម្តែងធម្មកថា ព្រះអង្គកុំអាលយាងទៅ ។

-ព្រះរាជាលិច្ឆវីទ្រង់ព្រះសណ្តាប់ហើយ ក៏យាងចូលទៅព្រះរាជវាំងរបស់ព្រះអង្គវិញ ដើម្បីបំពេញរាជកិច្ចផ្សេងៗ លុះបំពេញរាជកិច្ចហើយបានជ្រើសរើសយកសំពត់៨គូ ឲ្យទាសាកាន់តាមយាងទៅទីដែលសមណៈគង់នៅបានទតឃើញលោកគង់នៅក្រោមម្លប់ឈើ ក៏ថ្វាយបង្គំមានព្រះបន្ទូលរាក់ទាក់ប្រកាសនាមថា ខ្ញុំជាសេចលិច្ឆវីឈ្មោះអម្ពសក្ខរៈ សូមលោកម្ចាស់ទទួលយកសំពត់ទាំង៨គូរបស់ខ្ញុំព្រះករុណា ខ្ញុំមកទីនេះក៏ព្រោះប្រយោជន៍នេះឯង គួរឲ្យខ្ញុំមានចិត្តត្រេកអរផង ។

ព្រះថេរតបថា ពួកសមណៈតែងជៀសវាង នូវព្រះរាជនិវេសន៍របស់ព្រះអង្គ ព្រោះព្រះអង្គបានធ្វើបាប វាយទាត់ជាក់សមណៈ ឲ្យដេកដួលសំយុងក្បាលចុះ បែកបាត្រហែកស្បង់ចីវរ ។ ព្រះអង្គជាអ្នកកំណាញ់មិនដែលឲ្យប្រេងប៉ុនចុងស្បូវដល់អ្នកណាឡើយ ព្រះអង្គច្រើនតែប្រើអាជ្ញាអន្ធពាល ។ តើព្រះអង្គឃើញហេតុអ្វី បានជាធ្វើនូវការចែករំលែកជាមួយអាត្មាដូច្នេះ ។

-បពិត្រលោកម្ចាស់ ខ្ញុំប្រព្រឹត្តដូច្នោះមែន ព្រោះខ្ញុំជាអ្នកចូលចិត្តលេងច្រើន មិនមែនធ្វើដោយចិត្តប្រទូស្តឡើយ ខ្ញុំធ្វើអំពើអាក្រក់មែនហើយ ពួកជនទាំងឡាយតែងទទួលទុក្ខព្រោះតែសន្សំបាបដោយការលេងនេះឯង ខ្ញុំបានឃើញប្រេតអាក្រាត ព្រោះតែការលេងនេះដែរ សូមលោកម្ចាស់ទទួលសំពត់ទាំង៨គូនេះចុះ ទក្ខិណាទាននេះសូមឲ្យបានសម្រេចផលដល់ប្រេតអាក្រាតនោះផង ។

សាធុ! ការមិនចេះអស់ ចូរមានចំពោះព្រះអង្គការឲ្យទានព្រះពុទ្ធទាំងឡាយទ្រង់សរសើរដោយប្រការដ៏ច្រើន អាត្មានឹងទទួលសំពត់របស់ព្រះអង្គទាំង៨គូ សូមទក្ខិណាទានសម្រេចដល់ប្រេតចុះ ។ ក្នុងពេលដែលព្រះថេរៈទទួល សំពត់ហើយ ស្តេចលិច្ឆវីបានទតឃើញប្រេតស្លៀកដណ្តប់សំពត់ ផ្ទាល់ព្រះនេត្រ ទតឃើញខ្លួនប្រេតនោះលាបដោយលំអិតខ្លឹមចន្ទន៍ មានរូបឆោមស្រស់ មានគ្រឿងប្រដាប់តែងកាយគ្រប់សព្វ មានបរិស័ទចោមរោមបានឡើងជិះសេះស ប្រកបដោយអានុភាពធំ លុះទតឃើញដូច្នេះហើយ ព្រះអង្គមានបីតិសោមនស្សមានព្រះទ័យត្រេកអរខ្ពស់អណ្តែតឡើង យល់ច្បាស់នូវកម្មផលបុណ្យបាប ទើបយាងទៅរកប្រេតនោះ មានព្រះបន្ទូលថា យើងនឹងឲ្យទានអ្វីៗបន្តិចបន្តួច ក៏យើងឲ្យទានដែរ អ្នកមានឧបការគុណចំពោះយើងច្រើនណាស់ ។

-ប្រេតតបថា បពិត្រព្រះរាជាព្រះអង្គបានឲ្យទានទាំងឡាយចំពោះតែបច្ច័យមួយ ការឲ្យទាននេះមិនមែនសោះសូន្យឡើយ ខ្ញុំជាអមនុស្សធ្វើជាសាក្សីជាមួយព្រះអង្គជាមនុស្ស ។

ស្តេចលិច្ឆវីតបថាប្រពៃណាស់ អ្នកជាគតិជាផៅពង្សជាអ្នកនាំមុខជាមិត្រសម្លាញ់ និងជាទេវតារបស់យើងៗ សូមលើកអញ្ជលីប្រណម្យចំពោះអ្នក យើងចង់ឃើញអ្នកទៀត ។

-ប្រេតទូលថា បើព្រះអង្គមានសទ្ធាគោរពក្នុងធម៌ ត្រេកអរ្រ្េងទានមានអត្តភាពជាអ្នកសង្គ្រោះ ជាអណ្តូងរបស់សមណៈព្រាហ្មណ៍យ៉ាងនេះ ទើបព្រះអង្គអាចឃើញខ្ញុំបាន ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គដោះលែងអ្នកទោសពីឈើអណ្តោតឲ្យឆាប់ផង ដើម្បីគ្នាបានប្រព្រឹត្តធម៌បានរួចពីនរកលុះដោះលែងបុរសនោះហើយ សូមព្រះអង្គយាងទៅរកកប្បិតកភិក្ខុចាត់ចែងថ្វាយទានទ្រង់ព្រះសណ្តាប់នូវធម្មកថារបស់លោកកុំខាន ។

ស្តេចលិច្ឆវី បានដោះលែងនូវបុរសជាប់ឈើអណ្តោត និងអ្នកទោសដទៃទៀតដែលគួរដោះលែងបាន ។ ព្រះអង្គប្រាប់បុរសជាប់ឈើអណ្តោតថា នែសម្លាញ់អ្នកកុំភ័យ យើងនឹងប្រគល់ខ្លួនអ្នកឲ្យពេទ្យថែរក្សាបានឆាប់សះជា ។ មានបន្ទូលដូច្នេះហើយ ក៏យាងទៅរកកប្បិតកភិក្ខុ បានចាត់ចែងភោជនាហារក្នុងកាលដ៏គួរហើយចូលទៅគង់ជិតព្រះថេរៈស្តាប់ធម្មកថា មានព្រះទ័យជ្រះថ្លាថ្វាយខ្លួនចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹក បានសមាទាននូវសីល៥ និងសមាទាននូវឧបោសថសីលតាមកាល ។

ពួកឧបាសកឧបាសិកាក្នុងក្រុងវេសាលី មានសេចក្តីត្រេកអរដោយបានដឹងថា ស្តេចលិច្ឆវីព្រះនាមអម្ពសក្ខរៈ ជាឧបាសកប្រាកដដូច្នោះ ជាអ្នកមានសទ្ធាមានចិត្តទន់ភ្លន់ ជាអ្នកទំនុកបម្រុងភិក្ខុសង្ឃដោយគោរព ឈប់បៀតបៀនភិក្ខុសង្ឃទៀតហើយ ។

ចំណែកបុរសដែលជាប់ឈើអណ្តោតនោះ បានសះជាមុខរបួសហើយ ក៏ចូលទៅបួសក្នុងសំណាក់ព្រះថេរៈកប្បិតក ខំចម្រើនសមណធម៌ក៏បានសម្រេចមគ្គផលជាន់ខ្ពស់ ។

ឯស្តេចលិច្ឆវីព្រះនាមអម្ពសក្ខរៈ បានសម្រេចសោតាបត្តិផលក្នុងពេលស្តាប់ធម្មកថារបស់ព្រះថេរកប្បិតកនោះឯង ។

ចំណែកខាងប្រេតនោះ បានសោយនូវសម្បត្តិទិព្វគ្រប់យ៉ាងដូចជា ពួកទេវតាទាំងឡាយក្នុងឋានសួគ៌ដែរ ។

## ២៥. រឿងសានុវាសីប្រេត[27]

(ទៅកើតជាប្រេត ព្រោះមិនបានធ្វើបុណ្យ)

សម័យមួយព្រះថេរៈឈ្មោះបោដ្ឋបាទ ជាអរិយសាវ័កនៅអាស្រ័យលើភ្នំឈ្មោះ សានុវាសី នាក្រុងកុណ្ឌី មាតាបិតារបស់លោកបានកើតជាប្រេត មានមាត់តូចប៉ុនរន្ធក្តិតម្ជុល ស៊ីចំណីអាហារ ផឹកទឹកមិនបានរងទុក្ខវេទនាដោយ

[27] ប្រជុំនិទានជាតក ភាគ៧ទំព័រ ១០១៧

ការស្រេកឃ្លានយ៉ាងក្រៃលែង មានកាយស្គមកំព្រឹងអាក្រាតខ្លួនទទេ ឃើញសុទ្ធតែឆ្អឹង មានសេចក្តីភ័យតក់ស្លុតរន្ធត់ញាប់ញ័រជានិច្ចមិនហ៊ានបង្ហាញខ្លួនឲ្យគេឃើញឡើយ ។ ឯបងប្រុសរបស់ព្រះថេរៈនោះ ក៏កើតជាប្រេតអាក្រាតដែរនៅក្នុងច្រកព្រៃតែម្នាក់ឯង ជាប្រេតវារលូនលើផែនដី ។ គឺចង់ទៅទីណាៗទៅបានដោយឥរិយាបថវារ ។

ថ្ងៃមួយព្រះថេរៈនិមន្តដើរកាត់ព្រៃ ដែលប្រេតនោះនៅប្រេតជាបង ក៏ខំវារតាមព្រះថេរៈ បង្ហាញខ្លួនឲ្យឃើញ ព្រះថេរៈមិនបានឃើញនិមន្តហួសទៅប្រេតនោះខំស្រែកថា លោកម្ចាស់ៗខ្ញុំជាបងរបស់លោក បានមកកើតជាប្រេតឯមាតាបិតារបស់លោកក៏មកកើតជាប្រេតដែរ ព្រោះមិនបានធ្វើបុណ្យទាន ក្នុងជាតិមុនលោកជាអ្នកមានបុណ្យ មានចិត្តអាណិតអាសូរ សូមអនុគ្រោះឲ្យទានឧទ្ទិសផលចំពោះខ្ញុំ និងមាតាបិតាលោកផង ។

បោដ្ឋបាទត្ថេរ បានឃើញបានជ្រាប នូវសេចក្តីទុក្ខវេទនារបស់ប្រេតទាំងបីនោះហើយ ក៏និមន្តទៅបិណ្ឌបាតជាមួយនឹងភិក្ខុ១២អង្គ លុះត្រឡប់មកវិញបានប្រជុំគ្នាក្នុងទីមួយ ព្រះថេរៈសុំចំណីអាហារខ្លះអំពីភិក្ខុទាំង១២អង្គ នោះធ្វើសង្ឃទានឧទ្ទិសផលចំពោះប្រេតទាំងបីរូបៗ ក៏បានចំណីអាហារទិព្វបរិបូណ៌មានកម្លាំងមានសម្បុរល្អបានសេចក្តីសុខ ហើយប្រេតជាបងបង្ហាញខ្លួនឲ្យព្រះថេរៈឃើញនិយាយសុំសំលៀកបំពាក់ទៀត ។

ព្រះថេរៈ បានរើសកំណាត់ទាំងឡាយពីគំនរសំរាមមកធ្វើចីវរ ហើយប្រគេនដល់សង្ឃ ឧទ្ទិសផលចំពោះប្រេតទាំងបីៗ ក៏បានសំពត់ទិព្វប្រើប្រាស់គ្រប់ៗគ្នា ។ ប្រេតជាបងបានបង្ហាញខ្លួនឲ្យព្រះថេរៈឃើញ ហើយសុំផ្ទះនៅទៀត ។ ព្រះថេរៈបានធ្វើកុដិប្រក់ស្លឹក ហើយប្រគេនដល់សង្ឃ ដែលនិមន្តមកពីទិសទាំង៤ ឧទ្ទិសផលចំពោះប្រេតទាំងបីៗ ក៏បានប្រាសាទទិព្វនៅជាសុខក្សេមក្សាន្ត ហើយបានសុំទឹកសម្រាប់ផឹកទៀត ។

ព្រះថេរៈ បានចាក់ទឹកបំពេញធម្មក្រក (បំពង់ទឹក) ហើយប្រគេនដល់សង្ឃ ឧទ្ទិសផលចំពោះប្រេតទាំងបីៗ ក៏បានស្រះបោក្ខរណីទិព្វកើតឡើងមានទឹកត្រជាក់ មានកំពង់ល្អសម្រាប់ចុះងូតដេរដាសដោយផ្កាឈូកមានក្លិនក្រអូប ។

ប្រេតទាំងនោះ បានបង្ហាញខ្លួនចំពោះ ព្រះថេរៈ ហើយនិយាយថា ពួកយើងបានចំណីអាហារបានសំពត់ បានប្រាសាទ បានស្រះបោក្ខរណី សុទ្ធតែរបស់ទិព្វប្រើប្រាស់ហើយ ប៉ុន្តែជើងទាំងឡាយរបស់យើងឈឺពុរពងដោយគ្រួស និងបន្លាសូមលោកម្ចាស់ឲ្យនូវយានជំនិះចំពោះពួកយើងផង ។

ព្រះថេរៈ បានប្រគេនស្បែកជើងដល់សង្ឃ ហើយឧទ្ទិសផលចំពោះប្រេតទាំងបីៗ ក៏បានរាជរថទិព្វជិះទៀត ទើបនាំគ្នាជិះរាជរថទៅថ្វាយបង្គំថ្លែងអំណរគុណព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកយើងមកដើម្បីថ្វាយបង្គំលោកជាអ្នកប្រាជ្ញប្រកបដោយសេចក្តីករុណាក្នុងលោក ថាដូច្នោះហើយក៏បាត់អំពីនោះទៅ ។[28]

## ២៦. រឿងព្រះបាទបិង្គលកៈ និងប្រេត[29]

(ទោសជេរប្រទេចផ្តាសាសមណព្រាហ្មណ៍អ្នកបួស)

សម័យក្រោយពុទ្ធកាល មានព្រះរាជាមួយព្រះអង្គព្រះនាម បិង្គលកៈជាស្តេចក្នុងសុរដ្ឋប្រទេស ស្តេចទៅគាល់ព្រះបាទធម្មាសោកជាស្តេចចុល្លចក្រ ។ លុះត្រឡប់មកវិញ ស្តេចយាងកាត់កក់កណ្តាលថ្ងៃត្រង់ កំពុងតែយាងស្រាប់តែបានទតឃើញផ្លូវថ្នល់យ៉ាងល្អ ដែលប្រេតនិម្មិតថ្វាយ ប៉ុន្តែព្រះរាជាមិនជ្រាប ស្តេចមានបន្ទូលទៅកាន់ពួកចតុរង្គសេនាថា នែអ្នករាល់គ្នាយើងធ្វើដំណើរតាមផ្លូវល្អនេះវិញ ទើបឆាប់បានដល់ប្រទេសយើង ។ ព្រះរាជាក៏នាំពលសេនាយាងតាមផ្លូវនោះទៅ ។

---

[28] បានកើតជាមនុស្សព្រោះបុណ្យ ខ្វះបុណ្យមិនអាចបានកើតជាមនុស្សនុ៎ះទេ ! ច្រាកដជាទៅកើតជាប្រេត បើតាមរឿងនេះ ។

[29] ប្រជុំនិទានជាតក ភាគ៧ទំព័រ ១១៣៤

ពេលនោះពួកពលសេនាព្រឺរោមព្រឺស្បែកគ្រប់ៗគ្នា បានក្រឡេកមើលគ្រប់ទិស នាយសេនាម្នាក់ដែលមានការតក់ស្លុតជាងគេបាន ក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជ យើងធ្វើដំណើរតាមនេះមិនស្រួលទេ មានសភាពតក់ស្លុតណាស់ មើលទៅខាងមុខឃើញផ្លូវដល់ក្រឡេកមើលក្រោយវិញមិនឃើញផ្លូវដែលយើងមកសោះ ។ ម្យ៉ាងទៀតមានក្លិនប្លែកបក់មកទាំងមានសំឡេងគិកកងគួរឲ្យភ័យខ្លាចផង ។

ព្រះរាជាទ្រង់មានសេចក្តីតក់ស្លុតដែរ ទើបត្រាស់ប្រាប់នាយសារថីថា យើងដើរពារផ្លូវមិនស្រួលហើយ បានជាពួកយើងមានចិត្តតក់ស្លុត ព្រឺរោម ព្រឺស្បែកចម្លែកជុំក្លិនអាក្រក់ ឮសំឡេងគឹកកងគួរឲ្យខ្លាចយ៉ាងនេះ ។ មានព្រះបន្ទូលហើយ ក៏ឡើងលើខ្នងដំរីទតមើលគ្រប់ទិសទាំង៤បានឃើញដើមជ្រៃធំមួយមានស្លឹកខៀវស្រងាត់ក៏នាំចតុរង្គសេនាយាងសំដៅដើមជ្រៃធំនោះ។

ថ្លែងពីប្រេតឈ្មោះនន្ទិកា ដែលនៅអាស្រ័យដើមជ្រៃនោះ បាននិម្មិតខ្លួនជាទេវតា ស្អិតស្អាងគ្រឿងអាភរណៈទាំងពួងមានរូបកាយល្អស្រស់ ចូលទៅរកព្រះរាជា ហើយនិយាយថា បពិត្រមហារាជ ស្តេចយាងមកនេះល្អហើយ សូមទ្រង់សោយនូវរសុទ្ធិរសទឹកមានរសឆ្ងាញ់ និងនំទាំងឡាយដែលទូលបង្គំរៀបថ្វាយនេះសិនសឹមបន្តព្រះរាជដំណើរទៅមុខទៀត ។

ព្រះរាជា និងពួកពលសេនា បានសោយ និងបរិភោគនូវរសុទ្ធិរស និងនំទិព្វឆ្អែតស្កប់ស្កល់ហើយ ត្រាស់សួរប្រេតថា អ្នកជាទេវតា ឬជាគន្ធព្វ ឬជាព្រះឥន្ទចូរអ្នកប្រាប់យើងឲ្យបានដឹងផង ។

បពិត្រមហារាជ ខ្ញុំមិនមែនទេវតា មិនមែនគន្ធព្វ មិនមែនជាព្រះឥន្ទទេខ្ញុំជាប្រេតឈ្មោះនន្ទិកាមកនៅក្នុងទីនេះ ។

អើហ្ន! អ្នកមានអានុភាពច្រើន មានចំណីអាហារទិព្វ តើអ្នកមានសីលមានសមាចារៈ ដូចម្តេច? អ្នកបានប្រព្រឹត្តធម៌ដ៏ប្រសើរដូចម្តេចខ្លះ?

បពិត្រមហារាជ ជាស្តេចចម្រើនក្នុងដែនសុរដ្ឋប្រទេស សូមព្រះអង្គព្រមទាំងពួកអាមាត្យ និងព្រាហ្មណ៍បុរោហិត ទ្រង់ព្រះសណ្តាប់ និងស្តាប់ពាក្យរបស់ខ្ញុំចុះ ។ ពីដើមខ្ញុំនៅក្នុងសុរដ្ឋប្រទេសនោះដែរ ជាបុរសមានចិត្តអាក្រក់ ជាមិច្ឆាទិដ្ឋិទ្រុស្តសីល កំណាញ់ប្រទេចផ្តាសា សមណព្រាហ្មណ៍ ។ លុះខ្ញុំស្លាប់ហើយបានទៅកើតក្នុងអវិចីនរក ដែលមានភ្លើងឆេះរន្ទាលច្រាលផ្តៅក្តៅក្រហាយក្រៃលែង ។ នរកនោះមានកំពែងដែកព័ទ្ធជុំវិញ មានគម្របដែក កំដៅក្នុងនរកនោះខ្លាំងណាស់ ផ្សាយចេញមកក្រៅចំនួន១រយយោជន៍ជុំវិញ ។ ខ្ញុំឆេះក្នុងនរកនោះអស់កាលយូរអង្វែង ដោយផលនៃបាបកម្មនោះឯង ។ សេសល់ផលកម្មនោះ បានមកកើតជាប្រេតក្នុងកាលឥឡូវនេះ ។ ខ្ញុំមានកូនស្រីម្នាក់បានមកកើតជានាងឧត្តរា ជាឧបាសិការបស់ព្រះសក្យមុនីសម្ពុទ្ធ ជាអ្នកមានសីល មានសទ្ធាត្រេកអរក្នុងទាន មិនកំណាញ់បានប្រគេននូវទឹកសម្រាប់ផឹក និងនំទាំងឡាយចំពោះភិក្ខុសង្ឃ មានសីលបរិសុទ្ធ ហើយឧទ្ទិសផលថា សូមផលនៃទាននេះសម្រេចដល់បិតារបស់ខ្ញុំ ដែលចែកឋានហើយ ។ ផលក៏សម្រេចដល់ខ្ញុំជាលំដាប់គ្រប់ពេលដែលនាងឧទ្ទិស ខ្ញុំបានសម្បត្តិទិព្វតាមប្រាថ្នាដូចជាស្តេចវេស្សវ័ណ ។

អាស្រ័យហេតុនេះ សូមមហារាជ ព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹកផង សូមព្រះអង្គវៀរនូវបញ្ចវេរទាំង៥ផង ។

ព្រះរាជតបថា ម្នាលប្រេតដូចជាទេវតា អ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ចំពោះយើង យើងធ្វើតាមពាក្យរបស់អ្នកហើយ អ្នកជាអាចារ្យរបស់យើង យើងសូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរល័កផង វៀរចាកនូវបញ្ចវេរទាំង៥ផង ។ លុះពោលវាចានេះ ព្រះរាជាប្តេជ្ញាចំពោះមុខប្រេតនន្ទិកាថា:

**បាណាតិបាតា វិរមាមិ ខិប្បំ**
**លោកេ អទិន្នំ បរិវជ្ជយាមិ**

**អមជ្ជបោ នោ ច មុសា ភណាមិ**
**សកេន ទារេន ហោមិ តុដ្ឋោ ។**
**និថុនាភិ មហាវាតេ**
**នទិយា វា សីឃគាមិយា**
**វមាមិ បាបកំ ទិដ្ឋិ**
**ពុទ្ធានំ សាសនេ រតោ ។**

យើងវៀរចាកបាណាតិបាត យ៉ាងដាច់រហ័ស យើងលះបង់ការកាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងលោក យើងលែងផឹកទឹកស្រវឹង លែងនិយាយកុហក យើងជាអ្នកត្រេកអរ តែនឹងប្រពន្ធរបស់ខ្លួន ៗ ម្នាលប្រេត យើងត្រេកអរក្នុងសាសនារបស់ព្រះពុទ្ធទាំងឡាយ ប្វាចនូវទិដ្ឋិអាក្រក់ចោលដូចជាអង្កាមក្នុងទីមានខ្យល់ធំផង បន្សាត់ចោលនូវទិដ្ឋិអាក្រក់ ដូចសំរាមក្នុងទន្លេមានខ្សែទឹករហ័សផង ៗ

ព្រះបាទបិម្ពិសារ: មានព្រះរាជឱង្ការដូច្នេះហើយ ក៏លើកព្រះហស្តប្រណមថ្វាយបង្គំ ឧទ្ទិសចំពោះព្រះមានព្រះភាគអរហន្តសម្ពុទ្ធ ហើយលាប្រេតយាងគង់លើភជរថជៀសចេញទៅ ។

## ២៧. រឿងមាតាព្រះសារីបុត្តកើតជាប្រេត[30]

ព្រះសារីបុត្តសួរថា ម្នាលស្រីស្គម មានឆ្អឹងជំនីរគាម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ពេកក្រៃ មានខ្លួនស្គាំងស្គម មានខ្លួនរវាមទៅដោយសរសៃ នាងជាអ្វីមកឈរនៅទីនេះ ?

នាងប្រេតតបថា អំពីមុនខ្ញុំជាមាតាបង្កើតរបស់លោក ក្នុងជាតិទាំងឡាយដទៃមកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្តីស្រេកឃ្លាន បរិភោគទឹកមាត់ដែលគេស្តោះចោល ទឹកសម្បោរ ស្លេស្ម ខ្លាញ់រាវនៃសាកសព ដែល

---

[30] នានាធម្មសមុហោ ទំព័រ ៧០

គេដុត និងឈាមនៃស្រីទាំងឡាយដែលសម្រាលកូន និងឈាមនៃដំបៅច្រមុះ និងក្បាលដាច់ មានសេចក្ដីស្រេកឃ្លានគ្របសង្កត់ ខ្ញុំបរិភោគនូវខ្ទុះ និងឈាមដែលជាប់នឹងសរីរៈនៃបុរសស្ត្រី នូវខ្ទុះ និងឈាមនៃបសុសត្វ និងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីលំនៅ ដេកតែលើទីស្មសានដូចគ្រែលោកម្ចាស់ជាបុត្ត សូមលោកម្ចាស់ឲ្យទានដើម្បីខ្ញុំ លុះឲ្យហើយចូរឧទ្ទិសផលដល់ខ្ញុំគិតធ្វើដូចម្ដេចហ្ន៎ឲ្យខ្ញុំគប្បីបានរួចចាកការបរិភោគនូវខ្ទុះ និងឈាមផង។

ព្រះអគ្គសាវ័ក មាននាមថា ឧបតិស្សៈ[31] លុះបានស្ដាប់ពាក្យនៃនាងប្រេតជាមាតាហើយ មានចិត្តប្រកបដោយករុណា បានហៅព្រះមោគ្គល្លានមួយ ព្រះអនុរុទ្ធមួយ ព្រះកប្បិនមួយ ឲ្យធ្វើកុដិទាំងឡាយបួនខ្នង ហើយវេកុដិផងឲ្យបាយ និងទឹកផងចំពោះសង្ឃដែលមកអំពីទិសទាំងបួន ហើយឧទ្ទិសទក្ខិណាទានដល់មាតា ។ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិស ហើយភោជនាហារ ទឹកផឹក និងសំពត់ ក៏កើតឡើងដល់ប្រេតជាមាតានោះ ស្រីនោះមានរូបស្អាត មានសំពត់ស្លៀកពាក់ស្អាតបាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសីមានគ្រឿងវត្ថាភរណៈដ៏វិចិត្របានចូលទៅរកព្រះកោលិត ។

ព្រះកោលិតសួរថា ម្នាលនាងទេវធីតា នាងមានសម្បុរល្អមកឈរនៅទីនេះភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹកឯសម្បុរប្រាកដដូច្នោះកើតឡើងដល់នាង ដោយហេតុដូចម្ដេច ផលនៃសុចរិតសម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្ដេចបានជាភោគៈណានីមួយដែលជាទីពេញចិត្តកើតឡើងដល់នាង ?

ម្នាលនាងទេវធីតា មានអានុភាពច្រើនយើងសូមសួរនាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្ដេច នាងជាទេវធីតាមានអានុភាពភ្លឺផ្លេកយ៉ាងនេះ ទាំងសម្បុរនាងក៏ភ្លឺសព្វទិសដោយបុញ្ញកម្មដូចម្ដេច ?

---

[31] *ព្រះសារីបុត្ត មាននាមថា ឧបតិស្សៈ ។*

ប្រេតតបថា អំពីមុនខ្ញុំជាមាតារបស់ព្រះសារីបុត្ត ក្នុងជាតិទាំងឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ដេកតែលើទីស្មសានដូចគ្រែ ។ ខ្ញុំបានត្រេកអរ ដោយទាននៃព្រះសារីបុត្ត (គឺអនុមោទនា) ទើបមិនមានភ័យក្នុងទីណាៗ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមកដើម្បីថ្វាយបង្គំលោកជាអ្នកប្រាជ្ញប្រកបដោយសេចក្តីករុណាក្នុងលោក ។

## ២៨. រឿងនាងមត្តាប្រេត[32]

១. នាងតិស្សាសួរថា ម្នាលស្រីស្គមមានឆ្អឹងជំនីរគាម នាងជាស្រីមានកាយអាក្រាត មានរូបអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គមមានខ្លួនរវាមដោយសរសៃ នាងជាអ្វីបានជាមកឈរនៅក្នុងទីនេះ ។

២. នាងមត្តាប្រេតប្រាប់ថា កាលពីមុននាងឯងឈ្មោះតិស្សាខ្ញុំឈ្មោះមត្តា ជាស្រីរួមប្តីរបស់នាង បានធ្វើអំពើបាប ទើបបានឃ្លាតអំពីមនុស្សលោកនេះទៅកាន់បេតលោក ។

៣. តិ, ចុះអំពើអាក្រក់ ដែលនាងបានធ្វើហើយ ដោយកាយវាចាចិត្តនោះ តើដូចម្តេចនាងឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ព្រោះវិបាកនៃកម្មដូចម្តេច?

៤. ម, ខ្ញុំជាស្រីកាចឆ្នាស់ បានពោលផរុសវាទ ជាស្រីឫស្យា កំណាញ់អួតអាង ខ្ញុំនោះបានពោលពាក្យអាក្រក់ ទើបបានឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

៥. តិ, ពិតមែនហើយ យើងបានដឹងថា នាងជាស្រីឆ្នាស់ យើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងមានខ្លួនប្រាណប្រឡាក់ដោយអាចម៍ដីព្រោះកម្មដូចម្តេច?

៦. ម, នាងបានលុបលាងក្បាលរួចហើយ មានសំពត់ដ៏ស្អាតប្រដាប់ហើយខ្លួនយើងសោត ក៏ប្រដាក់តាក់តែងដោយគ្រឿងអលង្ការដ៏ក្រៃលែងជាង

[32] នានាធម្មសម្មុហោទំព័រ ៧២

នាង កាលខ្ញុំនោះកំពុងសម្លឹងមើល នាងក៏ពោលចរចានឹងស្វាមី ក្នុងលំដាប់នោះ ខ្ញុំមានចិត្តឬស្សាពេកណាស់ សេចក្ដីក្រោធកើតឡើងតអំពីនោះ ខ្ញុំក៏ប្រវាយក អាចម៍ដីទៅពោយដាក់នាង ព្រោះហេតុនោះ ខ្ញុំទើបមានខ្លួនប្រឡាក់ដោយ អាចម៍ដី ព្រោះវិបាកនៃកម្មនោះឯង ។

៧. តិ, ពិតមែនហើយ តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាង ត្រូវពោគកមរមាស់បៀតបៀនដោយកម្មអ្វី?

៨. ម, យើងទាំងពីរនាក់ បានចូលទៅកាន់ព្រៃដើម្បីរកថ្នាំ ចំណែកនាង បានយកថ្នាំមក ឯខ្ញុំបាននាំយកខ្ទេរមកវិញកាលបើនាងមិនដឹងខ្ញុំក៏យកពោយ ខ្ទេរលើដំណេករបស់នាងព្រោះហេតុនោះ រាងកាយរបស់ខ្ញុំ ទើបត្រូវពោគកមរមាស់ បៀតបៀន ព្រោះវិបាកនៃកម្មនោះឯង ។

៩. តិ, ពិតមែនហើយ តែយើងសូមសួរនាងអំពីហេតុដទៃទៀតចុះនាង មានកាយអាក្រាតដោយកម្មអ្វី?

១០. ម, មានការប្រជុំមិត្តសម្លាញ់ និងជួបជុំពួកញាតិ គេបានហៅនាង ព្រមទាំងស្វាមី តែខ្ញុំគេមិនហៅ កាលបើនាងមិនបានដឹង ខ្ញុំក៏លួចយកសំពត់ នាងទៅលាក់ ហេតុនោះខ្ញុំទើបមានរាងកាយអាក្រាត ព្រោះវិបាកនៃកម្មនោះ ឯង ។

១១. តិ, ពិតមែនហើយ ចុះរាងកាយរបស់នាងមានក្លិនស្អុយដូចក្លិន លាមក ព្រោះកម្មអ្វី?

១២. ម, ខ្ញុំបានលួចយកគ្រឿងក្រអូប ផ្កាកម្រង និងគ្រឿងលាបដ៏មាន តម្លៃរបស់នាងទៅចោលក្នុងរណ្ដៅលាមក ខ្ញុំបានធ្វើអំពើអាក្រក់នោះ ហេតុនោះ បានជាខ្ញុំមានក្លិនស្អុយដូចលាមក ព្រោះហេតុវិបាកនៃកម្មនោះឯង ។

១៣. តិ, ពិតមែនហើយ ចុះនាងជាស្រីទុគ៌ត ព្រោះវិបាកនៃកម្មអ្វី?

១៤. ម, កាលយើងទាំងពីរនាក់ មានទ្រព្យសម្បត្តិក្នុងផ្ទះស្មើគ្នា កាល ទេយ្យធម៌មាន ខ្ញុំក៏មិនបានធ្វើទីពឹងដើម្បីខ្លួន ព្រោះហេតុនោះបានជាខ្ញុំជាស្រី ទុគ៌តដោយវិបាកនៃកម្មនោះឯង ។

១៥. តិ, នាងឯងបានស្តីឲ្យខ្ញុំថា នាងកុំសេពអំពើអាក្រក់ជឿតថាសុគតិ មិនមែនបានដោយងាយ ព្រោះបាបកម្មឡើយ ។ នាងបានកំហែងយើង ដោយផ្លូវខុស ទាំងបានឫស្យាយើង នាងចូរមើលចុះ វិបាកនៃ អំពើអាក្រក់ប្រាកដយ៉ាងណាអំពីមុនខ្ញុំស្រីទាំងឡាយក្នុងផ្ទះនោះ និងគ្រឿងប្រដាប់ប្រដារនោះឯងជារបស់ខ្ញុំក៏មាន ឥឡូវនេះរបស់អស់នោះក៏បានទៅអ្នកដទៃប្រើប្រាស់ទ្រព្យទាំងឡាយក៏ជារបស់មិនទៀង ឥឡូវនេះ កុដុម្ពីជាបិតារបស់ខ្ញុំត្រឡប់អំពីផ្សារមកផ្ទះធ្វើដូចម្តេច កុដុម្ពីនឹងឲ្យទេយ្យធម៌ តិចតួចដល់នាង នាងកុំអាលទៅអំពីទីនេះឡើយ ។

១៦. ម, ខ្ញុំជាស្រីអាក្រាត មានរូបរាងអាក្រក់ក្រៃពេកជាស្រីស្គម មានខ្លួនរាំមទៅដោយសរសៃ នេះជាកេរ្តិ៍ខ្មាសរបស់ស្រីទាំងឡាយ កុំឲ្យកុដុម្ពីជាបិតានាងមកឃើញខ្ញុំឡើយ ។

១៧. តិ, បើដូច្នោះ ខ្ញុំគួរឲ្យអ្វីដល់នាង ម្យ៉ាងទៀតខ្ញុំនឹងធ្វើឧបការៈអ្វីដល់នាងដ៏ជាហេតុឲ្យនាងសម្រេច ដោយសេចក្តីប្រាថ្នាទាំងពួង ដល់នូវសេចក្តីសុខ។

១៨. ម, នាងចូរនិមន្តភិក្ខុ៨រូប គឺភិក្ខុ៤រូបអំពីសង្ឃ ភិក្ខុ៤រូបទៀតអំពីបុគ្គលឲ្យឆាន់ ហើយឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំនោះ ជាហេតុឲ្យខ្ញុំសម្រេចសេចក្តីប្រាថ្នាទាំងពួងដល់នូវសេចក្តីសុខ ។

នាងតិស្សា បានទទួលពាក្យនាងមត្តាប្រេតថា សាធុហើយទើបនិមន្តភិក្ខុ៨រូបឲ្យឆាន់ រួចហើយឲ្យស្លៀកដណ្តប់ ដោយសំពត់ទាំងឡាយហើយឧទ្ទិសទក្ខិណាទាន ដល់នាងមត្តាប្រេតនោះ ។ វិបាកកើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយភោជនាហារ សំពត់ស្លៀកដណ្តប់និងទឹកផឹក ក៏កើតឡើងនេះជាផលនៃទក្ខិណាទាន ពេលនោះនាងប្រេតក៏ក្លាយជាស្រីស្អាតមានគ្រឿងស្លៀកពាក់ស្អាត ទ្រទ្រង់សំពត់ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសីមានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ទើបបានចូលទៅរកនាងតិស្សាជាស្រីរួមប្តី ។

នាងតិស្សាសួរថា ម្នាលនាងទេវធីតា នាងមានសម្បុរដ៏រុងរឿងដោយរស្មី មកបិតនៅ ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ ដោយហេតុដូចម្ដេច ផលនៃសុចរិត សម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្ដេច បានជាភោគៈទាំងឡាយណានីមួយ ដែលជាទីពេញចិត្ត កើតឡើងដល់នាង ម្នាលនាងទេវធីតាមានអានុភាពច្រើន យើងសូមសួរនាង កាលកើតជាមនុស្សបានធ្វើបុញ្ញកម្មដូចម្ដេច នាងជាទេវធីតាមានអានុភាពភ្លឺផ្លេកយ៉ាងនេះ ដោយបុញ្ញកម្មដូចម្ដេចបានជានាងមានអានុភាពដ៏រុងរឿងទាំងសម្បុររបស់នាងក៏ភ្លឺសព្វទិស ។

នាងមត្តាប្រេតតបថា កាលអំពីមុននាងឈ្មោះតិស្សា ខ្លួនខ្ញុំឈ្មោះមត្តា ជាស្រីរួមប្ដីរបស់នាង បានធ្វើនូវអំពើអាក្រក់ ទើបបានឃ្លាតអំពីមនុស្សលោក នេះ ទៅកាន់បេតលោក ខ្ញុំត្រេកអរដោយទានរបស់នាង ដែលបានឲ្យហើយ ទើបមិនមានភ័យក្នុងទីណាឡើយ ។ ម្នាលប្អូន ចូរនាងរស់នៅអស់កាលយូរ ព្រមដោយពួកញាតិទាំងអស់ចុះ ម្នាលនាងល្អចូរនាងខំប្រព្រឹត្តធម៌ ខំឲ្យទាន ក្នុងលោកនេះ និងចូលទៅកាន់ឋានសួគ៌ ដែលមិនសោកមិនមានធូលី ជាទីនៅ នៃវសវត្តីទេវរាជទាំងឡាយ ។ នាងចូរបន្ទោបង់នូវមន្ទិល គឺសេចក្ដីកំណាញ់ ព្រមទាំងឫសគល់ចេញ ដែលគេនិន្ទាមិនបានចូលទៅកាន់ឋានសួគ៌ ។

## ២៩. រឿងនាងនន្ទាប្រេត[33]

នន្ទសេនជាស្វាមីសួរថា នាងជាស្រីមានខ្លួនខ្មៅ មានរូបអាក្រក់គ្រោត គ្រាតមើលគួរឲ្យខ្លាច មានភ្នែកលឿង មានធ្មេញរង្វើលយើងមិនសម្គាល់ថានាង ជាស្រីមនុស្សទេ។

នាងនន្ទាប្រេតតបថា ម្នាលនន្ទសេន ខ្ញុំឈ្មោះនន្ទាជាភរិយារបស់អ្នកក្នុង កាលមុន បានធ្វើអំពើអាក្រក់ ទើបបានទៅអំពីមនុស្សលោកនេះ ទៅកាន់ បេតលោក ។

---

33.បិដកលេខ 56 ទំព័រ 33

នន្ទសេនសួរថា ចុះអំពើអាក្រក់ដែលនាងបានធ្វើហើយដោយកាយវាចាចិត្តនោះ តើដូចម្តេចខ្លះ នាងទៅអំពីមនុស្សលោកនេះ ទៅកាន់បេតលោកដោយវិបាកនៃកម្មដូចម្តេចខ្លះ?

នាងនន្ទាប្រេតតបថា ខ្ញុំជាស្រីកំណាចផងមានវាចាអាក្រក់ផងឥតមានសេចក្តីគោរពចំពោះអ្នកផង ខ្ញុំពោលពាក្យអាក្រក់ចំពោះអ្នក ទើបបានទៅអំពីមនុស្សលោកនេះទៅកាន់បេតលោក (គឺទៅកើតជាប្រេត) ។

នន្ទសេនថា បើដូច្នោះ យើងនឹងឲ្យសំពត់បង់កដល់នាងចូរនាងស្លៀកសំពត់នេះចុះ លុះនាងស្លៀកសំពត់នេះហើយចូរចូលមកយើងនឹងនាំនាងទៅផ្ទះ នាងទៅដល់ផ្ទះហើយនឹងបានសំពត់ បាយ ទឹក បានឃើញនូវបុត្តទាំងឡាយរបស់នាងផង បានឃើញកូនប្រសាស្រីរបស់នាងផង ។

នាងប្រេតតបថា វត្ថុដែលអ្នកបានឲ្យផ្ទាល់ដៃដោយដៃមិនសម្រេចដល់ខ្ញុំទេ អ្នកចូរញ៉ាំងភិក្ខុទាំងឡាយ ដែលបរិបូណ៌ដោយសីល ជាអ្នកប្រាសចាករាគៈ ជាពហុស្សុត ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ហើយឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំក្នុងវេលានោះ ខ្ញុំទើបនឹងដល់នូវសេចក្តីសុខ សម្រេចនូវសេចក្តីប្រាថ្នាទាំងពួងបាន ។

លំដាប់នោះ នន្ទសេនឧបាសកនោះទទួលថាសាធុ ដូច្នេះហើយបានចាត់ចែងនូវទានដ៏បរិបូណ៌ គឺបាយ ទឹក បង្អែម សំពត់ សេនាសនៈ ឆ័ត្រ គ្រឿងក្រអូប ផ្កាកម្រង ស្បែកជើងផ្សេងៗ ។ នន្ទសេនឧបាសក ក៏ញ៉ាំងភិក្ខុទាំងឡាយ ដែលបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សុត ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ហើយឧទ្ទិសទក្ខិណាទានដល់នាងនន្ទប្រេត ។

វិបាកក៏កើតឡើងក្នុងខណៈដែលបានឧទ្ទិស ភោជនាហារ សំពត់ស្លៀកទាំងទឹកផឹកក៏កើតឡើងសុទ្ធតែជារបស់ទិព្វនេះជាផលនៃទក្ខិណាទាន លំដាប់នោះនាងនន្ទាប្រេតក៏ក្លាយខ្លួនជាទេវធីតា ជាស្រីស្អាត មានសំពត់ស្អាតទ្រទ្រង់

នូវសំពត់ដ៏ឧត្តមជាងសំពត់ដែលកើត ក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រចូលទៅរកស្វាមី ។

នន្ទសេនឧបាសកសួរថា ម្នាលនាងទេវធីតា នាងមានសម្បុរដ៏រុងរឿងភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះដោយហេតុដូចម្ដេច ផលនៃសុចរិតសម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្ដេចបានជាភោគៈទាំងឡាយណានីមួយ ដែលជាទីពេញចិត្តកើតឡើងដល់នាង។

នាងទេវធីតាតបថា ម្នាលនន្ទសេនខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ចំពោះអ្នក លុះស្លាប់ទៅបានទៅកាន់បេតលោកគឺកើតជាប្រេត ខ្ញុំបានត្រេកអរដោយទានរបស់អ្នក ដែលបានឲ្យហើយ ទើបរួចពីកំណើតប្រេត មិនមានភ័យក្នុងទីណាៗឡើយ។

ម្នាលគេហបតី អ្នកព្រមទាំងពួកញាតិទាំងអស់គ្នា ចូររស់នៅអស់កាលយូរម្នាលគហបតីអ្នកចូរខំប្រព្រឹត្តធម៌ ខំឱ្យទានក្នុងលោកនេះ នឹងចូលទៅកាន់ទិព្វស្ថានដែលមិនមានសោក មិនមានធូលីជាទីនៅនៃវសវត្តីទេវរាជទាំងឡាយ។

អ្នកចូរបន្ទោបង់នូវមន្ទិល គឺសេចក្ដីកំណាញ់ព្រមទាំងឫសគល់ចេញប្រាសចាកនិន្ទា ចូរទៅកាន់ឋានសួគ៌ ។

## ៣០. រឿងប្រេតជាញាតិព្រះបាទពិម្ពិសារ[34]

មានសេចក្ដីដំណាលថា ក្នុងកប្បទី៩២ អំពីភទ្ទកប្បនេះព្រះសាស្ដាព្រះនាមបុស្សៈ ទ្រង់ឧប្បត្តិឡើងក្នុងកាសិកនគរ ។ ព្រះបិតាទ្រង់ព្រះនាមព្រះជ័យសេនព្រះមាតាទ្រង់ព្រះនាមសិរិមា ។ ព្រះពុទ្ធអង្គនេះមានប្អូនប្រុស៣ព្រះអង្គមានព្រះមាតាផ្សេងគ្នា ព្រះរាជបុត្រទាំង៣ព្រះអង្គនោះ ព្រះរាជបុត្តមួយអង្គៗមាននាយឃ្លាំងម្នាក់ៗ នាយស្មៀនជនបទម្នាក់ ។ កាលណោះព្រះរាជបុត្តទាំង

[34] ខុទ្ទកនិកាយ បេតវត្ថុ អដ្ឋកថា ភិក្ខុឡេង លេខ ទំព័រ ១៣

៣ព្រះអង្គមាន ព្រះរាជហឫទ័យចង់បម្រើ ព្រះសាស្ដាជាបងរបស់ខ្លួនបានចូលទៅសូមអនុញ្ញាតអំពីព្រះរាជា ជាព្រះបិតាទ្រង់យល់តាមពាក្យសុំ៣ខែ ។

ទើបព្រះរាជបុត្តទាំង៣ព្រះអង្គ ទ្រង់បញ្ជូនព្រះរាជសារផ្ញើទៅឲ្យស្មៀនជនបទរបស់ព្រះអង្គ បង្គាប់ឲ្យចាត់ចែងកសាងព្រះវិហារថ្វាយព្រះសាស្ដា ។ នាយស្មៀនកសាងព្រះវិហារ រួចហើយព្រះរាជបុត្តទាំង៣ព្រះអង្គទ្រង់និមន្តព្រះសាស្ដាទៅកាន់ជនបទ ហើយវេរថ្វាយព្រះវិហារដល់ព្រះសាស្ដាគង់ប្រថាប់ ទើបទ្រង់បង្គាប់នាយឃ្លាំង និងនាយស្មៀនថា អ្នកទាំងឡាយចូរចាត់ចែងខាទនីយភោជនីយាហារ សព្វៗថ្ងៃថ្វាយដល់ព្រះសាស្ដាដែលមានភិក្ខុសង្ឃ៩ម៉ឺនជាបរិវារផងដល់យើងព្រមទាំងបរិពារផង យើងនឹងមិននិយាយចាប់តាំងអំពីថ្ងៃនេះទៅ ។

ទ្រង់កាន់យកនូវបុរស១ពាន់នាក់ជាបរិពារ សមាទានសីល១០ទ្រង់ស្លៀកសំពត់កាសាវៈ ប្រថាប់នៅក្នុងព្រះវិហារអស់៣ខែ ។ នាយឃ្លាំងព្រមទាំងភរិយា នាយស្មៀនព្រមទាំងបុរសនៅក្នុងជនបទចំនួន១១នហុត ជាអ្នកមានសទ្ធាជ្រះថ្លាចាត់ចែងទានវត្ថុតាមវេនរបស់ខ្លួន ដោយគោរពផ្ចិតផ្ចង់ចាប់តាំងពីថ្ងៃទីមួយទៅ ។ បណ្ដាពួកអ្នកជនបទទាំងអស់ នោះពួកអ្នកជនបទមានចំនួន ៨៤ ០០០ ជាអ្នកមានចិត្តប្រអូសក្នុងទានកិច្ចម្ល៉ោះហើយ ពួកអ្នកជនបទទាំងនោះ បានធ្វើសេចក្ដីអន្តរាយដល់ទាន ទំពាស៊ីទេយ្យវត្ថុដោយខ្លួនឯងខ្លះៗ ឲ្យកូនស៊ីខ្លះដុតបំផ្លាញរោងបាយចោលអស់ ។

ពួកអ្នកជនបទទាំងនោះ ដល់ស្លាប់ទៅកើតក្នុងនរក រីឯព្រះរាជបុត្តព្រមទាំងបរិពារនិងនាយឃ្លាំង នាយស្មៀនបានទៅកើតក្នុងឋានសួគ៌ ។ ពួកជនទាំងពីរក្រុមនោះ ច្យុតចាកឋានសួគ៌ទៅកាន់ឋានសួគ៌ ច្យុតចាកពីឋាននរកទៅកាន់ឋាននរកអស់៩២កប្ប ។ ក្នុងភទ្ទកប្បនេះ ក្នុងសាសនានៃព្រះពុទ្ធកស្សបៈ ពួកជនដែលទៅកើតក្នុងនរកនោះឡើងមកកើតជាប្រេត ។ កាលណោះមនុស្ស

ទាំងឡាយគេនាំគ្នាចាត់ចែងទានឧទ្ទិសផល ដើម្បីជាប្រយោជន៍ដល់ប្រេតជាញាតិរបស់ខ្លួនៗថា ៖

**អម្ហាកំ ញាតីនំ ហោតុ**

ទានចូរបានសម្រេចដល់ញាតិទាំងឡាយរបស់យើង ។

ប្រេតជាញាតិនោះ បានទទួលសោយសម្បត្តិតាមគាប់ចិត្ត ។ គ្រានោះពួកប្រេតទាំងនោះ ឃើញគេបានសម្បត្តិដូច្នោះ ក៏ចូលទៅសួរព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈថា បពិតព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយនិងបានសម្បត្តិដូចគេ នោះអង្កាល់ទៅហ្ន៎? ព្រះពុទ្ធកស្សបៈទ្រង់ប្រាប់ថា ឥឡូវអ្នកទាំងឡាយមិនទាន់បានសម្បត្តិទេដល់ទៅក្នុងសាសនាព្រះពុទ្ធ ទ្រង់ព្រះនាមគោតម មានស្តេចមួយព្រះអង្គទ្រង់ព្រះនាម ពិម្ពិសារត្រូវជាញាតិរបស់អ្នកទាំងឡាយ ទ្រង់ថ្វាយទានដល់ព្រះពុទ្ធអង្គនោះ រួចឧទ្ទិសផលចំពោះអ្នកទាំងឡាយ អ្នកទាំងឡាយនឹងបានសម្បត្តិក្នុងកាលនោះឯង ។

ពួកប្រេតអស់នោះ ទន្ទឹងរង់ចាំព្រះបាទពិម្ពិសារ អស់ចន្លោះព្រះពុទ្ធមួយអង្គទៀត ព្រមទាំងបរិវារច្យុតចាកឋានសួគ៌ ទៅកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងមគធរដ្ឋ ចេញបួសជាជដិល មានជដិលឈ្មោះ ឧរុវេលកស្សបៈជាដើម ។ នាយឃ្លាំងជាកូនសេដ្ឋី ឈ្មោះនាងធម្មទិន្នា ។ នាយស្មៀនជាស្តេចព្រះនាមពិម្ពិសារជនជាបរិស័ទទាំងអស់មកជាបរិវារនៃស្តេច ។

កាលនោះ ព្រះសាស្តាជាម្ចាស់នៃយើង ព្រះអង្គត្រាស់ដឹងសព្វញ្ញុតញ្ញាណហើយទ្រង់និមន្តទៅកាន់លដ្ឋិវនឧទ្យាន តាមលំដាប់ទ្រង់ញ៉ាំងព្រះបាទពិម្ពិសារជាមួយនឹងព្រាហ្មណ៍គហបតីនៅក្នុងមគធរដ្ឋ នហុត១១ម៉ឺននាក់ដែលចូលទៅថ្វាយបង្គំ គាល់ក្នុងលដ្ឋិវនឧទ្យាននោះ ឲ្យតាំងនៅក្នុងសោតាបត្តិផល ព្រះបាទពិម្ពិសារទ្រង់អារាធនានិមន្ត សូមឲ្យព្រះអង្គទទួលមហាទាន ក្នុងព្រះរាជដំណាក់ក្នុងថ្ងៃទីពីរ ។ ពួកប្រេតទាំងនោះ មកឈរចោមរោមជុំវិញ ព្រះរាជដំណាក់នឹកថា ព្រះរាជាទ្រង់នឹងឧទ្ទិសទានចំពោះយើងទាំងឡាយក្នុងកាល

ឥឡូវនេះ ។ ព្រះរាជទ្រង់ថ្វាយទានហើយ កំពុងខ្វល់ព្រះរាជហឫទ័យរិតក្ត្រិះរិះរកទីកន្លែង "ប្រគេនថ្វាយព្រះសាស្តាជាម្ចាស់គង់ប្រថាប់នៅក្នុងទីណាទៅហ្ន៎" ទ្រង់មិនបានឧទ្ទិសទានចំពោះ ពួកប្រេតឯណានីមួយឡើយ ។

ពួកប្រេតទាំងឡាយនោះ មិនបានទទួលផលទាន តាមបំណងដូច្នោះហើយ ក៏នាំគ្នាស្រែកនូវសម្រែកគួរឲ្យខ្លាចក្តួតក្តឹកណាស់ក្បែរដំណាក់ ព្រះរាជាក្នុងវេលារាត្រីស្ងាត់ ។ ព្រះរាជា លុះដល់ព្រឹកឡើងទ្រង់ចូល ទៅបង្គំសួរព្រះពុទ្ធថា បពិតព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮសំឡេង គួរឲ្យខ្លាចក្នុងរាត្រីស្ងាត់តើហេតុភេទនឹង កើតមានដល់ខ្ញុំព្រះអង្គដូចម្តេចទៅ? ព្រះសាស្តាទ្រង់ត្រាស់ថា បពិតមហារាជ សូមព្រះអង្គកុំទន្ទត់ក្នុងព្រះទ័យឲ្យសោះ នឹងមិនមានវត្ថុកាចអាក្រក់ដល់មហារាជឡើយ សំឡេងនោះជាសំឡេងប្រេតជាញាតិរបស់ព្រះអង្គដែលមិនបានទទួលផលទានមកពីព្រះអង្គពុំបានឧទ្ទិសឲ្យ ។

ព្រះរាជាទ្រង់សាកសួរដឹង ហេតុសព្វគ្រប់ហើយទ្រង់និមន្តព្រះសាស្តាទទួលចង្ហាន់ក្នុងថ្ងៃស្អែក រួចទ្រង់យាងទៅកាន់ដំណាក់ចាត់ចែងទានដល់កំណត់កាលទ្រង់ប្រើរាជបុរសទៅនិមន្តព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃជាបរិវារទ្រង់និមន្តទៅគង់ប្រថាប់ក្នុង ព្រះរាជដំណាក់ ។ ពួកប្រេតទាំងឡាយនោះមានសេចក្តីរីករាយ ថាថ្ងៃនេះយើងត្រូវបានទទួលផលទាន ក៏នាំគ្នាមកកាន់ព្រះរាជដំណាក់ ព្រះបាទពិម្ពិសារជាផ្ទះញាតិកាលពីមុនដោយសម្គាល់ថាជាផ្ទះរបស់ខ្លួន ហើយឈរនៅក្នុងទីទាំងឡាយមានជញ្ជាំងជាដើម ។

ពួកប្រេតទាំងពួងនោះ សោយផលនៃសេចក្តីប្រណែនឈ្នានីស និងកំណាញ់ពួកខ្លះមាន ពុកមាត់ និងសក់វែងអន្លាយ មុខដូចស្វាមានអវយវៈខ្មៅស្គមកំព្រឹង ឆ្អឹងរខេករខាកសរសៃពាក់ព័ន្ធព័ទ្ធរយុររយារសំយុងចុះដូចដើមត្នោតដែលត្រូវភ្លើងឆេះ ពួកខ្លះមានអណ្តាតភ្លើងឆេះឡើងពីពោះ ព្រោះសេចក្តីស្រេកឃ្លាន ផ្សាយចេញទៅតាមមាត់ឆេះស្រោបសរីរៈទាំងអស់ ។ ពួកខ្លះមានបំពង់កប៉ុនម្ជុលពោះប៉ុនភ្នំ មិនដែលបានបរិភោគទឹកភោជនឆ្អែតម្តងណាឡើយ មាន

សេចក្តីស្រេកឃ្លានជានិច្ច ពួកខ្លះលិទ្ធស៊ីវត្ថុមិនស្អាត មានឈាមខ្ទុះទឹករំអិល ដែលហូរចេញចាកមុខរបួសកមនៃគ្នានឹងគ្នា ដូចទេវតាសោយនូវទឹកអម្រឹត ពួកប្រេតទាំងនេះមានខ្លួនអាក្រាតគួរឲ្យខ្ពើម ។

ព្រះសាស្តាទ្រង់អធិដ្ឋាន ឲ្យព្រះរាជាទតឃើញច្បាស់នូវពួកប្រេតទាំងអស់នោះ ។ ព្រះរាជាប្រួចទឹកទក្ខិណោទកៈហើយឧទ្ទិសថា ៖

**ឥទំ វោ ញាតីនំ ហោតុ**[35]

សូមទាននេះ ចូរមានដល់ញាតិរបស់យើង ។

**តំ ខណញ្ញេវ**

ក្នុងខណៈនោះឯងស្រាប់តែ ស្រះបោក្ខរណីដុះដេរដាសពាសពេញដោយផ្កាឈូក ក៏កើតឡើងសម្រាប់ពួកប្រេតទាំងនោះ ។ ពួកប្រេតទាំងនោះនាំគ្នាងូតទឹក ផឹកទឹកក្នុងស្រះបោក្ខរណីរម្ងាប់សេចក្តីខ្វល់ខ្វាយ សេចក្តីលំបាក និងសេចក្តីស្រេកឃ្លានមានសម្បុរភ្លឺថ្លាដូចជាមាស ។ ព្រះរាជាទ្រង់ថ្វាយបបរ បង្អែមចម្អាបទាំងឡាយ ចំពោះព្រះសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃ រួចឧទ្ទិសផលទៅ ស្រាប់តែបបរ បង្អែមចម្អាបទិព្វកើតមានឡើងដល់ពួកប្រេតទាំងនោះ ក្នុងខណៈនោះភ្លាម ។ ពួកប្រេតនាំគ្នាបរិភោគ ឆ្អែតស្កប់ស្កល់ មានឥន្ទ្រីយ៍ពេញលេញ ដុះសាច់ឈាមបរិបូណ៌ ព្រះរាជាទ្រង់ថ្វាយសំពត់ ទីសេនាសនៈ រួចឧទ្ទិសទៅទៀត ។

ស្រាប់តែគ្រឿងអលង្ការ មានបែបផែនផ្សេងៗមានសំពត់យានជំនិះ កម្រាល ប្រាសាទ សុទ្ធតែជារបស់ទិព្វកើតឡើងដល់ពួកប្រេតទាំងនោះ ពួកប្រេតទាំងអស់រួចចាកអត្តភាពជាប្រេត ទៅកើតក្នុងទេវលោកសោយសម្បត្តិជាសុខទៅ ។ ព្រះសាស្តាអធិដ្ឋានឲ្យ ព្រះរាជាទតឃើញ សម្បត្តិដែលសម្រេចដល់ពួកប្រេតទាំងនោះ ។ ព្រះរាជាទ្រង់ទតឃើញហើយ មានព្រះទ័យរីករាយយ៉ាងក្រៃលែង កាលព្រះពុទ្ធទ្រង់សោយស្រេចហើយ កត្តានុមោទនាដោយ

---

[35] គាថានេះមានក្នុងសង្ឃទានមានផលច្រើន ទំព័រ ១១៤

តិរោកុឌ្ឌសូត្រ សម្តែងប្រារព្ធបុណ្យទក្ខិណានុប្បទាន របស់ព្រះបាទពិម្ពិសារ ដែលព្រះសង្ឃតែងនិយមសូត្រពេលឆាន់ ឬក៏រដូវភ្ជុំបិណ្ឌនោះឯង ។

## ៣១. រឿងកូនធ្វើបុណ្យជូនមាតាបិតាស្លាប់[36]

(បុណ្យទក្ខិណាទានអាចជួយអ្នកស្លាប់ ឲ្យរួចពីកំណើតប្រេត)

ក្នុងកាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាម ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងក្រុងពារាណសីកាលនោះ នាងចន្ទបទុមវតីកើតស្រុកធំ ចម្ងាយអំពីក្រុងពារាណសី១២យោជន៍ ។ នាងជាស្រីប្រកបដោយសីល៥ ពុំមានដាច់នាងមានរូបល្អណាស់ ដល់អាយុ១៦ឆ្នាំបានទៅកាន់ត្រកូលប្តី នាងនៅរួម សុខទុក្ខជាមួយប្តីតែងតែធ្វើបុណ្យ ទាំងឡាយមានទានជាដើមពុំដែលដាច់ឡើយ ។

នាងគិតថាអញនឹងបរិច្ចាគជីវិតឲ្យជាទាន អញនឹងធ្វើបុណ្យទាំងឡាយមានទានជាដើម អញនឹងរក្សាសីល អញនឹងប្រគេនចង្ហាន់បិណ្ឌសាលាកកត្តដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រឹកឡើងនាងកាន់យកនូវវត្ថុទាំងឡាយមានគ្រឿងក្រអូប និងកម្រងផ្កាជាដើមទៅកាន់វត្ត ចាត់ចែងចង្ហាន់បិណ្ឌបាត ប្រគេនដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានរៀងរាល់ថ្ងៃ ព្រមទាំងធ្វើបណ្ណសាលាសម្រាប់ព្រះភិក្ខុសង្ឃគង់នៅ រួចនាងតាំងសេចក្តីប្រាថ្នាថា៖

**ឥមិនា តត្តទានេន តន្តេ ហោមិ**
**អនាគតេ ឧលិទ្ធតា នច ហោមិ**
**តត្ថ តត្ថ ភវេ ភវេ ។**

បពិត្រព្រះអង្គដ៏ចម្រើន ដោយទត្តទាននេះ ខ្ញុំព្រះអង្គទៅកើតភពឯណា នាអនាគតសូមកុំឲ្យជាអ្នកទីទាល់ក្រកំសត់ អត់ឃ្លានក្នុងភពនោះៗ ។

[36] ទក្ខិណានុប្បទានអធិប្បាយ ភិក្ខុឡេង លេខ ទំព័រ២៣

អ្នកទាំងពីរស្វាមី-ភរិយា ខំប្រឹងបំពេញបុណ្យទានជាដើម ដរាបដល់អស់អាយុក្នុងកាលដែលរៀបនឹងស្លាប់ មានចិត្តនឹករឭកចំពោះកូន ដល់ស្លាប់ទៅកើតជាប្រេតអស់រយៈពេល៧ថ្ងៃ ។

កូនប្រុសស្រី ឃើញឪពុកម្តាយស្លាប់ដូច្នោះ នាំគ្នាទួញយំសោកខ្សឹកខ្សួលអួលអាក់ ហើយចាត់ចែងគ្រឿងសក្ការៈដង្ហែសពមាតាបិតាទៅដុតក្នុងព្រៃស្មសាន រួចត្រឡប់ទៅកាន់ផ្ទះចាត់ចែងធ្វើបុណ្យមានទានជាដើម រួចច្រួចទឹកទក្ខិណោទកៈឧទ្ទិសផលចំពោះមាតាបិតា ។

**តស្មឹ ខណេ ឯវ តេហិ បុត្តធីតរេហិ**
**កតបុញ្ញានុភាវេន បេតភាវតោ មុញ្ចិត្វា**
**ភាវតឹសភវនេ ទ្វាទសយោជនិកេ កនកវិមានេ**
**ទេវច្ឆរេហិ សហស្សេហិ បរិភិណ្ណោ និព្វត្តឹសុ ។**

ក្នុងខណៈនោះឯង អ្នកទាំងពីរស្វាមី-ភរិយា បានរួចចាកកំណើតជាប្រេត ដោយអានុភាពនៃបុណ្យដែលកូនប្រុស ស្រីបានធ្វើ បានទៅកើតក្នុងវិមានមាស ប្រកបដោយ១២យោជន៍ មានស្រីទេពអប្សរ១ពាន់នាក់ ជាបរិវារនាស្ថានតាវត្តិង្សពិភព ។

ថ្ងៃមួយកូនប្រុស ស្រីកាន់យកវត្ថុទាំងឡាយ មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ចូលទៅរកព្រះដ៏មានបុណ្យ ថ្វាយបង្គំបូជាដោយគ្រឿងសក្ការៈអង្គុយក្នុងទីដ៏សមគួរមួយហើយទូលសួរព្រះដ៏មានបុណ្យថាៈ

**ភន្តេ មាតាបិតារោ បន កុហឹ អម្ហាកំ និព្វត្តឹសុ ។**

បពិត្រព្រះអង្គដ៏ចម្រើន ចុះមាតាបិតា របស់ខ្ញុំព្រះអង្គទាំងឡាយទៅកើតក្នុងទីណា?

ព្រះអង្គទ្រង់ត្រាស់ថា មាតាបិតារបស់អ្នកទាំងឡាយ ឥឡូវនេះទៅកើតក្នុងវិមាន មាសនាតាវត្តិង្សពិភពហើយ ។

**តំសុត្វា បុត្តធីតរោ បសន្នចិត្តា អហេសុំ ។**

កូនប្រុស-ស្រីឮព្រះពុទ្ធត្រាស់ដូច្នោះហើយ មានចិត្តជ្រះថ្លាពន់ពេក ។

គ្រានោះព្រះអង្គទ្រង់ត្រាស់ហៅ ព្រះមហាមោគ្គល្លានហើយទ្រង់ប្រើថា នែបា-មោគ្គល្លាន ចូរអ្នកនិមន្តទៅកាន់តាវត្តិង្សពិភពសង្កេតមើលទីកន្លែងសម្រាប់នៅរបស់មាតាបិតានៃកូនទាំង១៤នាក់ ហើយចូរនិមន្តមកវិញយ៉ាងប្រញាប់ ។ ព្រះមហាមោគ្គល្លានទទួលព្រះពុទ្ធដីកាថា សាធុ ហើយថ្វាយបង្គំលាព្រះដ៏មានបុណ្យហោះទៅកាន់អាកាសដោយកម្លាំងឫទ្ធិ របស់ព្រះអង្គបានដល់វិមានរបស់ទេវបុត្តជាផៅពង្ស លោកឈរក្នុងទីនោះហាក់ដូចជាឈរបិណ្ឌបាត ។

គ្រានោះទេវបុត្តឃើញព្រះថេរៈ និមន្តមក ក៏ចូលទៅជិតព្រះថេរៈហើយសួរថា បពិតលោកម្ចាស់ដ៏ចម្រើនលោកម្ចាស់ជាអ្នកប្រកបដោយសេចក្ដីករុណាធំ តើនិមន្តមកអំពីទីណា?

ព្រះមហាមោគ្គល្លានប្រាប់ថា អាត្មានិមន្តមកអំពីមនុស្សលោក ។ ទេវបុត្តឮដូច្នោះហើយ និយាយទូលព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទើបនិមន្ត មកអំពីមនុស្សលោក ខ្ញុំព្រះករុណាកាលនៅក្នុងមនុស្សលោកនោះ មានកូនប្រុស៧នាក់ កូនស្រី៧នាក់ នៅក្នុងស្រុកឯណោះ បពិតលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់និមន្តទៅកាន់មនុស្សលោកវិញ សូមប្រាប់ដល់កូនខ្ញុំព្រះករុណាផងថា មាតាបិតារបស់អ្នកទាំងឡាយ ក្នុងកាលទៀបស្លាប់ មានចិត្តនឹករឭកចំពោះអ្នកទាំងឡាយ ព្រោះសេចក្ដីស្រលាញ់ ស្លាប់ទៅកើតជាប្រេតអស់៧ថ្ងៃ បានរួចចាកអត្តភាពជាប្រេតនោះ ដោយអានុភាពនៃបុណ្យដែលអ្នកទាំងឡាយបានធ្វើ ឥឡូវនេះបានទៅកើតក្នុងឋានតាវត្តិង្សហើយ ចូរអ្នកទាំងឡាយកុំធ្វេសប្រហែសក្នុងកុសលកម្មទាំងពួង ចូរអ្នកឲ្យទានរក្សាសីលចម្រើនភាវនាឡើង ។

ព្រះមហាមោគ្គល្លានទទួលថា សាធុ ហើយនិមន្តចុះចាក់ឋានសួគ៌ចូលទៅកាន់វត្តជេតពន ប្រាប់ពាក្យបណ្ដាំទាំងអស់ដល់កូនប្រុសស្រី ទាំង១៤នាក់

ចំពោះ ព្រះភក្ត្រព្រះដ៏មានបុណ្យកូនប្រុសស្រី ឮពាក្យនោះ ហើយមានចិត្តជ្រះថ្លាពន់ពេក ។

ព្រះសាស្ដា ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់ប្រទានធម្មទេសនាដល់ពួកមហាជនទាំងឡាយថា:

**យោ មរណកាលេ ធនំ វា**
**បុត្តទារំ វា, មាតាបិតរំ វាពន្ធុំ វា**
**អនិស្សរិត្វា បេតភវេ និព្វត្តិ**
**តស្មាតត្ថិវា បុរិសោវា មាតាបិតរោ បុត្តទារំ**
**ពន្ធុំច ន អនុស្សរេយ្យ សោ សគ្គមោក្ខំ គមិស្សតិ ។**

បុគ្គលឯណា រឭកទ្រព្យ កូនប្រពន្ធមាតាបិតាញាតិផៅពង្ស ក្នុងកាលទៀបនឹងស្លាប់ រមែងទៅកើតក្នុងបេតតពពីព្រោះហេតុដូច្នោះ បុគ្គលនោះស្រីក្ដី ប្រុសក្ដី មិនត្រូវរលឹកមាតាបិតា កូន ប្រពន្ធ ញាតិផៅពង្សក្នុងកាលទៀបស្លាប់បុគ្គលនោះ នឹងទៅកាន់ឋានសួគ៌ និងព្រះនិព្វាន ។

ធម្មទេសនាចប់ សម្រេចប្រយោជន៍ដល់ពួកជនជាច្រើន ពួកមហាជនបានលុះនូវផលទាំងឡាយមានសោតាបត្តិផលជាដើម ។

## ៣២. រឿងបុរសស្លាប់ធ្លាក់នរក[37]

(ធ្លាក់នរកព្រោះតែស្រលាញ់ប្រពន្ធពេកធ្វើចោរ)

ក្នុងអតីតកាល គ្រាព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ សោយព្រះជាតិជាអាកាសដ្ឋទេវតា គ្រានោះក្នុងនគរពារាណសី មានការលេង មហោស្រពក្នុងថ្ងៃពេញបូណ៌មី ខែកត្តិកមនុស្សម្នារៀបចំតាក់

---

[37] ការបម្រើភ្លើងរបស់ព្រះតេជៈគុណ ឌី ប៉ោហ៊ៃណៃ ទំព័រ ៣៨

តែងផ្ទះ និងនគរយ៉ាងស្អាតដូចជាទេវនគរ ។ មនុស្សទាំងពួងត្រៀមនឹងលេងមហោស្រព ប៉ុន្តែមានមនុស្សក្រីក្រម្នាក់មានសំពត់សាច់ទន់តែមួយគូប៉ុណ្ណោះ គាត់យកមកបោកឲ្យស្អាត តែសំពត់នោះសាច់ជ្រួញជ្រួញជាផ្នត់រាប់រយរាប់ពាន់ផ្នត់ ។ គ្រានោះប្រពន្ធរបស់គាត់និយាយនឹងគាត់ថា បងខ្ញុំប្រាថ្នានឹងស្លៀកសំពត់ដែលជ្រលក់ដោយទឹកដកគាំមួយផ្ទាំង ដណ្ដប់មួយផ្ទាំង កាន់ដៃលោកដើរលេងក្នុង រាត្រីមហោស្រពខែកត្តិក ។ ប្ដីពោលថាប្រពន្ធសម្លាញ់យើងក្រម្លឹងនឹងមានសំពត់ជ្រលក់ដោយទឹកដកគាំពីណាមក នាងចូរដណ្ដប់សំពត់សដើរលេងចុះ ។ នាងប្រពន្ធពោលថា កាលបើមិនបានសំពត់ជ្រលក់ដោយទឹកដកគាំទេ ខ្ញុំនឹងមិនទៅលេងក្នុងមហោស្រព លោកនាំស្ដ្រីដទៃទៅលេងចុះ ។ ប្ដីពោលថា ប្រពន្ធសម្លាញ់ ម្ដេចក៏បង្ខំខ្ញុំឲ្យលំបាកម្ល៉េះ យើងនឹងបានសំពត់ជ្រលក់ដោយ ទឹកដកគាំអំពីទីណាមក? នាងពោលថាកាលសេចក្ដីប្រាថ្នារបស់កូនប្រុស មានអ្វីដែលថាមិនសម្រេចនុ៎ះ ផ្កាដកគាំក្នុងចំការផ្កាដកគាំរបស់ព្រះរាជាមានច្រើន មិនមែនឬ? ប្ដីពោលថាប្រពន្ធសម្លាញ់ទីនោះមានការ ការពារយ៉ាងមាំទាំដូចជា ស្រះទឹកដែលមានអារក្សទឹកហួងហែង យើងមិនអាចចូលទៅជិតបានទេ នាងកុំពេញចិត្តផ្ដេសផ្ដាសឡើយ ចូរត្រេកអរតាមមានតាមបានប៉ុណ្ណោះចុះ ។ នាងជា ភរិយាពោលថាបងចាំពេលរាត្រីងងឹត ចូរបងចូលទៅលួចផ្កាដកគាំមក ហើយបងអាចមានទេវតាជួយថែរក្សា ។

កាលនាងនិយាយរឿយៗយ៉ាងនេះ ប្ដីដ៏ជឿពាក្យសម្ដីរបស់នាងជាប្រពន្ធដោយអំណាចសេចក្ដីស្រលាញ់ ហើយពោលលួងលោមថាណ្ហើយចុះនាងកុំគិតអ្វីឡើយចាំខ្ញុំទៅ ។ ដល់វេលាយប់គេក៏ប្រថុយជីវិតចេញអំពីក្រុងទៅកាន់ចម្ការផ្កាដកគាំរបស់ស្ដេចផ្លោះរបងចូលទៅក្នុងចម្ការ ពួកអ្នកយាមចម្ការបានឮសំឡេងរបងម្នាក់ៗស្រែកថា ចោរចោរ ហើយឡោមព័ទ្ធចាប់បាន ជួយគ្នាចងទុកគ្រាភ្លឺឡើងក៏នាំទៅថ្វាយព្រះរាជាៗបញ្ជាថា ពួកអ្នកចូរយកលំពែងដោតវា ។

អ្នកយាមទាំងនោះចងដៃគេព័ទ្ធទៅក្រោយ នាំចេញអំពីក្រុងដោយមានមនុស្សវាយស្គរ ប្រកាសទោសប្រហារជីវិតទៅផង ហើយយកទៅជោតនឹងលំពែងបញ្ឈរចោល ។ គេសោយទុក្ខវេទនាដ៏សែនធ្ងន់ ហ្វូងក្អែកនាំគ្នាទៅទុំត្រង់ក្បាលចិកទាញយកគ្រាប់ភ្នែកមកស៊ីនឹងចុងចំពុះយ៉ាងមុតដូចចុងកាំបិត គេមិនបានដាក់ចិត្តក្នុងទុក្ខដ៏ធ្ងន់ធ្ងរនោះឡើយ គិតដល់តែប្រពន្ធប៉ុណ្ណោះ រំពឹងគិតថាយើងគ្មានឱកាសទៅលេងបុណ្យ ប្រចាំរាត្រីក្នុងខែកត្តិកជាមួយប្រពន្ធ ដែលស្លៀកសំពត់ជ្រលក់ដោយទឹកដកគាំ កាន់ដៃគ្នាកៀកកើយគ្នា ។ ហើយពោលពាក្យទាំងនេះថា៖

ក្អែកចោះអញដោយហេតុណា ហេតុនេះមិនជាទុក្ខទេសេចក្ដីទុក្ខនោះត្រង់ប្រពន្ធឈ្មោះសាមា មិនបានស្លៀកដណ្ដប់សំពត់ដែលជ្រលក់ដោយទឹកដកគាំ ដើរមើលមហោស្រពក្នុងខែកត្តិក ។ គេនិយាយរឿយៗ ត្អូញត្អែរដល់ប្រពន្ធនោះ តែម្យ៉ាងប៉ុណ្ណោះរហូតស្លាប់ទៅកើតក្នុងនរក ព្រោះតែជាប់ជំពាក់ចិត្តនឹងប្រពន្ធ និងទោសលួចផ្កាដកគាំរបស់ព្រះរាជានោះឯង ។

ដូច្នេះសត្វណាក៏ដោយឲ្យតែទៀបស្លាប់ ជាប់ជំពាក់ចិត្តនឹងប្រពន្ធកូនមាតាបិតា ទ្រព្យសម្បត្តិស្រែចម្ការស្លាប់ទៅកើតជានរកប្រេតជាជាច់ខាត ដូច្នេះយើងត្រូវតែរៀន ហាត់ពត់ចិត្តកុំឲ្យជាប់ចិត្តនឹងរបស់ទាំងអស់នេះខ្លាំងពេក គួររៀនត្រេកអរក្នុងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃវិញដើម្បីបានជាទីពឹង សម្រាប់ខ្លួន និងបញ្ចៀសទុក្ខភ័យទាំងនោះ បុរសគប្បីប្រព្រឹត្តនូវអំពើសុចរិត ហើយសង្គ្រោះភរិយាដោយធម៌៥យ៉ាងគឺ ដោយការរាប់អានជាភរិយាពេញ មុខ១ ដោយមិនមើលងាយ១ ដោយមិនប្រព្រឹត្តក្បត់ចិត្តនាង១ ដោយប្រគល់ ឲ្យជាធំក្នុងផ្ទះ១ ដោយការឲ្យគ្រឿងអលង្ការតែងខ្លួន១ ។

ចំណែកភរិយា ដើម្បីបញ្ចៀសទុក្ខសោក គប្បីបម្រើស្វាមីដោយធម៌៥យ៉ាងគឺ ជាអ្នកចាត់ចែងការងារដោយប្រពៃ១ ជួយសង្គ្រោះញាតិខាងស្វាមីដោយប្រពៃ១ ជាអ្នកមិនប្រព្រឹត្តក្បត់ចិត្តស្វាមី១ រក្សាទ្រព្យដែលស្វាមីរកបានមក

ហើយមិនឲ្យវិនាសដោយហេតុមិនសមគួរ១ ជាស្ត្រីមិនខ្ជិលច្រអូសក្នុងកិច្ចការ-ងារគ្រប់បែបយ៉ាង១ ។ កិរិយាណាបានប្រតិបត្តិយ៉ាងនេះ រមែងបាននូវសុខចម្រើនក្នុងលោកនេះ និងលោកខាងមុខសមដូចព្រះពុទ្ធដីកាទ្រង់ត្រាស់ថាៈ

ស្ត្រីប្រកបដោយធម៌ទាំង៥យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងពួកទេវតាមានរាងកាយជាទីគាប់ចិត្ត ។

## ទក្ខិណេយ្យគ្គិ

ទក្ខិណេយ្យគ្គិ ភ្លើងគឺទក្ខិណេយ្យបុគ្គលនេះ បានដល់បព្វជិតឬព្រះភិក្ខុសង្ឃដែលមានកិលេសស្ងប់រម្ងាប់ ហើយជាអ្នកមានកាយវាចា ចិត្ត និងបញ្ញាបានអប់រំមកហើយ ជាអ្នកប្រកបដោយការហ្វឹកហាត់ដ៏ប្រសើរ ហើយទ្រទ្រង់នូវគុណទាំងឡាយមានសីលជាដើម និងជាអ្នកណែនាំគ្រហស្ថឲ្យប្រព្រឹត្តកល្យាណធម៌។

សួរថា តើលោកជាភ្លើងយ៉ាងណា?

ឆ្លើយថា លោកជាភ្លើង ព្រោះបើបុគ្គលណាមានចិត្តប្រទូសរ៉ាយចំពោះលោកបុគ្គលនោះរមែងដល់នូវសេចក្តីទុក្ខ មានទុក្ខក្នុងនរកជាដើម ។ ក្នុងដំណើរនេះ មានរឿងខាងក្រោមជាឧទាហរណ៍បញ្ជាក់សម្រាប់ឲ្យពិចារណាឲ្យឃើញពិតជាក់ស្តែងច្បាស់ដូចតទៅនេះ ៖

### ៣៣. រឿងនន្ទយក្សធ្លាក់មហានរក[38]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថានជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុនិងព្រះមហាមោគ្គល្លានដ៏មានអាយុ នៅក្នុងវត្តឈ្មោះកបោតកន្ទរា សម័យនោះព្រះសារីបុត្តដ៏មានអាយុ មានសក់ទើបកោរថ្មីៗអង្គុយក្នុងទីវាលចូលកាន់សមាធិណាមួយក្នុងរាត្រីខាងខ្នើត ។

[38] បិដកលេខ៥២ ទំព័រ២០៦

សម័យនោះ មានយក្ខពីរនាក់ជាសម្លាញ់នឹងគ្នា មកអំពីទិសខាងជើងទៅទិសខាងត្បូងដោយកិច្ចណាមួយ ។ យក្សទាំងនោះបានឃើញព្រះសារីបុត្តដ៏មានអាយុ មានសក់ទើបកោរថ្មីៗ អង្គុយក្នុងទីវាលរាត្រីខាងខ្មៅត លុះយក្សម្នាក់ឈ្មោះនន្ទៈ បានឃើញហើយនិយាយប្រាប់យក្សម្នាក់ទៀតថា ម្នាលសម្លាញ់ចិត្តរបស់ខ្ញុំកើតប្រាកដ ដើម្បីប្រហារព្រះសិរ្សៈ (ត្រង់ក្បាល) សមណៈនេះ ។ និយាយយ៉ាងនេះអស់វារៈបីដង យក្សជាសម្លាញ់បានឃាត់ថា កុំសម្លាញ់អ្នកកុំប្រហារ សមណៈឡើយ ម្នាលសំលាញ់សមណនោះ មានគុណដ៏លើសលុបមានឫទ្ធិច្រើន មានអានុភាពច្រើន យក្សជាសម្លាញ់បានឃាត់អស់វារៈ៣ដងយ៉ាងនេះ ។

ប៉ុន្តែយក្សឈ្មោះនន្ទៈ មិនអើពើនឹងយក្សនោះឡើយ ហើយប្រហារព្រះសិរ្សៈ (ក្បាល) ព្រះសារីបុត្តដ៏មានអាយុ ពេលនោះស្រាប់តែយក្សនោះស្រែកពោលថា ខ្ញុំក្តៅណាស់ដូច្នេះ ហើយធ្លាក់ទៅកាន់មហានរកត្រង់ទីនោះឯងភ្លើងអវិចីមហា នរកអូសទាញលេបត្របាក់ យកទៅមិនអាចតាំង នៅលើអាកាសបានទៀតឡើយ ។ បានឮថាកាលពីជាតិមុនយក្សនោះបានចងអាឃាតជាមួយព្រះថេរៈ បានជាគ្រាន់តែឃើញភ្លាម ចិត្តគិតនឹងប្រទូសរ៉ាយក៏កើតឡើងពេញកំហឹងហើយ វាយប្រហារព្រះថេរៈ ត្រង់សិរ្សៈ(ក្បាល) ធ្វើនូវអនន្តរិយកម្ម ជាបាបកម្មដ៏ធ្ងន់ សោយទុក្ខដ៏យូរអង្វែង អស់រយៈពេលមួយកប្ប។

ទោសអនន្តរិយកម្ម មានប្រាំសម្លាប់ មាតាមួយ សម្លាប់បិតាមួយ បំបែកសង្ឃមួយ ញុំាងលោហិតព្រះពុទ្ធឲពងមួយ សម្លាប់ព្រះអរហន្តមួយ ទោសទាំងប្រាំនេះបើធ្វើឲ្យព្រមទាំងអស់ ទោសបំបែកសង្ឃឲ្យផលមុន ។ ប៉ុន្តែអនន្តរិយកម្មប្រាំនេះ បើធ្វើមួយណាត្រូវធ្លាក់ទៅសោយទុក្ខក្នុងអវិចីមហានរកនោះមួយកប្បឬមួយអាយុផែនដីដូចគ្នា ។

ព្រះមហាមោគ្គល្លាន បានឃើញយក្សនោះ កំពុងប្រហារចំព្រះសិរ្សៈព្រះសារីបុត្ត ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា លុះឃើញ

ហើយក៏ចូលទៅរកព្រះសារីបុត្តក៏និយាយនឹងព្រះសារីបុត្តថា ម្នាលអាវុសោលោក ល្មមអត់ធន់បានដែរឬ ល្មមប្រព្រឹត្តទៅបានដែរឬ មិនមានសេចក្តីទុក្ខតិចតួចទេឬ? ព្រះសារីបុត្តប្រាប់ថា ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមអត់ធន់បាន ខ្ញុំល្មមប្រព្រឹត្តទៅបាន តែមានសេចក្តីទុក្ខបន្តិច ត្រង់ក្បាលរបស់ខ្ញុំ ។

ម្នាលអាវុសោសារីបុត្ត អស្ចារ្យណាស់ ចម្លែកណាស់ ព្រោះថាសារីបុត្តដ៏មានអាយុ មានឫទ្ធិច្រើន មានអានុភាពច្រើន ។ ម្នាលអាវុសោសារីបុត្តក្នុងទីនេះ មានយក្សមួយ ប្រហារចំព្រះសិរ្សៈនៃលោក ការប្រហារនោះ ពេញជាការប្រហារខ្លាំង ឯយក្សនោះអាចពន្លិចដំរីមានកម្ពស់៧ហត្ថ ឬ៨ហត្ថ ឲ្យស្រុតទៅក្នុងផែនដីបាន អាចធ្វើកំពូលភ្នំធំឲ្យបែកខ្ទេចខ្ទីបាន ដោយការប្រហារនោះ ។ ហេតុអ្វីក៏ព្រះសារីបុត្តដ៏មានអាយុ និយាយយ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមអត់ធន់បានល្មមប្រព្រឹត្តទៅបាន តែថាមានសេចក្តីទុក្ខបន្តិចត្រង់ក្បាលរបស់ខ្ញុំ ។

ម្នាលអាវុសោមោគ្គល្លានអស្ចារ្យណាស់ ចម្លែកណាស់ ព្រោះថាមហាមោគ្គល្លានដ៏មានអាយុមានឫទ្ធិច្រើន មានអានុភាពច្រើន មើលយក្ខឃើញបាន ចំណែកខាងយើងមិនឃើញសូម្បីបិសាច ដែលអាស្រ័យនឹងអាចម៍ដី[39]សោះឡើយ។

ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់ពាក្យចរចា មានសភាពយ៉ាងនេះរបស់ព្រះមហាថេរៈទាំងពីរអង្គនោះ ដោយទិព្វសោតធាតុដ៏បរិសុទ្ធ កន្លងសោតធាតុរបស់មនុស្សធម្មតា ។

**អថខោ ភគវា ឯតមត្ថំ**
**វិទិត្វា តាយំ វេលាយំ**
**ឥមំ ឧទានំ ឧទានេសិ**
**យស្សសេ លុបមំ**
**ចិត្តំ ឋិតំ នានុបកម្បតិ**

[39] សំដៅយកប្រេតតូចៗ ដែលត្រាចរង្គាតក្នុងទីទាំងឡាយ មានគំនស់រាមជាដើម ។

**ទិវត្តំ វេនីយេសុ កោបនេយ្យេ នកុប្បតិ**
**យស្សេវំ ភាវិតំ ចិត្តំ**
**កុតោតំ ទុក្ខមេស្សតីតិ ចតុត្ថំ ។**

លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបបន្លឺឧទាននេះ ក្នុងវេលានោះថា ចិត្តរបស់បុគ្គលណា មានឧបមាដោយថ្មតាន់ នៅនឹងមិនញាប់ញ័រ ប្រាសចាកតម្រេក ក្នុងហេតុគួរីករាយទាំងឡាយ មិនក្រោធក្នុងវត្ថុគួរក្រោធ ចិត្តដែលបុគ្គលណា បានចម្រើនយ៉ាងនេះហើយ សេចក្តីទុក្ខនឹងមានមកដល់បុគ្គលនោះអំពីណាបាន ។

## ៣៤. រឿងនាងចិញ្ចាមាណវិកា[40]

(ធ្លាក់អវិចីមហានរក ព្រោះតែនិយាយមូលបង្កាច់...)

នៅក្នុងបឋមពោធិកាល ព្រះកិត្តិនាមនៃព្រះបរមសាស្តាល្បីល្បាញខ្ចរខ្ចាយសព្វទិសទី ពួកទេវតានិងមនុស្សទាំងឡាយបានសម្រេចនូវអរិយធម៌ ដោយបានស្តាប់ធម្មទេសនាព្រះអង្គ ម៉្លោះហើយលាភសក្ការៈកើតឡើងដល់ព្រះអង្គប្រៀបដូច ទឹកដែលហូរចូលកាន់មហាសមុទ្រ រីឯពួកនិគ្រណ្ឋតិរ្ថិយត្រូវសាបសូន្យចាកលាភ សក្ការៈ ប្រៀបដូចជាអំពិលអំពែកចាញ់រស្មីនៃព្រះអាទិត្យ ។ ដោយលាភសក្ការៈ សាបសូន្យយ៉ាងនេះ ពួកតិរ្ថិយទៅជាអាក់អន់ស្រពន់តូចចិត្ត ទើបប្រជុំគ្នាក្បែរផ្លូវធំមួយ ពិភាក្សារកមធ្យោបាយ ដើម្បីបន្ថុះបង្អាប់ព្រះកិត្តិនាមនៃព្រះបរមសាស្តា ដោយសេចក្តីថា ព្រះសមណគោតម ជាព្រះពុទ្ធអ្នកត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ឯពួកយើងក៏ត្រាស់ដឹងដូចគ្នាដែរ ទានដែលគេឲ្យដល់ព្រះសមណគោតមឈ្មោះថា បានផលានិសង្សច្រើនបើឲ្យដល់យើងផងក៏មានផលានិសង្សច្រើនដូចគ្នា ចុះហេតុដូចម្តេចបានជាគេឲ្យតែព្រះសមណគោតម គេមិនឲ្យពួកយើង? បើដូច្នេះ យើងគិតរកមធ្យោបាយយ៉ាងណា ដើម្បីបំផ្លាញព្រះកិត្តិនាមព្រះសមណគោតម គ្រានេះម្តងទើបសម្រេចចិត្តគិតឃើញឧបាយ

---

[40] ប្រជុំនិទានជាតកភាគ៥ ទំព័រ ៨២៧

មួយថា អើ! អាំ! នៅក្រុងសាវត្ថី មានស្ត្រីម្នាក់ឈ្មោះនាងចិញ្ចាមាណវិកា មានរូបសម្ប័ទល្អៈល្អឆើតឆាយគួរជាទី ប្រតិព័ទ្ធស្នេហានៃជនទាំងពួង មានរស្មីចេញពីខ្លួនដូចទេពកញ្ញា ទាំងប្រាជ្ញាក៏ឈ្លាសវៃល្មមយើងពឹងពាក់យកជាការបាន បើអញ្ចឹងពួកយើងត្រូវជួលនាង ព្រមទាំងប្រាប់ឧបាយកលផ្សេងៗឲ្យនាងធ្វើតាម ។

លុះគិតគ្នាស្រេចហើយ ក៏ចាត់ការតាមសេចក្តីសម្រេចចិត្តនោះ នាងចិញ្ចាមាណវិកា កាលបើបានទទួលរង្វាន់ពីពួកតិរ្ថិយហើយ ក៏ទទួលភារៈធ្វើតាមបញ្ជាពួកតិរ្ថិយដោយសំដែងមាយាដូចតទៅ៖

ថ្ងៃមួយក្នុងពេលដែលព្រះបរមសាស្តា កំពុងសម្តែងធម្មទេសនាក្នុងវត្តជេតពន ប្រោសពុទ្ធបរិស័ទ នាងចិញ្ចាមាណវិកាតែងដណ្តប់សំពត់ពណ៌ដូចមេធ្លៀង ដើរតម្រង់ទៅកាន់វត្តនោះសំដែងអាការៈហាក់ដូចជានាងមានទីលំនៅតែក្នុងវត្តហ្នឹងឯង ។ កាលបើមានមហាជនសួរ នាងប្រាប់ថាខ្ញុំជាមហេសីព្រះសមណគោតម ។ នាងចិញ្ចាមាណវិកាតែងដើរ ចេញចូលក្នុងវត្តជេតពនអស់វារៈពីរ បីខែ លុះដល់ខែទី៤ ទី៥ នាងយកកំណាត់សំពត់រុំពោះនាង រួចទទូរសំពត់ក្រហម សំដែងអាការៈហាក់ដូចជាមានផ្ទៃពោះ ដើរឃោសនាប្រាប់ពួកជនអន្ធពាលថា នាងមានផ្ទៃពោះជាមួយព្រះសមណគោតម ពួកជនអន្ធពាលល្ងង់ខ្លៅ ដែលមាន ប្រាជ្ញាស្តួចស្តើងក៏ជឿថា ជារឿងពិតមែន ។ លុះដល់ខែទី៨ ទី៩ ជួលជាងឲ្យ ធ្លាក់ឈើឲ្យមានសណ្ឋានមូល រួចចងភ្ជាប់នឹងពោះធ្វើហាក់ដូចជាពោះកាន់តែធំឡើងៗ ជិតគ្រប់ខែហើយ នាងជួលឲ្យគេដំសាច់ខ្នងជើងឲ្យមានសាច់ ដូចជាស្ត្រី មានផ្ទៃពោះ រួចដើរសន្សឹមៗចូលទៅក្នុងចំណោមពុទ្ធបរិស័ទដែលកំពុងស្តាប់ធម៌ ស្រែកប្រកាសឡើងថា នែសមណគោតម! លោកនៅសម្តែងធម៌យ៉ាងម៉េចទៀត? ខ្ញុំមានកូនក៏ព្រោះតែលោករួមរស់មេត្រីប្រពៃណីជាមួយខ្ញុំ ម្តេចក៏លោកមិនរកផ្ទះសម្បែងអុសភ្លើងទុកឲ្យខ្ញុំប្រសូតកូន

បើលោកមិនធ្វើខ្លួនឯងទេគួរតែប្រើអ្នកណាធ្វើក៏បានដូចជា អនាថបិណ្ឌិក ឬនាងវិសាខាជាដើម លោកបានតែស្វែងរស់ត្រេកត្រអាលកាមរាគៈជាមួយខ្ញុំ តែដល់ខ្ញុំមានផ្ទៃពោះ លោកមិនចេះថែរក្សាទេ នៃ! នៅសម្តែងធម៌ដល់ណាទៀត!

គ្រានោះព្រះសាស្តាបង្អាក់ធម្មទេសនា រួចទ្រង់មានព្រះពុទ្ធដីកាថា អើនាង! មានតែយើងទាំងពីរនាក់គត់ដែលដឹងថា "រឿងនេះជារឿងពិតឬពុំពិតនៅថ្ងៃក្រោយ" ចូរនាងជ្រាបតែប៉ុណ្ណេះចុះ ។ នាងថាត្រូវហើយរឿងនេះមានតែយើងពីនាក់ដែលដឹង ព្រោះយើងជាអ្នកធ្វើ ។ មហាជនសង្ស័យយី! យ៉ាងម៉េចអញ្ចឹងសម្តែងធម៌កំពុងតែពីរោះម៉េចក៏ធ្វើអញ្ចឹង!

លំដាប់នោះដោយអំណាច បារមីនៃព្រះសាស្តា ក៏ក្តៅដល់អាសនៈរបស់ព្រះឥន្ទ្រ ព្រះឥន្ទ្រក៏តំណែងខ្លួនជាបុរសមួយឈរកាន់ផ្លិតបក់ថ្វាយព្រះសាស្តា ហើយបក់ខ្លាំងៗ គ្រាតែសំពត់រុំពោះនាងចិញ្ចាមាណវិការបើកប៉ើងអស់ពីខ្លួន ។ ពួកមហាជនឃើញដូច្នេះ ក៏ជេរប្រទេចផ្តាសាថា "នែមេកាឡកណ្ណី! មេចោរធន្ធា! ហងឯងបានតែបង្ខូចកិត្តិនាមព្រះសាស្តាយើង" រួចយកដំបងដេញឲ្យចេញពីទីប្រជុំនោះភ្លាម ។ ចិញ្ចាមាណវិកា គ្រាន់តែចេញផុតពីព្រះកក្រ្ត ព្រះសាស្តាមក ស្រាប់តែផែនដីស្រូបទម្លាក់ ទៅក្នុងគំនរភ្លើងអវិចីមហានរក ។ ឯពួកតិរ្ថិយរឹតតែលិបរស្មីថែមទៀត ឯលាភសក្ការៈរឹតតែកើតឡើងៗដល់ព្រះសាស្តា ។

ក្នុងពេលជាមួយនោះព្រះសាស្តាទ្រង់សំដែងថា "អ្នកណាក៏ដោយ បើមិនទាន់ឃើញទោសកំហុសតូចធំរបស់អ្នកដទៃទេ មិនត្រូវទម្លាក់កំហុសតែផ្តេសផ្តាសដល់គេទេ ត្រូវពិចារណាមើល ឬយកការណ៍ឲ្យច្បាស់សិន" ។

រួចសម្តែងរឿងមហាបទុមកុមារដូចតទៅៈ

សេចក្តីថា ក្នុងកាលនោះ នាងចិញ្ចាមាណវិកានេះ ជាស្ត្រីរួមប្តីជាមួយមាតាមហាបទុមកុមារ ជាទេពីចុងនៃព្រះរាជាមួយអង្គ ។ ថ្ងៃមួយ ក្នុងពេលដែល

ព្រះរាជាយាងទៅក្រសាលព្រៃផុតទៅ នាងបានលួងលោមមហាបទុមកុមារឲ្យធ្វើសន្ថវកិច្ចជាមួយនាង តែមហាបទុមកុមារពុំព្រម នាងក៏សម្តែងអាការៈហាក់ដូចជាអាក់អន់ស្រពន់ចិត្តក្លែងទោសថា មហាបទុមកុមារសង្កត់សង្កិនបង្ខំខ្លួនដោយអសទ្ធម្ម ថ្វាយស្វាមីក្នុងគ្រាដែលយាងមកដល់ ។

ក្នុងខណៈនោះព្រះរាជាទ្រង់ពិរោធ ក៏ចាត់ប្រើពេជ្ឈឃាតឲ្យចាប់បទុមកុមារទៅទម្លាក់ក្នុងជ្រោះ សម្រាប់ទម្លាក់ចោរ តែទេវតាដែលនៅអាស្រ័យក្បែរជ្រោះ បីទ្រហើយយកទៅដាក់ឲ្យគង់នៅឯពិភពនាគ ។ នៅក្នុងពិភពនាគមិនយូរប៉ុន្មាន បទុមកុមារក៏ទៅបួសជាឥសីនៅក្នុងព្រៃហិមពាន្ត បានសម្រេចឈាននិងអភិញ្ញា ។ ថ្ងៃមួយព្រានព្រៃម្នាក់បានជួបនឹងបទុមតាបស ក៏នាំដំណឹងនោះទៅថ្វាយព្រះមហាក្សត្រ ។ ព្រះមហាក្សត្រទ្រង់មានព្រះទ័យអាល័យបុត្រទ្រង់យាងទៅនិមន្តបទុមតាបស ឲ្យមកសោយរាជ្យវិញ តែតាបសទេសនាទូន្មានឲ្យព្រះបិតាគ្រប់គ្រងរាជ្យ ដោយទសពិធរាជធម៌ចុះ កុំឲ្យប្រកាន់អគតិដោយមិនបានពិចារណាជាមុន ។

ឯព្រះមហាក្សត្រយាងត្រឡប់មកនគរវិញ មានព្រះឱង្ការជាមួយមហាមាត្យថា កូនយើងមានអាចារៈសមរម្យយ៉ាងនេះ មិនគួរយើងធ្វើដូច្នេះសោះ អ្នកណាធ្វើឲ្យកូនយើងមានទោសដល់ម្លឹង? មហាមាត្យក្រាបទូលថា មានតែព្រះទេពីចុងទេ! ។ ព្រះរាជាទ្រង់បញ្ជាឲ្យចាប់ទេពីចុង យកទៅប្រហារជីវិតក្នុងគ្រានោះ ហើយសោយរាជដោយធម៌រហូតមក ព្រោះហេតុនោះមុននឹងទម្លាក់កំហុសទៅលើនរណាមួយ បុគ្គលត្រូវស៊ើបរកការណ៍ពិតឲ្យឃើញច្បាស់ ឬពិចារណាមើលឲ្យសព្វគ្រប់សិនមុននឹងវិនិច្ឆ័យ ។

[41] គាថាធម្មបទវិប្រែ ទំព័រ២២

## ៣៥. រឿងនាយចុន្ទសូករិក[41]

(ធ្លាក់អវិចីមហានរក ព្រោះតែសម្លាប់សត្វ)

ព្រះបរមសាស្តា ទ្រង់ប្រារព្ធបុរសម្នាក់ ឈ្មោះនាយចុន្ទសូករិកនេះ ជាមនុស្សដែលកាចសាហាវខ្លាំងណាស់ ប្រាសចាកមេត្តាគិតតែពីកាប់សម្លាប់ជ្រូកយកសាច់លក់ចិញ្ចឹមជីវិតអស់រយៈពេល៥៥ឆ្នាំ គាត់មិនដែលបានធ្វើបុណ្យឲ្យទានអ្វីៗបន្តិចសោះ ថ្ងៃដែលគាត់បានឃើញបាបកម្មដ៏កាចសាហាវរបស់គាត់នោះ គឺនៅថ្ងៃដែលគាត់ជិតនឹងស្លាប់ គាត់មានការក្តៅក្រហល់ក្រហាយអន្ទះអន្ទែងវារទៅមកបីដូចជាភ្លើងក្នុងអវិចីមហានរក ដុតរោលទាំងរស់ បម្រះនៀលដូចជាសត្វជ្រូក ដែលគាត់បានច្រកទឹកក្តៅចូលទៅក្នុងមាត់ ដើម្បីនឹងសម្លាប់យ៉ាងនោះឯង គាត់ទទួលនូវសេចក្តីទុក្ខវេទនាបែបនេះរហូតដល់៧ថ្ងៃទើបបានធ្វើមរណកាល ស្លាប់អស់អាយុសង្ខារ ទៅកើតសោយទុក្ខទោសយ៉ាងធ្ងន់ នៅក្នុងអវិចីមហានរក ។

ពេលដែលនាយចុន្ទសូករិក កំពុងតែទទួលវេទនាវាងៗថ្ងៃនោះពួកភិក្ខុទាំងឡាយបាននិមន្តចូលទៅបិណ្ឌបាត ក្បែរផ្ទះនាយចុន្ទសូករិកនោះ បានឮសូរសំឡេងគាត់ស្រែកទ្ងូរយំបីដូចជាសំឡេងសត្វជ្រូកស្រែក ទើបយករឿងនោះទៅក្រាបទូលដល់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ត្រាស់ថា "សំឡេងនោះមិនមែនជាសំឡេងជ្រូកស្រែកទេគឺជាសំឡេងរបស់នាយចុន្ទសូករិក" ហើយព្រះអង្គត្រាស់នូវព្រះគាថានេះថា៖

**ឥធ សោចតិ បេច្ច សោចតិ**
**បាបការី ឧភយត្ថ សោចតិ**
**សោ សោចតិ សោ វិហញ្ញតិ**
**ទិស្វា កម្មកិលិដ្ឋមត្តនោ ។**

អ្នកដែលធ្វើអំពើបាបកម្ម រមែងសោកសៅក្នុងលោកទាំងពីរ គឺរមែងសោកសៅក្នុងលោកនេះផង សោកសៅក្នុងលោកខាងមុខផង, គេរមែងសោកសៅក្ដៅក្រហល់ក្រហាយព្រោះឃើញកម្មដែលសៅហ្មងរបស់ខ្លួន ។

## ៣៦. រឿងឧប្បលវណ្ណាថេរី[42]

(ធ្លាក់មហាអវិចីនរក ព្រោះតែប្រទូសរ៉ាយព្រះខីណាស្រព)

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនាងឧប្បលវណ្ណាថេរី ជាធីតារបស់សេដ្ឋីក្រុងសាវត្ថី ។ កាលនៅជាគ្រហស្ថ មានព្រះរាជា និងមហាសេដ្ឋីជាច្រើនចង់បាននាងមកធ្វើជាមហេសី ។

លោកសេដ្ឋីជាបិតា មានការចង្អៀតចង្អល់ចិត្តយ៉ាងខ្លាំងពុំដឹងជាធ្វើយ៉ាងណាបាន គឺមិនដឹងជាលើកកូនក្រមុំឲ្យទៅអ្នកណា? ទើបបានបង្ហាញផ្លូវម្យ៉ាងឲ្យនាងទៅបួសជាភិក្ខុនី ។ នាងឧប្បលវណ្ណាបានឮបិតាប្រាប់ផ្លូវឲ្យយ៉ាងដូច្នេះហើយមានចិត្តត្រេកអរខ្លាំងណាស់ ហើយបានចូលបួសជានាងភិក្ខុនីនៅក្នុងសំណាក់នៃនាងភិក្ខុនីទាំងឡាយ មិនយូរប៉ុន្មាននាងក៏បានសម្រេចជាព្រះអរហត្តផល ។

គ្រានោះនន្ទមាណព ដែលជាកូនឪពុកធំរបស់នាង មានចិត្តស្រលាញ់នាងឧប្បលវណ្ណាថេរី តាំងតែអំពីពេលដែលនាងនៅជាគ្រហស្ថម្ល៉េះ លុះបានឱកាសល្អហើយនន្ទមាណព ក៏បានចូលទៅប្រទូសរ៉ាយចាប់រំលោភលើនាងឧប្បលវណ្ណាថេរី បានសម្រេចដូចបំណងរបស់ខ្លួន ។

នៅពេលជាមួយគ្នានោះ ព្រះធរណីមិនអាចនឹងទ្រ នូវជនពាលនោះបានឡើយ បានប្រេះបែកញែកជាពីរបំណែក ស្រូបយកនន្ទមាណពចូលទៅដល់កាន់មហាអវិចីនរក ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា "ព្រះខីណាស្រពទាំងឡាយត្រេកអរនឹងកាមសុខនៅតែសេពកាម" ។

---

[42] គាថាធម្មបទវិប្រែ ទំព័រ ១០៧

ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយព្រះខីណាស្រពទាំងឡាយ មិនត្រេកអរក្នុងកាមសុខ មិនមានចិត្តជាប់ជំពាក់ក្នុងកាមដូចជាតំណក់ទឹកមិនជាប់លើស្លឹកឈូកយ៉ាងនោះឯង" ហើយត្រាស់គាថានេះថា៖

**មធុវា មញ្ញតី ពាលោ**
**យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ**
**អថ ទុក្ខំ និគច្ឆតិ ។**

ដរាបណា បាបមិនទាន់ហុចផលឲ្យ, ដរាបនោះបុគ្គលពាល សំគាល់ថាបាបមានរសជាតិផ្អែម ដូចជាទឹកឃ្មុំ, ពេលណាបាបឲ្យផល, ពេលនោះបុគ្គលពាលនឹងបានជួបប្រទះនូវសេចក្តីទុក្ខដោយពិតប្រាកដ ។

## ៣៧. រឿងជម្ពុកាជីវក[43]

(ធ្លាក់មហាអវិចីនរក ព្រោះជេរព្រះខីណាស្រព)

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវជម្ពុកាជីវកម្នាក់នៅក្នុងសាសនានៃព្រះពុទ្ធព្រះនាមកស្សបជម្ពុកាជីវកនេះ ធ្លាប់បានបួសជាភិក្ខុប្រព្រឹត្តមិនល្អបានជេរប្រទេចព្រះខីណាស្រពមួយអង្គ ដោយផលវិបាកនៃកម្មនោះឯង លុះស្លាប់ទៅក៏បានទៅសោយទុក្ខវេទនាយ៉ាងធ្ងន់ នៅក្នុងមហាអវិចីនរកអស់មួយពុទ្ធន្តរចន្លោះព្រះពុទ្ធមួយអង្គ ដល់សាសនានៃព្រះសមណគោតមនេះបានមកកើតជាមនុស្ស នៅក្រុងរាជគ្រឹះដើរស្រាតមិនស្លៀកពាក់ខោអាវមិនស៊ីបាយស៊ីតែលាមកប៉ុណ្ណោះ ចូលចិត្តដេកលើផែនដី នៅពេលដែលមានសក់វែងយកជង្កាប់គ្រាប់ត្នោតមកចាប់ដក ។ ពួកមហាជន ភាគច្រើនបាននិយមរាប់អាន ជ្រះថ្លានឹងជម្ពុកាជីវកនេះខ្លាំងណាស់បាននាំយកម្ហូបអាហារ ជាច្រើនទៅល្បួងលោមដើម្បីឲ្យគាត់បរិភោគ ។ ជម្ពុកាជីវកមិនព្រមបរិភោគសោះ គ្រាន់តែយកចុង

---

[43] គាថាធម្មបទប្រែ ទំព័រ ១០៩

ស្បូវភ្លាំង មកជ្រលក់ផ្ដិតនឹងម្ហូបអាហារ ហើយយកទៅដាក់លើចុងអណ្ដាត់ប៉ុណ្ណោះឯង គាត់ប្រព្រឹត្តធ្វើយ៉ាងនេះអស់រយៈពេល៥៥ឆ្នាំ ។

សម័យនោះ ព្រះសាស្ដាទ្រង់បានទតព្រះនេត្រឃើញ នូវឧបនិស្ស័យហើយ ទើបទ្រង់យាងចូលទៅជិតៗគាត់ ។ នៅក្នុងបឋមយាមមហារាជទាំង៤អង្គ បានចូលទៅគាល់ព្រះសាស្ដាក្នុងមជ្ឈិមយាម សក្កទេវរាជបានចូលមកគាល់ ក្នុងបច្ឆិមយាមមហាព្រហ្មបានចូលមកគាល់ មានពន្លឺភ្លឺស្វាងយ៉ាងត្រចះត្រចង់រហូតរាត្រី ។ ជម្ពុកាជីវក បានឃើញហើយនឹកអស្ចារ្យ ចំឡែកក្នុងចិត្តយ៉ាងខ្លាំង ព្រឹកឡើងបានចូលទៅ ក្រាបទូលសួរដល់ព្រះសាស្ដា ព្រះអង្គទ្រង់បានទេសនា ពន្យល់ឲ្យជម្ពុកាជីវកបានសម្រេចជាព្រះអហត្តផល ។

គ្រានោះពួកប្រជាជន ជាច្រើនបានមកក្នុងទីនោះដែរ កើតសេចក្ដីសង្ស័យថា "ព្រះសមណគោតម" និងជម្ពុកាជីវក តើអ្នកណាធំជាងអ្នកណា?

ព្រះសាស្ដាទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់បញ្ជាឲ្យព្រះថេរៈ គឺជម្ពុកាជីវកដោះស្រាយនូវ សេចក្ដីសង្ស័យរបស់ប្រជាជន កុំឲ្យមានការសង្ស័យតទៅទៀតហើយត្រាស់នូវព្រះគាថានេះថា៖

**មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ**
**នសោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ ។**

ជនពាលគប្បីបរិភោគភោជនាហារ ដោយចុងស្បូវខ្លាំងរាល់ៗខែ, គេមិនបានដល់នូវចំណែកទី១៦ នៃព្រះអរិយបុគ្គល ដែលលោកមានធម៌ កំណត់រាប់បានហើយទាំងឡាយតាំងពីសោតាបន្នឡើងទៅ ។

[44] គាថាធម្មបទប្រែ ទំព័រ ៣៤៥

## ៣៨. រឿងគោឃាតកបុត្រ[44]

(ធ្លាក់អវិចីនរក ព្រោះកាចសាហាវឃោរឃៅ)

ព្រះបរមសាស្តា ទ្រង់ប្រារព្ធបុត្ររបស់នាយគោឃាតកបិតា ជាអ្នកសម្លាប់គោចិញ្ចឹមជីវិត បើថ្ងៃណាគាត់មិនបានសាច់គោទេ ថ្ងៃនោះគាត់បរិភោគអាហារក៏មិនបានដែរ វេលាថ្ងៃមួយ គាត់រកសាច់គោមិនបាន ទើបចាប់កាំបិតដើរតម្រង់ទៅរកគោ ដែលកំពុងឈរនៅក្រោយផ្ទះ ដល់ហើយក៏លូកដៃចូលទៅក្នុងមាត់គោនោះ ហើយទាញអណ្តាតគោមកកាត់ ស្រេចហើយក៏យកអណ្តាតគោនោះទៅអាំង ដើម្បីបរិភោគជាមួយនឹងបាយ ។

ពេលនោះស្រាប់តែ អណ្តាតរបស់នាយគោឃាតដាច់ចេញពីក្នុងមាត់ធ្លាក់ទៅលើចានបាយ គាត់បានទទួលនូវបាបកម្មឃើញប្រាកដទាន់ភ្នែក ក្នុងបច្ចុប្បន្ន ស្រែករោទិ៍ដូចជាគោដែលគាត់បានសម្លាប់ លុះគាត់ស្លាប់ហើយក៏បានទៅកើតនៅក្នុងអវិចីនរក ។ ចំណែកឯកូនរបស់នាយគោឃាតកបានឃើញយ៉ាងនេះហើយ ក៏ភ័យខ្លាចយ៉ាងខ្លាំងចំពោះមរណភ័យ បានរត់ទៅរស់នៅឯនគរតក្កសិលាបានភរិយា និងបុត្រនៅនគរនោះ ។ តមកបុត្ររបស់គាត់បានទៅរស់នៅឯក្រុងសាវត្ថីជាអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយបាននាំបិតារបស់ខ្លួនឲ្យទៅរស់នៅជាមួយផង ។

ថ្ងៃមួយគាត់បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមកឆាន់នូវភត្តាហារ នៅផ្ទះរបស់ខ្លួនក្រាបទូលនិមន្តព្រះសាស្តាសុំឲ្យព្រះអង្គធ្វើអនុមោទនាដើម្បីបិតារបស់ខ្លួន ។ ព្រះអង្គទ្រង់ត្រាស់ព្រះគាថានេះថា៖

**បណ្ឌុបលាសោវ ទានិសិ**
**យមបុរិសាបិ ច តេ ឧបដ្ឋិតា ។**

ខ្លួនអ្នកក្នុងកាលឥឡូវនេះ ជាបុគ្គលប្រៀបដូចស្លឹកឈើទុំ មានពណ៌លឿង, បុរស (ជាបម្រើ) នៃយមរាជគឺមរណៈ ក៏ប្រាកដដល់អ្នកហើយ ។

**ឧយ្យោគមុខេ បតិដ្ឋសិ**
**បាថេយ្យំបិ ច តេ នវិជ្ជតិ ។**

អ្នកជាបុគ្គលស្ថិតនៅក្នុង ប្រធាននៃសេចក្តីសាបសូន្យ, ស្បៀងគឺកុសលរបស់អ្នកសោតក៏គ្មាន ។

**សោ ករោហិ ទីបមត្តនោ**
**ខិប្បំ វាយម, បណ្ឌិតោ ភវ ។**

អ្នកចូរធ្វើនូវទីពឹងនៃខ្លួនចុះ, ចូរតាំងព្យាយាមរួតរះ, ចូរជាអ្នកឈ្លាស (កុំជាមនុស្សល្ងង់ខ្លៅឡើយ) ។

**និទ្ធន្តមលោ អនង្គណោ**
**ទិព្វំ អរិយភូមិមេហិសិ**

អ្នក (កាលធ្វើយ៉ាងនេះ) នឹងជាបុគ្គលមានមន្ទិល (មានរាគៈជាដើម), ខ្ចាត់ចេញ មិនមានគ្រឿងពួកគឺកិលេស ហើយនឹងដល់នូវអរិយភូមិដ៏ជាទិព្វ ។

**ឧបនីតវយោច ទានិសិ**
**សម្បយាតោសិ យមស្ស សន្តិកំ។**

ខ្លួនអ្នក ក្នុងកាលឥឡូវនេះ ជាបុគ្គលមានវ័យចូលដល់ជរាហើយ, ជាអ្នកជិតនឹងទៅកាន់ទៅកាន់សំណាក់នៃយមរាជហើយ ទីនៅអាស្រ័យរបស់អ្នកក៏មិនមានទៀត ។

**វាសោបិ ច តេ នត្ថិ អន្តរា**
**បាថេយ្យំបិច តេ ន វិជ្ជតិ ។**

ស្បៀងគឺកុសល របស់អ្នកសោត ក៏គ្មានដែរ, អ្នកចូរធ្វើនូវទីពឹងនៃខ្លួនចុះ ។

**សោ ករោហិ ទីបមត្តនោ**
**ខិប្បំ វាយម បណ្ឌិតោ ភវ ។**

ចូរតាំងព្យាយាមរួតរះ, ចូរជាអ្នកឈ្លាស (កុំជាមនុស្សល្ងង់ខ្លៅឡើយ) ។

**និទ្ធន្តមលោ អនង្គណោ**

**ន បុន ជាតិជរំ ឧបេហិសិ ។**

អ្នក (កាលធ្វើយ៉ាងនេះ) នឹងជាបុគ្គលមានមន្ទិល (មានរាគៈជាដើម) ខ្ជាត់ចេញមិនមានគ្រឿងពួនគឺកិលេស ហើយនឹងមិនចូលទៅដល់ជាតិ និងជរាតទៅទៀតឡើយ ។

## កម្មឲ្យផលតាមពូជដើម[45]

កម្មឲ្យផលតាមពូជដើម ព្រះសក្យមុនីគោតមជាបរមគ្រូនៃពុទ្ធសាសនិកជនទ្រង់ប្រកាសសាសនាដល់បរិស័ទ របស់ព្រះអង្គឲ្យជឿ កម្ម និងផលនៃកម្ម គឺឲ្យជឿថាកម្ម អំពើដែលសត្វលោកធ្វើដោយកាយ វាចា ចិត្ត មានល្អមានអាក្រក់ អំពើល្អហៅថាកល្យាណកម្មឬកុសលកម្ម អំពើអាក្រក់ហៅថា បាបកម្មឬអកុសលកម្ម ត្បិតកម្មគឺអំពើដែលខ្លួនធ្វើនេះតែងកើតមក ក៏សឹងមានផលកម្មជាប់មកផង ពុំមានឃ្លាត ជាពូជពង្សវស្សាគណាញាតិមិត្តសម្លាញ់ ថាបើអំពើអតីតខ្លួនបានប្រព្រឹត្តល្អ ឬអាក្រក់ ដល់ខ្លួនកើតមកនេះ ក៏ត្រូវតែទទួលនូវមរតកនោះៗពុំខាន បើក្នុងបច្ចុប្បន្នជាតិនេះខ្លួនយើងបានធ្វើនូវអំពើអ្វីមួយជាបុណ្យ ឬបាបទាំងប៉ុន្មាន លុះដល់ខ្លួនទម្លុះកាយទម្លាយខន្ធអំពីជាតិនេះទៅកាន់លោកខាងមុខទៀត ក៏មិនអាចនឹងឃ្លាតអំពីផលកម្មដែលខ្លួនបានធ្វើនោះឡើយ ។

មានជនពួកខ្លះក្នុងលោកនេះ ច្រើនយល់ជ្រុល បើខ្លួនបានប្រព្រឹត្តអំពើអ្វីមួយមិនគប្បី ហើយមានគេស្ដីបន្ទោស ខ្លួនក៏ឆ្លើយឡើងថា៖ ខ្ញុំមិនចង់ធ្វើប៉ុន្មានដែរ តែនេះវាបណ្ដាលមកពីកម្មរបស់ខ្ញុំទេ អើសំដីនេះបើស្ដាប់ទៅ ឃើញថានេះគេមានអត្តភាពមួយពូកែដែរ សូម្បីតែចិត្តគេមិនចង់ធ្វើផង តែកម្មនោះបង្វែរទៅផ្លូវណា ចិត្តរបស់គេក៏សឹងមានប្រទិចបែរទៅផ្លូវនោះ បើប្រសិនជាកម្មនោះដូច្នោះមែន ព្រះសម្ពុទ្ធជាម្ចាស់នៃយើង មិនមែនទ្រង់ប្រដៅឲ្យពួកបរិស័ទហាត់ធ្វើសីល សមាធិ បញ្ញាអ្វីដែរ បើទុកជាធ្វើទៅហើយក៏គ្មានប្រយោជន៍អ្វី ព្រោះវា

[45] វិធីបង្រៀនធម្មកថិកថ្មីឲ្យចេះទេសនា យិន វន់ ទំព័រ ៨០-៨៥

ស្រេចតែលើកម្មគេដឹកនាំទៅផ្លូវណាក៏បាន ។

ម្យ៉ាងទៀត បើថាកម្មនោះក្រៅចិត្តរបស់ខ្លួនមែន បុរសដែលចង់បានស្ត្រីជាភរិយា មិនចាំបាច់ទៅរកអ្នកផ្លូវចៅមហាទៅដណ្ដឹងរៀបអាពាហ៍ពិពាហ៍ នាំឲ្យខាតទុនសូន្យទ្រព្យនោះឡើយ ត្រូវតាំងចិត្តនៅឲ្យស្ងៀមតែម្យ៉ាង ទុកឲ្យកម្មគេចាត់វិធានការណ៍ ក៏គង់តែកម្មនោះចាប់ផ្សំផ្គុំគ្នាស្រេចមិនបាច់ខ្វល់ ។ សមដូចឧត្តមគតិបុរាណាចារ្យបានពោលថា សក់ល្អព្រោះប្រេង ទឹករីងព្រោះខ្យល់ កម្មអកុសលព្រោះចិត្ត ។

ដូច្នេះ ត្រង់ឧត្តមគតិនេះហើយ ដែលបុរាណាចារ្យបានលាតសន្ធឹងឲ្យឃើញច្បាស់ថា គឺជាតួចិត្តនេះឯងហើយដែលជារោងចក្រសម្រាប់ធ្វើផលិតកម្ម ។ កម្មជាកុសល ឬអកុសលតែងឲ្យអំណោយផលច្រើនប្រការ តែក្នុងឱកាសនេះអាត្មាភាពសូមសំដែងតែផលក្នុងសង្ខិតកថា ដូចតទៅនេះ ៖

សេចក្ដីថា បុគ្គលឯណាមានកម្មគឺអំពើដែលខ្លួនធ្វើ ទោះបីធ្វើកម្មជាកុសលក្ដី អកុសលក្ដីក្នុងបច្ចុប្បន្ន ហើយឲ្យអំណោយផលក្នុងបច្ចុប្បន្ន ផលនេះជាផលទិដ្ឋធម្មវេទនីយកម្ម បើឲ្យអំណោយផលបន្ទាប់អំពីជាតិនេះ ហៅថា ឧបបជ្ជវេទនីយកម្ម បើថាធ្វើក្នុងបច្ចុប្បន្នជាតិនេះ តែដល់ទៅជាតិទី៣ ឬច្រើនជាតិទៅទៀតទើបឲ្យផល ហៅថា អបរាបរវេទនីយកម្ម កម្មដែលផ្ដល់អំណោយផលកម្មផ្សេងពីគ្នាយ៉ាងនេះមានកន្លែងខ្លះសំដែងថា: ព្រោះជនដែលប្រព្រឹត្តធ្វើនូវកម្មនោះមានចេតនាមិនដូចគ្នា មានអន់មានក្លាហាន ។

ន័យមួយវិញទៀត ផលកុសលកម្ម និងអកុសលកម្មមានឲ្យផលកាត់មុខគ្នាក្នុងបច្ចុប្បន្នក៏មាន ដូចអង្គុលីមាលដែលធ្វើឃាតមនុស្សស្លាប់ច្រើនគឺ៩៩៩ នាក់ អំណោយផលត្រូវព្រះមហាក្សត្រចាប់ពិឃាដប្រហារជីវិត តែដោយអំណាចកម្មដែលបានបព្វជ្ជាជាបព្វជិត ហើយបានទាំងសម្រេចជាព្រះអរិយផល កម្មល្អ អាចទៅកាត់ផលអាក្រក់បានរួចខ្លួនទទេយ៉ាងនេះក៏មាន ឯផលកម្មអាក្រក់ទៅកាត់ផលល្អនោះ ដូចជាព្រះបាទអជាតសត្រូវជាព្រះមហាក្សត្រក្រុងមគធៈ បើ

តាមផលល្អ អំពីអតីតៈ មកត្រូវបានសម្រេចជាព្រះអរិយបុគ្គលក្នុងបច្ចុប្បន្នដែល ព្រះអង្គនៅក្នុងព្រះរាជសម្បត្តិ តែផលកម្មអាក្រក់ទៅកាត់ឧបនិស្ស័យ ព្រោះ ទ្រង់ធ្វើបិតុឃាតឲ្យព្រះបិតាក្ស័យព្រះជន្ម បានជាលោកឲ្យពិចារណាថា យើង ជាអ្នកទទួលនូវផលនៃអំពើនោះ បើមិនបានទទួលអំណោយផលខាងល្អ ក៏គង់ បានទទួលផលខាងអាក្រក់ឲ្យប្រែខានទទេសោះនោះពុំមានឡើយ ។

ដូចជាមានរឿងបញ្ជាក់ ឲ្យឃើញជាក់ច្បាស់ក្នុងគម្ពីរធម្មបទដ្ឋកថាដូចត ទៅ៖

## ៣៩. រឿងឧត្តរៈសាមណេរ

ក្នុងសាសនាព្រះសម្ពុទ្ធព្រះនាមសុមេធៈ មានវិជ្ជាធរមួយរូបនៅក្នុងព្រៃ ហិមពាន្ត ជាអ្នកមានសេចក្ដីជ្រះថ្លាមុតមាំក្នុងព្រះពុទ្ធសាសនា ។ ថ្ងៃមួយ ព្រះអរហន្តសម្ពុទ្ធ ព្រះនាមសុមេធៈ ទ្រង់យាងទៅកាន់ព្រៃហិមពាន្ត វិជ្ជាធរបាន ចូលទៅថ្វាយបង្គំបូជាផ្កាកណិការបីទង ដោយអំណាចជ្រះថ្លានឹងពុទ្ធតេជៈ ផ្កា ៣ទងនោះក៏ប្រតិស្ឋានលើអាកាសបាំងព្រះសម្ពុទ្ធ ហាក់ដូចជាបាំងទិព្វ ។ វិជ្ជាធរ នោះក៏មានបីតិសោមនស្ស ក្រៃលែងចំពោះពុទ្ធបូជារបស់ខ្លួន លុះអស់អាយុ បានទៅកើតទេវលោក នឹងមនុស្សលោកសោយសុខអស់កាលជាយូរ អង្វែង មិនដែលធ្លាប់ទៅអបាយភូមិម្ដងឡើយ អន្ទោលទៅមកទេវលោក និងមនុស្ស អស់ចំនួនព្រះពុទ្ធ១៥អង្គ ។ ចង់ជ្រាបច្បាស់សូមរាប់ ចំនួនព្រះពុទ្ធតាំង ពីព្រះពុទ្ធសុមេធៈ មកដល់ព្រះពុទ្ធសមណគោតម បរមគ្រូនៃយើង១៥ព្រះអង្គ គត់ក្នុងធម៌នមោមេ ។

លុះមកដល់សាសនាព្រះសមណគោតម បរមគ្រូយើងនេះបានកើតក្នុង ត្រកូលព្រាហ្មណ៍ មហាសាសនាក្រុងរាជគ្រឹះ មានឈ្មោះថា ឧត្តរកុមារ ជាអ្នក មានបញ្ញាឈ្លាសវៃ នឹងបរិបូណ៌ដោយរូបសម្បត្តិល្អឆើត ជាងអ្នកដទៃគេ ទាំងអស់។

ឧត្តរកុមារនេះ មានអាយុ១៦ឆ្នាំ មានព្រាហ្មណ៍ម្នាក់ឈ្មោះវស្សការជាមហាមាត្យ បានឃើញឧត្តរកុមារមានរូបល្អ ចង់បានធ្វើជាកូនប្រសា បានប្រើអ្នកបម្រើឲ្យទៅប្រាប់ដល់មាតាបិតារបស់ឧត្តរកុមារ ឲ្យចូលមកដណ្តឹងកូនក្រមុំរបស់ខ្លួន ។ ចំណែកឧត្តរកុមារឮដំណឹងនោះហើយ ក៏ហាមឃាត់មាតាបិតាមិនឲ្យចូល ទៅដណ្តឹង ព្រោះចង់ចេញទៅបួស មាតាបិតាក៏ព្រមតាម ។ មិនយូរប៉ុន្មាន ឧត្តរកុមារក៏បានលា មាតាបិតាចូលទៅបួសក្នុងសំណាក់ព្រះសារីបុត្ត ខំប្រតិបត្តិធម៌វិន័យដោយផ្ចិតផ្ចង់ ។

ថ្ងៃមួយព្រះសារីបុត្ត ជាឧបជ្ឈាយ៍មានអាពាធ ឧត្តរសាមណេរក៏លាឧបជ្ឈាយ៍ទៅរកថ្នាំ ទៅដល់ស្រះមួយដាក់បាត្រក្រោមដើមឈើចុះទៅស្រង់ទឹកក្នុងវេលាព្រឹកព្រហាម ពេលនោះជួនជាមានចោរលួចយកបង្វិច ទ្រព្យអ្នកនគរពួករាជអាមាត្យដេញតាម ចោរបានយកបង្វិចទ្រព្យ ទៅដាក់ក្នុងបាត្ររបស់សាមណេរហើយរត់ហួសទៅ ។ ពួករាជអាមាត្យទៅឃើញបង្វិចទ្រព្យនៅក្នុងបាត្រ ក៏ចាប់សាមណេរនោះយកមកឲ្យវស្សការព្រាហ្មណ៍ជាមហាមាត្យ ដោយសម្គាល់ថាៈ សាមណេរនោះជាចោរពិត ។ វស្សការមហាមាត្យស្គាល់ជាក់ថាឧត្តរសាមណេរហើយ ក៏កើតសេចក្តីក្រោធឡើង ព្រោះចងគំនុំនឹងឧត្តរសាមណេរដែលមិនព្រម ទទួលយកកូនក្រមុំរបស់ខ្លួនបានប្រើឲ្យពេជ្ឈឃាតចាប់ចងស្លាបសេកយកទៅដោតលើចុងឈើ ចាក់ទម្លុះទម្លាយមានឈាមហូរពាសពេញខ្លួន ។ សាមណេរខំអត់អន់មិនអើពើនឹងការចាក់ដោតនោះឡើយ ខំបញ្ជូនចិត្តទៅរកឧបជ្ឈាយ៍នឹកថា បាននរណាយកថ្នាំទៅប្រគេនឧបជ្ឈាយ៍របស់អញ! ម្ល៉េះលោកចាំមើលផ្លូវអញយ៉ាងណាទៅហ្ន៎! កំពុងតែគិតដូច្នោះ ព្រះសារីបុត្តជាឧបជ្ឈាយ៍លោកជ្រាបថាៈ

ឧត្តរសាមណេរកំពុងត្រូវទោសជាទម្ងន់ ក៏ទៅក្រាបទូលដល់ព្រះសម្ពុទ្ធទ្រង់ជ្រាបថា សាមណេរនេះមាននិស្ស័យខ្ពស់ល្មមព្រះអង្គទៅជួយសង្គ្រោះបាន

ក៏ស្តេចយាងទៅដល់ទីនោះមួយរំពេច ជាមួយនឹងភិក្ខុសង្ឃជាច្រើនពាន់អង្គ ។

ឯឧត្តរសាមណេរ កាលបើឃើញព្រះសម្ពុទ្ធស្តេចយាងទៅដល់ហើយក៏ថ្លែងសេចក្តីទុក្ខរបស់ខ្លួនថ្វាយព្រះសម្ពុទ្ធៗ ទ្រង់យកព្រះហស្តស្ទាបព្រះសិរ្សឧត្តរសាមណេរយ៉ាងថ្នាក់ថ្នម មានពន្លឺរស្មីផ្សាយចេញពីព្រះហស្តក្នុងនោះ ទើបមានព្រះពុទ្ធដីកាថា: ម្នាលសាមណេរអ្នកកុំតូចចិត្ត អំពើនេះជាអំពើរបស់អ្នកបានសន្សំទុក្ខមកយូរហើយ អ្នកទទួលទុក្ខលំបាកម្តងនេះ ជាទីបំផុតហើយលែងមានតទៅទៀត ទ្រង់រំលឹកយ៉ាងនេះហើយ ទ្រង់នាំអតីតៈនិទានមកសម្តែងប្រាប់ថា:

កាលកន្លងយូរយាណាស់ហើយ នេនឯងកើតជាកូនអ្នកស្រែបានចាប់រុយយកបន្លាដោតគូថ ហើយយកទៅដោតភ្ជាប់នឹងសម្បកស្តៅសើចលេងសប្បាយមាតាបិតាស្តីបន្ទោស បានចំអកឲ្យវិញថា បើមិនឲ្យដោតរុយលេង មានតែដោតម៉ែឪឯងលេង ។ ដោយអំពើអាក្រក់នេះឯង បានជានេនឯង ទទួលសេចក្តីលំបាកដោយគេដោតឲ្យដេកលើឈើអណ្តោតរាប់រយពាន់ ជាតិមកហើយ ។ ម្យ៉ាងទៀតដែលតថាគតមកជួយសង្គ្រោះនេះ ដោយផលដែលនេនឯងកើតជាវិជ្ជាធរបានបូជាផ្កាកណិកាពាទងដល់ព្រះសម្ពុទ្ធព្រះនាម សុមេធៈ ។

កាលបើព្រះសម្ពុទ្ធសម្តែងបុព្វកម្មចប់ហើយ ឧត្តរសាមណេរ ក៏សម្រេចជាព្រះអរហត្តផល ព្រមទាំងបដិសម្ភិទា ហើយទៅឰដ៏អាកាសធ្វើបដិហារ្យ ថ្វាយព្រះសាស្តាយ៉ាងអស្ចារ្យដល់ទីបំផុតព្រះជន្មក៏បរិនិព្វានទៅ ។

សាធុរ៉ា អស់លោកសប្បុរសទាំងឡាយ! អាត្មាទាញរឿងមកនេះដើម្បីបញ្ជាក់ឲ្យឃើញ ថាកម្មជាកុសលក្តី អកុសលក្តីដែលខ្លួនបានធ្វើទុកមកហើយតែដល់ពេលផលហុចឲ្យត្រូវតែទទួលជៀសពុំរួចឡើយ ដូចជាឧត្តរសាមណេរដែលបានទទួលទុក្ខលំបាកដូច្នោះ ក៏ព្រោះតែផលអកុសលកម្មហុចឲ្យដែលបានសម្រេចជាព្រះអរហត្តផលនោះ ក៏ព្រោះតែផលជាកុសលកម្មដែលលោក

បានថ្វាយផ្កាកណិកាពាទងដល់ព្រះពុទ្ធសុមេធៈហុចឲ្យផល ។

គ្រង់នេះហើយ ដែលឈ្មោះថា កម្មឲ្យផលតាមពូជដើមព្រះសក្យមុនី សព្វញ្ញុពុទ្ធជាសាស្តាចារ្យ ទ្រង់ពុំដែលប្រៀនប្រដៅថា ឲ្យពុទ្ធសាសនិកជនផ្អែកវេរគំនិតអាងដល់ព្រះអង្គ សូមឲ្យព្រះអង្គជួយទទួលបាបជំនួសខ្លួននោះសោះឡើយ ព្រោះទ្រង់ជ្រាបតាមការពិតថាៈ សត្វលោកសុទ្ធតែមានកម្ម ជារបស់ខ្លួនរាល់រូបទាំងព្រះអង្គក៏មានកម្មជារបស់ព្រះអង្គដែរ ។

ទ្រង់មានព្រះពុទ្ធតម្រាស់បញ្ជាក់ថា ព្រះតថាគតជាព្រះពុទ្ធគ្រាន់តែជាអ្នកដឹង ហើយប្រកាសប្រាប់អ្នករាល់គ្នាឲ្យដឹងផងប៉ុណ្ណោះ ពុំមែនទទួលរ៉ាប់រងអំពើរបស់អ្នកទេ ការធ្វើការប្រតិបត្តិប្រព្រឹត្តកាន់ជាការផ្ទាល់ខ្លួនរាល់រូបឥតមានអ្នកណាជំនួសអ្នកណាកើតទេ ទាំងសេចក្តីបរិសុទ្ធនិងសេចក្តីសៅហ្មង ក៏ជំនួសគ្នាពុំកើតដូច្នោះដែរ ។ សមដូចសុភាសិតពោលថា សុចរិត ទុច្ចរិតដែលខ្លួនប្រព្រឹត្ត ក្នុងជាតិនេះណាជាប់ជានិស្ស័យបច្ច័យវាសនា ជិតជាប់អាត្មាទៅបរលោកនាយ ។

## ៤០. រឿងនាងបជិបូជិកា[46]

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងបជិបូជិកា កាលពីអតីតជាតិនាងបានកើតជានាងទេពធីតា របស់មាលាភារីទេវបុត្រនៅឋានតាវត្តិង្សទេវលោក ។

សម័យថ្ងៃមួយនាងបានមកកើត ក្នុងឋានមនុស្សលោកនៅក្រុងសាវត្ថីជាស្រីដែលចាំជាតិបាន អ្នកមានសទ្ធាជ្រះថ្លាណាស់ក្នុងព្រះពុទ្ធសាសនាគឺបានបំពេញ បុណ្យកុសលជាច្រើន ហើយនាងបានប្រាថ្នាថា "ដោយអំណាចបុណ្យកុសលដែលនាងខ្ញុំបានធ្វើហើយនេះ សូមឲ្យនាងខ្ញុំនេះបានទៅកើតនៅក្នុងឋានទេវលោក ដូចជាកាលពីដើមវិញ" ។ នៅឋានមនុស្សលោកនេះនាងបានប្តីហើយមានកូន៤នាក់ ក្រោយមកនាងបានធ្វើមរណកាល ស្លាប់អំពីមនុស្សលោកនេះ

---

[46] គាថាធម្មបទប្រែ ទំព័រ ៧៦

ហើយ បានទៅកើតនៅក្នុងឋានទេវលោកដូចសេចក្តីប្រាថ្នារបស់នាង ។

បានឮមកថា មួយថ្ងៃនៃឋានតាវត្តិង្សទេវលោក ត្រូវនឹង១០០ឆ្នាំនៃឋានមនុស្សលោកយើងនេះ ព្រោះហេតុនោះ មាលាភារីទេវបុត្រ ក៏មិនទាន់បានវិលត្រឡប់ចេញមកពីសួនច្បារ នៅឡើយទេ លុះឃើញនាងទេពធីតាត្រឡប់មករកខ្លួនវិញ ទើបសួរនាងថា "កាលពីពេលមុនបន្តិចនេះ តើនាងទៅលេងកំសាន្តឯណា បានជានាងទើបនឹងមកនេះ?" នាងបាននិយាយរៀបរាប់ប្រាប់រឿងសព្វគ្រប់ទាំងអស់ឲ្យប្តីនាងបានជ្រាប ។

មាលាភារីទេវបុត្រ បានស្តាប់រឿងនោះហើយ ក៏កើតសេចក្តីសង្វេគតក់ស្លុតយ៉ាងខ្លាំងគិតថា "ឱ! អាយុជីវិតរបស់មនុស្សលោកនេះតិចអ្វីម្ល៉េះហ្ន៎! ប្រៀបបីដូចជាដេកលក់ហើយក្រោកឡើងវិញអញ្ចឹង!" ។

ពេលនោះ ពួកភិក្ខុទាំងឡាយបានដឹងថា "នាងបដិបូជិកាបានធ្វើមរណកាលទៅហើយ" ទើបបាននាំគ្នាទៅក្រាបទូលដល់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ត្រាស់សម្តែងរឿង នាងបដិបូជិកាឲ្យពួកភិក្ខុទាំងនោះស្តាប់ហើយត្រាស់នូវព្រះគាថានេះថា:

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**
**អតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ។**

មច្ចុរាជ រមែងធ្វើនូវនរជន ដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ជាអ្នកកំពុងតែជ្រើសយកផ្កា ឈើទាំងឡាយគឺបញ្ចកាមគុណ ជាអ្នកមិនចេះឆ្អែតឆ្អន់ក្នុងកាមទាំងឡាយឲ្យចូលកាន់អំណាចរបស់ខ្លួន ។

---

[47] ប្រជុំនិទានជាតកភាគ១ ទំព័រ ៤

## ៤១. រឿងព្រះបាទមន្ធាតុ[47]

(សេចក្តីប្រាថ្នារបស់សត្វលោកគ្មានទីបំផុត)

ក្នុងខាងដើមនៃភទ្ទកប្បនេះ មានព្រះបរមចក្រពត្រាធិរាជមួយព្រះអង្គ ព្រះនាមមន្ធាតុ មានឫទ្ធិធំអស្ចារ្យ សោយរាជ្យក្នុងទ្វីបទាំង៤ មានមហាក្សត្រីយ៍ ៨ម៉ឺន៤ពាន់ព្រះអង្គជាបរិវារ ។

មនុស្សក្នុងជំនាន់នោះ មានអាយុកំណត់១អសង្ខេយ្យឆ្នាំ ឯព្រះបាទមន្ធាតុនោះ មានឥទ្ធិពលសម្បើមអស្ចារ្យណាស់ គ្រាន់តែទះដៃវេលាណា មានភ្លៀងកែវ៧ប្រការ ធ្លាក់ចុះមកវេលានោះ ទ្រង់នៅជាកុមាររត់លេងសប្បាយ ដោយល្បែងក្មេងជាង៨ម៉ឺនឆ្នាំ ដល់ព្រះជន្មគម្រប់៨ម៉ឺន៤ពាន់ព្រះរាជបិតាទ្រង់ប្រទានកិត្តិយសឲ្យធ្វើជាឧបរាជៗ បាន៨ម៉ឺន៤ពាន់ឆ្នាំ បានទទួលរាជភិសេកជាស្តេចបរមចក្រពត្រាធិរាជ សោយរាជ្យបាន៨ម៉ឺន៤ពាន់ឆ្នាំ ទ្រង់មិនស្កប់ស្កល់ដោយរាជសម្បត្តិ បានត្រាស់សួរមហាមាត្យថា ទីដែលបរិបូណ៌ដោយរាជ្យសម្បត្តិវិសេសជាងនេះទៅទៀតមាន ឬទេ?

មហាមាត្យទូលថា បពិត្រព្រះសម្មតិទេព ក្នុងមនុស្សលោកនេះពុំមានទេ មានតែឋានចាតុមហារាជិកា ទើបបរិបូណ៌ដោយសេចក្តីសុខ ប្រសើរជាងឋានមនុស្ស ។ ព្រះបាទមន្ធាតុបានជ្រាបហើយ ក៏កាន់ចក្ករតន៍គ្រវី អណ្តែតទៅពួជអាកាសព្រមទាំងចតុរង្គសេនា ទៅចុះនៅឋានចាតុមហារាជិកាពួកទេវតាក្នុងឋាននោះ បានឃើញព្រះបាទមន្ធាតុហើយក៏នាំគ្នាកាន់ភ្ញីផ្កាចូលទៅបូជាថ្វាយរាជសម្បត្តិទិព្វដល់ព្រះបាទមន្ធាតុៗ បានសោយរាជ្យសម្បត្តិ នៅឋានចាតុមហារជិកានោះ បាន៨ម៉ឺន៤ពាន់ឆ្នាំមនុស្ស ទ្រង់មិនបានស្កប់ស្កល់ក្នុងរាជសម្បត្តិនោះទៀត ទើបត្រាស់សួរទៅស្តេចចតុលោកបាលទាំង៤ថា ទីឋានដែលបរិបូណ៌ដោយសេចក្តីសុខជាងនេះមានដែរ ឬទេ?

ស្តេចចតុលោកបាលទាំង៤ ក្រាបទូលថា រាជសម្បត្តិក្នុងនេះមិនវិសេសជាងឋានមនុស្សប៉ុន្មានទេ មានតែរាជសម្បត្តិក្នុងស្ថានត្រៃត្រិង្សទើបប្រសើរជាងនេះ១រយគុណស្មើនឹង១ម៉ឺនដង ។

ព្រះបាទមន្ធាតុជ្រាបហើយ ក៏ចាប់ចក្ករតន៍គ្រវី ហោះទៅឋានត្រៃត្រិង្ស ទៀត ព្រះឥន្ទ្រាធិរាជបានទតឃើញហើយ ក៏មានព្រះទ័យសោមនស្សរីករាយ កាន់ផ្កាភ្ញីចូលទៅបូជាថ្វាយរាជសម្បត្តិពាក់កណ្តាល ។ ព្រះបាទមន្ធាតុបាន សោយរាជ្យសម្បត្តិពាក់កណ្តាលនៅឋានត្រៃត្រិង្សនោះ ជាសុខក្សេមក្សាន្តអស់ ចំនួន៣៦ជំណព្រះឥន្ទ ។ ឯសេចក្តីប្រាថ្នារបស់ព្រះអង្គ មិនចេះពេញសោះ នៅតែខ្វះកន្លះជានិច្ច សូម្បីសោយរាជ្យសម្បត្តិទិព្វ ជាយូរអង្វែងដល់ម្ល៉ោះ ក៏មិន ចេះស្កប់ស្កល់ ទើបទ្រង់ព្រះចិន្តាថា បើអញសម្លាប់ព្រះឥន្ទចោល ហើយ សោយរាជតែម្នាក់ឯង ទើបល្មមសមនឹងបុណ្យស័ក្តិរបស់អញ ។

គ្រាន់តែគិតយ៉ាងនេះ ការទ្រុឌទ្រោមនៃសរីរៈ ក៏កើតឡើងប្រាកដ ពុំអាច នៅលាយឡំជាមួយនឹងពួកទេវតាបាន ស្រាប់តែច្យុតមកស្ថិតនៅក្នុងឧទ្យាន របស់ព្រះអង្គ នាឋានមនុស្សដូចកាលមុនវិញ ។ នាយឧទ្យានបាល បានឃើញ ព្រះបាទមន្ធាតុចុះពីឋានសួគ៌មកស្ថិតនៅក្នុងឧទ្យានដូច្នេះ ក៏ចូលទៅក្រាបទូល ដល់ព្រះរាជត្រកូល ។ ព្រះរាជាដែលជាធំក្នុងព្រះរាជត្រកូលបានជ្រាបដំណឹង នោះហើយ មានសេចក្តីត្រេកអរណាស់ ទ្រង់មីម្នាយាងទៅឧទ្យាន ជាមួយនឹង ស្តេចទាំង៨ម៉ឺន៤ពាន់អង្គ ចាត់ចែងក្រាលរៀបចំរាជសេយ្យាសនៈដ៏ប្រសើរក្នុង ឧទ្យាននោះ ។

ព្រះបាទមន្ធាតុ ទ្រង់ឡើងផ្ទំលើសិរីរាជសេយ្យាសនៈនោះហើយបាន ប្រកាសប្រាប់ដល់ព្រះរាជវង្សានុវង្សទាំងឡាយថា យើងលែងក្រោកចាកអាសនៈ នេះហើយ អ្នកទាំងឡាយចូលចាំគ្រប់គ្នាថា សេចក្តីប្រាថ្នារបស់សត្វលោក ធំ ទូលាយវែងឆ្ងាយឥតមានទីបំផុត ទ្រង់មានព្រះបន្ទូលដូច្នេះជាដើមហើយក៏ ទ្រង់សោយទិវង្គតទៅ បានទៅកើតក្នុងសុគតិភព តាមសមគួរដល់បុញ្ញកម្ម របស់ព្រះអង្គ ។

ឯបុព្វកម្មរបស់ព្រះបាទមន្ធាតុ ដែលមានឥទ្ធិពលធំអស្ចារ្យមានព្រះជន្ម វែងគ្រាន់តែទះដៃមាន ភ្លៀងកែវ៧ប្រការធ្លាក់ចុះមកពីលើអាកាស និងបាន

សោយរាជ្យសម្បត្តិទិព្វ ទៀតនោះគឺកាលសាសនាព្រះសម្ពុទ្ធវិបស្សី រាប់ពីភទ្ទកប្ប នេះទៅក្រោយវិញចំនួន៩១កប្ប កាលនោះព្រះបាទមន្ធាតុកើតជាបុរសកំសត់ ម្នាក់នៅក្នុងនគរពន្ធុមតី ជាអ្នកស៊ីឈ្នួលជួលប៉ះជុលសំលៀកបំពាក់ចាស់ដាច់ ដាចរបស់អ្នកនគរនោះ ។

ថ្ងៃមួយពួកពុទ្ធបរិស័ទ បានរៀបចាត់ចែងថ្វាយមហាទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ឯបុរសកំសត់បានដឹងថា គេរៀបចាត់ចែងនឹង ថ្វាយ មហាទាន ដូច្នេះហើយក៏នឹកសង្វេគចំពោះខ្លួនថាឱ! អាត្មាអញ ជាមនុស្ស សេសសល់ថោកទាបជាទីបំផុត ពុំបានចាត់ចែងមហាទាននឹងគេសោះ ពីព្រោះ ជាអ្នកទ័លក្រ ពេលនេះបើអញមិនឆ្លៀតធ្វើទានទេ ពុំដឹងជាជាតិណា នឹងបាន រួចផុតពីសេចក្តីទុក្ខលំបាក គិតឃើញដូច្នេះហើយ សទ្ធាក៏កើតឡើងមាំ ចំពោះ គុណព្រះសម្ពុទ្ធ ។

ពេលនោះខំជួសប៉ះជុលសំពត់ឲ្យបុគ្គលម្នាក់ បានលុយមួយមាសក ដឹង ថា ពេលថ្វាយមហាទានជិតដល់ហើយ ក៏ម្នីម្នាទៅផ្សារទិញបានគ្រាប់ សណ្តែក ស្ងោរមួយកំបង់ យកទៅដាក់បាត្រទៅដល់រោងទានពុំបានឱកាស នឹងចូលទៅ ដាក់បាត្រឡើយ ព្រោះខ្លួនជាអ្នកទ័លក្រថោកទាប ពួកមហាជន មិនបើក ឱកាសឲ្យចូលទើបគិតថាអញអស់បានចូល ទៅជិតព្រះសម្ពុទ្ធនឹង ព្រះសង្ឃ ហើយ បើដូច្នេះអញគួរបោះគ្រាប់សណ្តែក សំដៅទៅត្រង់បាត្រ ព្រះសម្ពុទ្ធនឹង ព្រះសង្ឃចុះ បើចូលទៅក្នុងបាត្រតែមួយគ្រាប់គង់មានផលច្រើន។

បុរសកំសត់ ក៏ចាប់គ្រាប់សណ្តែកស្ងោរបោះទៅ ដោយអំណាចឫទ្ធិព្រះសម្ពុទ្ធ គ្រាប់សណ្តែកក៏អណ្តែតទៅធ្លាក់ចុះក្នុងបាត្រជាលំដាប់ តាំងពីបាត្រព្រះពុទ្ធ ដរាបដល់បាត្រព្រះសង្ឃឥតមានជ្រុះទៅទីដទៃមួយគ្រាប់ឡើយ ។ បុរសកំសត់ ឃើញអស្ចារ្យដូច្នោះហើយ សេចក្តីជ្រះថ្លាក៏រឹតតែកើតឡើងយ៉ាងក្រៃលែង ទើប តាំងសេចក្តីប្រាថ្នាថា ដោយអំណាចការបូជារបស់ខ្ញុំនេះក្នុងអនាគតកាល សូម

ឲ្យបានជាធំជាងជនអ្នកត្រូវការដោយកាមទាំងឡាយ បើខ្ញុំលើកដៃទះឡើងវេលាណា សូមឲ្យភ្លៀងកែវ៧ប្រការ ធ្លាក់ចុះពីផ្ទៃអាកាសវេលានោះកុំខាន។

បុរសកំសត់ លុះអាយុអស់បានទៅកើតក្នុងទេវលោកសោយសុខ និងមនុស្សលោកអស់កាលជាអង្វែង លុះមកដល់ខាងដើមនៃភទ្ទកប្បនេះ បានមកកើតជាព្រះរាជបុត្ររបស់ព្រះបាទកល្យាណរាជ មាននាមបញ្ញត្តិថា ព្រះបាទមន្ធាតុនេះឯង ដែលទិវង្គតក្នុងឧទ្យាននោះ ហើយកាន់សុគតិភព តាមសមគួរដល់បុណ្យដែលព្រះអង្គបានធ្វើឲ្យផលមិនទាន់អស់នោះឯង ។

## ៤២. រឿងនាងថុនទាសី[48]

(ទឹកមួយក្អមរបស់ស្ត្រីមានសទ្ធា ដូរយកសម្បត្តិសួគ៌បាន)

ក្នុងពុទ្ធកាល ថ្ងៃមួយព្រះសម្ពុទ្ធបរមគ្រូ ស្តេចយាងទៅដែនកោសល ជាមួយនឹងភិក្ខុសង្ឃ៥រយអង្គ ទ្រង់យាងចូលទៅសម្រាកព្រះកាយក្នុងថុនគ្រាម ដើម្បីកំចាត់បង់នូវមិច្ឆាទិដ្ឋិរបស់ពួកព្រាហ្មណ៍ក្នុងថុនគ្រាមនោះ ។ ពួកព្រាហ្មណ៍ទាំងឡាយបានឮដំណឹងថា ព្រះសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃ ស្តេចយាងនិមន្តមកដល់ត្រើយស្ទឹងខាងនាយ បម្រុងនឹងឆ្លងចូលទៅក្នុងថុនគ្រាមហើយ ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យទាំងឡាយ បានប្រកាសប្រាប់ដល់ព្រាហ្មណ៍ជាបរិស័ទថា យើងទាំងអស់គ្នាមិនគប្បីគួរសមរាប់រកឲ្យវត្ថុអ្វី ដល់សមណគោតមឡើយ ។ ម្យ៉ាងទៀតយើងទាំងអស់គ្នា ត្រូវអូសទូកឡើងពីកំពង់ឲ្យអស់ ហើយរុះស្ពានចោលចេញ ទាំងសាលាសំណាក់ក៏ត្រូវរុះស្សូវរើរនាបឲ្យអស់ បើអ្នកណាមួយទៅគួរសមឲ្យវត្ថុអ្វីដល់សមណគោតមនឹងភិក្ខុសង្ឃ ត្រូវធ្វើទោសអ្នកនោះដល់ជីវិត ។

ព្រះសម្ពុទ្ធជ្រាបវិប្បការៈ របស់ព្រាហ្មណ៍ដូច្នោះហើយក៏នាំភិក្ខុសង្ឃទាំង៥រយ ហោះឮដ៏អាកាស ឆ្លងស្ទឹងទៅចុះត្រង់កណ្តាលស្រុកនោះ ទ្រង់និមន្តទៅ

---

[48] ប្រជុំនិទានជាតកភាគ១ ទំព័រ ៩

គង់ក្រោមម្លប់ឈើមួយដើមក្បែរអណ្តូងទឹក ។ សម័យនោះ មាននាងទាសីម្នាក់ជាខ្ញុំបម្រើត្រកូលព្រាហ្មណ៍មួយក្នុងស្រុកថូនគ្រាមនោះ កំពុងកណ្តៀតក្អមទៅដងទឹកអណ្តូង បានឃើញព្រះមានព្រះភាគ ក៏មានចិត្តជ្រះថ្លាកើតឡើង នាងគិតថាសម័យនេះក្តៅណាស់ ព្រះសម្ពុទ្ធ និងព្រះសង្ឃទាំងអស់អង្គប្រហែលជាស្រេកទឹកខ្លាំង បានជាមកគង់ក្នុងទីនេះ អញត្រូវតែដងទឹកមួយក្អម យកទៅប្រគេនទើបគួរ ប៉ុន្តែព្រាហ្មណ៍ព្រឹទ្ធាចារ្យបានដាក់អាជ្ញាថា បើអ្នកណាទៅគួរសមយកវត្ថុអ្វីៗ ទៅប្រគេនដល់សមណគោតម និងភិក្ខុសង្ឃនេះត្រូវមានទោសដល់ជីវិត ។ នាងគិតដូច្នោះហើយ ក៏ដើរហួសទៅដងទឹក លុះត្រឡប់មកវិញសទ្ធាក៏កាន់តែកើតខ្លាំងឡើងៗ ទើបគិតថា ណ្ហើយចុះអញបានជួបនឹងស្រែបុណ្យដ៏ប្រសើរយ៉ាងនេះហើយ គួរតែធ្វើទានកុំខាន ទោះបីគេសម្លាប់ ឬដាក់អាជ្ញាយ៉ាងណាតាមការចុះ នាងក៏កណ្តៀតក្អមចូលទៅ កណ្តាលហ្វូងភិក្ខុសង្ឃយកទឹកមួយក្អមទៅប្រគេនព្រះសម្ពុទ្ធៗ ទ្រង់ទទួលដោយព្រះហស្តទាំងពីរថ្លែងអាការៈឲ្យនាងដឹងថា ព្រះអង្គត្រូវការទឹកនោះណាស់ ទ្រង់ចាក់ទឹកនោះ លុបព្រះភក្ត្រ ហើយឆាន់ ក្នុងទីចំពោះមុខរបស់នាង ដោយអំណាចឫទ្ធិរបស់ ព្រះអង្គទឹកក្នុងក្អមនៅពេញដដែល ទើបឲ្យក្អមទឹកនោះទៅភិក្ខុសង្ឃទាំង ៥រយឆាន់ទៀតទឹកក្អមក៏នៅតែពេញដដែល ។

នាងថូនទាសីបានឃើញ ចំឡែកអស្ចារ្យដូច្នេះហើយ សេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ក៏កាន់តែចម្រើនស្ថាពរឡើងជារយគុណ ។ កាលភិក្ខុសង្ឃទាំង ៥រយ ឆាន់ឆ្អែតស្កប់ស្កល់ហើយ ព្រះសម្ពុទ្ធទ្រង់ប្រទានក្អមទឹកនោះដល់នាងថូនទាសីវិញនាងបានទទួលក្អមហើយថ្វាយបង្គំលាព្រះមានព្រះភាគទៅគេហដ្ឋានរបស់នាងវិញ ។

លំដាប់នោះ ពួកព្រាហ្មណ៍ទាំងឡាយ ក៏ចាប់នាងវាយតប់ បណ្តើរយកទៅឲ្យព្រាហ្មណ៍ជាចៅហ្វាយនាយៗ ទាំងឡាយបានវាយថែម ទៀតទាល់តែ

ស្លាប់ ក្នុងពេលនោះទៅ ។ ចំណែកខាងព្រះមានព្រះភាគ កាលបើនាងថូនទាសីចេញទៅផុតហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទប្រើឲ្យយក បាត្រព្រះអង្គទៅដងទឹកអណ្តូង ព្រះអានន្ទមិនហ៊ានទៅដង ព្រោះខ្លាចព្រាហ្មណ៍ វាយសម្លាប់ ទ្រង់ប្រើជាគម្រប់៣ដង ព្រះអានន្ទមិនហ៊ានប្រកែក ទើបកាន់យកបាត្រនិមន្តទៅអណ្តូងទឹក គ្រាន់តែទៅដល់មាត់អណ្តូង ទឹកក៏បាញ់ចេញពី ក្នុងអណ្តូងជោរជន់សាចទៅលើមហាប្រឹថពី លិចភូមិស្រុកថូនគ្រាមនោះមួយរំពេច ប៉ុន្តែត្រង់ដែលព្រះសម្ពុទ្ធ និងព្រះសង្ឃគង់នោះឥតមានទឹកលិចឡើយ។

ពួកព្រាហ្មណ៍ទាំងឡាយ ឃើញហេតុអស្ចារ្យដូច្នោះហើយភិតភ័យខ្លាំងណាស់ ក៏នាំគ្នារត់ចូលទៅសុំទោសព្រះសម្ពុទ្ធ ថ្វាយខ្លួនជាឧបាសកឧបាសិកាយកព្រះរតនត្រ័យជាទីពឹងទីរលឹកស្មើដោយជីវិត ទឹកក៏បាត់អស់រលីងក្នុងខណៈនោះទៅ ។

ឯនាងថូនទាសី ដែលព្រាហ្មណ៍វាយសម្លាប់នោះ បានទៅកើតនៅក្នុងឋានត្រៃត្រិង្ស មានរូបល្អឥតឧបមា មានរស្មីចែងចាំង ចេញអំពីកាយផ្សាយទៅក្នុងទិសទាំងពួង មានស្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ស្ថិតនៅក្នុងវិមានមាស មានសណ្ឋានដូចជាទូកកឹង ប្រតិស្ឋាននៅលើទឹកទិព្វ ក្នុងមហាស្រះបោក្ខរណីមួយ ។ លើមាត់ស្រះមានដើមកប្បព្រឹក្សដុះព័ទ្ធជុំវិញក្នុងស្រះនោះមានដើមឈូកដុះព្រោងព្រាត បញ្ចេញផ្កាផ្លែផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ ឈូកនោះមានផ្កា៥ពណ៌ ខ្លះដើមជាមាស ស្លឹកជាកែវមណីផ្កាជាប្រាក់ ផ្លែជាត្បូងទទឹម ខ្លះដើមជាត្បូងទទឹមស្លឹកជាប្រាក់ ផ្កាជាកែវមណីផ្លែជាមាសដុះព័ទ្ធព័ន្ធវិមានប្រាសាទ ។

ក្នុងពេលនោះ នាងគិតពិចារណាមើលអតីតជាតិរបស់នាងក៏បានដឹងសព្វគ្រប់ថា ឱ! អញដែលបានមកកើតជាទេវធីតាបរិបូណ៌ដោយទិព្វសម្បត្តិដូច្នេះ ដោយសារតែទឹកមួយក្អមដែលអញបានប្រគេនព្រះសម្ពុទ្ធ ក្នុងស្រុក

ថុនគ្រាម ឥឡូវនេះព្រះសម្ពុទ្ធគង់នៅក្នុងទីនោះ ពុំទាន់និមន្តទៅណាឡើយ ដូច្នេះគួរតែអញទៅ បំពេញសម្បត្តិរបស់អញ ឲ្យវិសេសជាងនេះទៅទៀតគិតដូច្នេះហើយចុះមកភ្លាម វិមានប្រាសាទក៏អណ្តែត ដោយមកប្រតិស្ឋានលើផែនដីក្នុងទីចំពោះព្រះភក្រ្តព្រះសម្ពុទ្ធ ។

នាងទេពធីតា បាននាំបរិវារទាំង១៣ន់ ចេញពីវិមានប្រាសាទចូលទៅថ្វាយបង្គំព្រះសម្ពុទ្ធជាបរមគ្រូ ពេលនោះពួកព្រាហ្មណ៍ទាំងឡាយដែលកំពុងអង្គុយ គាល់ព្រះដ៏មានព្រះភាគក៏ផ្អើលឈូឆរនឹកស្ញើចក្នុងចិត្តឥតឧបមា ។ ព្រះមានព្រះភាគត្រាស់សួរនាងទេពធីតា ដើម្បីឲ្យព្រាហ្មណ៍ទាំងអស់បានដឹងក្នុងពេលនោះថាម្នាលទេពធីតា អ្នកបរិបូណ៌ដោយទិព្វសិរី មានពន្លឺចែងចាំងជានិច្ច តើនាងមកអំពីទីណា? បានធ្វើបុណ្យអ្វីក្នុងជាតិមុន?

នាងទេពធីតាក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមកពីឋានត្រៃត្រិង្ស កាលពីម្សិលមិញខ្ញុំព្រះអង្គ នៅក្នុងស្រុកថុនគ្រាមនេះបានដងទឹកមួយក្អមប្រគេនព្រះអង្គ លុះត្រឡប់ទៅផ្ទះពួកព្រាហ្មណ៍ទាំងឡាយដែលអង្គុយនៅជុំវិញនេះ នាំគ្នាចាប់វាយខ្ញុំព្រះអង្គបណ្តើរទៅ ឲ្យព្រាហ្មណ៍ជាចៅហ្វាយរបស់ខ្ញុំ ព្រះអង្គបានវាយថែមទៀតដរាបដល់ស្លាប់ ។ បន្ទាប់មកនាងក៏បានថ្លែងរៀបរាប់អំពី ទិព្វសម្បត្តិរបស់នាងក្នុង ស្ថានសួគ៌ដោយសព្វគ្រប់រហូតដល់ចប់ហើយ ។

ព្រះសម្ពុទ្ធបរមគ្រូទ្រង់សម្តែងនូវធម្មកថា ពន្យល់អំពីអរិយសច្ចធម៌ ៤ប្រការ នាងទេពធីតា ក៏បានសម្រេចសោតាបត្តិផល ក្នុងពេលនោះ ទើបថ្វាយបង្គំលាព្រះសម្ពុទ្ធទៅស្ថានត្រៃត្រិង្សវិញ ។ ពួកព្រាហ្មណ៍ក្នុងថុនគ្រាម ក៏បានយល់ជាក់ច្បាស់នូវព្រះពុទ្ធសាសនាក្នុងពេលនោះមក ។

---

[49] ប្រជុំនិទានជាតកភាគ១ ទំព័រ ១៨

## ៤៣. រឿងនាងទុគ្គតធីតា[49]

(បាយក្តាំងមួយដុំរបស់ស្ត្រីមានភ័ព្វ ដូរយកសម្បត្តិសួគ៌បាន)

កាលព្រះសម្ពុទ្ធទ្រង់គង់នៅវត្តវេឡុវ័ន មានត្រកូលមួយនៅក្នុងក្រុងរាជគ្រឹះ កើតអហិវាតរោគស្លាប់អស់នៅសល់តែកូនស្រីមួយនាងធីតានោះ កាលបើមាតាបិតាបងប្រុសស្រីស្លាប់អស់ហើយ ក៏រត់ចុះពីផ្ទះទៅជ្រកកោននៅក្រោមសំយាបផ្ទះរបស់ជនដទៃ មនុស្សទាំងឡាយបានឃើញធីតាកំណត់នោះ ក៏មានចិត្តមេត្តាករុណាឲ្យបាយកកបាយក្តាំងដែលសល់ពីខ្លួនបរិភោគឲ្យដល់នាងតែរាល់ៗថ្ងៃ ។

ថ្ងៃមួយព្រះមហាកស្សបត្ថេរ លោកចេញពីនិរោធសមាបត្តិបានរំពឹងពិចារណារកបុគ្គលដែលគួរទៅជួយសង្គ្រោះ ក៏បាននាងទុគ្គតធីតានោះ ហើយបានជ្រាបដោយសព្វគ្រប់ថា បើអាត្មាអញទៅដល់នាងទុគ្គតធីតានឹងឲ្យបាយក្តាំងដល់អាត្មាអញពុំខាន កាលបើឲ្យដូច្នោះហើយ នាងនឹងបានទៅកើតក្នុងឋានសួគ៌ពិតប្រាកដ ។ ម្យ៉ាងទៀតនាងនេះត្រូវជាមាតារបស់អាត្មាអញក្នុងជាតិជាគម្រប់បីរាប់អំពីជាតិនេះទៅ ។

ព្រះមហាកស្សបត្ថេរ បានជ្រាបដូច្នេះហើយក៏យកបាត្រនិមន្តសំដៅទៅទីដែលនាងទុគ្គតធីតានៅអាស្រ័យនោះ ។ លំដាប់នោះសក្កទេវរាជព្រះចៅឋានត្រៃត្រិង្ស បានជ្រាបហេតុនោះហើយ ក៏និម្មិតខ្លួនជាមាណពកាន់អាហារទិព្វដើរទៅស្កាត់មុខព្រះមហាកស្សបត្ថេរៗ បានជ្រាបថាព្រះឥន្ទ្រមកក្លែងដូច្នោះក៏មានថេរដីកាហាមឃាត់ថា មហារាជកុំប្លន់យកសម្បត្តិរបស់នាងទុគ្គតធីតាឡើយសូមព្រះអង្គចៀសចេញទៅ ។

សក្កទេវរាជក៏វិលត្រឡប់ទៅទេវលោកវិញ ព្រះមហាកស្សបត្ថេរបាននិមន្តទៅឈរក្នុងទី ចំពោះមុខនាងទុគ្គតធីតាៗគិតថា ព្រះថេរៈនេះលោកមកប្រោសអញហើយតើ! អញចំជាស្ត្រីមានលាភប្រសើរណាស់ ។ សេចក្តីជ្រះថ្លារបស់នាងក្នុងពេលនោះ ក៏កើតឡើងពេញបរិបូណ៌ជរាបដល់ព្រំពោមព្រំស្បែកនាងបានយកបាយក្តាំងមួយដុំដែលនៅក្នុងអំបែង ទៅដាក់បាត្រព្រះមហាកស្សបត្ថេរៗ កាលបើបានបាយក្តាំងហើយ ក៏ងាកមើលនាយអាយ បម្រុងនឹងរកកន្លែងឆាន់

ពួកមហាជនឃើញអាការៈនោះហើយ នាំគ្នាក្រាលអាសនៈប្រគេនលុះឆាន់ហើយក៏ធ្វើកត្តានុមោទនាសរសើរអានិសង្សទាន ដោយពិស្តារទើបមានថេរដីការទៅរកនាងទុគ្គតធីតាថា ម្នាលនាងកំសត់កាលពីជាតិមុននាងត្រូវជាមាតាបង្កើតរបស់អាត្មាក្នុងជាតិទី៣រាប់ជាតិនេះទៅ ។

នាងទុគ្គតធីតា បានឮដូច្នោះហើយក៏រឹងរឹតជ្រះថ្លារីករាយជាតិយោ្យភាព បន្ទាប់មកនាងក៏ធ្វើមរណកាល ទៅកើតក្នុងឋាននិម្មានរតីទេវលោក បរិបូណ៌ដោយទិព្វសិរីខ្ពាត់ផុតសេចក្តីទ័លក្រគ្រប់យ៉ាងសោយសម្បត្តិជាសុខទៅ ។

## ៤៤. រឿងនាងពុទ្ធេណី[50]

(អ្នកមានសទ្ធាអាច គេចផុតសេចក្តីអន្តរាយបាន)

កាលព្រះបរមគ្រូរបស់នៃយើង បរិនិព្វានហើយក្នុងកាលជាខាងក្រោយមកមានសេដ្ឋីម្នាក់មានទ្រព្យ៨៧កោដិនៅក្នុងក្រុងបាតលីបុត្ត សេដ្ឋីនោះមានធីតាមួយរូបឈ្មោះពុទ្ធេណីនាងមានអាយុ៧ឆ្នាំ មាតាបិតាស្លាប់ចោលអស់ទៅនៅតែម្នាក់ឯងជាមួយនឹងក្រុមញាតិ សម្បត្តិទាំងប៉ុន្មានធ្លាក់នៅលើដៃនាងទាំងអស់ ។

ឯនាងពុទ្ធេណីនេះ ជាស្រីមានរូបល្អដូចជារូបស្រីទេពអប្សរ ដល់អាយុគម្រប់១៦ឆ្នាំ ពួកឥស្សរជនទាំងឡាយមានក្សត្រិយ៍ និងមន្ត្រីជាដើម តែងចោមរោមដណ្តឹងនាងតែនាងពុំព្រមយកស្វាមីឡើយ ព្រោះជាស្រីមាននិស្ស័យខ្ពស់នាងខំតែធ្វើទានរក្សាសីលប្រព្រឹត្តសុចរិតតែម្យ៉ាង ។

ថ្ងៃមួយ មានឈ្មួញសេះម្នាក់នៅក្នុងឧត្តរទិស បាននាំសេះជាច្រើនចូលទៅលក់ក្នុងបាតលីបុត្ត ទៅសំណាក់ក្នុងរោងទានរបស់នាងបានឃើញចរិយាសម្បត្តិនិងគុណសម្បត្តិរបស់នាងហើយ ក៏មានចិត្តប្រតិព័ទ្ធស្រឡាញ់ ហាក់បីដូចជាធីតាបង្កើតទើបសុំនាងធ្វើជាកូនចិញ្ចឹម នាងក៏ព្រមតាមពាក្យសុំ ។ ឈ្មួញសេះ

---

[50] ប្រជុំនិទានជាតកភាគ១ ទំព័រ២០

នោះបានឲ្យកូនសេះសិន្ធវៈ មួយដល់នាងៗក៏មានចិត្តស្រឡាញ់សេះនោះដូចជាកូនបង្កើត ខំថែរក្សាដោយផ្ចិតផ្ចង់ ឯសេះក៏បានស្រឡាញ់នាងវិញ ដូចជាម្ដាយបង្កើត ។

ថ្ងៃមួយនាងបានដឹងថា សេះនោះមានមហិទ្ធិឫទ្ធិច្រើន អាចហោះហើរព្ធដ៏អាកាសបានក៏គិតថា អញបានចិញ្ចឹមសេះនេះប្រពៃណាស់ ព្រោះមានបំណងចង់ទៅថ្វាយបង្គំមហាពោធិព្រឹក្សជាយូរហើយ លុះគិតដូច្នេះហើយក៏ចាត់ចែងធ្វើកូងផ្កាមាស ព្រមទាំងគ្រឿងក្រអូបផ្សេងៗមានខ្លឹមចន្ទន៍ជាដើម ធ្វើហើយវេចខ្ចប់ស្រួលបួលកាន់ដើរទៅរោងសេះ និយាយប្រាប់សេះថា ម្នាលកូនសំឡាញ់អ្នកជូនម្ដាយទៅថ្វាយបង្គំមហាពោធិព្រឹក្ស ។

សេះព្ធដូច្នេះក៏ដើរចេញពីក្រោលមក ឲ្យនាងឡើងជិះលើខ្នងហើយហោះសំដៅទៅពោធិមណ្ឌល ទៅចុះក្បែរគល់មហាពោធិព្រឹក្ស ដោយសន្ទុះយ៉ាងរហ័សក្រៃលែង ដូចជាបុរសមានកម្លាំងបត់ជុំដៃហើយលាចេញ ។ ពេលនោះមានព្រះសង្ឃមួយអង្គ ព្រះនាមធម្មរក្ខិតនឹងព្រះសង្ឃដទៃទៀតជាបរិវារ នៅថែរក្សាមហាពោធិព្រឹក្សនោះ ។ នាងពុទ្ធេណីយកកូងផ្កាមាសនិងគ្រឿងក្រអូបផ្សេងៗ ទៅបូជាមហាពោធិព្រឹក្សហើយ បានប្រកាសប្រាប់ដល់ព្រះសង្ឃថា គ្រឿងសក្ការៈនេះ សូមព្រះសង្ឃចាត់ចែងទុកដាក់ថែរក្សាចុះ ។

តាំងពីពេលនោះមក នាងតែងជិះសេះទៅបូជា និងបោសសម្អាតគល់មហាពោធិព្រឹក្ស តែរាល់ៗពេល ។ ថ្ងៃមួយព្រះរាជាក្រុងបាតលីបុត្តបានជ្រាបថា នាងពុទ្ធេណីជិះសេះទៅថ្វាយបង្គំមហាពោធិព្រឹក្សតែរាល់ថ្ងៃដូច្នោះ ក៏ចាត់អាមាត្យឲ្យនាំគ្នាទៅចាំស្ទាត់ចាប់នាងយកមកអភិសេកជាអគ្គមហេសី ។ ពេលនោះនាងពុទ្ធេណី បូជាមហាពោធិព្រឹក្សហើយរៀបដំណើរនឹងត្រឡប់មកវិញ ព្រះធម្មរក្ខិត ជាព្រះអរហន្តបានជ្រាបហេតុដែលអាមាត្យពួនចាំចាប់នោះ ទើបប្រាប់ដល់នាងពុទ្ធេណីថា ម្នាលនាងដល់ត្រឡប់ទៅវិញចូរប្រយ័ត្នខ្លួនកុំប្រមាទ។

នាងពុទ្ធេណីបានទៅដល់ពាក់កណ្ដាលផ្លូវ ពួកអាមាត្យដែលពួនចាំចាប់នោះ នាំគ្នាស្រែកសន្ធាប់ឡើង សេះក៏ភ្ញាក់ហោះឡើងទៅលើអាកាស ធ្លាក់នាងពុទ្ធេណីពីខ្នងនាងភ័យខ្លាំងណាស់ខំស្រែកហៅសេះថា នែ! កូនសម្លាញ់ម្ដាយជួយម្ដាយផង សេះនោះដឹងថានាងធ្លាក់ពីខ្នងហើយ ក៏ហក់ចុះដោយសន្ទុះយ៉ាងឆាប់រហ័ស យកខ្នងទៅរងទទួលនាងឲ្យជិះដូចដើមវិញ ឥតឲ្យធ្លាក់ដល់ដីឡើយ ទើបហោះទៅគេហដ្ឋានរបស់ខ្លួនដោយសួស្ដី ។

តាំងពីពេលនោះមកនាងពុទ្ធេណី បានចំណាយទ្រព្យចាត់ចែងទានជរាបដល់អស់៨៧កោដិ លុះអស់អាយុក៏បានទៅកើតក្នុងឋានសួគ៌ សោយទិព្វសម្បត្តិបរិបូណ៌ដោយសុខភាពអស់កាលជាអង្វែង ។

## ៤៥. រឿងមាតុឃាតក[51]

(បុរសធ្លាក់នរក ព្រោះតែជឿពាក្យប្រពន្ធ)

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់នៅក្នុងដែនកាសី កាលបើបិតាធ្វើមរណកាលទៅហើយ ក៏ទំនុកបម្រុងបម្រើមាតាដោយគោរព ឯមាតាឃើញកូនមានវត្តប្រតិបត្តិល្អ ក៏នាំស្ត្រីមានរូបស្រស់ប្រិមប្រិយម្នាក់មករៀបចំឲ្យកូននោះ ។ ចំណែកខាងនាងនោះ បិតាស្លាប់ចោលតាំងពីក្មេង នៅសល់តែមាតាទើបនាំមកនៅ រួមក្នុងត្រកូលស្វាមី ហើយទំនុកបម្រុងដោយគោរពដល់មាតាទាំងពីរ ។ តមកខាងក្រោយ នាងក៏មានចិត្តនឿយណាយធុញទ្រាន់ចំពោះមាតាទាំងពីរ មានគំនិតអាក្រក់កើតឡើង គិតសម្លាប់ម្ដាយក្មេកចោល បាននិយាយញុះញង់ស្វាមីថា ឥឡូវនេះយើងគិត សម្លាប់ម្ដាយយើងចោល ព្រោះចាស់ចង្រៃនេះខុសអស់នឹងចាស់ទាំងពួង តែងបន្ទោបង់មូត្រលាមកដាក់ពេញផ្ទះសំបែង ហើយប្របាច់លេងដូចកូនក្មេង ទើបនឹងកើត បើឯងមិននៅពេលណាហើយគាត់ធ្វើបាបតែអញឲ្យវេទនាពប់មិនឈ្នះ បើដូច្នេះយើងគិតសម្លាប់គាត់ទៅឬ?

---

[51] ប្រជុំនិទានជាតកភាគ១ ទំព័រ២៩

បុរសជាស្វាមីបានឮភរិយានិយាយរ៉ាយរ៉ាប់ប្រាប់ជាញយៗ ហើយក៏និយាយថា ការសម្លាប់មនុស្សនីមួយៗមិនងាយទេក្រណាស់ ភរិយានោះនិយាយតបវិញថា បពិត្រ ស្វាមីការសម្លាប់នោះងាយទេ មើលតែគាត់ដេកលក់ យើងចងគ្រែសែងទៅទម្លាក់ក្នុងស្ទឹង ខាងក្រោយផ្ទះឲ្យឆ្លាមមកទំពាស៊ី ។ បុរសជាស្វាមីសួរថា ម្ដាយអញគាត់ដេកកន្លែងណា? ម្ដាយឯងដេកកន្លែងណា?

ភរិយាប្រាប់ថា ម្ដាយអ្នកសម្រាន្តខាងនេះ ម្ដាយខ្ញុំសម្រាន្តខាងនុ៎ះ ស្វាមីប្រាប់ថាបើដូច្នោះ ចូរនាងចងគ្រែម្ដាយអញទុកឲ្យស្រេចទៅ ដល់យប់ជ្រៅយើងនឹងសែងទៅទម្លាក់ក្នុងស្ទឹង ។ ភរិយាត្រេកអរណាស់ ក៏ធ្វើតាមបង្គាប់ស្វាមី ហើយដេកលក់ទៅ ។ បុរសជាស្វាមីបានដឹងថា ភរិយារបស់ខ្លួនដេកលក់ហើយក៏ចូលទៅស្រាយចំណងពីគ្រែម្ដាយខ្លួនចេញ យកខ្សែទៅចងគ្រែម្ដាយក្មេកវិញ លុះចងសព្វគ្រប់ហើយ ដើរចូលទៅដាស់ភរិយាថា នែ! ក្រោកឡើងយើងល្មមសែងជូនចាស់ទៅទម្លាក់ចោលហើយ ។

ជនទាំងពីរនាក់ក៏ម្នីម្នាសែងគ្រែយក ទៅទម្លាក់ក្នុងស្ទឹងខាងក្រោយផ្ទះដោយប្រញាប់ប្រញាល់ខ្លាចក្រែង ជនទាំងឡាយមើលឃើញ ។ ពួកសត្វសាហាវទាំងឡាយមានឆ្លាមមកជាដើម ក៏ដណ្ដើមប្រជែងគ្នាស៊ីយាយចាស់នោះអស់ទៅ ។ លុះព្រឹកឡើងនាងភរិយាបានដឹងច្បាស់ថា ម្ដាយខ្លួនស្លាប់ហើយ ក៏នឹកតូចចិត្តក្ដៅក្រហាយអន្ទះសាពន់ពេក ទើបប្រាប់ស្វាមីថា យើងគិតសម្លាប់ជូនចាស់មួយទៀត ។

បុរសជាស្វាមីក៏ទទួលព្រមថាល្អហើយ ទើបនាំគ្នាទៅធ្វើថ្ករក្នុងព្រៃស្មសាន ដល់យប់ជ្រៅម្ដាយដេកលក់ ក៏នាំគ្នាសែងទាំងគ្រែយកទៅ ដាក់លើជើងថ្ករប្រារព្ធនឹងដុតភ្លើងជូនជាពេលនោះភ្លេចដាក់ភ្លើងទៅ ក៏នាំគ្នាត្រឡប់មកយកភ្លើងវិញ ។

កាលជនទាំងពីរនាក់ត្រឡប់មកផ្ទះវិញហើយ យាយចាស់នោះក៏ភ្ញាក់ឡើង ក្រោកអង្គុយ ដោយត្រូវសន្សើមត្រជាក់ខ្លាំងលុះមើលសព្វគ្រប់ដឹងខ្លួនថាគេយកមកសម្លាប់ ក៏ចុះចេញទៅបានយកសាកសពខ្មោចពពៃមួយ ទៅដាក់លើ

គ្រែគ្រប សំពត់ពីលើ ហើយគៀសខ្លួនចេញពីទីនោះ ដើរចូលទៅក្នុងគុហាមួយ បានរំពឹងគិតថា ឱ!អាត្មាអញនឹកស្មានថាបានកូនប្រសាជាទីពឹងឥឡូវនេះវាធ្វើអញឲ្យភ័យយ៉ាងក្រៃលែង ។ ចំណែកខាងបុរសប្ដីប្រពន្ធ យកភ្លើងបានមកក៏ដុតសាកសពពៃនោះទៅដោយសម្គាល់ថា ជាម្ដាយរបស់ខ្លួនពិត ។

ឯគុហាដែលយាយចាស់ចូលទៅអង្គុយនោះ មានចោរម្នាក់យកបង្វិចមាសប្រាក់ ទៅលាក់ទុកក្នុងទីនោះជាច្រើន ។ យាយចាស់បានឃើញមាសប្រាក់នោះ ហើយក៏នឹកដល់កូនថាឱ! កូនសម្លាញ់អញ ប្រសិនបើបានមាសប្រាក់ច្រើនយ៉ាងនេះ ប្រហែលជាត្រេកអរក្រៃលែងណាស់ កំពុងតែគិតដូច្នេះស្រាប់តែចោរទៅដល់ ចោរនោះបានឃើញយាយចាស់ហើយ ក៏ភ្ញាក់គិតភ័យញ័ររន្ធត់មិនហ៊ានចូលទៅជិតឡើយ ដោយនឹកស្មានថាយក្សក៏ត្រឡប់មកវិញបានហៅពេទ្យខ្មោចម្នាក់ឲ្យចូលទៅសង្កេតមើល ពេទ្យខ្មោចនោះក៏រាយមន្តវិជ្ជា ហើយដើរចូលទៅកាន់គុហា ។

ចំណែកខាងយាយចាស់បានឃើញពេទ្យខ្មោចនោះ ក៏និយាយថាយើងមិនមែនជាយក្សទេ អ្នកចូលមកយើងទាំងពីរនាក់នឹងចែកទ្រព្យគ្នា ។ ពេទ្យខ្មោចនោះនិយាយថា យើងមិនជឿទេ ។ យាយចាស់ថាបើអ្នកឯងមិនជឿយើង ចូរអ្នកលៀនអណ្ដាតមកដាក់លើអណ្ដាតយើង ចុះនឹងដឹងច្បាស់ថាយើងជាមនុស្សពិត ។

ចំណែកពេទ្យខ្មោច ក៏ធ្វើតាមពាក្យយាយចាស់នោះទៅ យាយចាស់ក៏ខាំអណ្ដាតពេទ្យខ្មោច ជាប់ដោយចង្កូមមួយយ៉ាងចំណាប់ពេទ្យខ្មោចខំបម្រះរើបហើយក៏ស្រែកប្រាប់គ្នាថា យក្សទេវើយ! យក្សទេ! ទើបនាំគ្នារត់ចេញទៅ ។ លុះដល់ភ្លឺច្បាស់ឡើងយាយចាស់ ក៏ប្រមូលមាសប្រាក់វេចស្ពាយយកទៅឲ្យកូន ។

ចំណែកខាងកូនប្រសា ក្រឡេកឃើញម្ដាយស្ពាយបង្វិចទ្រព្យមកដូច្នោះក៏ចុះទៅទទួលរាក់ទាក់បដិសណ្ឋារៈ គួរសមយ៉ាងអស្ចារ្យ ហើយនិយាយថាឱ!

លោកម្តាយគេយកទៅដុតក្នុងព្រៃខ្មោច ត្រឡប់ជាបានមាសប្រាក់មកឲ្យកូន បើដូច្នោះខ្ញុំសូមឲ្យលោកម្តាយយកខ្ញុំទៅដុតម្តងវិញ ខ្ញុំនឹងកើបវេចយកមាសប្រាក់ឲ្យច្រើនជាងនេះទៅទៀត ។

ស្ត្រីនោះជាស្ត្រីពាល កាឡកណ្ណីល្មោភចង់បានទ្រព្យមិនគិតវែងឆ្ងាយ បានឲ្យស្វាមីយកទៅដុតក្នុងព្រៃស្មសាន ស្វាមីក៏នាំយកទៅដុតឆេះខ្ទេចខ្ទីស្លាប់ទៅកើតក្នុងនរកទៅ ។ ឯស្វាមីដល់អស់អាយុក៏ទៅកើតក្នុងនរកជាមួយគ្នា ។

## ៤៦. រឿងមហាល្លកចណ្ឌាល[52]

(ការថ្វាយបង្គំព្រះសម្ពុទ្ធ ដោយជ្រះថ្លារមែងបានសម្បត្តិសួគ៌)

ថ្ងៃមួយព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ស្ថិតនៅជាសុខក្នុងនិរោធសមាបត្តិនាក្រុងរាជគ្រឹះក្នុងពេលជិតភ្លឺ ព្រះអង្គទ្រង់ប្រមើលមើលនិស្ស័យសត្វដោយពុទ្ធចក្ខុទ្រង់បានឃើញស្រីចណ្ឌាលចាស់ម្នាក់ នៅក្នុងចណ្ឌាលគ្រាម នាក្រុងរាជគ្រឹះនោះ ជាស្រីល្ងង់អាប់ឥតប្រាជ្ញា តាំងតែពីកើតជាបដល់ចាស់ជរា ពុំដែលបានធ្វើកុសលណាមួយឡើយ ប្រព្រឹត្តធ្វើតែអំពើទុច្ចរិតម្យ៉ាង កាលបើស្លាប់ហើយ នឹងធ្លាក់ទៅកើតមហានរកពុំខាន លុះទ្រង់ជ្រាបដូច្នេះហើយ ក៏មានព្រះទ័យករុណាចំពោះយាយចណ្ឌាលនោះពន់ពេកដល់ភ្លឺច្បាស់ឡើង ក៏ទ្រង់បាត្រចីវរនាំភិក្ខុសង្ឃជាច្រើនអង្គមានព្រះមហាមោគ្គល្លានជាដើម ចូលទៅបិណ្ឌបាតក្នុងចណ្ឌាលគ្រាមនោះ។

យាយចណ្ឌាល កំពុងតែដើរទប់ខ្លួននឹងឈើច្រត់តាមមាគ៌ាព្រះភគវាទ្រង់ឈរវាំងផ្លូវ ពុំឲ្យយាយចណ្ឌាលនោះដើរទៅទីដទៃបានឡើយ ។ ព្រះមោគ្គល្លានបានជ្រាបហេតុនោះហើយ ក៏ប្រាប់យាយចណ្ឌាលថា នែ! យាយព្រឹទ្ធាយាយអញ្ជើញទៅណា? ចូរថ្វាយបង្គំព្រះសម្ពុទ្ធជាបរមគ្រូសិន ការដែលបានជួបនឹងព្រះបរមគ្រូនេះប្រសើរពេកណាស់ ព្រោះព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងសព្វដោយព្រះអង្គឯង ឥតមានគ្រូអាចារ្យណាប្រដៅជាស់តឿន

[52] ប្រជុំនិទានជាតកភាគ១ ទំព័រ ៣៣

ព្រះអង្គឡើយ ព្រះអង្គមានព្រះទ័យករុណាអាណិតដល់យាយ ទើបទ្រង់និមន្ត មកដើម្បីឲ្យយាយ បានសេចក្តីសុខចម្រើន ទៅកើតក្នុងស្ថានសួគ៌ ចូរយាយក្រោកអរចំពោះព្រះសម្ពុទ្ធបរមគ្រូចុះ ។

យាយចណ្ឌាលលើកដៃឡើងបាំងថ្ងាស អើតមើលព្រះភក្ត្រព្រះសម្ពុទ្ធ សេចក្តីជ្រះថ្លាកើតឡើង ក៏អង្គុយដាក់ឈើច្រត់ក្បែរខ្លួន ហើយថ្វាយបង្គំដោយសេចក្តីជ្រះថ្លា មានពុទ្ធានុស្សតិជាអារម្មណ៍ ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបថា យាយចណ្ឌាលនេះអស់អាយុហើយត្រូវស្លាប់ក្នុងពេលឥឡូវនេះ កាលបើស្លាប់ហើយនឹងបានទៅកើតក្នុងឋានតាវត្តិង្សពុំខាន លុះជ្រាបដូច្នេះហើយក៏និមន្តហួសទៅបិណ្ឌបាតក្នុងចណ្ឌាលគ្រាមនោះទៅ ។

ឯយាយចណ្ឌាល ក៏ក្រោកដើរទៅផ្ទះ មានចិត្តស្ថិតនៅក្នុងពុទ្ធគុណជាឯកគ្គតារមណ៍ ក្នុងពេលនោះ មានមេគោមួយមានកូនខ្ចីបានឃើញព្រះសម្ពុទ្ធនិងព្រះសង្ឃ ក៏ផ្អើលស្ទុះទៅជាន់យាយចណ្ឌាលនោះស្លាប់ទៅ ។ យាយចណ្ឌាលក៏បានទៅកើតក្នុងវិមានមាសកម្ពស់ ១២យោជន៍នាស្ថានតាវត្តិង្ស ទេវលោកសោយទិព្វជាសុខក្សេមក្សាន្ត ។

## ៤៧. រឿងនាងកេសការី[53]

(អានិសង្សសីល៥ និងចម្រើនអាការៈទាំង៣២)

កាលព្រះសម្ពុទ្ធបរមគ្រូ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ននាក្រុងពារាណសីជាមួយនឹងភិក្ខុសង្ឃច្រើនរយអង្គ ។ កាលនោះក្នុងក្រុងពារាណសីមានធីតាមួយរូបឈ្មោះកេសការី កំពុងអង្គុយរកចៃឲ្យមាតាក្នុងផ្ទះបានឃើញភិក្ខុសង្ឃចូលទៅបិណ្ឌបាត ក៏និយាយប្រាប់មាតាថា បពិត្រអ្នកម្តាយភិក្ខុសង្ឃដែលគង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន បានចូលមកបិណ្ឌបាតក្នុងភូមិរបស់យើង

---

[53] ប្រជុំនិទានជាតកភាគ១ ទំព័រ ៣៩

ភិក្ខុទាំងនោះនៅក្មេងៗ កំពុងពេញកំលោះមានរូបស្អាតផូរផង់ល្អ ហេតុដូចម្ដេច បានជានាំគ្នាបួសដើរសុំគេយ៉ាងនេះ? លោកមានប្រាថ្នាដូចម្ដេច?

មាតានិយាយប្រាប់ថា លោកបួសយកបុណ្យ កុំសួរអ្វីគិតតែរកចៃទៅ ។ ក្នុងពេលនោះមានឧបាសកម្នាក់សម្រេចដល់សោតាបត្តិផល កំពុងដើរនៅមុខផ្ទះ បានឮនាងព្រាហ្មណីនិយាយ និងកូនក្រមុំដូច្នោះ ក៏ឡើងទៅលើផ្ទះនោះ ។ នាងព្រាហ្មណី និងកូនក្រមុំ បានឃើញឧបាសកឡើងលើផ្ទះខ្លួនដូច្នោះហើយក៏រៀបចំអាសនៈឲ្យអង្គុយ ទើបនាងកេសការីជាកូន សួរទៅឧបាសកនោះថា បពិត្រលោកអ៊ុំ ភិក្ខុសង្ឃដែលនិមន្តបិណ្ឌបាតអម្បាញ់មិញនេះ នៅក្មេងៗកំពុងពេញកំលោះ មានរូបស្អាតបាតអង្គខ្លះ ប្រហែលជាកូនគហបតី សេដ្ឋីឬក៏ព្រះរាជបុត្រ របស់ក្សត្រិយ៍អង្គណាមួយក៏មិនដឹង លោកគិតឃើញដូចម្ដេច បានជាបួសៗប្រាថ្នាអ្វី? ខ្ញុំសង្ស័យណាស់ ។

ឧបាសកប្រាប់ថា ម្នាលនាងក្រមុំ ភិក្ខុសង្ឃទាំងអស់នេះលោកប្រាថ្នាឲ្យរួចចាកទុក្ខក្នុងវដ្តសង្សារ ព្រោះលោកពិចារណាឃើញច្បាស់នូវទោសរបស់វត្ថុកាម និងកិលេសកាម និងឃើញច្បាស់នូវអានិសង្សរបស់បព្វជ្ជា ព្រោះបព្វជ្ជានេះមានគុណខ្ពង់ខ្ពស់បំផុត អាចធ្វើសត្វឲ្យធាប់រួចពីការកើតចាស់ឈឺស្លាប់បានសម្ដែងដូច្នេះហើយ ក៏សរសើរអំពីអានិសង្ស ត្រៃសរណគមន៍និងសីល៥ តទៅទៀត លុះចប់ហើយនាងកេសការី សួរឧបាសកនោះទៀតថា លោកអ៊ុំ! បើខ្ញុំ ដល់នូវត្រៃសរណគមន៍ ហើយរក្សាសីល៥ តើបានអានិសង្សដូចលោកអ៊ុំមាន ប្រសាសន៍ដែរ ឬទេ?

ឧបាសកឆ្លើយថា ប្រសើរវិសេសណាស់នាង! ព្រោះធម៌របស់ព្រះសម្ពុទ្ធមិនរើសថាក្មេងចាស់ទេ ។ នាងក៏សូមសមាទានសីល៥ អំពីឧបាសកនោះ ហើយសួរថាកិច្ចដែលខ្ញុំត្រូវធ្វើមានដូចម្ដេចទៀត? ឧបាសកប្រាប់ថា កិច្ចដទៃក្រៅពីនេះមានច្រើនណាស់ ប៉ុន្តែនាងចូរពិចារណានូវទ្វត្តិំសាការកម្មដ្ឋានជានិច្ចរាល់ថ្ងៃចុះដើម្បីឲ្យបានអានិសង្សច្រើន ។

ឧបាសកបានពន្យល់អាការៈ៣២ប្រការ និងវិធីពិចារណាដោយពិស្តារហើយ ក៏លានាងទាំងពីររូបទៅផ្ទះរបស់ខ្លួនទៅ ។ ឯនាងកេសការី កូនក្រមុំរបស់នាងព្រាហ្មណីនោះ ជាស្រីមានឧបនិស្ស័យចាស់ក្លា គ្រាន់តែបានពិចារណានូវអាការៈ៣២ប្រការក្នុងថ្ងៃនោះ ក៏បានសម្រេចសោតាបត្តិផល ។

ក្នុងកាលខាងក្រោយមក នាងអស់អាយុក៏បានទៅកើតក្នុងវិមានកែវពិទូរ្យកំពស់៣០យោជន៍ នាស្ថានត្រៃត្រិង្ស បានជាអគ្គមហេសីរបស់ព្រះឥន្ទ្រាធិរាជ នាងមានស្រីទេពអប្សរ១សែនចោមរោមជាបរិវារ មានពន្លឺផ្សាយចេញអំពីកាយដ៏រុងរឿងដូចជាពន្លឺព្រះច័ន្ទ បរិបូណ៌ដោយទិព្វសិរី ស្ថិតនៅក្នុងទេវលោកជាសុខក្សេមក្សាន្ត ។

## ៤៨. រឿងបល្ល័ង្កអណ្តែត[54]

(ថ្វាយទានព្រះភិក្ខុសង្ឃ ដោយសទ្ធាជ្រះថ្លារមែងបានសម្បត្តិទិព្វ)

ក្នុងពុទ្ធកាល ព្រះមហាមោគ្គល្លានត្ថេរ បាននិមន្តទៅឋានត្រៃត្រិង្សទេវលោក បានឃើញពួកទេវតាទាំងឡាយ កំពុងនាំគ្នាលេងមហោស្រពក្នុងនន្ទវនឧទ្យានមួយស្របក់ស្រាប់តែឃើញ បល្ល័ង្កមាសកម្ពស់១យោជន៍អណ្តែតព្វដ៏អាកាសមានល្បឿនយ៉ាងលឿន សំដៅចុះមកក្នុងនន្ទវនឧទ្យាន ។ បល្ល័ង្កនោះសណ្ឋានជាបុស្បុក មានស្រីទេពអប្សរ១៣ាន់ អង្គុយចោមរោមនាងទេពធីតាម្នាក់លើបល្ល័ង្កនោះ នាងទេពធីតាជាម្ចាស់បល្ល័ង្កអណ្តែតនោះ មានរូបឆោមល្អស្រស់ប្រិមប្រិយ មានពន្លឺភ្លឺចេញអំពីកាយដូចជាព្រះច័ន្ទពេញវង់ នាងទ្រទ្រង់នូវគ្រឿងអលង្ការទម្ងន់៦០រទេះ បានឃើញព្រះមោគ្គល្លាន ហើយនាងមានសេចក្តីជ្រះថ្លារីករាយឥតឧបមា បាននាំស្រីទេពអប្សរជាបរិវារទាំង១៣ាន់ ចុះពីបល្ល័ង្កទៅថ្វាយបង្គំនមស្ការព្រះមោគ្គល្លានត្ថេរៗមានថេរដីកាសួរថា ម្នាលនាងទេពធីតាអ្នកមានកាយរុងរឿង ដូចជាព្រះចន្ទ្រពេញវង់ ទ្រទ្រង់នូវគ្រឿងអលង្ការទិព្វ

[54] ប្រជុំនិទានជាតកភាគ១ ទំព័រ ៤៥

ទម្ងន់៦០រទេះ មានកេសាព័ទ្ធព័ន្ធប្រទាក់ធ្លាក់ដោយភួងផ្កា កាលពីជាតិមុន នាងបានធ្វើបុណ្យដូចម្តេចខ្លះ ?

នាងទេពធីតា ថ្លែងរៀបរាប់ប្រវត្តិរបស់នាងប្រាប់ដល់ព្រះមោគ្គល្លានត្ថេរ ថា បពិត្រលោកម្ចាស់ដ៏ចម្រើនកាលព្រះសម្មុទ្ធបរមគ្រូគង់នៅក្នុងវត្តជេតពន សម័យនោះមានភិក្ខុមួយអង្គ ជាអ្នករក្សាធុតង្គ បាននិមន្តចូលទៅបិណ្ឌបាតក្នុង ក្រុងសាវត្ថី ។ កាលនោះខ្ញុំព្រះករុណាកើតជាធីតាក្នុងត្រកូលមួយ នៅក្នុង ក្រុងសាវត្ថីនោះដែរ បានឃើញភិក្ខុនោះកំពុងនិមន្តបិណ្ឌបាត ក៏មានចិត្តត្រេក អររីករាយឥតឧបមា បាននិមន្តលោកចូលទៅក្នុងគេហដ្ឋាន ហើយចាត់ចែង រៀបគ្រែតូចមួយជា អាសនៈ បានយកសំពត់កម្ពលពណ៌លឿងទៅក្រាលលើគ្រែ នោះជាគ្រឿងលម្អលុះ ក្រាលហើយនិមន្តភិក្ខុនោះឲ្យគង់ ខ្ញុំព្រះករុណាក៏ម្នីម្នាទៅ ចាត់ចែងភោជនាហារ យកទៅប្រគេនលោកឆាន់ ហើយបានកាន់ផ្តិតចូលទៅ អង្គុយបក់ប្រគេនលោកទៀត លុះភិក្ខុនោះឆាន់ហើយសំដែងនូវភត្តានុមោទនា ចប់ក៏និមន្តទៅវត្តជេតពនទៅ ។

ខ្ញុំព្រះករុណា បានរំពឹងពិចារណានូវទានដែលបានធ្វើហើយ សទ្ធាគឺសេចក្តី ជ្រះថ្លា ក៏កាន់តែកើតឡើងជាភិយ្យោភាព ខ្ញុំព្រះករុណាជ្រះថ្លាខ្លាំងពេក បាន យកគ្រែដែលរៀបតាក់តែងដោយសំពត់កម្ពលនោះ ទៅតាមប្រគេនលោកដល់ វត្តទៀត។

ក្នុងកាលជាខាងក្រោយមក ខ្ញុំព្រះករុណាអស់អាយុ ក៏បានមកកើតក្នុង វិមានមាសកម្ពស់១២យោជន៍ មានស្រីទេពអប្សរ១ពាន់ជាបរិវារ មានបល្ល័ង្ក មាសមួយកម្ពស់១យោជន៍កើតឡើងក្នុងវិមាននោះ សម្រាប់ជាយានរបស់ខ្ញុំ ព្រះករុណា បល្ល័ង្កនោះមានសន្ទុះលឿនស្មើនឹងចិត្ត បើចិត្តរបស់ខ្ញុំព្រះករុណា នឹកចង់ទៅទីណាក៏អណ្តែតទៅដល់ទីនោះមួយរំពេច ។ ព្រះមោគ្គល្លានបាន ស្តាប់ ប្រវត្តិរបស់នាងទេពធីតានោះចប់ហើយ ក៏និមន្តហួសទៅកាន់ទីដទៃ ទៀតទៅ។

សមដូចក្នុងសៀវភៅ ការបម្រើភ្លើង របស់ព្រះភិក្ខុ ទ្រី ប៉ាណៃ ត្រង់ទំព័រ៤៩ បានសម្ដែងថា បើបុគ្គលមានចិត្តជ្រះថ្លា ចំពោះទក្ខិណេយ្យបុគ្គលគឺលោកអ្នកទ្រទ្រង់នូវគុណមានសីលជាដើម រមែងសម្រេចនូវប្រយោជន៍ដ៏ច្រើនដោយ ហោចទៅសូម្បីតែសម្លឹងមើលដោយចិត្តជ្រះថ្លា ដូចសេចក្ដីដែលព្រះអង្គកថាកន្លែងខ្លះពន្យល់ថា កាលបុគ្គលសម្លឹងមើលលោកអ្នកទ្រទ្រង់គុណដ៏ធំដោយចិត្តជ្រះថ្លាបុណ្យដែលកើតមកពីកិរិយាសម្លឹងមើលនោះ ។

ជាហេតុរោគក្ដី ទោសក្ដី ឡើងបាយភ្នែកក្ដីរោគរលកកែវក្ដី រមែងមិនមានក្នុងភ្នែករហូត ១ពាន់ជាតិជាអនេក ភ្នែកទាំងឡាយជាធម្មជាតិ ភ្លឺស្វាងមានសិរីប្រកបដោយពណ៌៥យ៉ាង ប្រៀបដូចជាមេទ្វារកែវមណីដែលនាងទេពធីតាបើកហើយក្នុងរតនវិមាន ។ បុគ្គលរមែងជាអ្នកបានសម្បត្តិគ្រប់យ៉ាង ក្នុងពួកទេវតា និងមនុស្សអស់កាលប្រមាណ១សែនកប្ប ។

## ៤៩. រឿងសត្វមៀម

(ជ្រះថ្លាចំពោះព្រះពុទ្ធ និងព្រះសង្ឃ រមែងរួចចាកទុក្ខ)

កាលព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងគុហា ឈ្មោះឥន្ទសាលលើភ្នំវេទិយកៈ គ្រានោះមានសត្វមៀមមួយក្បាល កាលបើព្រះដ៏មានព្រះភាគទ្រង់ស្ដេចយាងទៅ ក្នុងស្រុកដើម្បីបិណ្ឌបាតសត្វនោះរមែងហើរទៅតាម រហូតដល់ពាក់កណ្ដាលផ្លូវ កាលបើព្រះអង្គស្ដេចយាងចេញមកវិញ តែងទៅទទួលតាំងពីពាក់កណ្ដាលផ្លូវមករហូតដល់គុហា ។

ក្នុងថ្ងៃមួយសត្វមៀមនោះបានហើរចុះអំពីភ្នំ ហើយថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលមានភិក្ខុសង្ឃចោមរោម ហើយទ្រង់គង់នៅក្នុងពេលសាយណ្ហសម័យ ហើយសត្វនោះប្រណមស្លាបទាំងពីរ ដូចមនុស្សផ្គងអញ្ជលី ហើយឱនក្បាលចុះក្រោម ឈរនមស្ការព្រះទសពល ។ ព្រះដ៏មានព្រះភាគទ្រង់ទតមើលសត្វមៀមនោះ ហើយទើបទ្រង់ធ្វើនូវការញញឹម ។

ព្រះអានន្ទត្ថេរ បានក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើនអ្វីទៅហ្ន៎ជាហេតុ? អ្វីទៅហ្ន៎ជាបច្ច័យ? នៃកិរិយាធ្វើនូវការញញឹមរបស់ព្រះដ៏មានព្រះភាគឲ្យប្រាកដ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកចូរមើលនូវសត្វមៀមនេះ វាបានញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងតថាគត និងភិក្ខុសង្ឃ ហើយនឹងត្រាច់រង្គាត់ទៅក្នុងទេវតា និងមនុស្សរហូត១សែនកប្ប ហើយនឹងបានត្រាស់ជាព្រះបច្ចេកពុទ្ធមួយអង្គនាមសោមនស្ស ។[55]

ពួករុក្ខទេវតាបានពោលគាថា ឲ្យសព្ទសាធុការព្រមៗគ្នាថា:

**ឧលូក មណ្ឌលក្ខិក**
**វេទិយកេ ចិរទីឃវាសិក**
**សុខិតោសិ ត្វំ អយ្យ កោសិយ**
**កាលុដ្ឋិតំ បស្សសិ ពុទ្ធវរំ ។**

ហៃមៀមកោសិយ៍ភ្នែកមូលម្ចាស់អើយ អ្នកនៅយូរហើយលើបព្វតា នាមវេទិយកៈដល់នូវសុខា ឃើញពុទ្ធវរាក្រោកក្នុងកាលគួរ ។

បន្ទាប់មក ព្រះសាស្តាពោលព្យាករថា:

**មយិ ចិត្តំ បសាទេត្វា ភិក្ខុសង្ឃេ អនុត្តរេ**
**កប្បានំ សតសហស្សានិ ទុគ្គតេសោ នគច្ឆតិ ។**

មៀមនេះច្យុតចាកទេវលោក គឺកុសលមូលដាស់តឿនហើយ នឹងបានជាព្រះបច្ចេកពុទ្ធមានវិស្សុតនាមថាសោមនស្សមានញាណគ្មានទីបំផុត ។[56]

បព្វជិត ឬភិក្ខុសង្ឃដែលជាអ្នកទ្រទ្រង់នូវគុណ ឈ្មោះថាភ្លើងព្រោះថាបុគ្គលណាចេះបម្រើ រមែងសម្រេចប្រយោជន៍តែបើមិនចេះបម្រើរមែងបានទោស

---

[55] ការបម្រើភ្លើង ទំព័រ ៥១ របស់ព្រះតេជគុណ បវរធម្មោ ទ្រី ប៉ោណៃ

[56] ប្រជុំនិទានជាតកភាគ៣ ទំព័រ ១៥០ ជាសៀវភៅភាគ៣ដាច់ពីគ្នាតែម្តង ។ ម្យ៉ាងទៀតប្រជុំនិទានជាតកនេះ មានភាគ១-ភាគ៣ជាសៀវភៅភ្ជាប់គ្នាតែ១ និងភាគដាច់ពីគ្នាក៏មាន ។

ឬបានបាបសោយទុក្ខក្នុងនរកប្រេត អសុរកាយជាដើម ។ ហេតុនេះដើម្បីបានសម្រេចប្រយោជន៍អំពីការបម្រើ បុគ្គលគប្បីប្រតិបត្តិចំពោះភិក្ខុសង្ឃដោយធម៌៥យ៉ាងគឺ:

១. ធ្វើនូវអំពើអ្វីគឺធ្វើដោយមេត្តាចិត្តមួយ
២. និយាយអ្វីគឺនិយាយដោយមេត្តាចិត្តមួយ
៣. គិតអ្វីគឺគិតដោយមេត្តាចចិត្តប្រាថ្នាឲ្យព្រះសង្ឃបានសុខមួយ
៤. មិនបិទទ្វារផ្ទះ គឺមានសទ្ធាទទួលដោយពេញចិត្តមួយ
៥. ធ្វើទានដោយការទំនុកបម្រុងដល់ព្រះសង្ឃមួយ ។[57]

បើសិនជាពុទ្ធបរិស័ទ គោរពបានដូចនេះហើយរមែងបានសេចក្តីសុខចម្រើនបានសោយសុខជាសម្បត្តិមនុស្សផង លុះអាយុសង្ខារពីមនុស្ស និងបានរីករាយសោយទិព្វសម្បត្តិក្នុងទេវលោកមិនខានឡើយ ចំពោះអ្នកមានសទ្ធាជ្រះថ្លា និងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

## ៥០. រឿងភ័យរបស់សុបតិដ្ឋិតាទេវបុត្ត[58]

### តេន ខោ បន សមយេន

ក្នុងសម័យមួយដែលព្រះបរមគ្រូ ជាម្ចាស់នៃយើងទ្រង់យាងទៅកាន់ឋានត្រៃត្រិង្ស ដើម្បីសម្តែងព្រះអភិធម្ម ប្រោសពុទ្ធមាតានោះ ពេលនោះមានទេវបុត្តមួយអង្គ ឈ្មោះសុបតិដ្ឋិតា ទេវបុត្ត មាននិមិត្ត៤កើតឡើងគឺ:

១. ផ្កាក្នុងសួនរុះរោយ
២. សំលៀកបំពាក់សៅហ្មង
៣. ញើសហូរចេញ
៤. សំពត់ទិព្វប៉ះខ្លួនក្តៅក្រហាយ

កាលណាមាននិមិត្តទាំង៤នេះ កើតឡើងអាចបញ្ជាក់ឲ្យដឹងថាខ្លួនត្រូវច្យុត

[57] ការបម្រើភ្លើង ទំព័រ ៥១ របស់ព្រះតេជគុណ បវរធម្មោ ឌី ប៉ោណៃ
[58] ជួបព្រះវិលងព្រួយ លោកតា ហ៊ុន ឡឹង ទំព័រ ១

ដោយអស់បុណ្យ ពេលនោះសុបតិដ្ឋិតាទេវបុត្ត ក៏បានទៅជួបនឹងទេវបុត្ត១អង្គទៀតឈ្មោះ អាកាសចារិនីដែលត្រូវជាមិត្តនឹងខ្លួន ដើម្បីបញ្ជាក់ប្រាប់នូវរឿងដែលខ្លួនត្រូវអស់បុណ្យច្យុតចុះចាកទេវលោកក្នុងរវាង៧ថ្ងៃទៀត ។

ពេលនោះ អាកាសចារិនីទេវបុត្តជាមិត្ត ក៏បានថ្លែងប្រាប់នូវបាបកម្មរបស់សុបតិដ្ឋិតាទេវបុត្ត ដើម្បីឲ្យបានជ្រាបថា ការច្យុតចុះចាកទេវលោកទៅនេះ សុបតិដ្ឋិតាទេវបុត្តឯងត្រូវទទួលបាបកម្មយ៉ាងធ្ងន់ គឺត្រូវទោសសោយទុក្ខក្នុងនរកអស់១សែនឆ្នាំ រួចពីនរកមកត្រូវចាប់កំណើតជា សត្វឆ្កួត៥រយជាតិ អក៥រយជាតិ ក្អែក៥រយជាតិ អណ្តើត៥រយជាតិ ឆ្កែ៥រយជាតិ កណ្តុរ៥រយជាតិ ជាមនុស្សខ្វាក់ខ្វិន គ ថ្លង់ ៥រយជាតិ សុបតិដ្ឋិតាទេវបុត្តបានឮពាក្យនេះហើយ ក៏មានសេចក្តីតក់ស្លុតយ៉ាងខ្លាំង ហើយក៏បានពោលទៅកាន់ អាកាសចារិនីជាមិត្តឲ្យជួយរកមធ្យោបាយយ៉ាងណា ដើម្បីគេចឲ្យផុតពីបាបកម្មទាំងអស់នោះ ។

ទើបទេវបុត្តនោះប្រាប់ថា នៅឋានត្រៃត្រិង្សយើងនេះ មានតែព្រះឥន្ទ្រាធិរាជព្រះអង្គ ជាធំនៃទេវតាទាំងឡាយដូច្នេះយើងត្រូវទៅជួបនឹងព្រះអង្គ ក្រែងព្រះអង្គអាចជួយយើងបាន ទេវបុត្តទាំងពីរព្រះអង្គស្របយោបល់គ្នាហើយ ក៏នាំគ្នាចូលទៅជួបព្រះឥន្ទ្រ លុះចូលទៅដល់ក៏ក្រាបថ្វាយបង្គំទូលតាមរឿងដែលខ្លួនត្រូវច្យុតចុះចាក់ទេវលោក និងរឿងដែលត្រូវទទួលបាបកម្មដ៏ធ្ងន់ ដើម្បីឲ្យព្រះឥន្ទ្របានជ្រាប ។

លុះព្រះឥន្ទ្របានស្តាប់ហើយ ក៏ឆ្លើយតបមកវិញថា ម្នាលទេវតាសត្វដែលរស់នៅ ក្នុងភពទាំង៣គឺ កាមភព រូបភព អរូបភព គ្មានសត្វណាគេចឲ្យផុតពីស្លាប់បានទេ តែកើតមកហើយតែងតែស្លាប់ ទៅវិញជាធម្មតា ចំពោះបាបកម្មរបស់អ្នកក៏ដូចគ្នា អ្នកណាបានសាងអ្នកនោះឯងក៏ត្រូវទទួល យើងគ្មានមធ្យោបាយអាច ជួយដោះស្រាយឲ្យអ្នកផុតពីស្លាប់ និងផុតពីបាបកម្មរបស់អ្នកបានឡើយ ។

តែពេលនេះជាឱកាសល្អហើយ ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់នៃយើង ព្រះអង្គគង់ក្រោមដើមបារិច្ឆត្តព្រឹក្ស កំពុងសំដែងធម៌ប្រោសពុទ្ធមាតានៅឋានត្រៃត្រិង្សយើងនេះស្រាប់ចូរអ្នកទាំងពីរទៅជាមួយយើង ព្រមទាំងនាំនូវផ្កាភ្ញីយកទៅបូជាចំពោះព្រះអង្គព្រមទាំងទូល សុំឲ្យព្រះអង្គជួយសង្គ្រោះព្រោះព្រះអង្គនេះហើយជាទីពឹងរបស់ សត្វក្នុងត្រៃភព ក្រែងព្រះអង្គអាចជួយបាន លុះព្រះឥន្ទ្រ និងទេវតាទាំងពីរ ចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រមទាំងបូជាផ្កាភ្ញីចប់សព្វគ្រប់ហើយ ព្រះឥន្ទ្រក្រាបទូលដោយសព្វគ្រប់ នូវរឿងរបស់សុបតិដ្ឋិតាទេវបុត្ត ថ្វាយចំពោះព្រះដ៏មានព្រះភាគ ឲ្យព្រះអង្គបានជ្រាប និងសូមឲ្យទ្រង់សម្ដែងព្រះសទ្ធម្មទេសនាត្រង់ណាដែលជាសច្ចធម៌ ដែលជាធម៌អាចជួយសង្គ្រោះដល់សត្វលោក និងជួយឲ្យសុបតិដ្ឋិតាទេវបុត្តរួចផុតពីស្លាប់ក្នុងរវាង៧ថ្ងៃទៀត និងឲ្យផុតរលត់នូវបាបកម្មរបស់ខ្លួនកុំឲ្យមានតទៅទៀត ។

ព្រះបរមគ្រូទ្រង់ត្រាស់ សំដែងនូវបុព្វកម្មរបស់ទេវបុត្តនោះថា កាលកើតជាមនុស្សមានគំនិត យល់ខុសបានសម្លាប់សត្វតូចធំនិងត្រីយកសាច់ ហើយថែមទាំងបានទះតប់មាតាបិតា សមណៈជីព្រាហ្មណ៍ កាលបើមានសមណៈអង្គណាចូលទៅរកគាត់ គាត់តែងងាកមុខចេញធ្វើជាមិនឃើញ ដោយវិបាកផលអកុសលកម្មនេះតាមមកទាន់ទើបត្រូវទទួលទៅរងទុក្ខក្នុងនរកជាដើមនោះ ។

រួចទ្រង់ត្រាស់ នូវគាថា ឧណ្ហិស្សវិជ័យដូច្នេះថា:

**អត្ថិ ឧណ្ហិស្សវិជយោ ធម្មោ**
**លោកេ អនុត្តរោ សព្វសត្តហិតត្ថាយ**
**តំ ត្វំ គណ្ហាហិ ទេវតេ បរិវជ្ជេ**
**រាជទណ្ឌោ អមនុស្សេហិ បាវកេ**
**ព្យគ្ឃេ នាគេ វិសេ ភូតេ អកាលមរណេន**
**វា សព្វស្មា មរណា មុត្តោ ឋបេត្វា**

ភាលមារិតំ តស្សេវ អានុភាវេន
ហោតុ ទេវោ សុខី សទា សុទ្ធសីលំ
សមាទាយ ធម្មំ សុច្ចរិត្តំ ចរេ តស្សេវ
អានុភាវេន ហោតុ ទេវោ សុខិ
សទា លិក្ខិត្តំចិន្តិតំបូជំ ធារណំ
វាចនំ គរុំ បរេសំ ទេសនំ សុត្វា
តស្ស អាយុបវឌ្ឍតីតិ ។

ម្នាលទេវតាទាំងឡាយ ព្រះធម៌នេះឈ្មោះថា ខ្វណ្ហិស្សវិជ័យជាកំពូលនៃធម៌ទាំងពួងជាប្រយោជន៍ដល់សត្វទាំងឡាយ អ្នកចូរយកព្រះធម៌នេះជាទីពឹងចុះ ខ្វស្សាហ៍ស្វធ្យស្វាធ្យាយរាល់យប់ ថ្ងៃ រមែងហាមឃាត់នូវភ័យទាំងពួងបាន ដែលបណ្តាលមកពីព្រាយបិសាច ក្រុមព្យត្បៈ ខ្លា ពស់ តូច ធំ ហើយនឹងផ្ចាញ់ពួតសេនាអាមាត្យទាំងឡាយដែលមានបំណងប៉ងឃាឃីអ្នកជាធម៌សម្រាប់ ការពារនូវសត្វទាំងពួង អ្នកណាបានសរសេរទុកក្តីបានស្តាប់ក្តី បានសូត្រតាវនារាល់យប់ថ្ងៃក្តី និងមានអាយុយឺនយូរ ម្នាលទេវតាទាំងឡាយអ្នកចូរមានសេចក្តីសុខចុះ ។

សក្កត្វា ពុទ្ធរតនំ ឱសថំ ឧត្តមំ
វរំ ហិតំ ទេវមនុស្សានំ ពុទ្ធតេជេន
សោត្ថិនា នស្សន្តុបទ្ទវា សព្វេ ទុក្ខា
វូបសមេន្តុតេ សក្កត្វា ធម្មរតនំ
ឱសថំ ឧត្តមំ វរំ បរិឡាហូបសមនំ
ធម្មតេជេន សោត្ថិនា នស្សន្តុបទ្ទវា
សព្វេ ភយា វូបសមេន្តុតេ សក្កត្វា

**សព្វរតនំ ឱសថំ ឧត្តមំ វរំអាហុនេយ្យំ**
**បាហុនេយ្យំ សព្វតេជេន សោត្ថិនា**
**នស្សន្តុបទ្ទវា សព្វេ រោគា ទុបសមេន្តុតេ ។**

ម្យ៉ាងទៀតបុគ្គលណាបានបូជាកែវទាំង៣ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នេះក៏ជាឱសថដ៏ ឧត្តម រមែងឃុំគ្រងបុគ្គលនោះ ឲ្យរួចផុតចាកទុក្ខ ភ័យ អាគទាំងពួងដោយអំណាចព្រះគាថា ឧណ្ហិស្សវិជ័យនេះ និងឃុំគ្រងជីវិត របស់អ្នកឲ្យចម្រើនតទៅអ្នកចូររក្សាទុកឲ្យគង់កុំឲ្យបាត់សោះ ឡើយ ។

លុះចប់ព្រះសទ្ធម្មទេសនានោះហើយ ទេវតាទាំងឡាយមានព្រះឥន្រ្ទជាប្រធាន បានក្រេប នូវរសនៃព្រះសទ្ធម្មនោះក៏មានសេចក្តីជ្រះថ្លាជាអនេកប្បការ ចំណែកសុបតិដ្ឋិតាទេវបុត្តក៏មានចិត្ត ចុះស្លុងទៅក្នុងក្រសែធម្មទេសនានោះខំប្រឹងភាវនាស្រាប់តែបានប្រែខ្លួនពីទេវតាចាស់ ក្លាយទៅជាទេវតាកំលោះមានរូបឆោមស្រស់បំព្រងមួយរំពេច ហើយត្រូវមានអាយុយឺនយូររស់នៅក្នុងឋានត្រៃត្រិង្សទល់គ្នា និងព្រះអរិយមេត្រីយ៍ចុះមកត្រាស់ក្នុងលោក ទើបទេវបុត្តនោះច្យុតមកកើតក្នុងមនុស្សលោក ព្រមទាំងបានសម្រេចជាព្រះអរហន្តខីណាស្រពមួយអង្គដោយអានិសង្សនៃសេចក្តីជ្រះថ្លាចំពោះព្រះគាថាឧណ្ហិស្សវិជ័យនេះ ។

តាមន័យច្បាប់ដើមលោកបញ្ជាក់ប្រាប់ថា ការពាររឿងគ្រោះថ្នាក់ ឧបសគ្គចង្រៃខ្ចាត់ខ្ចាយអស់ គាថានេះឆ្នើមខាងការពារ ជាគ្រោះកំផែងបាំងរាំងរា គ្រោះកាចនានាវិនាសសូន្យ ។

បញ្ជាក់ពាក្យថា "ជួបព្រះលែងព្រួយ" ជាឈ្មោះសៀវភៅលោកតា ហ៊ុន ឡឹង ជាអ្នករៀបរៀងចេញពីសៀវភៅថៃបកប្រែមកជាភាសាខ្មែរ ។

# ៥១. រឿងនាងគព្ភិនី[59]

(គ្រាប់ល្ងបន្តិច ដូរយកសម្បត្តិសួគ៌បាន)

ក្នុងពុទ្ធកាល មានស្ត្រីម្នាក់មានគភ៌ នៅក្នុងក្រុងរាជគ្រឹះ ថ្ងៃមួយនាងមានចំណង់ចង់ផឹកប្រេងល្ង បានយកគ្រាប់ល្ងទៅលាងទឹក ហើយហាលថ្ងៃដើម្បីបុកចម្រាញ់យកប្រេង ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូ ទ្រង់គង់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី បានប្រមើលមើលឧបនិស្ស័យរបស់សត្វទ្រង់ជ្រាបថា នាងគព្ភិនីនឹង ធ្វើមរណកាលក្នុងថ្ងៃស្អែកនេះ ហើយធ្លាក់ទៅកើតក្នុងនរកធំឈ្មោះអវិចី ប៉ុន្តែបើ បានឃើញតថាគតនឹងត្រឡប់ ទៅកើតក្នុងឋានសួគ៌វិញ លុះទ្រង់ជ្រាបដូច្នេះហើយ ក៏យកបាត្រហោះពួដ៏អាកាស សំដៅទៅក្រុងរាជគ្រឹះយាងទៅដល់ ហើយទ្រង់និមន្តបិណ្ឌបាត្រក្នុងទីក្រុងរៀងតាមមាគ៌ាជរាបទៅដល់ផ្ទះនាងគព្ភិនី។

ពេលនោះនាងកំពុងហាលគ្រាប់ល្ង លុះបានឃើញព្រះមានព្រះភាគហើយ ក៏មានចិត្តសោមនស្សជ្រះថ្លា ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ទើបគិតថាអាត្មាអញបានវត្ថុអ្វី គួរសមនឹងថ្វាយព្រះសម្ពុទ្ធ មានតែគ្រាប់ល្ងប៉ុណ្ណោះ ក្រៅពីគ្រាប់ល្ងនេះចេញគ្មានឡើយ គិតដូច្នេះហើយក៏កើបគ្រាប់ល្ងពីរកំបង់យកទៅដាក់បាត្រព្រះសម្ពុទ្ធៗទ្រង់ទទួលធ្វើអនុមោទនាហើយនិមន្តហួសទៅ ។

លុះដល់ថ្ងៃស្អែកឡើង នាងធ្វើមរណកាលទៅបានទៅកើតក្នុងវិមានមាសកំពស់១២យោជន៍នាស្ថានត្រៃត្រិង្ស បរិបូណ៌ដោយទិព្វសម្បត្តិមានពន្លឺភ្លឺថ្លាផ្សាយចេញអំពីកាយ មានស្រីទេពអប្សរ១ពាន់ចោមរោមជាបរិវារ ។ ថ្ងៃមួយព្រះមោគ្គល្លានត្ថេរ លោកនិមន្តទៅឋានត្រៃត្រិង្ស ដើម្បីពិនិត្យមើលស្ថានភាពនិងលក្ខណៈសម្បត្តិរបស់ទេវតា បានឃើញនាងទេពធីតានោះហើយ ក៏សួរប្រវត្តិរបស់នាងៗបានថ្លែងប្រាប់ដោយសព្វគ្រប់ ។

ព្រះមោគ្គល្លាន បានជ្រាបថានាងជាស្ត្រី មាននិស្ស័យខ្ពស់ទើបសំដែងអំពី

---

[59] ប្រជុំនិទានជាតកភាគ១ ទំព័រ ៥២

អរិយសច្ចធម៌ឲ្យនាងស្តាប់ លុះសម្តែងចប់ នាងទេពធីតាព្រមទាំងបរិវារ១៣ន់ ក៏បានសម្រេចដល់សោតាបត្តិផល ។ ព្រះមោគ្គល្លាន ក៏និមន្តត្រឡប់មក មនុស្សលោកវិញ ទៅថ្វាយបង្គំព្រះសម្ពុទ្ធដំណាលរឿងរ៉ាវរបស់នាងទេពធីតា នោះថ្វាយជាព្រះសណ្តាប់ ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលមោគ្គល្លានអ្នកមានឫទ្ធិរឿងនេះពិតណាស់ តថាគតបានដឹងយូរហើយ ប៉ុន្តែគ្មានអ្នកណាជាសាក្សី បានជាតថាគតមិន សម្តែងប្រាប់ដល់អ្នកទាំងឡាយ លុះមានព្រះពុទ្ធដីកាដូច្នេះហើយទ្រង់សម្តែង សរសើរអំពីអានិសង្សរបស់ទានជាកិយ្យោភាពទៅ ។

## ៥២. រឿងនាងសេសវតី[60]

(បូជាព្រះសារីរិកធាតុ ដោយជ្រះថ្លារមែងបានសោយទិព្វសម្បត្តិ)

ក្នុងសាសនាព្រះសម្ពុទ្ធកស្សប ព្រះអង្គបរិនិព្វានទៅហើយពួកមហាជន ទាំងឡាយ បាននាំគ្នាយកមាសទៅកសាងចេតិយកម្ពស់១យោជន៍ ដើម្បីបញ្ចុះ ព្រះសារីរិកធាតុ ។ កាលនោះមានឧបាសិកាម្នាក់ បាននាំនាងទារិកាជាកូន របស់ ខ្លួនទៅមើលជាងទងដែលកំពុងរំលាយមាសធ្វើឥដ្ឋ ។ នាងទារិកាឃើញ ជាងកំពុងរំលាយមាស ក៏សួរទៅមាតាថា បពិត្រអ្នកម្តាយ គេរំលាយមាស ធ្វើអ្វី?

មាតាប្រាប់ថា គេធ្វើចេតិយបញ្ចុះព្រះសារីរិកធាតុព្រះសម្ពុទ្ធ នាងទារិកា បានឮដូច្នេះ ក៏មានចិត្តជ្រះថ្លាចំពោះព្រះសម្ពុទ្ធ ទើបប្រាប់ម្តាយថា ខ្សែមាស ពាក់នៅករបស់ខ្ញុំនេះ ខ្ញុំយកទៅចូលធ្វើចេតិយនឹងគេ មាតាឆ្លើយថាល្អហើយកូន ស្រីម្តាយ ក៏យកខ្សែមាសនោះទៅចូលធ្វើចេតិយនឹងគេទៅ ។ សង្ខេបសេចក្តី ប៉ុណ្ណោះ លុះដល់នាងស្លាប់ទៅ បានទៅកើតក្នុងសុគតិភព ជាអនុលោម បដិលោមអស់មួយពុទ្ធន្តរ ដល់មកសាសនាព្រះសមណគោតម បរមគ្រូនៃយើង

---

[60] ប្រជុំនិទានជាតកភាគ១ ទំព័រ ៦៧

នេះ បានមកកើតក្នុងស្រុកនាឡន្ទគ្រាមមានឈ្មោះថា សេសវតីកាលនាងអាយុ ១៥ឆ្នាំ មាតាបានប្រើឲ្យទៅទិញប្រេងឯផ្សារ ។

ក្នុងស្រុកនាឡន្ទគ្រាមនោះ មានគហបតីម្នាក់ធ្លាក់ខ្លួនទៅជាអ្នកក្រ ព្រោះទ្រព្យសម្បត្តិមាសប្រាក់កែវទាំង៧ប្រការ ដែលមាតាបិតាចែកឲ្យទាំងប៉ុន្មាន ដល់មាតាបិតាស្លាប់ទៅរបស់ទាំងនោះក៏ក្លាយទៅជាថ្មនោសិលាអស់ឥតសល់ ។ អតីតគហបតីបានយកថ្មនោសិលានោះ ទៅដាក់លក់លើរានផ្សារផ្សងរកអ្នកមានបុណ្យដោយមានគំនិតថា បើអ្នកមានបុណ្យដើរមកឃើញរបស់ទាំងនេះនឹងក្លាយទៅជាមាសប្រាក់ ជាកែវ៧ប្រការដូចដើមវិញពុំខាន ។

កាលនោះនាងសេសវតី កាន់ដបប្រេងដើរទៅផ្សារបានឃើញរានមួយ ចាក់គរសុទ្ធតែមាសប្រាក់និងកែវទាំង៧ប្រការ នាងក៏ចូលទៅមើល ហើយសួរទៅម្ចាស់រានថា បពិត្រអ្នកដង្ហៅ ហេតុអ្វីក៏យកមាសប្រាក់កែវមកចាក់គរលើរានដូច្នេះ របស់ទាំងនេះគេតែងទុកដាក់ លាក់បំពួនក្នុងហឹបក្នុងឃ្លាំង ។ អ្នកម្ចាស់រានឮដូច្នោះហើយត្រេកអរណាស់ ទើបសួរទៅនាងសេសវតីថា នាងនៅទីណា? ជាកូនចៅអ្នកណា? នាងប្រាប់ថា ខ្ញុំជាកូនអ្នកស្រែ នៅក្នុងស្រុកនេះឯង ។

អ្នកម្ចាស់រានក៏កើបមាសប្រាក់ច្រកក្នុងបាវ ហើយនាំនាងសេសវតីទៅផ្ទះរបស់ខ្លួនបាននិយាយប្រាប់នាងថា កាលពីដើមខ្ញុំជាគហបតីមួយ នៅក្នុងស្រុកនេះ ឥឡូវធ្លាក់ខ្លួនទៅជាអ្នកក្រ ព្រោះមាសប្រាក់កែវទាំងប៉ុន្មាន ក្លាយទៅជាថ្មនោសិលាអស់ បានជាខ្ញុំយកថ្មនោះទៅដាក់នៅរានផ្សារដើម្បីផ្សងរកអ្នកមានបុណ្យឥឡូវទ្រព្យទាំងអស់នេះ ជាទ្រព្យរបស់នាងហើយ ព្រោះនាងជាអ្នកមានបុណ្យ ។ គហបតីបាននាំនាងសេសវតីទៅចាក់ឃ្លាំងមើលទៀត គ្រាន់តែនាងចូលទៅដល់របស់ក្នុងឃ្លាំងទាំងប៉ុន្មាន ក៏ក្លាយទៅជាមាសប្រាក់កែវដូចដើមវិញទាំងអស់ ។

គហបតីនោះ ក៏ជូននាងសេសវតីទៅផ្ទះនិយាយប្រាប់ឪពុកម្តាយនាងដោយសព្វគ្រប់ ទើបដណ្តឹងនាងឲ្យជាភរិយាកូនកំលោះរបស់ខ្លួន លុះរៀបអាពាហ៍ពិពាហ៍ហើយ មាតាបិតាក្មេកបាននាំនាងសេសវតី ទៅនៅក្នុងសំណាក់របស់ខ្លួន ។

ក្នុងកាលជាខាងក្រោយមក ព្រះសារីបុត្តត្ថេរជាធម្មសេនាបតីបានរំពឹងមើលអាយុសង្ខាររបស់លោកឃើញថា អស់ហើយក៏ចូលទៅថ្វាយបង្គំលាព្រះសម្មាសម្ពុទ្ធ សុំទៅបរិនិព្វានឯស្រុកនាឡន្ទគ្រាម ដើម្បីប្រោសមាតាបិតាដែលជាជនមិច្ឆាទិដ្ឋិ លុះទូន្មានមាតាបិតាហើយ ក៏បរិនិព្វានក្នុងបន្ទប់ដែលលោកប្រសូតនោះទៅ ។ កន្លងមកបាន៧ថ្ងៃពួកពុទ្ធបរិស័ទទាំងឡាយ នាំគ្នាធ្វើជើងថ្ករកម្ពស់១រយហត្ថ ដើម្បីបូជាសពរបស់លោក ។

កាលនោះនាងសេសវតី មានគភ៌ជិតគ្រប់ខែហើយបានឮពុទ្ធបរិស័ទទាំងឡាយ នាំគ្នាធ្វើបុណ្យរំលាយសពព្រះសារីបុត្តក៏សុំលាមាតាបិតាក្មេកយកមាសប្រាក់កែវផ្កាភ្ញីទៅបូជាសពព្រះសារីបុត្ត ។ មាតាបិតាឃាត់ថា នាងទៅពុំកើតទេព្រោះគភ៌ចាស់គ្រប់ខែហើយ នាងសេសវតី ជាស្ត្រីមានសេចក្តីជ្រះថ្លាខ្លាំងទ្រាំមិនបាន ក៏លាមាតាបិតានាំបរិវារកាន់មាសប្រាក់កែវ៧ប្រការ ភ្ញីផ្កាដើរសំដៅទៅកន្លែងដំកល់សពព្រះសារីបុត្ត ក្នុងពេលនោះមានមនុស្សច្រើនណែនណាន់ចង្អៀតជាទីបំផុត ប៉ុន្តែនាងសេសវតីជាស្ត្រី ស្អុកស្កម្ភដោយភោគសម្បត្តិ ពួកមហាជនបានឃើញហើយ ក៏បើកឱកាសឲ្យចូលទៅជិតព្រះសព នាងយកមាសប្រាក់កែវភ្ញីផ្កា ទៅចាក់គរក្បែរក្តារមឈូសហើយថយមកអង្គុយប្រណម្យអញ្ជលីនមស្ការ ។

ក្នុងពេលនោះ ចំហាយរបស់មនុស្ស ដែលកកកុញនោះក៏បណ្តាលឲ្យនាងសេសវតី ទៅជាខ្យល់ចាប់សន្លប់នៅទីនោះ ។ ឯដំរីរបស់ពួកឥស្សរជនទាំងឡាយ ដែលជិះទៅក្នុងទីនោះក៏ផ្អើលស្ទុះស្រែកជាខ្លាំង ពួកមហាជនភ័យនឹងដំរីស្ទុះរត់ជ្រួលច្របល់ទៅជាន់នាងសេសវតីនោះស្លាប់ទៅ នាងបានទៅកើត

ក្នុងឋានត្រៃត្រិង្សទេវលោក ស្ថិតនៅក្នុងវិមានប្រាសាទមាស រំលេចដោយកែវ៧ប្រការ មានស្រីទេពអប្សរ១ពាន់ចោមរោមជាបរិវារ ។

ថ្ងៃមួយនាងសេសវតីទេពធីតា បានរឭកឃើញបុព្វកម្មរបស់នាង ក៏ចុះមកទាំងវិមាន មកថ្វាយបង្គំព្រះសម្ពុទ្ធក្នុងវត្តជេតពន ។ កាលនោះព្រះវង្គិស្សត្ថេរលោកកំពុងអង្គុយគាល់ព្រះមានព្រះភាគ បានឃើញនាងទេពធីតានោះ ក៏សួរបុព្វកម្មរបស់នាងៗ បានប្រាប់ដោយសព្វគ្រប់ ព្រះសម្ពុទ្ធទ្រង់ប្រារព្ធហេតុនោះហើយ ក៏សម្តែងនូវធម្មទេសនា សរសើរអានិសង្សនៃការបូជាព្រះសារីរិកធាតុជាភិយ្យោភាពតទៅ ។

## ៥៣. រឿងឥល្លិសសេដ្ឋី[61]

(ធម៌នាំឲ្យបានកើត ជាព្រះឥន្ទ្រមាន៧)

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ។ កាលនោះមានមហាសេដ្ឋីម្នាក់ សទ្ធាមាំក្នុងព្រះពុទ្ធសាសនា បានបំពេញសត្តបទទាំង៧ ប្រការដោយបរិបូណ៌ ជាអ្នកពេញចិត្តក្នុងការឲ្យទាន បានសង់សាលាធទានជាច្រើនខ្នង ។ ធម៌ទាំង៧នាំឲ្យកើតជាព្រះឥន្ទ្រនោះគឺ:

១. គោរពចិញ្ចឹមមាតាបិតា

២. គោរពពាមច្បងក្នុងត្រកូលនិងចាស់ទុំ

៣. មានវាចាល្អ និយាយពាក្យផ្អែមល្ហែម

៤. មិននិយាយចាក់ដោតញុះញង់ឲ្យគេបែកបាក់សាមគ្គីគ្នា

៥. ឲ្យទានមិនកំណាញ់ទៅតាមកម្លាំងទ្រព្យខ្លួនមាន

៦. ជាអ្នកមានសច្ចៈ និយាយពាក្យពិត

៧. ជាអ្នកមិនក្រោធខឹង ពេលខឹងហាមឃាត់មិនឲ្យសេចក្តីក្រោធកើតឡើងបាន ។[62]

---

[61] *ប្រជុំនិទានជាតកភាគ១ ទំព័រ ៧៦*

មហាសេដ្ឋីនោះ មានកូនប្រុសមួយឈ្មោះឥល្លិស ជាទីស្រលាញ់ពេញចិត្ត ក្រៃពេក ដល់ពេលជិតស្លាប់ បានហៅឥល្លិសជាកូនមកប្រគល់ទ្រព្យសម្បត្តិឲ្យ ហើយប្រាប់ឲ្យខំធ្វើទានតាមដំណើរដែលខ្លួនបានធ្វើលុះស្លាប់ទៅ បានទៅកើតជា ព្រះឥន្ទ្រ ។ ព្រះបាទព្រហ្មទត្ត កាលបើមហាសេដ្ឋីស្លាប់ហើយ ក៏តាំងឥល្លិសសេដ្ឋីបុត្រនោះជាមហាសេដ្ឋី ។ ឯឥល្លិសសេដ្ឋីនោះ ជាមនុស្ស ពិការមានជើង ខ្វកដៃ ក្ញែង ភ្នែកស្រលៀង ក្បាលពក ហើយជាមនុស្ស កំណាញ់ស្វិតជាទីបំផុត ។

ថ្ងៃមួយឥល្លិសសេដ្ឋី ចង់ផឹកសុរា ក៏គិតថានឹងបិទសុរាក្នុងផ្ទះ ក្រែងជន ដទៃដណ្តើមផឹក ទើបកាន់យកសម្ភារៈសម្រាប់បិទសុរា មួយមុខបន្តិចៗចូល ទៅបិទក្នុងព្រៃឆ្ងាយអំពីភូមិ ។ ចំណែកខាងមហាសេដ្ឋីជាបិតា ដែលបានទៅ កើតជាព្រះឥន្ទ្របានដឹងថា ឥល្លិសសេដ្ឋីជាកូនកំណាញ់ស្វិតស្វាញ បានចូល ទៅបិទស្រាក្នុងព្រៃដូច្នោះហើយ ក៏ចុះមកនិម្មិតជាឥល្លិសសេដ្ឋីដើរចេញពីជង ព្រៃមកវិញ ។ ពួកមហាជនបានឃើញហើយក៏គិតថា ឥល្លិសសេដ្ឋីប្រហែលជា ស្រវឹងស្រា បានជាមានអាការៈខុសប្រក្រតី ។

ឥល្លិសសេដ្ឋីគឺព្រះឥន្ទ្រនិម្មិតនោះ ក៏ចូលទៅក្នុងព្រះបរមរាជវាំង លើក ទ្រព្យសម្បត្តិទាំងអស់ថ្វាយដល់ព្រះបាទព្រហ្មទត្តៗពុំព្រមទទួល ទើបក្រាបទូលថា បើមហារាជពុំទទួលទេ ខ្ញុំព្រះអង្គនឹងចំណាយទាន សូមថ្វាយព្រះរាជកុសល ដល់ព្រះអង្គ ។ ព្រះបាទព្រហ្មទត្តទ្រង់ទទួលហើយនឹកស្ងើចក្នុង ព្រះទ័យថា ឥល្លិសសេដ្ឋីកាលពីដើមជាមនុស្សកំណាញ់ណាស់ ឥឡូវនេះក៏មានសទ្ធាមាំ-ម៉ួនៈ! ។ ឥល្លិសសេដ្ឋីគឺព្រះឥន្ទ្រនិម្មិតនោះ ត្រឡប់ពីព្រះបរមរាជវាំង ទៅផ្ទះវិញ បានប្រកាសប្រាប់មហាជនឲ្យចូល ទៅទទួលយកទាន ។ ពេលនោះមានបុរស ម្នាក់ទទួលយកទានបានគោ និងរទេះ ផ្ទុកទ្រព្យពេញបរចេញ ទៅក្បែរជងព្រៃ

---

៙ គាថាធម្មបទប្រែ ទំព័រ ៤៤

ដែលឥល្លិសសេដ្ឋីបិទស្រាហើយ ស្រែកឲ្យពរដល់ឥល្លិសសេដ្ឋី ដោយសំឡេងយ៉ាងខ្លាំង ។

ឥល្លិសសេដ្ឋី ឮសំឡេងឲ្យពរដល់ខ្លួនហើយ ក្រឡេកមើលទៅស្គាល់ជាគោរទេះរបស់ខ្លួន ក៏រត់ទៅចាប់មុខរទេះហើយ ចោទប្រកាន់អ្នកបររទេះនោះថាលួចគោរទេះរបស់ខ្លួន ។ អ្នកបររទេះប្រាប់ថារទេះ និងគោនេះ ឥល្លិសសេដ្ឋីដាក់ទានឲ្យខ្ញុំៗ មិនមែនលួចយកទ្រព្យរបស់អ្នកទេ ឥល្លិសសេដ្ឋី និងអ្នកបររទេះបានជជែកគ្នាខ្លាំងឡើងៗ ដរាបដល់ចាប់ចំបាប់គ្នា ឯអ្នកបររទេះបានចាប់ប្រានឥល្លិសសេដ្ឋីដួលទៅលើផែនដី ហើយបររទេះដឹកឥវ៉ាន់យកទៅផ្ទះទៅ ។ ឥល្លិសសេដ្ឋីខឹងណាស់ ឈប់បិទស្រាដើរត្រឡប់មកផ្ទះវិញ លុះមកដល់ក្លោងទ្វារអ្នកចាំទ្វារ មិនឲ្យចូលដោយអាងថាសេដ្ឋីរបស់ខ្លួនកំពុងចែកទាននៅខាងក្នុង ។

ឥល្លិសសេដ្ឋី កាលបើមិនបានចូលទៅក្នុងផ្ទះរបស់ខ្លួនហើយ សេចក្ដីក្រោធក៏កាន់តែកើតឡើងជាខ្លាំង ទើបចូលទៅក្រាបទូលដល់ព្រះបាទព្រហ្មទត្តថា បពិត្រមហារាជ ថ្ងៃនេះមានមនុស្សអាក្រក់ ចូលទៅលួចទ្រព្យរបស់ទូលព្រះបង្គំដាក់ទានឲ្យមហាជន ។ ព្រះរាជាទ្រង់ត្រាស់ថា អម្បាញ់មិញនេះអ្នកមកប្រាប់ថា លើកសម្បត្តិទាំងអស់ឲ្យយើងៗ មិនព្រមទទួលអ្នកប្រាប់ម្ដងទៀតថានឹងបរិច្ចាគទាន ថែមទាំងបានថ្វាយកុសលដល់យើងទៀត ចុះពេលនេះហេតុអ្វីបានជាអ្នកមកនិយាយដូច្នេះវិញ ។

ឥល្លិសសេដ្ឋីក្រាបទូលដាច់អហង្ការថា មិនដឹងសោះ ហើយទូលសូមឲ្យហៅខ្លួនអ្នកទូលមុនមកពិចារណា ។ ព្រះបាទព្រហ្មទត្តទ្រង់ចាត់ឲ្យរាជអាមាត្យកោះយកខ្លួនអ្នកចុងចម្លើយៗ មកដល់ស្រាប់តែមានរូបដូចគ្នា ឥតប្លែកត្រង់ណាឡើយ អ្នកដើមចោទថាខ្លួនជាឥល្លិសសេដ្ឋី អ្នកចុងចោទក៏ថាខ្លួនជាឥល្លិសសេដ្ឋីដែរ ជជែកតវ៉ាគ្នាមិនដាច់ស្រេច ទើបអ្នកដើមចោទអាងយក

មនុស្សក្នុងផ្ទះជាបន្ទាល់សាក្សី ឯបន្ទាល់សាក្សីនោះបានចង្អុលយក អ្នកចុងចម្លើយថាជាសេដ្ឋីរបស់ខ្លួន អ្នកដើមចោទគឺឥល្លិសសេដ្ឋីមែនទែននោះមិនព្រមនិយាយអាងថា ខ្លួនមានពកត្រង់ក្បាលមានតែជាងកាត់សក់ទើបដឹង ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូទ្រង់សោយព្រះជាតិជាជាងកាត់សក់ ។

ព្រះបាទព្រហ្មទត្តទ្រង់ត្រាស់ បង្គាប់ឲ្យហៅជាងកាត់សក់នោះមក ជាងកាត់សក់មកដល់បានសង្កេតមើលសព្វគ្រប់ហើយក្រាបទូលថា មនុស្សពីរនាក់នេះមានជើងខ្វក់ដៃក្ងែង ភ្នែកស្រលៀងក្បាលពកដូចគ្នា ខ្ញុំព្រះអង្គមិនដឹងថាអ្នកណាជាឥល្លិសសេដ្ឋីឡើយ ។ ឥល្លិសសេដ្ឋីមែនទែន ឮដូច្នោះហើយនឹកតូចចិត្តណាស់ ទាល់តែខ្យល់ចាប់ដួលសន្លប់ទៅ ។ ពេលនោះឥល្លិសសេដ្ឋីគឺព្រះឥន្ទ្រនិម្មិតក៏ក្លាយខ្លួនជាព្រះឥន្ទ្រវិញ ហោះឰដ៍អាកាស លុះឥល្លិសសេដ្ឋីដឹងខ្លួនឡើងទើបប្រាប់ថា ខ្ញុំជាបិតារបស់ឥល្លិសសេដ្ឋី បានសង់រោងទានបំពេញការកុសលដរាបដល់អស់អាយុបានមកកើតជាព្រះឥន្ទ្រ ។

ឯឥល្លិសសេដ្ឋីកូនខ្ញុំនេះ ជាមនុស្សកំណាញ់ស្វិតស្វាញអាក្រក់បានជាខ្ញុំមកទូន្មានប្រដៅឲ្យលះបង់គំនិតអាក្រក់នោះចេញ ។ ទីបំផុតព្រះឥន្ទ្របានបង្គាប់ឲ្យឥល្លិសសេដ្ឋីប្ដេជ្ញាខ្លួនជាអ្នកបរិច្ចាគទាន បំពេញការកុសល ឥល្លិសសេដ្ឋីក៏ព្រមប្រតិបត្តិតាមទើបព្រះឥន្ទ្រហោះទៅឋានត្រៃត្រិង្សវិញ ។

## ៥៤. រឿងនាងវិសាខា[63]

(ស្ត្រីល្អគ្មានពីរ និងជាអ្នកមានសទ្ធាបំផុតក្នុងលោក)

កាលព្រះសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តបុព្វារាម នាក្រុងសាវត្ថីទ្រង់ប្រារព្ធនូវមហាឧបាសិកាឈ្មោះ វិសាខា បានសម្ដែងធម្មទេសនាមានបទថា **យថាបិ បុប្ផរាសិម្ហា** ដូច្នេះជាដើម ។ សេចក្ដីថានាងវិសាខា ជាធីតារបស់ធនញ្ជយសេដ្ឋី មាតាឈ្មោះសុមនាទេវី ជីតារបស់នាងឈ្មោះមេណ្ឌកៈ ជីដូន ឈ្មោះ

[63] ប្រជុំនិទានជាតកភាគ១ ទំព័រ ១៣៥

ចន្ទបទុមា ។ នាងវិសាខាជាស្ត្រីមានឧបនិស្ស័យខ្ពស់ បានសម្រេចសោតាបត្តិផលតាំងពីអាយុ៧ឆ្នាំ ជាមួយនឹងនាងទារិកា៥រយនាក់ជាបរិវាររបស់នាង នាងជាស្ត្រីប្រកបដោយបញ្ចពិធកល្យាណីមានលំអ៥យ៉ាងគឺ:

**១. កេសកល្យាណ** លំអសក់
**២. មំសកល្យាណ** លំអសាច់
**៣. អដ្ឋិកល្យាណ** លំអឆ្អឹង
**៤. ឆវិកល្យាណ** លំអសម្បុរថ្ងៃ
**៥. វយកល្យាណ** លំអវ័យ

**អធិប្បាយ**

**១. កេសកល្យាណ** លំអសក់ សក់នៃស្ត្រីមានលំអមានសរសៃល្អិត មានពណ៌ដូចស្លាបកំកេម កាលរំសាយចុះទៅមានចុងងឡើងលើ ដូចសណ្ឋានកន្ទុយក្ងោកពង់ មិនចេះស្កូវឡើយ សូម្បីមានអាយុ១រយឆ្នាំហើយ ក៏នៅតែមានពណ៌រលង់រលើបល្អដូចកាលនៅពីក្មេងយ៉ាងនេះហៅថាលំអសក់ ។

**២. មំសកល្យាណ** លំអសាច់ សំដៅយកសាច់បបូរមាត់ស្ត្រី មានលំអ សាច់បបូរមាត់ ឡើងពណ៌ក្រហមរលោង ដូចផ្លែបាសទុំ ឬផ្លែទន្លាប់ទុំ ជាសាច់ស្អាតឥតមន្ទិលសៅហ្មង ទោះបីមានអាយុ១រយឆ្នាំហើយ ក៏នៅតែក្រហមរលោងស្រស់ដូចដើម យ៉ាងនេះហៅថាលំអសាច់ ។

**៣. អដ្ឋិកល្យាណ** លំអឆ្អឹង សំដៅយកឆ្អឹងធ្មេញ ស្ត្រីប្រកបដោយលំអ មានធ្មេញជិតស្និទ្ធរាបស្មើ មិនចំពើសមានពណ៌សរលោងដូចជាត្បូងពេជ្យដែលជាងច្នៃយ៉ាងស្អាត ហើយដាក់តម្រៀបគ្នា ឬដូចជាស័ង្ខដែលបុគ្គលច្នៃយ៉ាងល្អ បើហានិយាយឡើងកាលណាមានពន្លឺទឹកជមព្រាតៗ សូម្បីមានអាយុ១រយឆ្នាំ ហើយក៏ធ្មេញនៅតែជិតស្និទ្ធល្អដូចកាលអាយុ១៦ឆ្នាំ យ៉ាងនេះហៅថាលំអឆ្អឹង ។

៤. **ឆវិកល្យាណ** លំអសម្បុរថ្ងៃ បានដល់លំអពណ៌ស្បែក ស្ត្រីប្រកបដោយលំអ មានពណ៌ពីរយ៉ាងគឺ ស១ ខ្មៅ១ .ស មានពណ៌ដូចជាកណិការ រលើងរលោងស្អាតឥតមានអាចម៍រុយ ឬសម្លាកមន្ទិលសៅហ្មងឡើយ សូម្បីតែសម្លាកកម រមាស់មួយក៏គ្មាន លំអខាងពណ៌ខ្មៅ មានពណ៌ខៀវស្រស់ដូចផ្កាឧប្បល[64] ជាសម្បុរ មានទឹកដមរលើបរលោង យ៉ាងនេះហៅថាលំអសម្បុរថ្ងៃ ។

៥. **វយកល្យាណ** លំអវ័យ ស្ត្រីបរិបូណ៌ដោយលំអ ទោះបីប្រសូតបុត្រ១០រយដង ក៏នៅតែស្អាតល្អដូចជាវ័យក្មេង កាលដែលមានអាយុ១៦ឆ្នាំ ទោះបីមានអាយុ១រយឆ្នាំហើយក៏ដោយ ក៏នៅតែល្អស្រស់គ្រប់អវយវៈដូចជាស្រីពេញក្រមុំយ៉ាងនេះហៅថាលំអវ័យ ។

ក្នុងកាលដែលនាងវិសាខាមានអាយុ១៦ឆ្នាំ ថ្ងៃមួយជាថ្ងៃបុណ្យនក្ខត្តឫក្សនាងបាននាំបរិវារទាំង៥រយ ព្រមទាំងធីតារបស់សេដ្ឋីគហបតីទៅលេងទឹកក្នុងស្ទឹង ។ ពេលនោះមហាមេឃបង្អុរភ្លៀងចុះមកពួកធីតាទាំងឡាយក៏នាំគ្នារត់ព្រោងព្រាតចូលទៅក្នុងសាលា ឯនាងវិសាខាដើរសន្សឹមៗ ហាក់ដូចជាមិនខ្លាចទទឹក ។ គ្រានោះមានព្រាហ្មណ៍៨នាក់ ជាបម្រើរបស់មិគារសេដ្ឋី ដែលប្រើឲ្យដើររកស្ត្រីប្រកបដោយលំអ ៥យ៉ាងដើម្បីផ្សំផ្គុំជាភរិយាឲ្យបុណ្ណវឌ្ឍនកុមារជាកូន ។

ព្រាហ្មណ៍ទាំង៨នាក់ បានឃើញចរិយាសម្បត្តិរបស់នាងវិសាខាដូច្នោះហើយ នាំគ្នាសង្កេតពិនិត្យមើលបានដឹងជាក់ថា ជាស្រីប្រកបដោយលំអ៥យ៉ាង ប៉ុន្តែមិនទាន់ឃើញធ្មេញរបស់នាង លុះនាងវិសាខាឡើងដល់លើសាលា មានសរីរៈទទឹកជោគដោយទឹកភ្លៀង ព្រាហ្មណ៍ក៏បានឱកាសនឹងឃើញធ្មេញរបស់នាង ទើបនាំគ្នានិយាយថា ស្ត្រីនេះប្រហែលជាកូនអ្នកក្រីក្រ បានជាខ្ជិលយ៉ាង

---

[64] ផ្កាឧប្បល មានពណ៌ចុងផ្កាខៀវទឹកសមុទ្រ កណ្តាលពណ៌ស លំអងពណ៌លឿង ។ អ្នកស្រុកខ្លះហៅថា ផ្កាព្រលិត ។

នេះស៊ូដើរឲ្យភ្លៀងទទឹកអស់ ។ នាងវិសាខាឮដូច្នោះហើយ ក៏សួរព្រាហ្មណ៍ថា អ្នកនិយាយពីអ្នកណា? ព្រាហ្មណ៍ថាយើងនិយាយពីនាង ។

ក្នុងពេលនោះនាងវិសាខាបាននិយាយប្រាប់ដល់ ព្រាហ្មណ៍ដោយសំឡេងពីរោះ ហាក់ដូចជាសំឡេងនៃគាំងសំរិទ្ធថា បានជាខ្ញុំមិនរត់ស៊ូដើរឲ្យទទឹកគ្រឿងអលង្ការនេះ ព្រោះពួកជនដែលគ្រប់លក្ខណ៍មាន៤ពួកគឺ បព្វជិត ស្តេចស្ត្រី ដំរី ជនទាំង៤ពួកនេះមិនគួររត់ឡើយព្រោះថា:

១. បព្វជិត ទោះបីមានហេតុយ៉ាងណា មានភ្លៀង និងខ្យល់ព្យុះជាដើម មិនត្រូវរត់ឡើយ ត្រូវតែដើរសន្សឹមៗ តាមធម្មតាទើបហៅថា បព្វជិតមានលក្ខណ៍ ។

២. ស្តេច ដែលបានអភិសេកហើយ កំពុងទ្រទ្រង់នូវគ្រឿងបញ្ចកុកុធភណ្ឌ ទោះបីមានហេតុយ៉ាងណា មានភ្លៀង និងខ្យល់ព្យុះជាដើម មិនគួររត់ដូចជាគហបតីឡើយ ត្រូវតែយាងសន្សឹមៗ ទើបហៅថា ស្តេចមានលក្ខណ៍ ។

៣. ស្ត្រីពេញក្រមុំ ទោះបីមានហេតុយ៉ាងណា មានភ្លៀង និងខ្យល់ព្យុះជាដើម មិនត្រូវរត់ដូចបុរសឡើយ ត្រូវតែដើរសន្សឹមៗ ទើបហៅថាស្ត្រីមានលក្ខណ៍ ។

៤. ដំរីមង្គលដែលគេប្រដាប់តាក់តែង ដោយគ្រឿងអលង្ការហើយទោះបីមានហេតុយ៉ាងណា មិនត្រូវរត់ឡើយ ត្រូវដើរដោយដំណើរធម្មតា ទើបហៅថាដំរីមានលក្ខណ៍ ។

ព្រាហ្មណ៍ទាំង៨នាក់ស្តាប់ហើយបានឲ្យពរសព្វសាធុការ ដល់នាងវិសាខា ការចង់ឃើញនូវធ្មេញរបស់នាង ក៏បានឃើញដូចបំណង ។ ព្រាហ្មណ៍ទាំង៨នាក់និយាយប្រាប់ដល់នាងវិសាខាថា យើងទាំងអស់គ្នា មានសេចក្តីប្រាថ្នាចំពោះនាង ហើយលើកក្បូងផ្កាមាសដែលមានតម្លៃ១សែនជូនជាគ្រឿងបញ្ចាំចិត្តដល់នាងៗ ក៏ព្រមទទួលយកមកពាក់នូវក ដើម្បីបញ្ជាក់ឲ្យព្រាហ្មណ៍ដឹងថា នាងព្រមទទួល ទើបនាងសួរទៅព្រាហ្មណ៍ថា អ្នកមកពីនគរណា?

ព្រាហ្មណ៍ថា ខ្ញុំមកពីនគរសាវត្ថី ត្បិតមិគារសេដ្ឋីមានកូនប្រុសមួយឈ្មោះ បុណ្ណវឌ្ឍនកុមារ បានបញ្ជូនខ្ញុំមកដណ្ដឹងនាង ។ នាងវិសាខាព្រមទទួល ទើបនាំព្រាហ្មណ៍ទាំង៨នាក់ ទៅប្រាប់ដល់ធនញ្ជយសេដ្ឋីជាបិតា ។ ធនញ្ជយសេដ្ឋីក៏ព្រមឲ្យ បានសួរអំពីសម្បត្តិរបស់មិគារសេដ្ឋី ព្រាហ្មណ៍ប្រាប់ថា មិគារសេដ្ឋីមានប្រាក់៤០កោដិ ។ ធនញ្ជយសេដ្ឋីលាន់មាត់ថា ប្រាក់៤០កោដិ នោះតិចពេកណាស់ មិនបានប្រហែលនឹងតម្លៃថៃរក្សា មានតម្លៃម្សៅ និងប្រេងជាដើមរបស់កូនខ្ញុំទេ ។

តមកធនញ្ជយ សេដ្ឋី និងមិគារសេដ្ឋី ក៏ចាត់ចែងរៀបមង្គលការបុត្រធីតាបាន អញ្ជើញស្ដេចពីនគរព្រមទាំងគហបតីសេដ្ឋី មន្ត្រីតូចធំប្រជារាស្ត្រទាំងអស់មកជាកិត្តិយសក្នុងមង្គលការក្នុងថ្ងៃទី១ ជាដំបូងធនញ្ជយសេដ្ឋីបានហៅ ជាងមាស៥រយនាក់ មកធ្វើគ្រឿងមហាលតាបសាធន៍អាវសម្រាប់ពាក់ការ ។ អាវនោះមានតម្លៃ៩កោដិ ថ្ងៃឈ្នួលជាង១សែនរៀល អាវនោះធ្វើអំពីមាស និងពេជ្រសុទ្ធគឺ ត្បូងពេជ្រចំនួន៤នាឡិ កែវមុក្តា១១នាឡិ កែវបវាឡ២២នាឡិ កែវមណី៣៣នាឡិ ព្រមទាំងមាស និងប្រាក់ជាច្រើនយកទៅហូតធ្វើជាអំបោះ។

អាវនោះរាងជាសត្វក្ងោក ស្លាបម្ខាងៗចំនួន៥រយស្លាប រចនាអំពីមាស និងប្រាក់ចំពុះរចនាដោយកែវបវាឡ ភ្នែករចនាដោយកែវមណី កន្ទុយមានស្លាប៥រយ រចនាដោយមាស និងប្រាក់ ។ អាវនោះលើកពាក់ឡើងកាលណា ឃើញហាក់ដូចជាក្ងោកមាសកំពុងរាំ ឮដំកំពូលភ្នំ ឮសូរសំឡេងលាន់ចេញអំពីស្លាបដូចជាតូរ្យតន្ត្រីទិព្វ ។ សេដ្ឋីរៀបមង្គលការបានចំនួន៣ខែ ពួកអ្នកចម្អិនអាហារប្រាប់ថាអស់ឧសដុតហើយ ។

សេដ្ឋីប្រាប់ឲ្យទៅរុះផ្ទះចាស់ៗ និងរោងដំរីយកមកដុត ដល់ដុតបានកន្លះខែក៏អស់ឧសដុតនោះទៀត ទើបសេដ្ឋីបង្គាប់ឲ្យចាក់ឃ្លាំងយកសំពត់សាច់ក្រាស់ៗជ្រលក់ប្រេងដុតចំអិនអាហារតទៅទៀត ដុតបានកន្លះខែទៀតជាគម្រប់៤ខែ ។

ជាងទាំង៥រយនាក់ ដែលធ្វើគ្រឿងមហាលតាបសាធន៍តាំងពីថ្ងៃចូលរោងមក ក៏គ្រប់៤ខែគត់ ទើបហើយអាវមហាលតាបសាធន៍នោះ ។ ធនញ្ជយសេដ្ឋី និង មិគារសេដ្ឋី បានផ្សំផ្គុំនាងវិសាខា និងបុណ្ណវឌ្ឍនកុមារ ឲ្យជាគូរស្វាមីភរិយាក្នុង ថ្ងៃជាគម្រប់៤ខែនោះ ។

លុះរៀបអាពាហ៍ពិពាហ៍ហើយ ធនញ្ជយសេដ្ឋី បញ្ជូននាងឲ្យទៅនៅខាង សំណាក់ម្តាយក្មេកឪពុកក្មេក បានចែកទ្រព្យសម្បត្តិឲ្យជាច្រើនគឺ ឲ្យភាជនៈ មាស៥រយរទេះ ភាជនៈប្រាក់៥រយរទេះ ភាជនៈទង់ដែង៥រយរទេះ ភាជនៈ សំរឹទ្ធ៥រយរទេះ សំពត់អំបោះ និងសំពត់សូត្រ៥រយរទេះ សប្បិ៥រយរទេះ ប្រេង៥រយរទេះ ស្ករអំពៅ៥រយរទេះ អង្ករស្រូវសាលី៥រយរទេះ គ្រឿង ឧបករណ៍ផ្សេងៗ មាននង្គ័ល និងផាលជាដើម៥រយរទេះ និងខ្ញុំប្រុស ខ្ញុំស្រីជា ច្រើន ។

ក្នុងថ្ងៃដែលនាងចេញទៅ បានបង្គាប់ឲ្យបុរសបើកទ្វារក្រោលគោ ហើយ ឲ្យដេញគោចេញទៅវាល បណ្តោយបីល្បីស្ករទទឹងបីឧសភៈ បុរសក៏ធ្វើតាម បង្គាប់របស់សេដ្ឋីលុះគ្រប់ចំនួនហើយ បុរសបិទទ្វារក្រោលគោក៏ស្ទុះទម្លាយ ក្រោលទៅតាមនាងទៀត ដោយផលបុណ្យដែលនាងបានធ្វើទានដោយចិត្ត ទូលាយពីជាតិមុនមក ។ ថ្ងៃមួយនាងវិសាខាទៅស្តាប់ធម៌នៅវត្តជេតពនបាន នាំកូន និងចៅជាច្រើនពាន់ទៅជាមួយផង កាលនោះមានភិក្ខុមួយរូបចង់ឃើញ នាងវិសាខាបានសួរ ភិក្ខុមួយរូបដែលអង្គុយជិតភិក្ខុនោះប្រាប់ថា មើលតែស្ត្រី ណាក្រោកឡើងយកដៃច្រត់ក្បាលជង្គង់ស្ត្រីនោះហើយគឺនាងវិសាខា ។

កាលនោះនាងវិសាខាមានអាយុជាង៧០ឆ្នាំ ហើយនាងនៅតែក្មេងដូច ជាចៅរបស់នាងដែលមានអាយុ១៦ឆ្នាំ ។ នាងវិសាខាមានកូន២០នាក់ ក្នុងកូន មួយៗ មានចៅ២០នាក់ ក្នុងចៅមួយៗមានកូន២០នាក់ រួមទាំងកូនទាំងចៅ ទាំងចៅទួតចំនួន៨៤២០នាក់ ឥតមានឈឺស្លាប់មួយឡើយ ។ នាងវិសាខា មានកម្លាំងស្មើកម្លាំងដំរី៥ ថ្ងៃមួយនាងត្រឡប់មកពីស្តាប់ធម៌ ព្រះរាជាចង់

ល្បងកម្លាំងរបស់នាងបានលែងដំរីចុះប្រេង១ ឲ្យទៅព្រេចនាងៗ បានយកម្រាមដៃពីរទប់ដំរីៗ ក៏ដួលក្រាបលើផែនដីមិនអាចក្រោកបានឡើយ ។

ថ្ងៃមួយនាងវិសាខាទៅស្ដាប់ធម៌ ដោះគ្រឿងមហាលតាបសាធន៍ទុកខាងក្រៅវិហារ ដល់ស្ដាប់ហើយភ្លេចចោលនៅទីនោះ ទើបប្រើនាងទាសីដែលកម្លាំងស្មើនឹងនាងឲ្យទៅយកអាវបានប្រាប់ថា បើភិក្ខុអង្គណាមួយលោករើសទុកនាងប្រគេនលោកចុះកុំយកមកវិញ ។ ពេលនោះព្រះអានន្ទបានរើសទុក ព្រោះលោកមានកម្លាំងលើកអាវនោះរួច ។ តម្លៃអាវនេះហើយដែលកសាងបានវត្តបុព្វារាមមួយ ។ នាងវិសាខាមានអាយុ១២០ឆ្នាំ នាងធ្វើមរណកាលទៅបានទៅកើតក្នុងឋាននិម្មានរតី ជាអគ្គមហេសីរបស់ព្រះបាទនិម្មានទេវបុត្តក្នុងឋានសួគ៌ជាន់ទី៥ ។

សួរថាចុះហេតុអ្វីពេលបិតា របស់នាងវិសាខាចែកឲ្យគោពេញក្រោលពេលបិទទ្វារក្រោល គោនៅតែលោតចូលទៅដោយផលបុណ្យអ្វី? ដោយផលធ្វើចិត្តទូលាយដូចម្ដេច?

ដោយផលទានដែលនាងវិសាខា ធ្វើភេសជ្ជៈទានដល់ភិក្ខុសង្ឃដោយទូលាយដោយចិត្តជ្រះថ្លា ពេលភិក្ខុសង្ឃឆាន់ទឹកដោះគោឆ្អែតហើយ នូវនិយាយលួងលោមលោកឲ្យឆាន់ថែមទៀត ថាលោកម្ចាស់របស់នេះល្អ របស់នេះឆ្ងាញ់សូមនិមន្តឆាន់ឲ្យឆ្អែតស្កប់ស្កល់ទោះបីលោកឆ្អែតហើយ ដោយអានិសង្សនេះហើយបានជាគោចេះតែលោតចូល ទោះបីពេញក្រោលហើយ នេះតាមដែលបានស្ដាប់លោកគ្រូ អគ្គបណ្ឌិត ប៊ុត សាវង្ស សម្ដែងតាមវិទ្យុជាតិមកនោះ ។

យើងខ្ញុំជាកូន ខ្លៅ យុនសំរ៉ង  ខ្លៅ យ៉ាតណៃ  ខ្លៅសុខផល  ខ្លៅ វិសាល  ខ្លៅ វ៉ាមុន  ខ្លៅ ភារាដា  ខ្លៅ ចំរើន  ខ្លៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្លៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

## មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **គឹម វាសនា**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្លៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org